ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា



- យុត្តិធម៌

# ស្វែងរកការពិត

ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ៣៥ ខែវិច្ឆិកា ឆ្នាំ២០០២


## មាតិកា


◆ សំបុត្រៈ យុត្តិធម៌........................................................១

**ផ្នែកឯកសារ**

◆ ប្រគល់ខ្លួននិងចិត្តគំនិតជូនអង្គការ........................................២

◆ បញ្ជីឈ្មោះជនរងគ្រោះបរទេស........................................ ៦

◆ ដំណើរឆ្លងកាត់តំបន់ខ្មែរក្រហម............................................៧

◆ បញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេចនៅមន្ទីរស-២១.........១០

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ មុនដំបូងខ្មែរក្រហមសម្លាប់ប៉ារបស់ខ្ញុំ................................ ១១

◆ នារីពេទ្យបដិវត្តស្រុកត្រាំកក់..........................................២០

**ផ្នែកច្បាប់**

◆ គំរូសម្រាប់ដាក់ឲ្យបុគ្គលរំលោភសិទ្ធិមនុស្សទទួលខុសត្រូវ.........២៣

◆ រដ្ឋធម្មនុញ្ញទាំងឡាយនៅកម្ពុជា........................................ ២៩

**វេទិកាពិភាក្សាសាធារណៈ**

◆ អង្គការសហប្រជាជាតិ................................................ ៤៦

◆ ការវិវត្តន៍ចុងក្រោយស្តីពីបញ្ហាតុលាការខ្មែរក្រហម................៤៧

◆ ដំណើរឈានទៅរកការកាត់ទោសមេដឹកនាំខ្មែរក្រហម.............. ៤៨

◆ បទសម្ភាសន៍ជាមួយសម្តេចព្រះឧត្តមបញ្ញា ជូង ជុង............... ៥៥

**សិល្បៈខ្មែរក្រហម**

◆ រូបថតយុទ្ធនារីកងទ័ពបដិវត្តន៍ខ្មែរក្រហម ................ក្របក្រោយ




តាម៉ុក

**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា


អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃរាជរដ្ឋាភិបាលកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ ០២៩១ពម.៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩







រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង


**ស្នេរលេខនេះ** លឿង អ៊ីង, អែម សុខឃីម, អេលីហ្សាប៊ែត វ៉ាន់ស្កាក់, វ៉ាអ៊ួល ដែន័រ, **អ្នកនិពន្ធនិងស្រាវជ្រាវៈ** លី សុផល, ជួង សុភារិទ្ធ **ជំនួយការនិពន្ធនាយកៈ** សាន់ កល្យាណ **និពន្ធនាយករងទី១ៈ** សួ ប៊ុនស៊ូ **និពន្ធនាយករងទី២ៈ** សីម សុរិយ៉ា **អ្នកបកប្រែៈ** អេង កុកថាយ **និពន្ធនាយកទូទៅៈ** ឆាំង យុ **ក្រាហ្វិកកុំព្យូទ័រៈ** ស៊ឹម សុភ័ក្រ្ត **គ្រប់គ្រងការចែកផ្សាយៈ** សុខ វណ្ណៈ

*សំបុត្រៈ*

# យុត្តិធម៌

ខ្ញុំបានគិតទៅដល់បងស្រីរបស់ខ្ញុំ នៅពេលដែលខ្ញុំដឹងថា មហាសន្និបាតអង្គការសហប្រជាជាតិកំពុងតែធ្វើការផ្ទេរលើសេចក្តីសម្រេចចិត្តមួយដើម្បីបន្តការចរចាសាជាថ្មីរវាងរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ ក្នុងការបង្កើតឲ្យមានតុលាការយុត្តិធម៌ សម្រាប់កាត់ទោសមេដឹកនាំខ្មែរក្រហម ។ មរណភាពដ៏អាណោចអធមរបស់បងស្រីខ្ញុំដោយស្នាដៃខ្មែរក្រហម បាននិងកំពុងតែតាមលងរូបខ្ញុំអស់ជាច្រើនទសវត្សរ៍មកហើយ ។ តើសេចក្តីសម្រេចចិត្តថ្មីនេះនឹងអាចនាំទៅដល់យុត្តិធម៌មួយដែលជនរងគ្រោះនិងអ្នករួចពីសេចក្តីស្លាប់នៃរបបខ្មែរក្រហមរាប់លាននាក់ ខិតខំស្វែងរកតាំងពីយូរណាស់មកហើយ បានដែរឬទេ? ឬមួយក៏យុត្តិធម៌នៅតែជាដំណើរនៃការភ័ន្តវិញ្ញាណដដែលជាដដែល?

ចាប់តាំងពីខែមិថុនា ឆ្នាំ១៩៩៧ ដែលនៅពេលនោះ សហនាយករដ្ឋមន្ត្រី សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ និង សម្តេច ហ៊ុន សែន បានស្នើសុំឲ្យអង្គការសហប្រជាជាតិ ជួយកម្ពុជាក្នុងការកាត់ទោសមេដឹកនាំខ្មែរក្រហម ខ្ញុំតែងតែគិតថា តុលាការមួយដែលគួរឲ្យជឿជាក់បាន នឹងលេចចេញជារូបរាងឆាប់ៗនេះហើយ ប៉ុន្តែការពិតបានធ្វើឲ្យខ្ញុំរកាំចិត្តទៅវិញ នៅខណៈដែលទំនាក់ទំនងរវាងរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិជួបនឹងបញ្ហារអាក់រអួលមិនឈប់ឈរ ។ តើពេលនេះខុសពីពេលមុនដែរឬទេ? ខ្ញុំសង្ឃឹមថានឹងខុសពីមុន ។ ខ្ញុំក៏ដូចជាប្រជាជនកម្ពុជារាប់សែននាក់ មិនដែលបោះបង់ចោលនូវក្តីសង្ឃឹមឡើយ ។ ការស្វែងរកយុត្តិធម៌នៅតែបន្តទៅមុខជានិច្ច ។

សេចក្តីសម្រេចចិត្តថ្មីនេះនឹងនាំឲ្យមានការចរចាសាជាថ្មីរវាងអង្គការសហប្រជាជាតិនិងកម្ពុជា ដែលត្រូវគាំងស្ទះម្តងរួចមកហើយនៅថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០០២ ។ នេះគឺជាការវិវត្តមួយជំហានទៅមុខដ៏គួរឲ្យស្វាគមន៍ ប៉ុន្តែអ្វីដែលជាបញ្ហាសំខាន់គឺសុឆន្ទៈពិតប្រាកដរបស់ភាគីទាំងពីរ ក្នុងការរកដំណោះស្រាយរួមគ្នាមួយ ។ ការខ្វែងយោបល់ដ៏សំខាន់មួយ គឺការប្រកាន់ខ្ជាប់របស់តុលាការនេះទៅនឹងគំរូបទដ្ឋានយុត្តិធម៌អន្តរជាតិ ។ មានមតិអ្នកស្រាវជ្រាវជាន់ខ្ពស់និងអ្នកច្បាប់អន្តរជាតិមួយចំនួន លើកឡើងថា តុលាការមួយដែលមានកម្រិតស្មើនឹងការអភិវឌ្ឍនៃប្រទេសកម្ពុជាសព្វថ្ងៃនេះ មិនអាចសង្ឃឹមថានឹងឆ្លើយតបឲ្យបានពេញលេញទៅនឹងគំរូបទដ្ឋានយុត្តិធម៌អន្តរជាតិបានទេ ។ ក៏ប៉ុន្តែ មានប្រទេសកំពុងអភិវឌ្ឍមួយចំនួន បានរៀបចំតុលាការកាត់ទោសជនជាប់ចោទពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។ ប្រទេសសេរ៉ាឡេអូននិងរ៉្វាន់ដាមានតុលាការដែលស្របតាមគំរូបទដ្ឋានយុត្តិធម៌អន្តរជាតិ ។ ហេតុអ្វីបានជាមិនអាចមាននៅកម្ពុជា? តើទ្វីបអាហ្វ្រិកមានគំរូយុត្តិធម៌ខ្ពស់ជាងយុត្តិធម៌នៅអាស៊ីឬមួយយ៉ាងណា?

បញ្ហាសំខាន់មួយទៀតគឺតម្រូវការចុះស៊ើបអង្កេតរឿងក្តីព្រហ្មទណ្ឌប្រឆាំងនឹងមេដឹកនាំខ្មែរក្រហមដែលត្រូវបានចោទប្រកាន់ថា ជាអ្នកទទួលខុសត្រូវពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។ សព្វថ្ងៃនេះមានតែខ្មែរក្រហមពីរនាក់គឺ តាម៉ុក និង ឌុច ដែលស្ថិតនៅក្នុងពន្ធនាគារ ។ មេដឹកនាំខ្មែរក្រហមដទៃទៀតដូចជា អៀង សារី, ខៀវ សំផន, នួន ជា រស់នៅដោយសេរីភាព ហើយគ្មានការដាក់កំហិតអ្វីទាំងអស់ ។ ប្រសិនបើកាត់ទោស តាម៉ុក និង ឌុច គឺមិនទាន់គ្រប់គ្រាន់ចំពោះពាក្យថាយុត្តិធម៌នោះឡើយ ហើយប្រសិនបើចង់ឲ្យតុលាការមានភាពគួរឲ្យជឿជាក់បាន តុលាការគួរតែមានសេរីភាពក្នុងការសម្រេចថាតើមេដឹកនាំខ្មែរក្រហមណាខ្លះដែលខ្លួនត្រូវធ្វើការស៊ើបអង្កេត ។ ក្នុងចំណោមឯកសារផ្សេងៗទៀត ភស្តុតាងពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រព្រឹត្តឡើងដោយខ្មែរក្រហម អាចរកមើលបាននៅមជ្ឈមណ្ឌលឯកសារកម្ពុជា និងបណ្ណសារដទៃទៀត ។

សេចក្តីសម្រេចចិត្តថ្មីរបស់អង្គការសហប្រជាជាតិមិនត្រូវបានអនុម័តជាឯកច្ឆ័ន្ទទេ ។ ប្រទេសចំនួន៣៧ ដែលស្មើនឹង២៥ភាគរយនៃចំនួនប្រទេសដែលមានវត្តមាន មិនចូលរួមបោះឆ្នោត ។ នេះគឺជាសញ្ញាណបញ្ជាក់អំពីភាពមន្ទិលសង្ស័យទៅលើអ្វីដែលនឹងអាចកើតមាន នូវតុលាការមួយដែលគួរឲ្យជឿជាក់បាន ។ នៅក្នុងចំណោមអ្នកដែលមិនចូលរួមបោះឆ្នោត គឺមានម្ចាស់ជំនួយកម្ពុជាជាច្រើនដូចជា ដាណឺម៉ាក ហ្វាំងឡង់ អៀរឡង់ ន័រវេ ស៊ុយអែដ និង ហុល្លង់ ដែលគ្មានគោលបំណងទាញយកផលប្រយោជន៍ពីនយោបាយភូមិសាស្ត្រ និងដែលបាននិងកំពុងជួយកម្ពុជាឲ្យស្តាបនានូវសង្គមមួយផ្អែកលើគោលការណ៍ប្រជាធិបតេយ្យ ។ ប្រទេសទាំងនេះគឺជាប្រទេសដែលគេសង្ឃឹមថា នឹងចូលរួមវិភាគទានយ៉ាងសំខាន់ ប្រសិនបើតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមត្រូវបានបង្កើតឡើង ។ ប្រសិនបើនៅតែមានចម្ងល់ ប្រទេសទាំងនេះនឹងមិនចូលរួមចំណែកវិភាគទាននៅក្នុងកិច្ចការនេះឡើយ ។ ខ្ញុំសង្ឃឹមថារដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិនឹងបង្ហាញឲ្យឃើញថាចម្ងល់នេះ គឺជាចម្ងល់ដែលគ្មានមូលដ្ឋាន ។

**ឆាំង យុ**

# ប្រគល់ខ្លួននិងចិត្តគំនិតជូនអង្គការ


តាំង ស៊ីវឡេង

តាំង ស៊ីវឡេង ជាសាស្ត្រាចារ្យនៅវិទ្យាល័យចាក់អង្រែ ដែលត្រូវបានអង្គការខ្មែរក្រហមចាប់ខ្លួនបញ្ជូនទៅកាន់មន្ទីរស-២១ នៅក្នុងឆ្នាំ១៩៧៦ ។

**ជីវប្រវត្តិសង្ខេប**

តាំង ស៊ីវឡេង កើតនៅថ្ងៃទី២០ ខែមេសា ឆ្នាំ១៩៤៨ នៅខេត្តក្រចេះ ជាកូនរបស់លោក តាំង ទ្រាង និងនាង លី តឹកឈុន ។

តាំង ស៊ីវឡេង ជាសិស្សដែលឧស្សាហ៍ព្យាយាមរៀនសូត្រ ។ នាងតែងតែទទួលបានរង្វាន់លេខ១ជារៀងរាល់ឆ្នាំ ។ ស៊ីវឡេង មិនត្រឹមតែជាសិស្សពូកែទេ ថែមទាំងជាអ្នកចម្រៀង និងអ្នកសម្តែងរបាំនៅក្នុងសាលាទៀតផង ។ ឆ្នាំ១៩៦៥ ស៊ីវឡេង បានប្រឡងបញ្ចប់សញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិនៅសាលាពញាហុកភ្នំពេញ ។ ឆ្នាំ១៩៦៧ ស៊ីវឡេង បានទទួលសញ្ញាប័ត្រមធ្យមសិក្សាភាគទី១ នៅវិទ្យាល័យព្រះមហាក្សត្រិយានី កុសុមៈ ។ ឆ្នាំ១៩៦៧ ស៊ីវឡេង បានប្រឡងជាប់នៅសាលាគរុវិជ្ជាទន្ទេបាទី ។ នៅពេលកំពុងសិក្សា ស៊ីវឡេង បានចូលរួមច្រៀងចម្រៀងជាពួក និងច្រៀងចម្រៀងចំនួនពីរបទដែលជាព្រះរាជនិពន្ធរបស់សម្តេចព្រះ នរោត្តម សីហនុ ។

ឆ្នាំ១៩៦៨-៦៩ ស៊ីវឡេង ចេញទៅបម្រើការនៅខេត្តកំពង់ចាម ។

ឆ្នាំ១៩៦៩-៧០ ស៊ីវឡេង បានចេញបង្រៀននិងធ្វើការនៅឧត្តមក្រុមសិក្សា ។ ក្រៅពីម៉ោងបង្រៀន ស៊ីវឡេង បានទៅរៀនបំប៉នបន្ថែមនូវមុខវិជ្ជាផ្សេង ដើម្បីត្រៀមប្រឡងយកសញ្ញាប័ត្រភាគទី២ ។ ស៊ីវឡេង បានប្រឡងជាប់ជាសាស្ត្រាចារ្យផ្នែកភូមិវិទ្យា និងប្រវត្តិវិទ្យា ។

ឆ្នាំ១៩៧០-៧១ ស៊ីវឡេង បានសិក្សានៅមហាវិទ្យាល័យគរុកោសល្យឆ្នាំទី១ និងបានចូលបម្រើការជាស្នងការគណនេយ្យនៅក្នុងសមាគមនិស្សិតគរុកោសល្យក្រោមការគ្រប់គ្រងរបស់លោកគ្រូ ប៉ែន សូវ៉ែន ។ ឆ្នាំ១៩៧២ ស៊ីវឡេង បានចូលសិក្សាឆ្នាំទី២ និងបានចូលរួមក្នុងមហាសន្និបាតប្រចាំឆ្នាំ ។ ក្រោយមក ស៊ីវឡេង ក៏បានជាប់ជាស្នងការគណនេយ្យនៅក្នុងសមាគមនិស្សិតខ្មែរ ដែលគ្រប់គ្រងដោយលោក អ៊ឹម ហៃយូ ។

នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ១៩៧២ ស៊ីវឡេង បានទៅទស្សនកិច្ចនៅសហរដ្ឋអាមេរិករយៈពេល៦៥ថ្ងៃ ។ ស៊ីវឡេង ក៏ធ្លាប់បានទៅហុងកុង ជប៉ុន និងបារាំង ។ ឆ្នាំ១៩៧៤ ស៊ីវឡេង បានទៅបង្រៀននៅវិទ្យាល័យចាក់អង្រែ ។

ស៊ីវឡេង មានចំណូលចិត្តធ្វើនយោបាយណាស់ ។ ដោយហេតុនេះហើយ ទើបនៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៧៤ ស៊ីវឡេង បានចូលបម្រើក្នុងអង្គការ Universal Fellowship ។ ឆ្នាំ១៩៧៥ ស៊ីវឡេង បានបំពេញការងារនៅក្នុងអង្គការមួយឈ្មោះ *Terre des Hommes* តួនាទីជាអ្នកចែកនិងជួយទិញថ្នាំផ្សេងៗ ។

**ទំនាក់ទំនងនៅក្នុង Universal Fellowship**

តាមចម្លើយសារភាពរបស់ ស៊ីវឡេង បានកត់ត្រាថាពេលដែលចូលបម្រើការសេ.អ៊ី.អា ខ្លួនគាត់ត្រូវបានសាបព្រោះគោលនយោបាយបានឲ្យវាយប្រហារខ្មែរក្រហមជាច្រើនដែលមានខ្លឹមសារថាខ្មែរក្រហមបានលក់ខ្លួនទៅឲ្យរុស្ស៊ី ចិនកុម្មុយនិស្តនិងយួនក្រហម ។ ខ្មែរក្រហមបានកាប់សម្លាប់និងដុតផ្ទះប្រជាជនដោយគ្មានអាណិតអាសូរឡើយ សូម្បីតែកូនក្មេងនិងស្ត្រីមានផ្ទៃពោះ ក៏ខ្មែរក្រហមមិនលើកលែងដែរ ។ ខ្មែរក្រហមបានប្រើប្រាស់វិធីសម្លាប់យ៉ាងព្រៃផ្សៃ ដូចជាវះពោះច្រកស្មៅ វះយកទារកមកធ្វើជាកូនក្រក វាយនឹងត្បូងចប ឬឲ្យជីករណ្តៅកប់ខ្លួនឯង

ៗល ។ អ្នកចេះដឹងត្រូវយកទៅសម្លាប់ចោល ។ រាល់ហេដ្ឋារចនាសម្ព័ន្ធដូចជា ស្ពាន ថ្នល់ និងផ្លូវគមនាគមន៍នានា ត្រូវខូចខាតទាំងស្រុង ។ ទីវត្តអារាមនិងព្រះពុទ្ធរូបត្រូវបានកម្ទេច ព្រះសង្ឃត្រូវបង្ខំឲ្យផ្សឹក ខ្លះទៀតសម្លាប់ចោល ។ ចំណែកឯប្រជាជនត្រូវពួកខ្មែរក្រហមកៀរចេញពីភូមិស្រុក ព្រាត់ប្រាសបងប្អូនគ្មានថ្ងៃជួប ខ្វះទាំងម្ហូបអាហារ ថ្នាំសង្កូវ សម្លៀកបំពាក់ ម្នាក់ៗមានរាងកាយស្គាំងស្គម ។ សម្តេច សីហនុ គ្រាន់តែជាឡប់ឡែរបស់ខ្មែរក្រហមទេ ពីព្រោះថាខ្មែរក្រហមមិនត្រូវការស្តេចទេ ។ គោលបំណងរបស់ខ្មែរក្រហមគឺធ្វើយ៉ាងណាឲ្យកម្ពុជាក្លាយជារណបរបស់បក្សកុម្មុយនិស្តឥណ្ឌូចិន ព្រោះ អៀង សារី ជាកូនចិញ្ចឹមរបស់ ហូ ជីមិញ ហើយ ខៀវ សំផន គឺជាកញ្ជះរបស់ ម៉ៅ សេទុង ។

នៅក្នុងអង្គការសេ.អ៊ី.អា ស៊ីវឡេង គឺជាអ្នកធ្វើសំណុំបែបបទធានាយកក្មេងកំព្រាទៅរស់នៅសហរដ្ឋអាមេរិក ។ ស៊ីវឡេង យកចិត្តទុកដាក់ខ្លាំងលើការងារនេះ ។ អង្គការ សេ.អ៊ី.អា ក៏ពេញចិត្តនឹងការងាររបស់នាងដែរ ហើយចាត់ទុកនាងជាអ្នកស្នេហាជាតិ ដោយសន្យាថានឹងជួយឧបត្ថម្ភបន្ថែមលើចំណុចខ្វះខាតទាំងអស់ ជូនរង្វាន់ជាសោហ៊ុយក្នុងការធ្វើដំណើរកម្សាន្តក្រៅប្រទេស និងផ្តល់អាហារូបករណ៍គ្រប់បែបយ៉ាងឲ្យ ស៊ីវឡេង និងទៅបន្តសិក្សានៅក្រៅប្រទេសទៀត ។

ស៊ីវឡេង បានចូលរួមប្រជុំនៅក្នុងអង្គការសេ.អ៊ី.អាចំនួនបីលើក÷

**ការប្រជុំលើកទី១ៈ នៅភោជនីយដ្ឋានលើភ្នំ**

- ខេ ហប់គីន យ៉េនឃីង ជាប្រធាន
- ខៀវ វ៉ន (រដ្ឋសភា) អនុប្រធាន
- សន ថាត (រដ្ឋសភា) ជាសមាជិក
- ស៊ីវឡេង និង សុខ ធី (ក្មេងខាត់ស្បែកជើងអាយុ៦ឆ្នាំ)

ខៀវ វ៉ន មានតួនាទីជាអ្នកមើលការខុសត្រូវឧបត្ថម្ភថវិកាដល់ ស៊ីវឡេង គ្រប់បែបយ៉ាងក្នុងការបំពេញសំណុំបែបបទលិខិតឆ្លងដែនរបស់ក្មេងៗ ។ សន ថាត ជាអ្នកមើលការខុសត្រូវក្នុងការដឹកជញ្ជូនក្មេងពីកន្លែងមួយទៅកាន់កន្លែងមួយទៀត និងមានតួនាទីមួយទៀតគឺជួយដើររកក្មេងកំព្រានិងជួយបង្ហាត់បង្រៀនភាសាអង់គ្លេសដល់ក្មេងដែលប្រមូលបាន ។

ស៊ីវឡេង មានភារកិច្ចនាំកុមារទៅធ្វើសំបុត្រកំណើតនិងនាំទៅមន្ទីរពេទ្យពិនិត្យសុខភាព រួចធ្វើសំបុត្រស្នាមជាលាយលក្ខណ៍អក្សរ ដោយមានចុះហត្ថលេខាពី ឡេស៊ីន ហ្គាឌិន ដើម្បីឲ្យស្ថានទូតអង់គ្លេសទទួលស្គាល់ ។ ក្រោយពេលទទួលបានការអនុញ្ញាត ស៊ីវឡេង ត្រូវរៀបចំសំណុំបែបបទទាំងអស់និងកាត់សម្លៀកបំពាក់ឲ្យក្មេងៗដើម្បីត្រៀមខ្លួនចេញដំណើរ ។

**ការប្រជុំលើកទី២ៈ នៅស្ថានទូតអង់គ្លេស ក្នុងឆ្នាំ១៩៧៤**

- ហាមិលតុន លេខាធិការទី៣ទូត ជាប្រធាន
- ដេវិត ជនជាតិអាមេរិក អនុប្រធាន
- បប ជនជាតិអាមេរិកាំង ជាសមាជិក
- យ៉ិន ជនជាតិអង់គ្លេស ជាសមាជិក
- សុខ វង់ ជនជាតិខ្មែរ ជាសមាជិក
- សាឃូរា ជាសមាជិក
- ម៉ាណូរី
- ស៊ីវឡេង ។

ខ្លឹមសារនៃការប្រជុំនៅលើកទី២នេះ គឺកង្វល់របស់អង្គការ សេ.អ៊ី.អា ចំពោះស្ថានភាពតានតឹងនៅក្នុងប្រទេសកម្ពុជាដែលខ្មែរក្រហមកំពុងរុករានវាយយកទីតាំងសំខាន់ៗរបស់ទីក្រុងភ្នំពេញ ។ អង្គការសេ.អ៊ី.អា បានចាត់តាំង សុខ វង់, សាឃូរា និង ម៉ាណូរី តាមដានចាប់មេក្លោងនិងយុទ្ធជនខ្មែរក្រហមជូនរដ្ឋាភិបាល និងប្រមូលឯកសារសំខាន់ៗ យកប្លង់នៃទីតាំងស្បៀងនិងសាស្ត្រាវុធរបស់ខ្មែរក្រហមទៅកម្ទេចចោល ។ ពិសេសចាប់ខ្មែរក្រហមទាំងរស់ ឬក៏សម្លាប់ចោលបើបានជួបប្រទះនៅកន្លែងណាមួយ ។

ហាមិលតុន បាននិយាយថា នៅឆ្នាំ១៩៧៤ នៅតាមសាលារៀន សិស្សនិស្សិតរំដើបរំជួល គ្មានមេកើយ គ្មានជំហររឹងមាំទេ ។ គ្រូម្នាក់ៗគិតតែពីប្រយោជន៍ផ្ទាល់ខ្លួន ធ្វើការបម្រើឲ្យខ្មែរក្រហម បះបោរពុំព្រមចូលបង្រៀន ប្រឆាំងនឹងរដ្ឋាភិបាល ។ ចំណែកឯស្ថានទូតអាមេរិកាំងបានអំពាវនាវឲ្យអង្គការមនុស្សធម៌ជួយរំដោះប្រជាជនឲ្យរួចផុតពីភាពអត់ឃ្លាននិងជំងឺតម្កាត់គ្រប់បែបយ៉ាង ។ អង្គការសេ.អ៊ី.អា ចង់រៀបចំប្រទេសកម្ពុជាឲ្យល្អ ព្រោះថាប្រទេសកម្ពុជាមានទឹកដីល្អ ដីនៅ

ទំនេរច្រើន ។ អង្គការបានសុំរដ្ឋាភិបាលខ្មែរកសាងស្ពានល្អៗ ផ្លូវថ្នល់ឲ្យស្អាត និងជំនួយផ្សេងៗជាច្រើនទៀត ។ ប៉ុន្តែខ្មែរក្រហមបែរជាបំផ្លិចបំផ្លាញឲ្យខ្ទេចខ្ទីជាបន្តបន្ទាប់ ។ ក្រោយពីនិយាយបញ្ចុះបញ្ចូលរួច ហាមិលតុន បានចាត់តាំង ស៊ីវឡេង ឲ្យបំពេញកិច្ចការពីរ÷ ទី១) បំផ្លាញគោលជំហរអ្នកដែលស្របនឹងខ្មែរក្រហម ទី២) សម្លាប់ឬដាក់ថ្នាំបំពុលនិស្សិតម្នាក់ឈ្មោះ ឡុច សឿន ដែលជាមេបំបះបំបោរឲ្យសិស្សនិស្សិតនៅមហាវិទ្យាល័យប្រឆាំងនឹងរដ្ឋាភិបាល ។ ហាមិលតុន បានប្រគល់កាំភ្លើងខ្លី និងថ្នាំបំពុលមកឲ្យ ស៊ីវឡេង ដោយសន្យាថាបើ ស៊ីវឡេង សម្រេចកិច្ចការនេះបាន នឹងឲ្យនាងទៅបន្តការសិក្សានៅអឺរ៉ុប ហើយណែនាំនាងឲ្យក្លាយជាអ្នកនយោបាយដ៏ឆ្នើមម្នាក់ ។ ស៊ីវឡេង បានបដិសេធដោយលើកហេតុផលថា÷ ខ្លួនជាពុទ្ធសាសនិក មិនអាចសម្លាប់មនុស្សបានទេ ។ ស៊ីវឡេង បានទទួលការប្រមាថថាជាស្ត្រីទន់ខ្សោយ មិនជឿជាក់លើអង្គការ បែរជាជឿលើទ្រឹស្តីនៃព្រះពុទ្ធសាសនាទៅវិញ ។

**ការប្រជុំលើកទី៣ៈ នៅថ្ងៃ១៨-៣-៧៥ នៅស្ថានទូតអង់គ្លេស**

បប បានចោទជាសំណួរមួយនៅក្នុងអង្គប្រជុំថា «តើយើងត្រូវប្រើមធ្យោបាយបែបណា ប្រសិនបើខ្មែរក្រហមវាយចូលភ្នំពេញ?» ។ បប បានបកស្រាយនូវសំណួរខ្លួនឯងថា ស្ថានទូតរបស់ខ្លួនបានរៀបចំផែនការមួយដកថយ គឺចុះចាញ់ខ្មែរក្រហមមួយរយៈ ដើម្បីជាការជៀសវាងនូវការបង្ហូរឈាម ធ្វើឲ្យប្រជាជនខ្មែរស្លាប់ពេញទីក្រុង ។ បប និយាយបន្តថា ការវិលត្រឡប់ទៅមាតុប្រទេសវិញនេះ ពុំមែនមានន័យថាក្រុមខ្លួនរត់ចោលប្រជាជនខ្មែរឡើយ ។ បប បានលើកចិញ្ចៀនផ្លាទីនមួយវង់មកបង្ហាញ ដែលចិញ្ចៀននោះមានផ្លាកសញ្ញា «បេះដូងពីរ មួយពណ៌ខៀវ តំណាងបក្សសេរីនិយម មួយទៀតពណ៌ក្រហម តំណាងឲ្យបក្សកុម្មុយនិស្ត និងរូបរង្វង់ទាំងពីរនៅក្បែរបេះដូង សម្គាល់ការប្រកួតគ្នា ។ បេះដូងក្រហមនៅពីលើបេះដូងខៀវ មានន័យថា គេសង្ឃឹមជានិច្ចថា បក្សសេរីនិយមនឹងយកឈ្នះបក្សកុម្មុយនិស្តឲ្យបាន ដោយពឹងផ្អែកទៅលើអ្នកចេះដឹងទាំងអស់ក្នុងពិភពលោកដែលគោរពយុត្តិធម៌និងមនុស្សធម៌» ។ «អ្នកដែលមានចិញ្ចៀននេះ សុទ្ធតែអ្នកស្មោះត្រង់នឹងជាតិ» ។ ហាមិលតុន បានលើកឡើងពីបញ្ហាត្រៀមចាញ់នៅក្នុងពេលនោះដែរថា ប្រសិនបើខ្មែរក្រហមឈ្នះ សេ.អ៊ី.អា ត្រូវៈ ទី១) ចាត់គ្នាជាខ្សែបណ្តាញដើម្បីវាយប្រហារតបវិញ ។ ទី២) គប់គ្រាប់បែកទៅលើក្បួនយោធាដែលដង្ហែចូលទីក្រុង និងបាញ់សម្លាប់មេក្លោង ។ ទី៣) គប់គ្រាប់បែកទៅលើ អៀង សារី, ខៀវ សំផន និង ដួន ជឿន នៅពេលអ្នកទាំងបីចេញពីកន្លែងធ្វើការ ។ ទី៤) សម្លាប់នារីជាមេគណៈដឹកនាំទ័ពនារី ។ ទី៥) លាក់អាវុធជាប់នឹងខ្លួន បើទប់ទល់មិនបានត្រូវរត់ទៅសៀម ។ ទី៦) បន្លំខ្លួនចូលបម្រើបក្សក្រហម ដើម្បីជាមធ្យោបាយយកការណ៍ឲ្យបានច្បាស់នូវផែនការនានាពីខ្មែរក្រហម ។ ទី៧) បោះគ្រាប់បែកទៅលើលំនៅឋានឬកន្លែងធ្វើការនានារបស់ទូត ។ ទី៨) ប្រមូលកម្លាំងរួមមេទាហានធំៗ ដែលមិនព្រមបម្រើបក្សក្រហម ទៅលាក់ខ្លួនដើម្បីរង់ចាំទ័ពអង្គការសហប្រជាជាតិជាជំនួយ ។ ទី៩) ផ្តួលរំលំកម្មាភិបាលខាងផ្នែកសីលធម៌ ដើម្បីប្រមូលឯកសារ និងសម្លាប់កម្មាភិបាលចោល ។ និងទី១០) ស៊ីវឡេង ត្រូវរៀបចំសំណុំលិខិតនិងប្រមូលក្មេងកំព្រាទាំងអស់ទុកមួយកន្លែង ដើម្បីត្រៀមចេញដំណើរតាមជើងយន្តហោះរបស់ស្ថានទូតអង់គ្លេស ។

នៅថ្ងៃទី១៣ ខែមេសា ឆ្នាំ១៩៧៥ យន្តហោះបានដឹកជញ្ជូនក្មេងកំព្រាចំនួន២០០នាក់ឆ្ពោះទៅកាន់សហរដ្ឋអាមេរិក ។ ដោយសារទឹកចិត្តស្រលាញ់ឪពុកម្តាយ បងស្រី និងប្អូនៗនៅផ្ទះ ស៊ីវឡេង មិនបានរួមដំណើរទៅសហរដ្ឋអាមេរិកទេ ។ ស៊ីវឡេង បានចាត់ទុកខ្លួនឯងថា ជាមនុស្សស្មោះត្រង់ ជាអ្នកស្នេហាជាតិពិតប្រាកដ ។ ដូច្នេះ «អ្នកធ្វើនយោបាយរត់ចោលប្រទេសគឺជាមនុស្សក្បត់ជាតិ» ។ ប៉ុន្តែនៅពេលដែលខ្មែរក្រហមចាប់ខ្លួន ស៊ីវឡេង បានសារភាពថាគាត់ជាមនុស្សមានមហិច្ឆតាខ្ពស់ ជាមនុស្សក្បត់ជាតិឯង ។

នៅខែវិច្ឆិកា ឆ្នាំ១៩៧៥ ស៊ីវឡេង ត្រូវបានខ្មែរក្រហមជម្លៀសទៅដល់ភូមិបារាយណ៍ ខេត្តកំពង់ធំ ។ ស៊ីវឡេង បានមកស្នាក់នៅមន្ទីរពេទ្យជាមួយ ហួត បុប្ផាណា ហៅ មុំ ។ រយៈកាលនៃការស្នាក់នៅភូមិបារាយណ៍ ស៊ីវឡេង បានដឹងថា ហួត បុប្ផាណា គឺជាសេ.អ៊ី.អា តាមរយៈចិញ្ចៀនមួយវង់ដែលមានផ្លាកសញ្ញា

ដូចបានរៀបរាប់ខាងលើ ។ ស៊ីវឡេង និង បុប្ផាណា បានរួមដៃគ្នាបន្តកិច្ចការ សេ.អ៊ី.អា តទៅទៀត ។

នៅក្នុងខែមីនា ឆ្នាំ១៩៧៦ ស៊ីវឡេង បានទទួលតំណែងជាប្រធានដឹកនាំអង្គប្រជុំនៅក្នុងមន្ទីរពេទ្យមួយដែលមាន មុំ ជាអនុប្រធាន ។

ការរស់នៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម ស៊ីវឡេង បានដឹងច្បាស់ពាក្យថា «អង្គការស្នើសុំ» ស្មើនឹងពាក្យសាមញ្ញថា «យកទៅវាយនឹងត្បូងចប» ។ ប្រជាជនតែងតែខ្លាចរអានៅពេលឮពាក្យនេះ ព្រោះថាអ្នកដែលអង្គការស្នើទៅនៅពេលត្រឡប់មកវិញ កដៃកជើងនៅប៉ុនកវែក អ្នកខ្លះពុំមានថ្ងៃត្រឡប់វិញផង ។ ម្នាក់ៗគ្មានជំនឿលើអង្គការបដិវត្តន៍ទេ ។ គ្រប់គ្នារស់នៅរង់ចាំតែសេចក្តីស្លាប់ប៉ុណ្ណោះ ។

ក្រៅពី បុប្ផាណា, ស៊ីវឡេង បានស្គាល់ស្ត្រីម្នាក់ទៀត ឈ្មោះ ម៉ាយូរ៉ា អតីតជាបុគ្គលិកនៅក្នុងអង្គការមនុស្សធម៌ និងជាសមាជិករបស់អង្គការសេ.អ៊ី.អា តាមរយៈចិញ្ចៀន ។ ស្ត្រីម្នាក់នោះបានប្រើគ្រប់វិធីបញ្ចុះបញ្ចូល ស៊ីវឡេង បំពេញកិច្ចការពីរឲ្យខ្លួន ទី១) សម្លាប់មនុស្សពីរនាក់ ម្នាក់ឈ្មោះ ស៊ុន ប្រធានសង្កាត់ស្វាយទាប និងម្នាក់ទៀតឈ្មោះ សែត អតីតអ្នកតស៊ូទីក្រុង និង ទី២) ដុតបំផ្លាញជង្រុកស្រូវធំៗ ។

ស៊ីវឡេង បានទាក់ទងជាមួយបុរសម្នាក់ឈ្មោះ វី ដើម្បីឲ្យជួយសម្លាប់ ស៊ុន និង សែត ។ ប៉ុន្តែ ការភ័យខ្លាចបានធ្វើឲ្យ ស៊ីវឡេង បញ្ឈប់ផែនការនោះភ្លាម ហើយព្យាយាមរិះរកគ្រប់វិធីដើម្បីចាកចេញពីភូមិបារាយណ៍ឆ្ពោះទៅខេត្តក្រចេះ ។

នៅខែវិច្ឆិកា ឆ្នាំ១៩៧៦ ស៊ីវឡេង ត្រូវអង្គការចាប់ខ្លួន ។ ដើម្បីរក្សាជីវិត ស៊ីវឡេង បានសារភាពនូវទោសកំហុសគ្រប់បែបយ៉ាង សុខចិត្តប្រគល់ខ្លួននិងចិត្តគំនិតជូនអង្គការ ដោយសង្ឃឹមថានឹងទទួលបាននូវការគ្រាប្រណីទោស ប៉ុន្តែផ្ទុយទៅវិញ ស៊ីវឡេង នៅតែមិនបានទទួលនូវការលើកលែងទោសពីអង្គការដដែល ។ ក្រោយពីសួរចម្លើយចំនួន១១លើក ស៊ីវឡេង ត្រូវអង្គការសម្លាប់ចោលនៅថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៧៧ ។

**លី សុផល**



**កម្មាភិបាលខ្មែរក្រហមធ្វើការនៅរោងបាយរួម**

# បញ្ជីឈ្មោះជនរងគ្រោះបរទេសដែលបានកម្ទេចនៅមន្ទីរស-២១

រៀបរៀងដោយៈ យិន នាន

(តពីលេខមុន)

| ល.រ | នាម-គោត្តនាម | សញ្ជាតិ | មុខងារ | ចាប់មកពី | ថ្ងៃចូល | ថ្ងៃកម្ទេច |
|---|---|---|---|---|---|---|
| ១៨០ | យ៉ យ៉ាងថា | យួន | គិញយួន | តំបន់២៥ | ៩-៤-៧៦ | ១៩៧៦ |
| ១៨១ | យ៉ យ៉ងថុង | យួន | គិញយួន | តំបន់២៥ | ៩-៤-៧៦ | ១៩៧៦ |
| ១៨២ | ង ប៊ីងឡុង | យួន | គិញយួន | ? | ២៥-៤-៧៦ | ១៩៧៦ |
| ១៨៣ | ដាន វ៉ាន់ភូ | យួន | គិញយួន | ? | ២៥-៤-៧៦ | ១៩៧៦ |
| ១៨៤ | វ៉ិត ប៊ូឡឹម | យួន | គិញយួន | ? | ២៥-៤-៧៦ | ១៩៧៦ |
| ១៨៥ | ឡេ មិនទ្រី | យួន | គិញយួន | ? | ២៥-៤-៧៦ | ១៩៧៦ |
| ១៨៦ | ង្វៀង ឡាំ | យួន | គិញយួន | ? | ២៥-៤-៧៦ | ១៩៧៦ |
| ១៨៧ | ង្វៀង ធីវ៉ាង (ស្រី) | យួន | ចារកិច្ចយួន | ? | ១៧-៤-៧៨ | ២១-៤-៧៨ |
| ១៨៨ | ដាម ធីឡាង (ស្រី) | យួន | ចារកិច្ចយួន | ? | ១៧-៤-៧៨ | ២១-៤-៧៨ |
| ១៨៩ | ហ៊្វា ធីនី (ស្រី) | យួន | ចារកិច្ចយួន | ? | ៤-៣-៧៨ | ២១-៤-៧៨ |
| ១៩០ | យ៉ ធីធុយ (ស្រី) | យួន | ចារកិច្ចយួន | ? | ១-៤-៧៨ | ២១-៤-៧៨ |
| ១៩១ | ត្រឹងធី ឡេស៊ីុន (ស្រី) | យួន | ចារកិច្ចយួន | ? | ១-៤-៧៨ | ២១-៤-៧៨ |
| ១៩២ | ណាំ ស៊ីវម៉េង (ស្រី) | យួន | ចារកិច្ចយួន | ? | ១-៤-៧៨ | ២១-៤-៧៨ |
| ១៩៣ | ប៊ុយ ធីហ្វាយ (ស្រី) | យួន | ចារកិច្ចយួន | ស្វាយរៀង | ២-១១-៧៨ | ១៥-១១-៧៨ |
| ១៩៤ | ង៉ូ យ៉ុំងកាយ | យួន | ចារកិច្ចយួន | ស្វាយរៀង | ៥-១១-៧៨ | ១៥-១១-៧៨ |
| ១៩៥ | ដាម ថាន់យ៉េត | យួន | ចារកិច្ចយួន | ស្វាយរៀង | ៥-១១-៧៨ | ១១-១២-៧៨ |
| ១៩៦ | ដាម ថាន់គួ | យួន | ចារកិច្ចយួន | ស្វាយរៀង | ៥-១១-៧៨ | ២០-១១-៧៨ |
| ១៩៧ | យ៉ាប វ៉ាន់បាច់ | យួន | បិញញី | ស្វាយរៀង | ៥-១១-៧៨ | ? |
| ១៩៨ | ដាង ថាន់មិន | យួន | បិញញី | ស្វាយរៀង | ៥-១១-៧៨ | ? |
| ១៩៩ | យ៉ ណាំដុង | យួន | បិញញី | ស្វាយរៀង | ៥-១១-៧៨ | ? |
| ២០០ | ង្វៀង យ៉ុំងឌី | យួន | ចារកិច្ចយួន | ស្វាយរៀង | ៨-១១-៧៨ | ២០-១១-៧៨ |
| ២០១ | ង្វៀង វ៉ាន់ធុក | យួន | បិញញី | ស្វាយរៀង | ៨-១១-៧៨ | ? |
| ២០២ | ង្វៀង យ៉ុំងថិន | យួន | ធីវគី | មណ្ឌលគិរី | ៨-១១-៧៨ | ១១-១២-៧៨ |
| ២០៣ | ង្វៀង ហ៊ូវធ្វី | យួន | ធីវគី | មណ្ឌលគិរី | ៨-១១-៧៨ | ១១-១២-៧៨ |
| ២០៤ | វិន ធិន | យួន | ធីវគី | មណ្ឌលគិរី | ៨-១១-៧៨ | ២-១២-៧៨ |
| ២០៥ | តា ថាន់ទី | យួន | ធីវគី | មណ្ឌលគិរី | ៨-១១-៧៨ | ២-១២-៧៨ |
| ២០៦ | ដាម ខិកធិប | យួន | យៀកកុង | ក្រចេះ | ៩-១១-៧៨ | ? |
| ២០៧ | ប៊ុយ ហុងវើ | យួន | យៀកកុង | ក្រចេះ | ៩-១១-៧៨ | ១១-១២-៧៨ |
| ២០៨ | ត្រឹង ឡុង | យួន | ចារកិច្ចយួន | កំពង់សោម | ១២-១១-៧៨ | ២-១២-៧៨ |

(នៅមានត)

# ដំណើរឆ្លងកាត់តំបន់ខ្មែរក្រហម

***(តពីលេខមុន)***

នៅម៉ោង៨យប់ យើងឮប្រធានគណៈកម្មាធិការរៀបចំមិទ្ទីង ស្រែកជយឃោសជូនពរស្វាគមន៍ដល់លោក ហ៊ូ យន់ មានសម្តីថាៈ "ជយោ! មិត្ត ហ៊ូ យន់ បុត្រដ៏ឆ្នើមរបស់ប្រជាជនកម្ពុជា" ។ ស្នូរទះដៃក៏លាន់ឮប្រាវ ។ ព្រមជាមួយនោះ ទស្សនិកជនក៏ក្រោកឈរស្រឡើង អើតករកមើលលោក ហ៊ូ យន់ ។ យើងក៏ភ្ញាក់ព្រើតកាលបើឃើញលោក ហ៊ូ យន់ ទាំងសាច់ទាំងឈាម លើកដៃទទួលការអបអរសាទរនៅជួរខាងមុខវេទិកា ។ បន្ទាប់ពីសុន្ទរកថារបស់ប្រធានចាត់ចែងបុណ្យមិទ្ទីងមក លោក ហ៊ូ យន់ ក៏បានឡើងថ្លែងសុន្ទរកថាយ៉ាងវែងដោយឥតព្រាងទុកអស់រយៈប្រហែល៣ម៉ោង ។ លោក ហ៊ូ យន់ បានសង្កត់ហើយសង្កត់ទៀតថា ជំហររបស់គេគឺ "មិនចរចាមិនសំរុះសំរួល មិនរាថយ" គេប្រយុទ្ធរហូតមានជ័យជំនះជាស្ថាពរ ទោះជាត្រូវឆ្លងការលំបាកវេទនាយ៉ាងណាក៏ដោយ ។ គេប្រកាន់ជំហរ "ឯករាជ្យម្ចាស់ការខ្លួនទីពឹងខ្លួន" ជាធំ តែគេ "ក៏ត្រូវរួមសាមគ្គីជាមួយប្រជាជនឡាវនិងវៀតណាម ក្នុងការដេញចក្រពត្តិអាមេរិកាំងចេញពីដែនដីឥណ្ឌូចិន" ។

បន្ទាប់ពីសុន្ទរកថាលោក ហ៊ូ យន់ មក ព្រះសង្ឃ "កម្មាភិបាល" ខ្មែរក្រហម មេបញ្ជាការកងទ័ព ស្នងការនយោបាយ ព្រមទាំងតំណាងអណិកជន ចិន-យួន ឡើងថ្លែងយោបល់គាំទ្រ "បដិវត្តន៍" របស់គេជាបន្តបន្ទាប់គ្នា ដែលតាមភាសារបស់គេហៅថា "ឡើងចាប់អារម្មណ៍" ។

រាត្រីសិល្បៈបដិវត្តន៍របស់គេបានកំដរទស្សនិកជននិងកងទ័ពរហូតដល់ម៉ោង៥ភ្លឺ ។

រហូតមកទល់ពេលនេះ យើងធ្លាប់អោមត្រចៀកនឹងពាក្យពេចន៍របស់គេ និងភាសាមួយបែបថ្មីរបស់គេ និងពាក្យឃោសនាមួលបង្កាច់ទាំងទទឹងទិសមកលើរដ្ឋាភិបាល មកលើរបបសាធារណរដ្ឋ មកលើសង្គមនៅភ្នំពេញដែលពួកគេចាត់ទុកថា ជា "សង្គមចាស់" ។

*ថ្ងៃ១២ ទៅ ១៤ ឧសភា ១៩៧២*

យើងធ្វើដំណើរចេញពីភូមិវាលល្មៀង នៅវេលាម៉ោង៩ព្រឹក ក្រោយពីបានជម្រាបនិងថ្លែងអំណរគុណបងប្អូនញាតិមិត្តជិតខាងដែលបានជួយឧបត្ថម្ភយើងយ៉ាងកក់ក្តៅ អស់ថេរវេលា ២២ថ្ងៃក្នុងការស្នាក់អាស្រ័យរបស់យើងនៅទីនេះ ។ មន្ទីរនីរសា របស់មិត្ត ចាន់ បានចាត់ឲ្យសហការីរបស់គេម្នាក់ជូនដំណើរយើង ។ លើកនេះ យើងធ្វើដំណើរដោយទោចក្រយានឆ្ពោះទៅទិសខាងជើងតាមផ្លូវលំ-ផ្លូវរទេះគោ ឆ្លងកាត់ភូមិតូចនានាដែលមានសភាពស្ងាត់ជ្រងំ ។ យើងឃើញផ្ទះបាក់បែក ឆេះដោយគ្រាប់បែក ដើមដូង ដើមត្នោតបាក់រលំដោយគ្រាប់រ៉ុក្កែត គុម្ពឬស្សី ដើមស្វាយស៊ិតស្រពោនរញ៉មដោយគ្រាប់ណាប៉ាល់ ។ នេះគឺជាទិដ្ឋភាពសង្គ្រាមគួរឲ្យខ្លាចផ្សា ។

យើងបានមកដល់ភូមិប្រាំងចោតវេលាម៉ោង១កន្ទះរសៀល បានចូលទៅសម្រាកក្នុងដំរិកងឈ្លបនិងក្រុមអ្នកនាំសារដែលសង់ប្របនឹងមាត់អូរក្រោមព្រៃឈើស៊ុបទ្រុប នៅខាងត្បូងភូមិចម្ងាយប្រមាណ៣០០ម៉ែត្រ ។ យើងស្រស់ស្រូបបាយកញ្ចប់ដែលយើងយកមកជាប់នឹងខ្លួន ។ នៅទីនេះ យើងបានជួបនឹងយុទ្ធជនរណសិរ្ស៣នាក់ទៀត ដែលធ្វើដំណើរពីស្អាង-កោះធំឆ្ពោះទៅអមលាំង ។ មានយុទ្ធជនពីរនាក់ដែលទើបនឹងចុះមកពី "ខាងលើ" (អង្គការថ្នាក់លើ) បានប្រាប់យើងថា គេមានបេសកកម្មមកដឹកអីវ៉ាន់និងមកទទួលអស់លោក "ធំៗ" ។ នៅម្ខាងផ្លូវជាតិលេខ៤៦ ណោះ មានឡានកង់ដប់មួយមកចាំទទួលអស់លោកទាំងនោះ ។ យើងចាប់ភ្លឹកថាប្រហែលគេមកចាំទទួលលោក ហ៊ូ យន់ និងសហការីរបស់លោកដែលបានមករួមក្នុងមិទ្ទីងនៅកាត់ភ្លុក នាយប់ថ្ងៃ១០ ឧសភា ។

មិត្ត សន អ្នកនាំផ្លូវរបស់យើងព្រមទាំងមិត្តរួមដំណើរដទៃទៀតប្រហែល១០នាក់ បានមកដល់វត្តពុទ្រា ក្បែរផ្លូវជាតិលេខ

៤ នៅម៉ោង៤កន្លះរសៀល ។ កងឈ្លប៤ឬ៥នាក់បានទៅពិនិត្យផ្លូវនិងយាមនៅទីនោះ ដើម្បីធ្វើសញ្ញាឲ្យយើងឆ្លង ។ នៅខាងលិចយើងចម្ងាយប្រមាណ៥គ.ម មានបន្ទាយកងទ័ពសាធារណរដ្ឋយើង ។

នៅម៉ោង៥កន្លះ យើងបានឆ្លងកាត់ផ្លូវជាតិលេខ៤ ។ កងឈ្លបដើរមុខធ្វើសញ្ញាឲ្យយើងឈប់ ព្រោះផ្លូវរទេះគោមានបង្កប់មីន ។ កងឈ្លបក៏គូសរង្វង់ហ៊ុមព័ទ្ធមីន និងធ្វើសញ្ញាឲ្យយើងដើរលើស្នាមវ៉ាងផ្លូវខ្សាច់ ។ ឆ្លងបានចម្ងាយប្រមាណ៣០០ម៉ែត្រ យើងក៏នាំគ្នាឡើងជិះកង់បន្តដំណើរទៅមុខទៀត កាត់តាមវាលស្រែ និង ឆ្លងអូរ ។

នៅម៉ោង៦និង១៥នាទី យើងបានមកឈប់សម្រាកនៅក្នុងវត្តគោករមៀត ។ ភូមិគោករមៀតជាភូមិចាស់សម្បូរទៅដោយដើមដូង-ដើមស្វាយ-ចេកស្វា ។ ផ្ទះក្បឿងធំៗជាច្រើនត្រូវបិទទ្វារចោល ។ ក្រៅពីព្រះសង្ឃ៦ឬ៧អង្គនៅក្នុងវត្ត ភូមិមានសភាពស្ងាត់ជ្រងំ ។ យើងអង្គុយសម្រាកនៅប្របមាត់ស្រះមួយដែលភ្ជាប់ទៅនឹងត្រពាំងបុរាណមួយយ៉ាងធំ ។ រស្មីព្រះអាទិត្យស្រទន់ពណ៌មាសជះមកលើកំពូលភ្នំទាំងពីរនៅខាងកើតយើងធ្វើឲ្យយើងនឹកស្តាយដល់សេចក្តីសុខសាន្តដែលបានវិនាសផុតទៅ ... ដោយសារសង្គ្រាម... ដោយសារមហិច្ឆតារបស់យួនកុម្មុយនិស្ត! វត្តអារាម ដើមដូងខ្ពស់លៃលៃមានចំណាស់ប្រហែល៥០ឆ្នាំ ដើមស្វាយមានគល់ប៉ុនកង់រទេះ ត្រពាំង ។ល ។ ទាំងអស់នេះជាព្រលឹងនៃជីវិតធ្លាប់សុខសាន្តរបស់អ្នកភូមិ! ជានិមិត្តរូបនៃព្រលឹងខ្មែរតែម្តង!

យប់ថ្ងៃ១២ ទៅ ១៣ ឧសភា យើងបានទទួលដំណេកនៅក្នុងជំរំ "នីរសា" នៅខាងលិចភូមិគោករមៀត ប្របនឹងមាត់ស្ទឹងព្រៃរមៀត ។ ព្រឹកថ្ងៃ១៣ ឧសភា យើងបន្តដំណើរទៅមុខទៀតកាត់តាមវាលស្រោង វាលព្រេច ។ យើងកម្រជួបប្រទះភូមិជនបទអ្នកស្រុកណាមួយនៅតាមផ្លូវលំ ។ នៅម៉ោង២កន្លះរសៀល យើងបានមកដល់ភូមិគោង-ម៉ោង (ឬគោង-ហោង?) ដែលមានចម្ងាយប្រមាណ៧០គ.ម ពីថ្នល់ជាតិលេខ៤ ។ នៅតាមផ្លូវ យើងបានជួបប្រទះយៀកកុង-យៀកណាមខាងជើង ដឹកជញ្ជូនអង្ករ មាន់ ទា តាមកង់ និងដឹកជញ្ជូនហិបគ្រាប់តាមជីរ៉ូឬឡានកង់ដប់ ហ្សេ អឹម សេ (GMC) ។ ចាប់ពីភូមិគោង-ម៉ោង យើងជិះឡានកង់ដប់យៀកណាមខាងជើងឆ្ពោះទៅស្រុកអមលាំង ។ នៅខាងឆ្វេងយើង ភ្នំឱរ៉ាល់បានលេចរូបរាងត្រដែត ។ គឺជាជម្រកយុទ្ធសាស្ត្ររបស់ខ្មែរក្រហមតាំងពីយូរយារណាស់មកហើយ ។

នៅព្រឹកថ្ងៃ១៤ ឧសភា យើងចេញដំណើរដោយកង់ពីស្រុកអមលាំង ឆ្ពោះទៅទិសខាងត្បូងតាមថ្នល់ខេត្ត (*Route proviciale*) ។ នៅតាមផ្លូវយើងបានជួបប្រទះមនុស្សម្នាជាច្រើនជាយុទ្ធជនខ្មែរក្រហមឬ ពួក"អង្គការ" ចុះឡើងទៅមក អមលាំងមិនដាច់ ។ ទាំងអស់គ្នាសុទ្ធសឹងតែស្លៀកពាក់ខ្មៅ មានបង់កក្រមាដូចគ្នា ។

នៅវេលាម៉ោង២រសៀល យើងបានមកដល់វត្តពោធិ៍ ។ នៅម៉ោង៤ យើងចូលមកដល់ភូមិតាំងខ្មៅ ក្នុងសង្កាត់ពាមជ្រាំបីមុម ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ។ មិត្ត សន អ្នកនាំផ្លូវបាននាំយើងចូលទៅសម្រាកក្នុងមន្ទីរនីរសានៃតំបន់៣០៥ ហើយបានប្រាប់យើងថា យើងបានមកដល់ទីដៅហើយ ។ យើងបានប្រាប់នីរសានៅទីនោះថា យើងមានលិខិតមួយត្រូវយកមកជូនមិត្ត"ហង់" មន្ទីរ៣០៥ ដោយផ្ទាល់ ។ មិត្តនីរសាគេមិនឲ្យយើងទៅជួបមិត្ត "ហង់" នោះផ្ទាល់ទេ គេទទួលយកលិខិតពីយើងទៅជូនមិត្ត ហង់ ។ យើងនៅរង់ចាំអស់រយៈជិតមួយម៉ោង រួចទើបឃើញមិត្តនិរសានោះវិលត្រឡប់មកវិញ ហុចកូនសំបុត្រមួយឲ្យទៅមិត្តសន ។ អ្នកនាំផ្លូវយើងសើចញញឹមញញែមបង្ហាញកូនសំបុត្រនោះឲ្យយើងអាន មានអក្សរតែមួយបន្ទាត់មានន័យថាៈ "សូមបង នាគ លៃលករៀបចំកន្លែងឲ្យបានសមរម្យដល់មិត្តបញ្ញាជន... ពីក្រុងផង ព្រោះខ្ញុំគ្មានមធ្យោបាយ" ។ មិត្ត សន បន្ថែមថាៈ "បងមានសំណាងហើយដោយបានមន្ទីរសេដ្ឋកិច្ចភាគរៀបចំទទួលផ្ទាល់" ។ មិត្ត សន ក៏បាននាំយើងទៅកាន់មន្ទីរមិត្ត "នាគ" (ឈ្មោះបដិវត្តន៍) ដែលនៅមាត់ស្ទឹងខាងលិចវត្តតាំងខ្មៅ ។

ពេលចូលទៅដល់ យើងបានជួបប្រទះនឹងយុវនារីមួយក្រុមកំពុងប្រជុំ "រៀនសូត្រនយោបាយ" នៅក្រោមដើមចំបក់មួយដ៏ធំ ។ មានតុមួយវែងសម្រាប់ជាកន្លែង "ហូប" បាយផង ជាកន្លែងប្រជុំផង ។ មិត្តនារីទាំងអស់នេះជាក្រុមកាត់ដេរ ។ បន្តិច

ក្រោយមក យើងឃើញកូនចៅចិទម្នាក់រូបស្អាតបាត ដើរតម្រង់មករកចាប់ដៃយើងដោយទឹកមុខញញឹមរាក់ទាក់ ។ មិត្ត នាត បានសាកសួរសុខទុក្ខនិងសុំទោសយើងដោយពុំបានយកឡានទៅទទួល ។ គេបានបញ្ជាក់ទៀតថា បានទទួលទូរលេខមួយពីមិត្ត ចាន់ ស្តីពីវត្តមានរបស់យើង ។ មិត្ត នាត នេះគឺគ្មាននរណាក្រៅពីលោក សៀង ប៉ៅសែ អតីតវិស្វករនិងអតីតនាយកក្រសួងសុរិយោដីនោះទេ ។

នៅទីនេះ ជាដំបូងយើងបានទទួលកិត្តិយសនិងការផ្ទាក់ផ្ទួមពីសំណាក់មិត្ត នាត គឺយើងមានវាសនាបានស្រស់ស្រូបកាហ្វេទឹកដោះគោយូរៗម្តង ។ មិត្ត នាត ឲ្យបញ្ជាទៅមិត្តនារីកាត់ដេរទាំងនោះឲ្យរៀបចំម្ហូបអាហារសម្រាប់យើងដោយឡែក ។ ក្រោយមក យើងទទួចចូលរួម "ហូប" បាយទឹកជាមួយមិត្តឯទៀតៗ ដោយមានម្ហូបតែមួយមុខដូចគ្នា ។

*ថ្ងៃ១៤ ដល់២៦ ឧសភា*

មិត្តនាត បានប្រគល់អង្រឹងនីឡុងថ្មីមួយមកឲ្យយើង ហើយទូន្មានយើងឲ្យរក្សាការសម្ងាត់ គឺលាក់ឈ្មោះដើម មុខងារ ស្រុកកំណើតរបស់យើង កុំឲ្យនរណាដឹង លើកលែងតែអង្គការថ្នាក់លើ ។

នៅថ្ងៃ១៥ ឧសភា វេលាម៉ោង៧យប់ លោក ហ៊ូ យន់ ជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃទទួលបន្ទុករៀបចំជនបទនិងសហករណ៍ ដែលយើងបានជួបម្តងហើយនៅជិតស្រុកបរសែត បានចូលទៅសាកសួរសុខទុក្ខយើងជាមួយវរជនម្នាក់ទៀតឈ្មោះ សុក ធួក មានងារជាអនុរដ្ឋមន្ត្រីក្រសួងសន្តិសុខជាតិ ក្នុងរាជរដ្ឋាភិបាលរណសិរ្សរបស់ សីហនុ និងជាប្រធាននៃភូមិភាគពិសេស (មន្ទីរ ៣០៥) ។

នៅថ្ងៃ១៥ ឧសភា ដដែលវេលាម៉ោង៤រសៀល យើងបានជួបសន្ទនាលេងជាមួយសមាជិកនៃមន្ទីរឃោសនាការភូមិភាគពិសេសចំនួន៣នាក់ទៀតគឺមិត្ត ឈន សុកធួន ជាវិស្វករមានឈ្មោះក្រៅហៅ "សោម" មិត្ត សៀក តឹកឆាយ ហៅ ថន អតីតសាស្ត្រាចារ្យមធ្យមសិក្សាបឋមភូមិ និងមិត្ត ឌៀន ឌីកាន ហៅ រិន អតីតគ្រូបង្រៀន ។ ក្នុងថ្ងៃដដែលមិត្ត ម៉ែន នីថូ ហៅ ថន អតីតវិស្វករខាងអគ្គិសនី ចូលទៅជួបរាក់ទាក់ជាមួយយើងផងដែរ ។ នៅមន្ទីរសេដ្ឋកិច្ចភាគនេះ យើងតែងបានជួបកម្មាភិបាលខ្មែរក្រហមជាច្រើនរូបទៀតដែលជាអតីតអ្នករដ្ឋការ អតីតនិស្សិតនៅក្រុងភ្នំពេញ ។ គេពុំទាន់ប្រគល់កិច្ចការអ្វីឲ្យយើងធ្វើទេ ។ មួយថ្ងៃៗ យើងរវល់តែទទួលភ្ញៀវនិងអានឯកសារផ្សេងៗដែលមិត្ត នាត បានប្រគល់មកឲ្យយើង មានទស្សនាវដ្តីរណសិរ្ស កាសែត"ពលករបដិវត្តន៍" កាសែត"ប្រជាជនបដិវត្តន៍" ជាដើម ។ យើងកាន់តែអផ្សុកខ្លាំងឡើងៗ ព្រោះយើងគ្មានសេរីភាពចេញដើរតាមភូមិជិតខាងបានទេ ។

នៅក្នុងមន្ទីរនេះ គេបាននិយាយប្រាប់យើងថា លោក ចេង សាយុំប៊ិន នៅឆ្ងាយពីយើងប្រមាណ៥០០ឬ៦០០ម ប៉ុណ្ណោះ គឺនៅក្នុងភូមិតាំងឡៅប៉ែកខាងកើត ។ គាត់រស់នៅជាមួយប្រពន្ធកូនរបស់គាត់ក្នុងភូមិអ្នកស្រុក ។ "អង្គការ" ជួយចិញ្ចឹមគ្រួសារលោក ចេង សាយុំប៊ិន តែពុំទាន់ហ៊ានប្រគល់ភារកិច្ចអ្វីមួយឲ្យគាត់ទេ ។

នៅថ្ងៃ២១ ឧសភា វេលាម៉ោង៦ល្ងាច មិត្ត នាត បាននាំយើងទៅចូលរួមបាយទឹកជាមួយលោក ហ៊ូ យន់ នៅមាត់ស្ទឹង ។ នៅពេលនេះហើយដែលយើងបានជួបមិត្ត ហង់ (យើងស្រាវជ្រាវរកឈ្មោះដើមនិងមុខងារចាស់ពុំលេចសោះ) អនុប្រធានភូមិភាគពិសេសលោក រស់ ជាឡោ ហៅ ជាតិ លោក ធួន អេង ហៅ នី (អតីតវិស្វករ) លោក កុយ ធុំ ហៅ ទីប (ធ្វើការនៅអយស្ម័យានកម្ពុជា) និង ស្ហួលខ្មែរក្រហម៣ឬ៤នាក់ទៀតដែលយើងពុំស្គាល់ឈ្មោះ ។ ប្រពន្ធលោក សៀង ប៉ៅសែ ប្រពន្ធមិត្ត ហង់ និងមិត្តនារីកាត់ដេរ ជាអ្នកចាត់ចែងរៀបចំម្ហូបចំណីពិសេសនេះ ។

លោក ហ៊ូ យន់ មានអង្គរក្សម្នាក់ជាខ្មែរលើនៅរតនគិរីដើរតាមការពារជានិច្ច ។ ***(នៅមានត)***

**អ៊ិត សារិន**

**ពាក្យស្លោកខ្មែរក្រហម**

◆ **កាន់តែវាយកាន់តែខ្លាំង កាន់តែខ្លាំងកាន់តែឈ្នះ។**

*(កំណត់ហេតុលេខ០០៤)*

# បញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេចនៅមន្ទីរ ស-២១ (គុកទួលស្លែង)

រៀបចំនិងចងក្រងដោយៈ យិន នាន

(តពីលេខមុន)

| ល.រ | ឈ្មោះ | តួនាទី | កន្លែងយក | ថ្ងៃចូល | ថ្ងៃកម្ទេច |
|---|---|---|---|---|---|
| ៥៥២ | រៀម រីន | ប្រជាជន | កំពង់ចម្លង | ២៧-៣-៧៦ | ២៧-៥-៧៦ |
| ៥៥៣ | អ៊ុច សន | ប្រជាជន | ព្រែកកប្បាស | ២៧-៣-៧៦ | ២៧-៥-៧៦ |
| ៥៥៤ | យិន ប៊ុនហុក | ប្រជាជន | ឫស្សីកែវ | ២៧-៣-៧៦ | ២៧-៥-៧៦ |
| ៥៥៥ | កង នួន ហៅ ហេង | ប្រជាជន | ស្រះចក | ២៧-៣-៧៦ | ២៧-៥-៧៦ |
| ៥៥៦ | យៀង សួង | ប្រជាជន | ឫស្សីកែវ | ២៧-៣-៧៦ | ២៧-៥-៧៦ |
| ៥៥៧ | អ៊ុង សើ | ប្រជាជន | កំពង់ចម្លង | ២៧-៣-៧៦ | ២៧-៥-៧៦ |
| ៥៥៨ | ង៉ែត ជិន | ប្រជាជន | កំពង់ចម្លង | ២៧-៣-៧៦ | ២៧-៥-៧៦ |
| ៥៥៩ | ម៉ាត់ សាស់ | ប្រជាជន | ពោធិចិនតុង | ២៧-៣-៧៦ | ២៧-៥-៧៦ |
| ៥៦០ | ព្រំ ដួង | ប្រជាជន | តំបន់២៥ | ២៧-៣-៧៦ | ២៧-៥-៧៦ |
| ៥៦១ | ម៉ី លីហ៊ាត ហៅ លីភាព | ប្រជាជន | តំបន់២៥ | ២៧-៣-៧៦ | ២៧-៥-៧៦ |
| ៥៦២ | ស ង៉ុន ហៅ អួន | ប្រជាជន | តំបន់២៥ | ២៧-៣-៧៦ | ២៧-៥-៧៦ |
| ៥៦៣ | តៀង មិត្ត | កម្មករ | កំពង់សោម | ៨-១-៧៦ | ២៧-៥-៧៦ |
| ៥៦៤ | សាម៉ាក់ ការីម | នេសាទត្រី | ពញាឮ | ៨-១-៧៦ | ២៧-៥-៧៦ |
| ៥៦៥ | ហូ ទ្រី | កម្មករ | ចាក់អង្រែក្រោម | ៧-១-៧៦ | ២៧-៥-៧៦ |
| ៥៦៦ | តា ជីវើង | កម្មករ | ផែកំពង់សោម | ២៩-១-៧៦ | ២៧-៥-៧៦ |
| ៥៦៧ | ប៉ោ ហួត | កម្មករ | តម្បាញ ត-៥ | ៨-៥-៧៦ | ២៧-៥-៧៦ |
| ៥៦៨ | ប៊ុត ជន | កម្មករ | រោងចក្រថ្មពិល | ១១-៤-៧៦ | ២៧-៥-៧៦ |
| ៥៦៩ | ហេង អឿន | កម្មករ | រោងចក្រថ្មពិល | ១១-៤-៧៦ | ២៧-៥-៧៦ |
| ៥៧០ | ស៊ឹម ឃន | កម្មករ | តម្បាញ ត-៥ | ១១-៤-៧៦ | ២៧-៥-៧៦ |
| ៥៧១ | ឆូ ប៊ុម | កម្មករ | តម្បាញ ត-៥ | ១១-៤-៧៦ | ២៧-៥-៧៦ |
| ៥៧២ | គីម ហួយ | កម្មករ | តាខ្មៅ | ១១-៤-៧៦ | ២៧-៥-៧៦ |
| ៥៧៣ | ឡាក់ ង៉ិចស៊ាង | កម្មករ | តាខ្មៅ | ១១-៤-៧៦ | ២៧-៥-៧៦ |
| ៥៧៤ | សុក ណាន់ | កម្មករ | តម្បាញ ត-៤ | ? | ២៧-៥-៧៦ |
| ៥៧៥ | សយ សារិន | កម្មករ | តម្បាញ ត-៥ | ? | ២៧-៥-៧៦ |
| ៥៧៦ | ជិន សុនឡេង | កម្មករ | តម្បាញ ត-៤ | ? | ២៧-៥-៧៦ |
| ៥៧៧ | ទី សុវត្ថា | កម្មករ | ចាក់អង្រែ | ១១-៤-៧៦ | ២៧-៥-៧៦ |

(នៅមានត)



# មុនជំបូងខ្មែរក្រហមសម្លាប់ប៉ារបស់ខ្ញុំ

## ការចងចាំរបស់កុមារីកម្ពុជាម្នាក់

**លឿង អ៊ុង**

***(តពីលេខមុន)***

ខ្ញុំខ្លាចបងប្រុស ឃួយ របស់ខ្ញុំណាស់ ជួនកាលគាត់ចាំខ្ញុំនៅចង្ក្រានបាយមើលខ្ញុំញ៉ាំបាយឲ្យបានត្រឹមត្រូវ ។ ពេលតម្រង់ទៅចង្ក្រានបាយ ខ្ញុំឆ្លៀតចូលបន្ទប់គេងរបស់ខ្ញុំ ឃើញ បងគាវ កំពុងតែញាត់សម្លៀកបំពាក់ចូលក្នុងថង់ប្លាស្ទិកពណ៌ត្នោតមួយ ។ នៅលើគ្រែ ហ្គិច អង្គុយលេងជាមួយកូនកញ្ចក់តូចមួយយ៉ាងស្ងៀមស្ងាត់ ក្នុងខណៈដែល បងជូ បោះក្រាសសិតសក់និងគង្កៀបសក់របស់យើងទៅក្នុងកាបូបរៀនរបស់គាត់ ។

ដើម្បីរក្សាភាពស្ងៀមស្ងាត់ ខ្ញុំក៏ដើរជំទើតជើងទៅចង្ក្រានបាយ ដោយដឹងច្បាស់ណាស់ថា បងឃួយ ពិតជានៅទីនោះ ។ គាត់កំពុងតែញ៉ាំបាយដោយប្រើដៃស្តាំ ចំណែកឯដៃឆ្វេងរបស់គាត់កំពុងកាន់រំពាត់ផ្តៅដ៏ស្តើងមួយដែលដាក់លើតុបាយជាស្រេច ។ នៅជិតរំពាត់ផ្តៅនោះមានបាយមួយចានគោមនិងពងទាប្រៃពីរ-បី ។ រំពាត់ផ្តៅនេះ គ្រូបង្រៀនភាសាចិនប្រើសម្រាប់ចង្អុលតួអក្សរនៅលើក្តារខៀន ។ ពេលនេះ រំពាត់នៅក្នុងដៃរបស់ បងឃួយ វាត្រូវបានគាត់ប្រើដើម្បីអប់រំប្អូនៗគ្រប់បញ្ហាទាំងអស់ ។ ខ្ញុំត្រូវបានបង្រៀនឲ្យភ័យខ្លាចអ្វីដែលបងប្រុសរបស់ខ្ញុំនឹងធ្វើជាមួយរំពាត់នោះ ក្នុងករណីដែលខ្ញុំមិនបានអនុវត្តតាមអ្វីដែលគាត់ប្រាប់ ។

ខ្ញុំញញឹមដាក់ បងឃួយ អស់មួយទំហឹង ប៉ុន្តែពេលនេះការញញឹមមិនអាចយកមកប្រើការបានទេ គាត់បញ្ជាខ្ញុំយ៉ាងតឹងរ៉ឹង ឲ្យខ្ញុំទៅលាងដៃហើយមកញ៉ាំបាយ ។ នៅក្នុងពេលភ្លាមៗដូច្នេះធ្វើឲ្យខ្ញុំស្អប់គាត់ជាខ្លាំង ខ្ញុំស្ទើរតែមិនអាចរង់ចាំសងសឹកគាត់រហូតទាល់តែខ្ញុំធំប៉ុនគាត់បានឡើយ ។ ពេលដែលខ្ញុំធំ ខ្ញុំនឹងសងសឹកគាត់វិញម្តង ប៉ុន្តែនៅក្នុងពេលនេះដោយហេតុខ្ញុំនៅតូចជាងគាត់ ខ្ញុំត្រូវតែស្តាប់គាត់សិន ។ ខ្ញុំយំហូរទឹកភ្នែករហាម ដកដង្ហើមអណ្តឹតអណ្តកបណ្តើរ ញាត់បាយបន្តិចៗចូលមាត់បណ្តើរ ។ គ្រប់ពេលដែល បងឃួយ សម្លឹងទៅកន្លែងផ្សេង ខ្ញុំលៀនអណ្តាត ហើយញាក់មុខដាក់គាត់ ។

បី-បួននាទីក្រោយមក ម៉ារត់មកចង្ក្រានបាយហើយចាប់ផ្តើមរៀបចានគោម ចានសំប៉ែត ស្លាបព្រា សម និងកាំបិតដែលធ្វើពីអាលុយមីញ៉ូម ដាក់ទៅក្នុងឆ្នាំងធំមួយ ។ សំឡេងម៉ឺងៗនៃការទង្គិចរវាងកាំបិត ស្លាបព្រា និងសមបានលាន់ឮយ៉ាងខ្លាំង ធ្វើឲ្យខ្ញុំប្រាស់ប្រាល់ បន្ទាប់មកគាត់ញាត់ស្ករស អំបិល ត្រីងៀតអង្ករ និងម្ហូបកំប៉ុង ទៅក្នុងថង់មួយ ។ នៅក្នុងបន្ទប់ទឹក បងគីមយកសាប៊ូកក់សក់ កន្សែងពោះគោ រៀបវាតាមលំដាប់លំដោយដាក់ក្នុងស្រោមខ្នើយកើយមួយ ។

គាត់សួរខ្ញុំដោយសង្កត់សំឡេងថា «ឯងមិនទាន់ញ៉ាំហើយទេឬ?» ។

«អត់ទាន់រួចទេ» ។

«មិនអីទេ ទៅ! ទៅលាងដៃចេញ ហើយដើរទៅឡានដឹកទំនិញរបស់យើងតែម្តងណា៎» ។

ដោយក្តីរីករាយ ខ្ញុំអាចគេចចេញពីក្រសែភ្នែករបស់បងឃួយ ដែលកំពុងសម្លឹងមើលមកខ្ញុំ ។ ខ្ញុំក៏ប្រញាប់ប្រញាល់លោតចេញពីកៅអីហើយដើរឆ្ពោះទៅបន្ទប់ទឹក ។

“ម៉ា! យើងទៅណា ហេតុអ្វីបានជាប្រញាប់ប្រញាល់ម៉្លេះ?” ខ្ញុំស្រែកពីបន្ទប់ទឹកទៅរកម៉ា ពេលដែល បងគីម កាន់ស្បោងដើរចេញទៅ ។

“ឯងគួរតែប្រញាប់ឡើងហើយដូរអាវចេញ អាវដែលឯងកំពុងពាក់នេះគគ្រិចណាស់ ហើយចុះទៅចូលឡាននៅខាងក្រោមពូទេ?” ។ ម៉ាប្រាប់ខ្ញុំ ហើយងាកមុខចេញដោយមិនឆ្លើយនឹងសំណួររបស់ខ្ញុំឡើយ ។ ខ្ញុំជឿថានេះមកពីអាយុរបស់ខ្ញុំ ទើបបានជាគ្មានអ្នកណាម្នាក់យកចិត្តទុកដាក់នឹងខ្ញុំ ។ ខ្ញុំតែងតែមានអារម្មណ៍ខកចិត្តនៅពេលដែលសំណួររបស់ខ្ញុំមិនបានទទួលការឆ្លើយតបម្តងហើយម្តងទៀត ។ ដោយមានអារម្មណ៍ភ័យខ្លាចបងឃួយ កាន់តែខ្លាំងឡើងៗ ខ្ញុំក៏ដើរចូលក្នុងបន្ទប់គេងរបស់ខ្ញុំ ។ បន្ទប់គេងមើលទៅហាក់ដូចជាមានខ្យល់មូសុងដ៏ធំបក់បោកចូលមកអីចឹង ។ ខោអាវ គន្លៀបសក់ ស្បែកជើង ស្រោមជើង ខ្សែក្រវាត់ និងក្រមា នៅរាត់រាយពេញគ្រែខ្ញុំ បងដូ និងហ៊ុច ។ ខ្ញុំដោះអាវចាក់ពណ៌ត្នោតរបស់ខ្ញុំចេញ ហើយយកអាវដៃខ្លីពណ៌លឿង និងខោខ្លីពណ៌ខៀវដែលខ្ញុំរើសពីលើឥដ្ឋមកពាក់វិញ ។ ពេលដែលខ្ញុំស្លៀកពាក់ខោអាវហើយ ខ្ញុំក៏ដើរចុះទៅក្រោមដើរសំដៅរកឡាន ។ ជិះឡានម៉ាស់ដាពណ៌ខ្មៅរលោង វាមានជាសុភាពជាងជិះខាងក្រោយឡានដឹកទំនិញ ។ ជិះឡានម៉ាស់ដារបស់យើង វាអាចប្រាប់មនុស្សគ្រប់គ្នាថាយើងមកពីគ្រួសារឋានៈកណ្តាល ។ ថ្វីដ្បិតតែម៉ាប្រាប់ខ្ញុំឲ្យឡើងជិះឡានដឹកទំនិញក៏ដោយ ខ្ញុំនៅតែដើរតម្រង់ទៅរកឡានតូច ។ នៅពេលដែលខ្ញុំហៀបឈានជើងឡើងជិះឡានម៉ាស់ដា ខ្ញុំឮ បងគីម ហៅខ្ញុំឲ្យចេញមកវិញ ។

ប៉ានិយាយថា “កុំឡើងឡានមួយហ្នឹង! យើងត្រូវទុកឡានម៉ាស់ដានៅទីហ្នឹងហើយ” ។

“ហេតុអីប៉ា? ខ្ញុំចូលចិត្តជិះឡានហ្នឹងជាងជិះឡានដឹកទំនិញ” ។ ជាថ្មីម្តងទៀត បងគីម បែរខ្នងចេញមិនឆ្លើយតបនឹងសំណួរខ្ញុំឡើយ ។ ប៉ាទិញឡានដឹកទំនិញនេះសម្រាប់ប្រើក្នុងការដឹកទំនិញឲ្យគេនៅពេលដែលគាត់ប្រកបអាជីវកម្មអាហរ័ណ-នីហរ័ណជាមួយមិត្តភក្តិ ប៉ុន្តែដោយសារមុខជំនួញនោះមិនដំណើរការ ឡានដឹកទំនិញនេះក៏ត្រូវចតចោលនៅផ្លូវតូចខាងក្រោយផ្ទះរបស់យើងជាច្រើនខែមកហើយ ។ ឡានដឹកទំនិញចាស់គំរិលនេះបញ្ចេញសូរសំឡេងង៉េតង៉ុតៗពេលដែល បងឃួយ បោះស្បោងខោអាវទៅលើវា ។ នៅពីមុខឡាន ប៉ាកំពុងតែចងក្រណាត់ពណ៌សមួយភ្ជាប់នឹងអង់តែនឡានក្នុងខណៈដែល បងម៉េង យកក្រណាត់មួយចម្រៀកទៀតទៅចងកញ្ចក់មើលក្រោយទាំងសងខាងរបស់ឡាន ។ ដោយគ្មាននិយាយអ្វីមួយម៉ាត់ បងឃួយ លើកខ្ញុំដាក់ខាងក្រោយគូទឡានដែលមានសុទ្ធតែស្បោង ខោអាវ ចានឆ្នាំង និងចំណីអាហារនៅក្នុងនោះ ។ បងប្អូនរបស់ខ្ញុំទាំងអស់បានឡើងលើឡាន ហើយយើងក៏បើកបរចេញទៅ ។

នាថ្ងៃនោះ នៅតាមដងវិថីនានាក្នុងក្រុងភ្នំពេញថ្លង់ជាងថ្ងៃណាៗទាំងអស់ ។ បងម៉េង បងគាវ បងគីម បងដូ និងខ្ញុំអង្គុយនៅក្រោយគូទឡានដឹកទំនិញ ហើយប៉ា ម៉ា និងហ៊ុចអង្គុយនៅក្នុងបាំងខាងមុខ ។ ចំណែក បងឃួយ ជិះម៉ូតូយឺតៗតាមពីក្រោយយើង ។ ពីលើឡានដឹកទំនិញរបស់យើង យើងឮសូរសំឡេងរោទ៍របស់ម៉ាស៊ីនឡាននិងម៉ាស៊ីនម៉ូតូយ៉ាងកងរំពងព្រមទាំងស្នូរគោះកណ្តឹងរបស់ស៊ីក្លូ ស្នូរចានឆ្នាំងទង្គិចគ្នា និងសំឡេងយំរបស់មនុស្សដែលនៅជុំវិញ ។ មិនមែនតែគ្រួសារយើងមួយទេដែលត្រូវចាកចេញពីទីក្រុងភ្នំពេញ ប្រជាជនដទៃទៀតក៏ត្រូវចាកចេញពីផ្ទះដែរ ។ មនុស្សទាំងអស់ដើរនៅតាមផ្លូវនានាដោយល្បឿនយឺតៗដើម្បីចេញពីទីក្រុង ។ដូចជាគ្រួសារយើងដែរ អ្នកខ្លះមានសំណាងល្អអាចមានយានជំនិះ ប៉ុន្តែទោះជាយ៉ាងនេះក៏ដោយ ក៏ប្រជាជនភាគច្រើនត្រូវតែធ្វើដំណើរដោយថ្មើរជើង ហើយស្បែកជើងសង្រែកផ្ទាត់ប៉ះ ទៅនឹងកែងជើងរបស់គេឮសូរផ្ទាប់ៗគ្រប់ជំហានទាំងអស់ ។ ឡានរបស់យើងរំកិលទៅមុខសន្សឹមៗ ធ្វើឲ្យយើងមើលឃើញព្រឹត្តិការណ៍ដែលកើតឡើងនៅជុំវិញយើងបានយ៉ាងស្រួល ។ នៅគ្រប់ទិសទីប្រជាជនស្រែកហៅអ្នកដែលមិនទាន់ចាកចេញទាំងទឹកភ្នែក ។ ក្មេងតូចៗកំពុងយំរកម្តាយដោយមានសំបោរ ហៀរកក្អាក់ពីច្រមុះចូលក្នុងមាត់ ។ អ្នកចម្ការវាយសត្វពាហនៈរបស់គេដោយគ្មានអាណិត ដើម្បីឲ្យសត្វទាំងនោះអូសរទេះកង់បួនរបស់គេទៅមុខលឿនជាងនេះបន្តិច ។ បុរសស្ត្រីនាំគ្នាយួរនិងលីស្បោងរបស់របរនៅលើស្មា ឬទូលលើក្បាល ។ អ្នកទាំងនោះដើរយ៉ាង

រហ័សរហួន ដោយស្រែកទៅកូនៗរបស់គេឲ្យដើរជុំគ្នាហើយកាន់ដៃឲ្យជាប់ កុំឲ្យដើរដាច់ពីគ្នា ។ ខ្ញុំត្រសុលទៅជិត បងគាវ ពេលដែលពិភពមនុស្សធ្វើដំណើរយ៉ាងប្រញាប់ប្រញាល់ដោយភាពច្របូកច្របល់ ដើម្បីចាកចេញពីទីក្រុង ។

យើងឃើញមានកងទ័ពច្រើនណាស់នៅជុំវិញយើង កងទ័ពនៅគ្រប់ទីកន្លែងទាំងអស់ ស្រែកខ្លាំងៗដាក់ប្រជាជន ពួកគេលែងញញឹមដូចដែលខ្ញុំបានឃើញពីដំបូងទៀតហើយ ។ ឥឡូវនេះ គេស្រែកយ៉ាងខ្លាំងដោយប្រើសម្តីឌឺដងសម្បុរមករកយើង ។ ដោយសឹកម្រាមដៃក្នុងកៃកាំភ្លើង គេស្រែកគំរាមប្រជាជនឲ្យបិទទ្វាររហាង ហើយឲ្យទម្លាក់អាវុធចុះ និងយកទៅប្រគល់ឲ្យគេ ។

គេស្រែកគំហកដាក់គ្រួសារផ្សេងៗទៀតឲ្យដើរលឿនៗទៅមុខ គេបញ្ជាឲ្យប្រជាជនដើរជៀសពីផ្លូវរបស់គេ ហើយហាមមិនឲ្យប្រជាជនបែរមកក្រោយនិយាយជាមួយអ្នកផ្សេងឡើយ ។ ខ្ញុំទ្រោបមុខទៅលើទ្រូង បងគាវ ដៃរបស់ខ្ញុំឱបចង្កេះគាត់យ៉ាងណែនដើម្បីលាក់ការយំរបស់ខ្ញុំ ។ បងដួ អង្គុយបិទភ្នែកយ៉ាងស្ងៀមស្ងាត់នៅចំហៀងម្ខាងទៀតនៃ បងគាវ ។ នៅក្បែរយើង បងគឹម និង បងម៉េង អង្គុយធ្វើមុខធ្មឹងដូចរូបចម្លាក់ដោយភាពរំជើបរំជួលក្នុងចិត្តពេលមើលឃើញទិដ្ឋភាពនៅជុំវិញឡាន ។

ខណៈដែលខ្ញុំយកដៃច្របាច់ដៃ បងគាវ កាន់តែណែនទៅៗ ខ្ញុំសួរគាត់ថា «បងគាវ! ហេតុអ្វីបានជាកងទ័ពចិត្តអាក្រក់ចំពោះយើងម្ល៉េះ?» ។

«ស៊ូត! (កុំមាត់) កងទ័ពទាំងនោះគេហៅថាខ្មែរក្រហម ពួកគេសុទ្ធតែជាពួកកុម្មុយនិស្ត» ។

«កុម្មុយនិស្តហ្នឹងស្អីទៅ?» ។

បងគាវ ខ្សឹបដាក់ខ្ញុំថា «កុម្មុយនិស្តមានន័យថា...វាពិបាកពន្យល់ណាស់ ។ ចាំសួរប៉ាពេលក្រោយទៅ» ។

បងគាវ ធ្លាប់ប្រាប់ខ្ញុំថា កងទ័ពទាំងនោះបានអួតថាគេស្រលាញ់ប្រទេសនិងប្រជាជនកម្ពុជាយ៉ាងខ្លាំង ។ អ៊ីចឹងហើយបានជាខ្ញុំឆ្ងល់ថា ប្រសិនបើពួកគេអួតថាស្រឡាញ់យើងខ្លាំង ហេតុអ្វីបានជាគេធ្វើអាក្រក់មកលើប្រជាជនយ៉ាងនេះ ។ ព្រឹកមិញ ខ្ញុំបានគ្រវីដៃអបអរសាទរដាក់ ប៉ុន្តែឥឡូវនេះ កងទ័ពទាំងនោះបែរជាធ្វើឲ្យខ្ញុំភ័យខ្លាចទៅវិញ ។

«យកតែរបស់បន្តិចបន្តួចដែលអ្នកឯងអាចយកទៅបានបានហើយ! អ្នកឯងមិនចាំបាច់យករបស់របរពីទីក្រុងទៅច្រើនទេ! អ្នកឯងនឹងត្រឡប់មកផ្ទះវិញក្នុងរយៈពេលបីថ្ងៃក្រោយ! គ្មាននរណាម្នាក់អាចនៅទីក្រុងបានទេ! ទីក្រុងត្រូវតែសម្អាតហើយទុកឲ្យនៅទទេស្អាត! អាមេរិកកាំងនឹងទម្លាក់គ្រាប់បែកមកលើទីក្រុងនេះ! យើងចេញទៅរស់នៅជនបទតែបីបួនថ្ងៃប៉ុណ្ណោះ! ទៅចេញក្លាមកុំបង្អង់!» ។ កងទ័ពនិយាយខ្លាំងៗនូវឃ្លាដដែលៗជាច្រើនលើកច្រើនសា ។

ខ្ញុំយកដៃខ្ទប់ត្រចៀករបស់ខ្ញុំ ហើយផ្ទប់មុខខ្ញុំទៅនឹងទ្រូងរបស់ បងគាវ ។ ខ្ញុំមានអារម្មណ៍ថា ដៃទាំងពីររបស់គាត់កំពុងឱបក្រសោបខ្លួនប្រាណដ៏តូចរបស់ខ្ញុំយ៉ាងណែន ។ កងទ័ពលើកកាំភ្លើងរបស់គេឡើងផុតក្បាល ហើយបាញ់រះទៅលើអាកាសដើម្បីបញ្ជាក់ឲ្យយើងទាំងអស់គ្នាយល់ច្បាស់ពីការគំរាមកំហែងរបស់ពួកគេ ។ បន្ទាប់ពីគេបាញ់គ្រាប់កាំភ្លើងមួយសាមក មនុស្សម្នាបានរុញច្រានគ្នាក្នុងសភាពយ៉ាងកោលាហល ដើម្បីស្រូតដើរទៅមុខចេញពីទីក្រុង ។ ខ្លួនខ្ញុំពោរពេញទៅដោយភាពភ័យខ្លាច ប៉ុន្តែជាសំណាងល្អ គ្រួសាររបស់ខ្ញុំមានឡានដឹកទំនិញមួយដែលយើងអាចជិះគេចចេញពីហ្វូងមនុស្សដ៏ស្ទង់ស្ទោទាំងនោះដោយសុវត្ថិភាព ។

## ការជម្លៀសចេញ

**ខែមេសា ឆ្នាំ១៩៧៥**

រយៈពេលជាច្រើនម៉ោងក្រោយមក ទីបំផុតយើងបានមកស្ថិតនៅលើដងផ្លូវក្រៅក្រុង ទោះបីជាយើងនៅតែធ្វើដំណើរទៅមុខដោយល្បឿនយឺតៗក៏ដោយ ។

ដោយខ្ញុំមានអារម្មណ៍ថាត្រូវធ្វើដំណើររហូតនោះ ខ្ញុំក៏សួរបងគឹម ម្តងហើយម្តងទៀតថា «តើយើងកំពុងធ្វើដំណើរទៅណាហ្នឹង?» ។

«បងក៏អត់ដឹងដែរ ប៉ុន្តែយើងទើបតែជិះហួសអាកាស-យានដ្ឋានពោធិចិនតុងអម្បាញ់មិញនេះ ដូច្នេះយើងអាចសន្និដ្ឋានបានថា យើងកំពុងឋិតនៅលើផ្លូវជាតិលេខ៤ ។ ឈប់សួរបងគ្រប់តែពេលអ៊ីចឹងទៀតទៅ» ។

ខ្ញុំយកក្រមាមកទទូរបាំងមុខកុំឲ្យត្រូវថ្ងៃ ហើយក៏ដាក់ចិត្តដាក់កាយឈប់មាត់តទៅទៀត ។

ខ្លួនប្រាណរបស់ខ្ញុំចាប់ផ្តើមខ្សោយទៅៗ គ្របកភ្នែករបស់ខ្ញុំព្យាយាមបើកទប់ទល់នឹងពន្លឺថ្ងៃនិងធូលីដែលហុយសំពោងតាមដងផ្លូវ ។ ខ្យល់បក់ផាត់សក់ខ្ញុំបើុងចុះឡើងធ្វើឲ្យមុខខ្ញុំរសើប ប៉ុន្តែខ្ញុំគ្មានញញឹមទេ ។ ខ្ញុំឈឺស្រៀវនៅពេលដែលខ្យល់ក្តៅស្ងួតផាត់ចូលរន្ធច្រមុះរបស់ខ្ញុំ ។ បងគាវ យកដាយក្រមាមករុំច្រមុះនិងមាត់របស់ខ្ញុំយ៉ាងតឹង ដើម្បីកុំឲ្យធូលីហុយចូល ហើយគាត់ប្រាប់ខ្ញុំកុំឲ្យបែរមុខងាកមើលចំហៀងឡាន ។

នៅប្រទេសកម្ពុជាមានរដូវតែពីរគត់គឺ រដូវប្រាំង និង រដូវវស្សា ។ អាកាសធាតុត្រូពិចនៅក្នុងប្រទេសកម្ពុជាគឺគ្របដណ្តប់ទៅដោយរបបខ្យល់មូសុងដែលបក់នាំភ្លៀងដ៏ជោកជាំមកធ្លាក់ពីខែឧសភាដល់ខែតុលា ។ បងគាវ និយាយថា នៅក្នុងខែវស្សា ប្រទេសទាំងមូលក្លាយទៅជាឋានសួគ៌ពណ៌បៃតងមួយ ។ គាត់និយាយថា នៅខែវស្សាមានទឹកច្រើនណាស់ ដែលធ្វើឲ្យដើមឈើដុះខ្ពស់ឡើង ហើយស្លឹកវាក្លាយជាមានពណ៌បៃតងស្រស់បំព្រងដោយសារសំណើម ។

មុនរបបខ្យល់មូសុងដែលបក់មកក្នុងខែឧសភា យើងត្រូវតែស៊ូទ្រាំនឹងខែមេសា ជាខែមានធាតុអាកាសក្តៅជាងគេបំផុតដែលជាញឹកញយសីតុណ្ហភាពឡើងដល់៤៣អង្សាសេ ។ កម្តៅដែលក្តៅខ្លាំងនេះ ធ្វើឲ្យក្មេងៗត្រូវស្ថិតនៅក្នុងផ្ទះដើម្បីជៀសពីពន្លឺព្រះអាទិត្យ ។ ខែមេសាក្តៅដូចជាពេលនេះអីចឹង ។ ក្នុងខណៈដែលយើងជិះឆ្ងាយទៅៗពីទីក្រុង អគារខ្ពស់ៗក៏បាត់ស្រមោល ហើយជំនួសមកវិញដោយខ្ទមស្បូវតូចៗ ។ សំណង់នៅក្នុងទីក្រុងខ្ពស់ៗ សង់កៀកៗគ្នា ប៉ុន្តែផ្ទះខ្ទមវិញ ត្រូវគេសង់ទាបៗ នៅរាយប៉ាយពាសពេញកណ្តាលវាលស្រែ ។ នៅពេលដែលឡានដឹកទំនិញរបស់យើងរំកិលទៅមុខបន្តិចម្តងៗ មហាវិថីដែលក្រាលកៅស៊ូយ៉ាងធំក៏ត្រូវជំនួសដោយផ្លូវដីហុយទ្រលោមដែលមើលទៅមិនខុសពីផ្លូវលំសម្រាប់រទេះគោទេ ។

ដើមឈើនិងផ្ការីកត្រកុំត្រកាលក្នុងទីក្រុងភ្នំពេញ ត្រូវបានជំនួសមកវិញដោយស្មៅដំរីខ្ពស់ៗនិងគុម្ពោតព្រៃដែលមានសុទ្ធតែបន្លា ។ ខ្ញុំចាប់ផ្តើមមានអារម្មណ៍ចង់ក្អួត ខណៈដែលខ្ញុំងាកមើលទៅភូមិដែលឡានបើកឆ្លងកាត់រំលងពីភូមិមួយទៅភូមិមួយទៀត ។ មើលទៅឆ្ងាយដាច់កន្ទុយភ្នែក ខ្ញុំឃើញមនុស្សម្នាកំពុងតែដើរតាមផ្លូវ ខណៈដែលផ្ទះខ្ទមត្រូវប្រជាជនចាកចោល ហើយវាលស្រែគ្មានមនុស្សថែទាំ ។ ខ្ញុំគេងលក់នៅលើឡាន ហើយសុបិនថាខ្ញុំកំពុងនៅឯផ្ទះឯណោះ ហើយកំពុងតែលេងមីកជាមួយមិត្តភក្តិរបស់ខ្ញុំ ។ នៅពេលខ្ញុំភ្ញាក់ដឹងខ្លួនឡើងវិញ ខ្ញុំឃើញឡានរបស់យើងនៅចតរួចទៅហើយ នៅជិតខ្ទមមួយដែលគ្មានមនុស្សរស់នៅ ។ យើងចង់នៅទីនេះដើម្បីសម្រាកពេលយប់ ។ ទោះបីជាយើងទើបតែធ្វើដំណើរបានតែដប់ប្រាំមួយគីឡូម៉ែត្រក៏ដោយ ក៏គ្រួសារយើងកំពុងតែស្ថិតនៅក្នុងពិភពមួយទៀតខុសប្លែកស្រឡះពីទីក្រុងភ្នំពេញ ។ ពន្លឺព្រះអាទិត្យបានបន្ធូរស្មើ ធ្វើឲ្យយើងទាំងអស់បានធូរស្រាលពីកម្តៅ ។ វាលស្រែដែលព័ទ្ធជុំវិញយើង ពោរពេញទៅដោយភ្នក់ភ្លើងតូចៗដែលបំភ្លឺឲ្យឃើញព្រាលៗនូវមុខស្ត្រីម្នាក់កំពុងអង្គុយចោងហោងរៀបចំចម្អិនអាហារ ។

ខ្ញុំនៅតែអាចមើលឃើញមនុស្សរាប់រយពាន់នាក់កំពុងដើរ រញៀវទៅកាន់ទីកន្លែងនានាដែលគេមិនស្គាល់ ។ អ្នកខ្លះទៀតតួយ៉ាងដូចជាពួកយើង បានឈប់នៅតាមចិញ្ចើមផ្លូវដើម្បីសម្រាកពីរ-បីម៉ោង ។

គ្រួសាររបស់ខ្ញុំខំស្រវាស្រទេញរកកន្លែងបោះជំរំនៅក្នុងវាលស្រែជិតខ្ទមមួយដែលម្ចាស់គេបោះបង់ចោល ។ បងប្រុសទាំងអស់របស់ខ្ញុំបានទៅប្រមែប្រមូលឈើមកបង្កាត់ភ្លើងក្នុងខណៈដែល ម៉ា និង បងគាវ រៀបចំអាហារ ចំណែកឯ បងជួកំពុងសិតសក់ឲ្យ ហ្គិច យ៉ាងផ្ចិតផ្ចង់ ។ នៅពេលអ្វីៗត្រូវរៀបចំរួចរាល់ហើយ យើងនាំគ្នាអង្គុយព័ទ្ធជុំវិញភ្នក់ភ្លើង ហើយទទួលទានបាយពេលល្ងាចជាមួយសាច់ជ្រូកប្រឡាក់ដែលម៉ាបានចម្អិនកាលពីព្រឹកមិញ ។ នៅទីនេះគ្មានតុ គ្មានកៅអីភ្ញាក់ដៃសម្រាប់ឲ្យយើងអង្គុយទេ ។ ពេលដែលកូនៗអង្គុយចោងហោងលើដី ប៉ានិងម៉ាអង្គុយលើកន្ទេលកក់តូចមួយដែលម៉ាបានយកមកជាមួយ ។

"ខ្ញុំត្រូវតែទៅបត់ទឹក" ខ្ញុំប្រាប់ម៉ាជាបន្ទាន់បន្ទាប់ពីទទួលទានអាហារពេលល្ងាចរួច ។

«កូនត្រូវតែទៅរកគុម្ពោតព្រៃ» ។

«ប៉ុន្តែទៅកន្លែងណាទៅ?» ។

«កន្លែងណាក៏ដោយឲ្យតែកូនរកឃើញ ចាំបន្តិច ម៉ាទៅយកក្រដាសបង្គន់ឲ្យខ្លះ» ។ ម៉ាក៏ដើរចេញទៅ ហើយត្រឡប់មកវិញដោយកាន់ក្រដាសមួយបាច់នៅក្នុងដៃផង ។

ភ្នែករបស់ខ្ញុំបើកធំៗហាក់មិនជឿខ្លួនឯង «ម៉ា! វាគឺជាលុយណា៎ ខ្ញុំមិនអាចយកលុយធ្វើជាក្រដាសបង្គន់បានទេ!» ។

នៅពេលម៉ាហុចក្រដាសលុយយ៉ាងស្រួយស្រោកនោះមកឲ្យខ្ញុំ ម៉ាឆ្លើយតបថា «ប្រើវាទៅ វាគ្មានន័យអ្វីចំពោះយើងទៀតទេ!» ។ ខ្ញុំមិនយល់ពីរឿងនេះទេ ខ្ញុំគ្រាន់ដឹងថា យើងពិតជាជួបប្រទះនឹងបញ្ហាពិបាកខ្លាំងពិតប្រាកដមួយ ។ ខ្ញុំដឹងថា នេះមិនមែនជាពេលដែលខ្ញុំត្រូវតវ៉ាទេ ដូច្នេះហើយ ខ្ញុំក៏ក្តោបលុយទាំងនោះរួចដើរសំដៅទៅរកគុម្ពោតព្រៃ ។

បន្ទាប់ពីខ្ញុំបត់ជើងហើយ បងដូ និង ខ្ញុំក៏សម្រេចចិត្តដើរពិនិត្យមើលនៅម្តុំកន្លែងគុម្ពោតព្រៃនោះ ។ ពេលដែលយើងដើរ យើងឮសូរល្បឿននៃសម្រឹបជាន់ស្លឹកឈើនៅក្នុងគុម្ពោតព្រៃរសាត់មកជិតយើង ។ យើងប្រឹងខ្លួន ហើយកាន់ដៃគ្នាទៅវិញទៅមក ដោយខំប្រឹងទប់ដង្ហើម ប៉ុន្តែបន្ទាប់មក យើងឃើញកូនឆ្មាមួយកំពុងដើរយ៉ាងស្ងៀមស្ងាត់ចេញមកពីគុម្ពោតព្រៃដើម្បីស្វែងរកចំណី ។ ម្ចាស់របស់វាប្រហែលជាប្រញាប់ប្រញាល់ចាកចេញពីផ្ទះរហូតដល់ភ្លេចយកវាទៅជាមួយហើយមើលទៅ ។

«បងដូ! ខ្ញុំចង់ដឹងថាមានរឿងអ្វីអាចកើតឡើងចំពោះឆ្មាយើងហ្ន៎» ។

«កុំខ្វល់រឿងឆ្មា» ។

នៅភ្នំពេញយើងមានឆ្មាប្រាំ ។ ទោះបីជាយើងនិយាយថាវាជាឆ្មារបស់យើងក៏ដោយ ក៏យើងមិនដែលប្រកាសប្រាប់គេឯងថាវាជារបស់យើងពិតប្រាកដដែរ ។ សូម្បីតែឈ្មោះវាក៏យើងមិនដែលដាក់ឲ្យផង ។ ឆ្មាទាំងនេះមកផ្ទះយើងនៅពេលដែលវាឃ្លាន ហើយចេញទៅវិញនៅពេលដែលវាធុញទ្រាន់ ។ នៅពេលយើងសួរគាត់ បងគឹម និយាយកំប្លែងលេងជាមួយយើងថា «ប្រហែលនរណាម្នាក់យកវាទៅធ្វើអាហារពេលល្ងាចបាត់ទៅហើយពេលនេះ» ។ យើងទាំងអស់គ្នាក៏សើច ហើយស្តីឲ្យគាត់ដែលយករឿងដូច្នេះមកនិយាយលេងសើច ។ ជាទូទៅប្រជាជនកម្ពុជាមិនបរិភោគសាច់ឆ្កែសាច់ឆ្មាទេ ។ មានហាងពិសេសខ្លះលក់សាច់ឆ្កែ ប៉ុន្តែតម្លៃរបស់វាថ្លៃណាស់ ។ សាច់នោះជាអាហារដ៏ឆ្ងាញ់ពិសាមួយ ។ ចាស់ៗនិយាយថា បរិភោគសាច់ឆ្កែធ្វើឲ្យខ្លួនប្រាណរបស់យើងឡើងកម្តៅ ហើយធ្វើឲ្យកម្លាំងរបស់យើងខ្លាំងជាងមុន ប៉ុន្តែយើងមិនត្រូវបរិភោគច្រើនពេកទេ បើយើងបរិភោគច្រើន ខ្លួនរបស់យើងនឹងក្តៅរោលរាលខ្លាំងជាមិនខាន ។ នៅពេលយប់នោះ ម៉ាបានដាក់ឲ្យខ្ញុំគេងនៅខាងក្រោយឡានដឹកទំនិញរបស់យើង ។ បងដូ ហ្កិច ហើយនិងខ្ញុំ គេងនៅលើឡានជាមួយគ្នា ចំណែកកូនធំៗគេងនៅខាងក្រោមជាមួយប៉ា ។ យប់នោះ មានខ្យល់ត្រជាក់បក់រំភើយៗដែលជាប្រភេទអាកាសធាតុមិនតម្រូវឲ្យយើងប្រើភួយដណ្តប់ឡើយ ។ ខ្ញុំចូលចិត្តគេងមើលផ្កាយនៅខាងក្រៅផ្ទះណាស់ ។ ការស្រមើស្រមៃរបស់ខ្ញុំបានមកគ្របដណ្តប់ខ្ញុំដោយពន្លឺភ្លើងដ៏ចែងចាំង ប៉ុន្តែខ្ញុំមិនយល់ពីភាពដ៏ធំល្វឹងល្វើយនៃផ្ទៃមេឃទេ ។ ជារៀងរាល់ពេល ខ្ញុំព្យាយាមក្រសោបចិត្តរបស់ខ្ញុំជុំវិញគំនិតយល់ដឹងអំពីពិភពលោកទាំងមូល ចិត្តរបស់ខ្ញុំវិលវល់មិនចេះចប់វាហាក់ដូចជារុំព័ទ្ធទៅដោយពត៌មានដែលខ្ញុំនឹងមិនមានឱកាសអាចយល់បាន ។

«បងដូ! មេឃធំណាស់ហ្ន៎!» ។

«ស៊ូត!! (ស្ងាត់!) បងកំពុងតែសម្ងំគេង» ។

«មើលផ្កាយហ្ន៎! ផ្កាយទាំងនោះស្អាតណាស់ ហើយវាកំពុងតែជះពន្លឺភ្លឹបភ្លែតៗដាក់យើង ។ ខ្ញុំបន់ស្រន់សុំឲ្យខ្ញុំអាចទៅនៅទីនោះជាមួយវានិងទេវតា» ។

«ល្អហើយ ឥឡូវគេងទៅ» ។

«បងដឹងទេ ផ្កាយទាំងនោះគឺប្រៀបដូចជាភ្លើងទៀននៅលើមេឃ ។ ជារៀងរាល់យប់ ទេវតាមកដុត បំភ្លឺវាឲ្យយើងទាំងអស់គ្នា ដូច្នេះហើយប្រសិនបើយើងវង្វេងផ្លូវយើងនៅតែអាចរកផ្លូវឃើញវិញបាន» ។

ជាយូរមកហើយ ប៉ាធ្លាប់ប្រាប់ខ្ញុំថា ខ្ញុំមាននិស្ស័យនឹងការស្រមើស្រមៃ ហើយគាត់ចូលចិត្តស្តាប់រឿងទាំងអស់ដែលខ្ញុំនិទានប្រាប់គាត់ ។

នៅពេលដែលខ្ញុំភ្ញាក់ឡើងវេលាព្រឹកថ្ងៃបន្ទាប់ បងប្អូនទាំងអស់របស់ខ្ញុំបានក្រោកមុនខ្ញុំរួចទៅហើយ ។ គេទាំងអស់គ្នាត្រូវបានដាស់ឲ្យភ្ញាក់ដោយស្នូរកាំភ្លើងរបស់ខ្មែរក្រហមដែលបាញ់នៅទីឆ្ងាយ ប៉ុន្តែដោយខ្ញុំអស់កម្លាំងពេក ខ្ញុំក៏គេងទៅវិញដោយមិនឮអ្វីទាំងអស់ ។ នៅខាងក្រោមភ្នែកបងប្អូនខ្ញុំ សុទ្ធតែមានស្នាមរាងជាំពណ៌ប្រផេះ សក់របស់គេបះច្រូង និងជំពាក់ក្រញេងក្រញាង ។ ខ្ញុំងើបឈរយឺតៗដោយពត់ស្មានិងខ្នងដែលឈឺចុកចាប់របស់ខ្ញុំ ។ គេងនៅលើឡានដឹកទំនិញវាមិនសប្បាយដូចជាខ្ញុំបានគិតពីមុនសោះ ។

បន្តិចក្រោយមក កងទ័ពខ្មែរក្រហមមួយក្រុមបានមកដល់ ហើយស្រែកឲ្យយើងប្រញាប់ចេញដំណើរទៅមុខទៀត ។

បន្ទាប់ពីបានញុាំបាយពេលព្រឹកបន្តិចជាមួយពងទាប្រៃ យើងក៏ត្រឡប់ឡើងទៅលើឡានវិញ ហើយចេញដំណើរបន្តទៅមុខទៀត ។ យើងបើកបរទៅមុខអស់ជាច្រើនម៉ោង ។ នៅគ្រប់ទីកន្លែងដែលយើងឆ្លងកាត់ យើងឃើញមនុស្សជាច្រើនដើរទៅគ្រប់ទិស ។ ព្រះអាទិត្យរះខ្ពស់ណាស់ទៅហើយ ដោយបញ្ចេញកម្តៅយ៉ាងខ្លាំងមកលើខ្នងរបស់យើង វាដុតកម្តៅសក់ក្បាលរបស់ខ្ញុំ ធ្វើឲ្យតំណក់ញើសហូរចុះមកតាមដើងសក់និងបបូរមាត់ខាងលើរបស់ខ្ញុំ ។ ក្រោយពីនោះបន្តិច យើងចាប់ផ្តើមមួម៉ៅដាក់គ្នា ហើយចាប់ផ្តើមប្រកែកគ្នាទៅវិញទៅមក ។

ប៉ាប្រាប់យើងនៅពេលដែលយើងឈប់ញុាំអាហារថ្ងៃត្រង់ថា «យើងនៅមិនឆ្ងាយប៉ុន្មានទៀតទេកូន យើងជិតទៅដល់គោលដៅហើយ បន្តិចទៀតយើងនឹងទៅដល់កន្លែងដែលមានសុវត្ថិភាពហើយ» ។

នៅពេលដែល ម៉ាំនិងបងគាវរៀបចំអាហារ ប៉ានិង បងម៉េងក៏នាំគ្នាចេញទៅរកអុស ។ ពេលគាត់ទាំងពីរត្រឡប់មកវិញ ប៉ាប្រាប់បងឃួយ ថា វាជាការល្អណាស់ដែលយើងចេញពីទីក្រុងបានលឿនដូចនេះ ។ គាត់និយាយថា ប្រជាជនដែលគាត់ទើបតែជួបនិយាយជាមួយអម្បាញ់មិញ បានប្រាប់គាត់ថា កងទ័ពបានបង្ខំឲ្យមនុស្សទាំងអស់ចាកចេញពីទីក្រុង ។ ពួកគេបានជម្លៀសមនុស្សចេញពីសាលា ភោជនីយដ្ឋាននិងមន្ទីរពេទ្យ អស់លើងគ្មានសល់ ។ សូម្បីតែអ្នកជំងឺក៏កងទ័ពខ្មែរក្រហមបង្ខំឲ្យចេញពីមន្ទីរពេទ្យដែរ ។ ប្រជាជនទាំងនោះមិនត្រូវបានអនុញ្ញាតឲ្យទៅផ្ទះរបស់គេសិនមុននឹងចាកចេញពីទីក្រុងទេ ដូច្នេះហើយទើបមានមនុស្សជាច្រើនត្រូវព្រាត់ប្រាសគ្នា ។

បងឃួយ និយាយទាំងទឹកមុខស្រពោនថា «មនុស្សចាស់និងអ្នកជំងឺត្រូវស្លាប់បាត់បង់ជីវិតអស់ជាច្រើន» ។

«ខ្ញុំឃើញមនុស្សចាស់និងអ្នកជំងឺទាំងនោះនៅព្យួរថ្លោកឈាមនៅឡើយ ។ អ្នកខ្លះកំពុងតែដើរ អ្នកខ្លះត្រូវបានបងប្អូនរុញនៅលើរទេះ ឬក៏លើគ្រែពេទ្យ» ។

ឥឡូវខ្ញុំយល់ហើយថា ហេតុអ្វីបានជា បងគាវប្រាប់ខ្ញុំឲ្យរុំក្រមាជុំវិញក្បាល ហើយឲ្យឱនក្បាលចុះដើម្បីកុំឲ្យខ្ញុំមើលឃើញទិដ្ឋភាពចំហៀងឡាន ។

ប៉ានិយាយទាំងគ្រវីក្បាលថា «កងទ័ពដើរក្រឡឹងជុំវិញផ្ទះអ្នកជិតខាងរបស់យើង គោះទ្វារឲ្យមនុស្សចេញមកក្រៅ ហើយប្រាប់ឲ្យចាកចេញពីផ្ទះ ។ នរណាដែលរឹងរូសត្រូវគេបាញ់ចោលនៅនឹងកន្លែងតែម្តង» ។

បងគីម សួរថា «ហេតុអ្វីបានជាគេធ្វើដូច្នេះប៉ា?» ។

«ពីព្រោះពួកគេចូលចិត្តបំផ្លាញអ្វីៗទាំងអស់» ។

បងជូ ហើយនិង បងគីម ក្រឡេកមើលមុខគ្នាទៅវិញទៅមក ចំណែកខ្ញុំអង្គុយចុះដោយអារម្មណ៍ភ័យខ្លាច ។

ខ្ញុំសួរគេថា «ខ្ញុំមិនយល់ទេ តើរឿងទាំងនេះវាមានន័យដូចម្តេច?» ។ គេទាំងអស់គ្នាក្រឡេកមើលខ្ញុំ ប៉ុន្តែមិននិយាយអ្វីទាំងអស់ ។ កាលពីម្សិលមិញ ខ្ញុំកំពុងលេងមីកជាមួយមិត្តខ្ញុំ តែថ្ងៃនេះខ្ញុំកំពុងរត់គេចពីកាំភ្លើងរបស់កងទ័ពខ្មែរក្រហម ។

បន្ទាប់ពីញុាំបាយថ្ងៃត្រង់យ៉ាងរហ័សជាមួយត្រីងៀតរួចមក យើងនាំគ្នាឡើងលើរថយន្តហើយបន្តដំណើរទៅមុខទៀត ។ ខ្ញុំមើលហ្វូងមនុស្សហាក់ដូចជាគេកំពុងដើរតាមស្នាមដូវរបស់យើងអ៊ីចឹង ។ ដោយទប់ទល់នឹងភាពងងុយគេងដែលបណ្តាលមកពីកម្តៅថ្ងៃ គំនិតរបស់ខ្ញុំបាននឹកគិតពីរឿងមួយទៅរឿងមួយទៀត ។ ខ្ញុំសួរខ្លួនឯងថា ហេតុអ្វីបានជាខ្ញុំត្រូវចាកចេញ ហើយយើងកំពុងតែទៅទីណា ហើយនៅពេលណាទើបយើងត្រឡប់ទៅផ្ទះវិញ ។ ខ្ញុំមិនយល់ទេ តើមានរឿងអ្វីកើតឡើង ខ្ញុំរង់ចាំទាំងអន្ទះសាឲ្យដល់ថ្ងៃត្រឡប់ទៅផ្ទះវិញ ។ រំពេចនោះ ម៉ាស៊ីនឡាន

របស់យើងបានចាប់ផ្តើមញ័រយឺកៗ កាត់ផ្តាច់សុបិនពេលថ្ងៃរបស់ខ្ញុំត្រឹមនេះ ។ សំឡេងក្រឹកៗរបស់ឡានយើងឮសូរយ៉ាងយូរ ទីបញ្ចប់ក៏លែងទៅមុខ ។ ខ្ញុំក៏ចុះពីឡានដោយសង្ឃឹមថាវានឹងទៅមុខបន្តទៀត ។

ប៉ាមានប្រសាសន៍ថា «ឡានដឹកទំនិញរបស់យើងអស់សាំង ហើយគ្មានស្ថានីយ៍លក់សាំងណាមួយ នៅជុំវិញទីនេះទេ ។ មើលទៅពីនេះទៅមុខទៀតយើងត្រូវតែដើរហើយ» ។ យើងគ្រប់គ្នាស្រវាចាប់យកតែខោអាវនិងចំណីអាហារមកយួរតែប៉ុណ្ណោះ ។ យើងនៅមានផ្លូវវែងឆ្ងាយទៀតដែលត្រូវដើរ ។ ប៉ាបានប្រាប់ឲ្យយើងយកអ្វីដែលគួរយក ហើយទុកអ្វីដែលគួរទុកចោល ។ មនុស្សម្នាក់កំពុងតែស្រែកមករកយើងថា «នែពួកឯងទាំងអស់គ្នា!» ។ យើងឈប់ធ្វើអ្វីទាំងអស់ ហើយឈរធ្មឹងដូចរូបចម្លាក់ ។


អ៊ឹង សេងអ៊ីម ឪពុករបស់ លឿង អ៊ឹង

កងទ័ពខ្មែរក្រហមម្នាក់ដើរសំដៅមករកយើង ហើយគំហកថា «ឯងទាំងអស់គ្នា! ឲ្យនាឡិកាឯងមកយើង» ។ ប៉ាឆ្លើយ «បាទ» បណ្តើរ ឱនស្មាបណ្តើរ ដើម្បីសម្តែងការស្តាប់បង្គាប់ រួចដោះនាឡិកាចេញពីកដៃ បងម៉េង និង បងឃួយ ហើយហុចទៅឲ្យកងទ័ពនោះ ដោយមិនហ៊ានសម្លឹងមើលភ្នែកវាទេ ។

«អើមិនអីទេ ឥឡូវធ្វើដំណើរទៅមុខទៀតចុះ» កងទ័ពនោះបញ្ជាហើយក៏ដើរចេញទៅ ។

ពេលដែលកងទ័ពដើរចេញទៅក្នុងចម្ងាយដែលមិនអាចស្តាប់ឮ ប៉ាក៏ខ្សឹបប្រាប់យើងថា ចាប់ពីពេលឥឡូវនេះទៅ យើងត្រូវតែឲ្យសម្ភារអ្វីក៏ដោយដែលកងទ័ពខ្មែរក្រហមចង់បាន បើមិនដូច្នោះទេ ពួកគេនឹងសម្លាប់យើងមិនខាន ។

យើងដើរតាំងពីព្រឹកព្រលឹមរហូតដល់ព្រះអាទិត្យលិច ។ នៅពេលយប់ចូលមកដល់ យើងបាននាំគ្នាសម្រាកនៅតាមជាយផ្លូវក្បែរវត្តមួយ ។ យើងបើកកញ្ចប់ត្រីងៀតនិងបាយ ហើយនាំគ្នាបរិភោគយ៉ាងស្ងៀមស្ងាត់ ។ ភាពអាថ៌កំបាំងនិងក្តីរំភើបបានរសាត់ផុតពីខ្ញុំបន្តិចម្តងៗ បន្សល់ទុកនៅតែការភ័យខ្លាចប៉ុណ្ណោះ ។

## ការធ្វើដំណើរចំនួនប្រាំពីរថ្ងៃ

**ខែមេសា ឆ្នាំ១៩៧៥**

ទិដ្ឋភាពមុនដំបូងបំផុតដែលខ្ញុំមើលឃើញពេលខ្ញុំបើកភ្នែកនៅព្រឹកថ្ងៃបន្ទាប់ គឺផ្ទៃមុខដ៏ស្រពាប់ស្រពោនរបស់ បងជូ ដែលលេចទ្រង់ទ្រាយឡើងពីផ្ទៃមេឃដេរដាសដោយពពក ។ បងជូ កន្ត្រាក់សក់របស់ខ្ញុំតិចៗ ហើយនិយាយថា «ក្រោកឡើង យើងត្រូវតែទៅមុខទៀត» ។ ខ្ញុំក្រោកអង្គុយយឺតៗ ហើយយកដៃញីភ្នែកដ៏ងងុយរបស់ខ្ញុំ ។ មនុស្សម្នា ដ៏សែនច្រើននៅជុំវិញខ្លួនខ្ញុំបាន កម្រើកខ្លួនដោយសំឡេងខ្សឹបខ្សៀវ សំឡេងកូនង៉ែតយំ សំឡេងថ្ងូររបស់មនុស្សចាស់ ស្នូរទង្គិចគ្នារវាងចានឆ្នាំងនឹងជ្រុងរទេះ ក្នុងខណៈដែលកង់រទេះលាន់សូរដូចធ្មេញសង្កៀត ។ មានមនុស្សច្រើនណាស់រហូតដល់ ខ្ញុំមិនអាចរាប់ចំនួនបាន ។ ភ្នែករបស់ខ្ញុំតាមមើល បងឃួយ និង បងម៉េង ពេលដែលគាត់ទាំងពីរនាក់ដើរសំដៅទៅវត្តដោយកាន់ឆ្នាំងប្រាក់ធំមួយដើម្បីដងទឹកយកមកប្រើ ។ បងគាវ និយាយថា នៅក្បែរព្រះវិហារនីមួយៗតែងតែមានអណ្តូងទឹកមួយជានិច្ច ។ មួយសន្ទុះក្រោយមក ខ្ញុំឃើញ បងឃួយ និង បងម៉េង ត្រឡប់មកវិញទាំងភិតភ័យជាមួយឆ្នាំងទទេ ។

បងឃួយ និង បងម៉េង និយាយប្រាប់ប៉ាថា «យើងដើរចូលទៅក្នុងវត្ត ប៉ុន្តែគ្មានឃើញមានព្រះសង្ឃមួយអង្គសោះ គឺមានតែកងទ័ពខ្មែរក្រហមម្នាក់តែប៉ុណ្ណោះ ។ កងទ័ពម្នាក់នោះស្រែកប្រាប់យើងកុំឲ្យចូលទៅជិតអណ្តូងវត្ត យើងក៏ត្រឡប់មកក្រោយវិញ ប៉ុន្តែអ្នកខ្លះនៅតែដើរទៅរកអណ្តូងទៀត» ។ ពាក្យសម្តីរបស់ បងឃួយ ត្រូវបានបង្អាក់ដោយស្នូរកាំភ្លើង

ដែលលាន់ឮចេញមកពីវត្ត ។ យើងក៏ប្រញាប់ប្រញាល់រៀបចំអីវ៉ាន់របស់យើង ហើយចាកចេញពីទីកន្លែងនោះជាបន្ទាន់ ។ បន្តិចក្រោយមក យើងឮថាកងទ័ពខ្មែរក្រហមបានសម្លាប់មនុស្សពីរនាក់នៅក្នុងវត្ត និងធ្វើឲ្យរបួសមនុស្សជាច្រើននាក់ទៀត ។

ថ្ងៃនេះគឺជាថ្ងៃទីបីដែលយើងនៅតាមផ្លូវ ខ្ញុំដើរលោតៗបន្តិចទៅមុខ ។ នៅទីក្រុងភ្នំពេញ កងទ័ពបាននិយាយថា បីថ្ងៃក្រោយយើងអាចត្រឡប់ទៅផ្ទះវិញបាន ។ កងទ័ពនោះប្រាប់យើងទៀតថា យើងត្រូវតែចាកចេញ ពីព្រោះអាមេរិកាំងនឹងមកទម្លាក់គ្រាប់លើទីក្រុង ប៉ុន្តែខ្ញុំមិនឃើញមានយន្តហោះណាមួយហោះនៅលើមេឃសោះ ហើយខ្ញុំក៏គ្មានឮស្នូរគ្រាប់បែកណាមួយផ្ទុះដែរ ។ ហេតុនេះវាគឺជារឿងចម្លែកមួយសម្រាប់ខ្ញុំដែលកងទ័ពបានបង្ខំឲ្យយើងចាកចេញពីទីក្រុង ហើយថាឲ្យយើងត្រឡប់ទៅផ្ទះវិញក្នុងរយៈពេលបីថ្ងៃ ។ ខ្ញុំចង់សើចនឹងរូបភាពឥតន័យដែលផុសឡើងក្នុងគំនិតខ្ញុំ ដែលឃើញហ្វូងមនុស្សហាក់ដូចជាស្រមោចខ្មៅដែលមកឈប់នៅកន្លែងមួយសម្រាប់គ្រាន់តែបកក្បាលត្រឡប់ទៅក្រោយវិញ ។ ខ្ញុំមិនយល់ទេ ប៉ុន្តែខ្ញុំសន្និដ្ឋានថា រយៈពេលបីថ្ងៃគឺគ្រប់គ្រាន់សម្រាប់ឲ្យគេបោសសម្អាតទីក្រុងហើយ ។

ខ្ញុំទាញខោប៉ា ហើយសួរថា «ប៉ា តើយើងនឹងទៅផ្ទះពេលឆាប់ៗនេះឬ? កងទ័ពនិយាយថាយើងអាចត្រឡប់ទៅផ្ទះវិញក្នុងរយៈពេលបីថ្ងៃ តើយើងនឹងត្រឡប់ទៅផ្ទះវិញឥឡូវនេះឬ?» ។

ប៉ាឆ្លើយទាំងស្រងូតស្រងាត់ថា «អត់ទេ យើងត្រូវតែបន្តដំណើរទៅមុខទៀត» ។ ខ្ញុំធ្វើតាមអ្វីដែលប៉ាប្រាប់ទាំងរារែកចិត្ត ។ គ្រប់ៗគ្នាត្រូវយួរអ្វីមួយ ហេតុដូច្នេះហើយ ខ្ញុំក៏យកឆ្នាំងបាយតូចជាងគេដែលនៅលើគំនរអីវ៉ាន់របស់យើងមកយួរ ។ ពេលដែលខ្ញុំដើរ ឆ្នាំងបាយក្នុងដៃខ្ញុំកាន់តែធ្ងន់ទៅៗក្នុងខណៈដែលព្រះអាទិត្យរះខ្ពស់ឡើងៗនៅលើមេឃ ។ ដៃឆ្នាំងដែលធ្វើពីលោហធាតុ បានធ្វើឲ្យដៃខ្ញុំទ្រុឌហើយឈឺ ។ ជួនកាលខ្ញុំយកដៃទាំងពីរកាន់វាដាក់ពីខាងមុខខ្ញុំ ជួនកាលខ្ញុំផ្លាស់ប្តូរវាដោយម្តងយួរដៃស្តាំ ម្តងយួរដៃឆ្វេង ប៉ុន្តែទោះបីជារកវិធីយួរតាមរបៀបណាក៏ដោយ ក៏ឆ្នាំងនោះនៅតែបុកទង្គិចជើងឬភ្លៅរបស់ខ្ញុំធ្វើឲ្យឈឺដដែល ។ ពេលនេះគឺពេលរសៀល ហើយក្តីសង្ឃឹមរបស់ខ្ញុំដែលចង់ទៅផ្ទះនៅថ្ងៃនេះក៏រលាយផុតទៅ ។ ដោយសារការអស់កម្លាំងនិងឃ្លានខ្លាំង ខ្ញុំបោះជើងខ្ញុំទៅមុខដោយជំហានខ្លីៗ រហូតដល់ធ្វើឲ្យខ្ញុំឋិតនៅដាច់ឆ្ងាយពីគេឯង ។

«ប៉ា! ខ្ញុំឃ្លានណាស់ហើយឈឺជើងទៀត» ខ្ញុំស្រែកដាក់ប៉ា ។

«ឯងមិនអាចញ៉ាំនៅពេលនេះបានទេ ។ យើងមានម្ហូបនៅសល់តិចតួចណាស់ ហើយយើងត្រូវចែករំលែកវាជាមួយសមាជិកគ្រួសារទាំងអស់ ពីព្រោះយើងនៅសល់ផ្លូវវែងឆ្ងាយទៀតដែលត្រូវទៅ» ។

«ខ្ញុំមិនដឹងថា ហេតុអ្វីបានជាយើងត្រូវសន្សំសំចៃអាហារទេ!» ។ ខ្ញុំឈរផ្ទឹងនៅលើផ្លូវ ដាក់ឆ្នាំងបាយចុះ ហើយយកដៃជូតដីនិងទឹកភ្នែកចេញពីថ្ពាល់របស់ខ្ញុំ ។ «រយៈពេលបីថ្ងៃបានកន្លងផុត យើងអាចត្រឡប់ទៅផ្ទះបានវិញហើយ តោះទៅផ្ទះ! ខ្ញុំចង់ទៅផ្ទះ» ។ ទោះបីជាយ៉ាងនេះក៏ដោយ ពាក្យសម្តីដែលខ្ញុំបញ្ចេញមក មានភាពក្តុកក្តួលព្រមទាំងការយំខ្សឹកខ្សួលផង ។ ខ្លួនខ្ញុំដែលមានទម្ងន់ដប់ប្រាំបួនគីឡូក្រាម បានបដិសេធមិនព្រមដើរទៅមុខទៀតទេ ។ ដីក្រហមដែលហុយមកពីផ្លូវ លាយច្របល់នឹងញើស បង្កើតបានទៅជាស្រទាប់ដីកកជាប់នៅលើស្បែកខ្ញុំធ្វើឲ្យស្បែកខ្ញុំស្ងួតហើយឡើងរមាស់ ។ លោកប៉ាដើរសំដៅទៅរកគាវ ដើម្បីយកបាយដំណើបមួយដុំចេញពីឆ្នាំងដែល បងគាវកំពុងយួរ ។ «មកជិតប៉ាមក» ហើយគាត់ហុចបាយមួយដុំនោះឲ្យខ្ញុំ ។ ខ្ញុំសម្លឹងចុះក្រោមទាំងខ្មាសអៀន ប៉ុន្តែខ្ញុំក៏កញ្ឆក់យកបាយដំណើបពីដៃរបស់គាត់ ។ ប៉ាយកដៃមកអង្អែលក្បាលខ្ញុំដោយមិននិយាយស្តីមួយម៉ាត់ ។ នៅពេលដែលខ្ញុំញ៉ាំបាយជាមួយការខ្សឹកខ្សួលនិងការក្តុកក្តួល ប៉ាឈ្ងោកមើលភ្នែករបស់ខ្ញុំហើយនិយាយយ៉ាងស្រទន់ថា «គេកុហកយើង កងទ័ពកុហកយើង យើងមិនអាចត្រឡប់ទៅផ្ទះវិញក្នុងយប់នេះបានទេ» ។ ពាក្យរបស់គាត់ធ្វើឲ្យខ្ញុំកាន់តែយំអណ្តឹតអណ្តកខ្លាំងឡើងៗ ។

«ប៉ុន្តែ គេនិយាយថាបីថ្ងៃ» ។

«ប៉ាដឹង ប៉ាសោកស្តាយណាស់ដែលកូនជឿគេ ប៉ុន្តែពួកគេកុហកយើងទេ» ។

«ខ្ញុំមិនយល់ ហេតុអ្វីបានជាគេកុហកយើង» សំឡេងរបស់ខ្ញុំ

ញ័រពេលដែលខ្ញុំនិយាយ ។

«ប៉ាក៏មិនដឹងដែរ ប៉ុន្តែពួកគេកុហកយើង» ។ ក្តីសង្ឃឹមរបស់ខ្ញុំត្រូវរលាយសាបសូន្យអស់ ខ្ញុំយកកំភួនដៃរបស់ខ្ញុំមកជូតច្រមុះបណ្តាលឲ្យសំបោរប្រឡាក់ពេញថ្ពាល់របស់ខ្ញុំ ។ ប៉ាយកដៃគាត់មកជូតមុខរបស់ខ្ញុំថ្នមៗ បន្ទាប់មក គាត់ក៏យកឆ្នាំងបាយចេញពីដៃរបស់ខ្ញុំ ហើយនិយាយថា «សម្រាប់ដំណើរតទៅទៀត កូនមិនចាំបាច់យួរអ៊ីទេ កូនយោងតែខ្លួនទៅបានហើយ» ។

មានប្រជាជនខ្លះដើរដោយជើងទទេ នៅក្រោមកម្តៅព្រះអាទិត្យដែលក្តៅស្ទើរខ្លោច ដោយមានស្ពាយបុទ្ទូលរបស់របរប្រចាំជីវិតរបស់គេនៅលើខ្នងឬនៅលើក្បាលជាមួយផង ។ ខ្ញុំមានអារម្មណ៍អាណិតអាសូរដល់គេណាស់ ពេលមើលឃើញស្ថានភាពរបស់គេលំបាកលំបិនជាងខ្ញុំទៅទៀតនោះ ។ នៅពេលយប់ខិតចូលមកដល់ជាថ្មីម្តងទៀត យើងបានយកផ្លូវធ្វើជាផ្ទះ ហើយគេងលង់លក់ជាមួយមនុស្សរាប់ពាន់គ្រួសារផ្សេងទៀតដែលត្រូវជម្លៀសពីទីក្រុងភ្នំពេញដែរ ។

ថ្ងៃទីបួនរបស់យើងបានចាប់ផ្តើមឡើងដូចជាបីថ្ងៃមុនដែរ ។

ខ្ញុំសួរទៅ បងគីម ថា «តើយើងទៅដល់ទីនោះឥឡូវឬ» ។ នៅពេលដែលខ្ញុំមិនបានទទួលការយកចិត្តទុកដាក់ ខ្ញុំក៏បញ្ចេញខ្យល់តាមច្រមុះ ហើយស្រែកយំ ។

ខ្ញុំថ្ងូរថា «គ្មាននរណាម្នាក់យកចិត្តទុកដាក់នឹងខ្ញុំសោះ!» ប៉ុន្តែខ្ញុំនៅតែបន្តដើរទៅមុខ ។

នៅពេលថ្ងៃត្រង់ យើងបានមកដល់ចំណុចឆែកឆេរមួយរបស់កងទ័ពខ្មែរក្រហម នៅត្រង់ទីប្រជុំជនកំបូល ។ នៅចំណុចឆែកឆេរនេះ មានតង់បណ្តោះអាសន្នតូចៗមិនលើសពីពីរឬបីឡើយ ជាមួយឡានដឹកទំនិញជាច្រើនដែលចតនៅក្បែរនោះ ។ មានកងទ័ពជាច្រើននៅក្នុងមូលដ្ឋាននេះ ។ វាងាយស្រួលមើលស្គាល់ពួកគេណាស់ ពីព្រោះអ្នកទាំងនោះសុទ្ធតែស្លៀកពាក់ខោអាវខ្មៅដូចៗគ្នា ។ កងទ័ពទាំងអស់សុទ្ធតែស្ពាយកាំភ្លើងម្នាក់មួយដើម ហើយដើរយ៉ាងលឿនពីកន្លែងមួយទៅកន្លែងមួយដោយស្រែកបញ្ជាខ្លាំងៗទៅប្រជាជន ។

«ទីនេះជាមូលដ្ឋានកំបូល! បងប្អូនទាំងអស់គ្នាមិនត្រូវបានអនុញ្ញាតឲ្យឆ្លងកាត់ខ្សែបន្ទាត់នេះទេ លុះត្រាតែយើងឆែកឆេររួចសិន! ត្រូវឈរជាជួរជាមួយគ្រួសាររបស់បងប្អូន! សមមិត្តកងទ័ពរបស់យើងនឹងមកសួរពីរបីសំណួរងាយៗឥឡូវនេះហើយ! បងប្អូនទាំងអស់គ្នាត្រូវតែឆ្លើយតាមការពិត កុំកុហកអង្គការឲ្យសោះ! ប្រសិនបើបងប្អូនកុហកអង្គការ យើងនឹងដឹងជាមិនខាន! អង្គការដឹងអ្វីៗទាំងអស់ អង្គការមានភ្នែកមានត្រចៀកនៅគ្រប់កន្លែង» ។

នេះគឺជាលើកទីមួយហើយដែលខ្ញុំឮពាក្យ «អង្គការ» ដែលពាក្យនេះមានន័យថា «របនាសម្ព័ន្ធ» ។ ប៉ាមានប្រសាសន៍ថា អង្គការគឺរដ្ឋាភិបាលថ្មីរបស់ប្រទេសកម្ពុជា ។ គាត់ប្រាប់យើងទាំងអស់គ្នាថា កាលពីដើម សម្តេចព្រះ នរោត្តម សីហនុ ជាអ្នកដឹកនាំប្រទេសកម្ពុជាដែលជារបបប្រជាធិបតេយ្យមួយ ។ បន្ទាប់មកនៅឆ្នាំ១៩៧០ ដោយមិនសប្បាយចិត្តនឹងរដ្ឋាភិបាលរបស់សម្តេច ឧត្តមសេនីយ៍ លន់ ណុល បានធ្វើរដ្ឋប្រហារទម្លាក់ព្រះអង្គចេញពីអំណាច ។

តាំងពីពេលនោះមករដ្ឋាភិបាល លន់ ណុល បានដឹកនាំធ្វើសង្គ្រាមស៊ីវិលមួយតទល់នឹងពួកខ្មែរក្រហមនិងពួកកុម្មុយនិស្ត ។ ឥឡូវនេះ ខ្មែរក្រហមឈ្នះសង្គ្រាម ហើយរដ្ឋាភិបាលរបស់ខ្មែរក្រហមហៅខ្លួនគេថា «អង្គការ» ។

**(នៅមានត)**

## ពន្យល់ពាក្យខ្មែរក្រហម

◆ ***ភារកិច្ចធំៈ*** គឺប្រមូលកម្លាំងទាំងអស់ពីក្រោមដល់លើការពារបូរណភាពនិងអធិបតេយ្យ ព្រមជាមួយនោះ ការពារលទ្ធផលនៃធនធានរបស់បដិវត្ត ។ *(កំណត់ហេតុលេខ ២០៩)*

◆ ***ជនកុម្មុយនិស្តៈ*** គឺជាអ្នកអង់អាចក្លាហាន ពុះពារនូវរាល់ឧបសគ្គគ្រប់បែបយ៉ាងមោះមុត ហ៊ានធ្វើពលិកម្មគ្រប់បែបយ៉ាង មានការលះបង់ស្ទួនតួ បុគ្គលអាត្មាខ្លួន រហូតដល់ជីវិតខ្លួនទៀតក៏ឥតរួញរា ។ រូបភាពគឺជាមនុស្សដូចគ្នា តែខ្លឹមសារវិញខ្ពស់ឧត្តុង្គឧត្តមណាស់ ។ *(កំណត់ហេតុលេខ ១៨១)*

# នារីពេទ្យបដិវត្តស្រុកត្រាំកក់

**(តចប់)**

សីលធម៌១២ប្រការត្រូវបានចែងឡើងក្នុងគោលបំណងឲ្យកម្មាភិបាលគ្រប់រូបកសាងខ្លួនឲ្យទៅមនុស្សល្អឥតខ្ចោះក្នុងសង្គមស្អាតស្អំ ។ ក្នុងនោះ ប្រការទី៦បានចែងអំពីស្នេហារវាងបុរស-នារីថា “កុំប្រព្រឹត្តអ្វីដែលល្មើសនឹងស្ត្រីភេទឲ្យសោះ” ។ ស្នេហាលួចលាក់ត្រូវអង្គការចាត់ទុកជាទោសឧក្រិដ្ឋនឹងត្រូវផ្តន្ទាទោសព្រោះការ“ប៉ះពាល់សីលធម៌បុរស-នារីជាធាតុពុករលួយរបស់ខ្មាំងសត្រូវ ហើយនាំឲ្យមានគ្រោះថ្នាក់ដល់ចលនាបដិវត្តន៍” ។

រៀល សន អតីតប្រធានពេទ្យនារី ស្រុកត្រាំកក់ បានឲ្យដឹងថា នារីពេទ្យមួយចំនួននៅស្រុកត្រាំកក់ មិនបានអនុវត្តតាមក្រមសីលធម៌ទាំង១២ប្រការទេ ។ រៀល សន និយាយថា នារីពេទ្យទាំងនោះពុំគោរពក្រមសីលធម៌ ហើយថែមទាំងប៉ះពាល់សីលធម៌ជាមួយបុរស និយាយស្តីមិនបានសមរម្យជាមួយអ្នកជំងឺ ធ្វើការខ្ជីខ្ជា មិនគោរពអង្គការវិន័យ ។ រៀល សន បានលើក



នារីពេទ្យខ្មែរក្រហមកំពុងផលិតថ្នាំគ្រាប់

ឧទាហរណ៍ នារី ហាន បានប៉ះពាល់សីលធម៌ត្រូវអង្គការបញ្ជូនទៅធ្វើទារុណកម្មនៅគុកក្រាំងតាចាន់។ នារី យឿន ត្រូវអង្គការដកពីចេញពីពេទ្យឲ្យទៅធ្វើការនៅកងចល័ត ព្រោះបានខុសសីលធម៌ជាមួយអ្នកជំងឺកងទ័ព។ នារី វី ត្រូវអង្គការដកចេញពីប្រធានពេទ្យឃុំព្រៃល្វា ព្រោះតែរឿងខុសសីលធម៌នេះដែរ។

នារីពេទ្យដែលភាគច្រើនជាអ្នកមូលដ្ឋាន បានប្រើសម្តីគំរោះគំរើយដាក់អ្នកជំងឺជាប្រជាជនថ្មី។ បងស្រី នាង បាននិយាយថា នៅជំនាន់នោះ កម្ររកពេទ្យជាអ្នកមូលដ្ឋានដែលមានចិត្តល្អណាស់។ ស៊ុន ក៏និយាយដែរថា ក្នុងមនុស្សចំណោមជាង ២០នាក់ មានអ្នកចិត្តល្អតែពីរឬបីនាក់ប៉ុណ្ណោះ។ ផន បាននិយាយថា នៅក្នុងមន្ទីរពេទ្យ គ្រូពេទ្យទាំងនោះមានការរើសអើងចំពោះអ្នកជំងឺជាប្រជាជន ១៧ មេសា ណាស់។ អ្នកជំងឺគ្មានសិទ្ធិតវ៉ាជាមួយពេទ្យទេ។ ផន បន្ថែមថា «ពេទ្យបដិវត្តក៏នៅតែនិយមបក្ខពួកដែរ សង្គមណាក៏ដោយនៅតែនិយមគ្នាអាងគ្នាអញគ្នាឯង។ ពេទ្យទាំងនោះគ្មានចំណេះវិជ្ជាអ្វីសោះ»។



ក្រៅពីការងារប្រចាំថ្ងៃ នារីពេទ្យត្រូវចូលរួមប្រជុំជីវភាពប្រចាំថ្ងៃ ឬប្រជុំទិតៀននិងស្វ័យទិតៀន។ គោលបំណងនៃការប្រជុំទិតៀននិងស្វ័យទិតៀនគឺ «កម្ចាត់និងកសាងកម្លាំង កម្ទេចចោលរបបចក្រពត្តិ នាយទុនសក្តិភូមិ ដើម្បីកសាងសង្គមនិយម កម្ទេចធាតុវណ្ណៈ និងតស៊ូកសាងសាមគ្គីភាពផ្ទៃក្នុងបដិវត្តន៍»។ នៅក្នុងកំណត់ហេតុអង្គប្រជុំគណៈអចិន្ត្រៃយ៍លើកទី២ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ១៩៧៦ ប៉ុល ពត បានកំណត់ឲ្យមន្ទីរក្រសួងទាំងអស់ប្រជុំមួយខែម្តងដើម្បីពិនិត្យសភាពការណ៍រួម ជំរុញកិច្ចដំណើរការក្រសួងនីមួយៗឲ្យខ្លាំងក្លាតាមសន្ទុះ មហាលោតផ្លោះមហាអស្ចារ្យ។ ប៉ុន្តែនៅថ្នាក់ក្រោមត្រូវដំណើរការប្រជុំជារៀងរាល់ថ្ងៃ ឬយ៉ាងហោចណាស់បីដងក្នុងមួយសប្តាហ៍។

ការតុបតែងខ្លួន ពាក់គ្រឿងអលង្ការ ឬស្លៀកពាក់ឆើតឆាយមានក្លិនក្រអូប និងទុកសក់វែង ត្រូវលុបបំបាត់ចោលទាំងស្រុង ព្រោះ «ធាតុក្រអូបជាសតិអារម្មណ៍របស់ពួកសក្តិភូមិ»។ នារី វុធ ត្រូវទទួលការកសាងនិងទិតៀនយ៉ាងខ្លាំងពីសំណាក់ប្រធានពេទ្យថា នៅជាប់កម្អែលសក្តិភូមិ ព្រោះតែគាត់ពាក់អាវដៃខ្លី ហើយទីបំផុត គាត់ក៏ត្រូវអង្គការបញ្ជូនទៅលត់ដំនៅគុកភ្នំសន្ទុង។

អង្គការមិនអនុញ្ញាតឲ្យនារីពេទ្យមានស្នេហានិងជ្រើសរើសគូស្រករទៅតាមមនោសញ្ចេតនាផ្ទាល់ខ្លួនឡើយ។ ការរៀបចំគូស្រករត្រូវតែអាស្រ័យទៅតាមការទុកដាក់របស់អង្គការ។ មុននឹងរៀបចំឲ្យនរណាម្នាក់មានគូស្រករ អង្គការបានត្រួតពិនិត្យប្រវត្តិរូបសីលធម៌ នយោបាយ និងជំហរសតិអារម្មណ៍។ នៅមុនថ្ងៃ១៧ មេសា ១៩៧៥ នារីដែលអាចរៀបការបានលុះត្រាមានអាយុចាប់ពី២៥ឆ្នាំឡើងទៅ ឯបុរសត្រូវមានអាយុ៣៥ឆ្នាំ។ ក្រោយថ្ងៃ១៧ មេសា ១៩៧៥ បុរសអាចរៀបការនៅអាយុ ២៥ឆ្នាំ នារីអាយុ២០ឆ្នាំ។ ការរៀបចំគ្រួសាររបស់អង្គការបដិវត្តន៍មិនមែនសំដៅ «ផលប្រយោជន៍សួនតួសុខសាន្តបានកូនចៅតពូជពង្សទេ។ សំខាន់គឺដើម្បីធ្វើឲ្យបដិវត្តន៍ សម្រេចភារកិច្ចដ៏ឧត្តុង្គឧត្តមរំដោះប្រទេសជាតិ ប្រជាជន និងវណ្ណៈក្រីក្រ ឈានទៅសង្គមនិយមកុម្មុយនិស្តនិយម»។

សាច់ញាតិក្រុមគ្រួសារ គ្មានសិទ្ធិដឹងឮឬពាក់ព័ន្ធចូលរួមក្នុងពិធីរៀបចំគ្រួសារកូនចៅណាម្នាក់ឡើយ។ អ្វីៗអាស្រ័យលើអង្គការអ្នកចាត់ចែងទាំងអស់។

នារីពេទ្យស្រុកត្រាំកក់ក៏ដូចគ្នាដែរ។ នារីពេទ្យគ្មានសិទ្ធិសម្រេចជ្រើសរើសគូជីវិតនិងស្វែងរកសុភមង្គលដោយខ្លួនឯងបានទេ។ អ្វីៗអាចប្រព្រឹត្តទៅបានទាល់តែមានការសម្រេចពីអង្គការ។ នៅពេលដែលអង្គការចង់ឲ្យនារីណាម្នាក់រៀបការ អង្គការបានជ្រើសរើសបុរសដែលមានវណ្ណៈភាពដូចគ្នា។ វណ្ណៈ

កសិករកណ្តាល ត្រូវរកវណ្ណៈកសិករកណ្តាលដូចគ្នា វណ្ណៈកសិករក្រីក្រត្រូវរកវណ្ណៈកសិករក្រីក្រដូចគ្នា ។ អ្នកចេះត្រូវយកអ្នកចេះដូចគ្នា បើមានបងប្អូនពាក់ព័ន្ធជាមួយខ្មាំង ត្រូវរើសរកអ្នកណាមានបងប្អូនពាក់ព័ន្ធជាមួយខ្មាំងដូចគ្នា ។ ប្រជាជន១៧មេសា អង្គការក៏អនុវត្តដូចគ្នានឹងកម្មាភិបាលនិងប្រជាជនមូលដ្ឋានដែរ ។

នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ នារីពេទ្យតែងតែជាទីប្រាថ្នារបស់បុរសកងទ័ព ។ នារីពេទ្យភាគច្រើនបានរៀបការជាមួយកងទ័ព ឬកម្មាភិបាលធំៗ ឬបុគ្គលិកពេទ្យដូចគ្នា ។ នារីពុំដែលបានដឹងខ្លួនជាមុន និងមិនដឹងថាតើបុរសមួយណាជាគូជីវិតរបស់ខ្លួនឡើយ ។ អ្វីៗស្ថិតក្នុងលាក់ការណ៍របស់អង្គការ ។ នារីមានសិទ្ធិត្រឹមតែអនុវត្តតាមបញ្ជា មិនអាចប្រកែកបានឡើយ ។ នៅក្នុងបទសន្ទនាជាមួយគណៈប្រតិភូប៉ែលហ្សិក ប៉ុល ពត បាននិយាយថា “យុវជនយុវនារីកសាងគ្រួសារដោយសាមីខ្លួនស្ម័គ្រចិត្ត ដល់រៀបគ្រួសារហើយមានបញ្ហាស្មុគស្មាញក្នុងគ្រួសារមហាជនជួយមតិដើម្បីដោះស្រាយសម្រុះសម្រួល តែបើសាមីខ្លួនមិនអាចរស់នៅជាមួយគ្នាបាន ការលែងលះស្រេចតែគេទាំងសងខាង គ្មានកាត់សេចក្តី” ។

ពិធីរៀបការរបស់អង្គការគឺគ្រាន់តែប្រកាសឈ្មោះបុរសនិងស្ត្រីដែលត្រូវរៀបការជាមួយគ្នាឲ្យមកចាប់ដៃគ្នា ហើយចាប់ផ្តើមសូត្រប្រវត្តិរូបបុរសនិងនារីម្នាក់ម្តងឲ្យអង្គប្រជុំស្តាប់និងឲ្យសាមីខ្លួនធ្វើការប្តេជ្ញាចិត្ត “ខ្ញុំសូមប្តេជ្ញាថាយកបុរសឈ្មោះនេះ ឬយកនារីឈ្មោះនេះ ធ្វើប្តីឬប្រពន្ធអស់មួយជីវិត” ជាការស្រេច ។ គូស្វាមីភរិយាដែលអង្គការរៀបការឲ្យបានក្លាយជាប្តីប្រពន្ធនិងទៅរស់នៅលើផ្ទះដែលអង្គការរៀបចំឲ្យ ។ ពិធីរៀបការម្តងៗមានយ៉ាងតិចពី៥ ទៅ១០គូ ឬលើសពីនេះ ។ នៅពេលយប់ឈ្លបចាំតាមដានគូស្រករដែលទើបរៀបការថ្មីថ្មោង ។ បើមានគូណាមួយមិនចុះសម្រុងគ្នា អង្គការហៅទៅកសាងសតិអារម្មណ៍ភ្លាម ហើយបើនរណាម្នាក់មិនកែប្រែ អ្នកនោះនឹងត្រូវទទួលទារុណកម្មឬបាត់ខ្លួន ។

សុក គីម បាននិយាយថា អង្គការមិនប្រាប់សាមីខ្លួនឲ្យដឹងជាមុនថាអ្នកណាជាគូរបស់ខ្លួនឡើយ ។ គ្មានអ្នកណាម្នាក់ហ៊ានជំទាស់នឹងបញ្ជារបស់អង្គការទេ ទោះបីពេញចិត្តឬមិនពេញចិត្តក៏ដោយ ។


សុក គីម


អ៊ីង វ៉ុធ

នៅឆ្នាំ១៩៧៧ អ៊ីង វ៉ុធ ត្រូវអង្គការបង្ខំឲ្យរៀបការជាមួយបុរសម្នាក់ដែលមិនធ្លាប់ស្គាល់គ្នាពីមុនមក ។ អង្គការបានយករថយន្តដឹក អ៊ីង វ៉ុធ ទៅកាន់មន្ទីរស្រុកត្រាំកក់ ដោយមិនប្រាប់មួយម៉ាត់ថាទៅណាឡើយ ។ នៅពេលមកដល់មន្ទីរស្រុក វ៉ុធ មានការភ្ញាក់ផ្អើលយ៉ាងខ្លាំង ហើយបានប្រកែកតវ៉ា ប៉ុន្តែអង្គការមិនធ្វើតាមសំណើរបស់គាត់ទេ ។ ក្រោយពេលរៀបការហើយ វ៉ុធ និងប្តីពុំចុះសម្រុងនឹងគ្នា ម្នាក់ៗចេះតែគេចមុខពីគ្នាទៅតាមការដ្ឋានរៀងៗខ្លួន ។ ឃើញដូច្នេះ អង្គការហៅទៅអប់រំសតិអារម្មណ៍អស់រយៈពេលយ៉ាងយូរ ទើប វ៉ុធ យល់ព្រម ព្រោះខ្លាចអង្គការយកទៅសម្លាប់ចោល ។

គោលការណ៍គ្រប់យ៉ាងដែលអង្គការយកមកអនុវត្តនៅក្នុងក្រសួងសុខាភិបាល ទទួលផលបានតិចតួច ព្រោះអ្នកជំងឺជាច្រើនត្រូវស្លាប់ដោយខ្វះបច្ចេកទេសនិងថ្នាំគ្មានប្រសិទ្ធភាព ។

ការងារដ៏មមាញឹក និងវិន័យដ៏តឹងតែងរបស់អង្គការ ធ្វើឲ្យនារីពេទ្យស្រុកត្រាំកក់មានការខ្លាចញញើតជាខ្លាំង ។ ការភ័យរន្ធត់និងព្រួយបារម្ភរបស់នារីពេទ្យ ធ្វើឲ្យប្រសិទ្ធភាពការងាររបស់ពេទ្យនៅទ្រឹងមិនរីកចម្រើនទៅមុខ ។ នារីធ្វើអ្វីៗតាមតែអង្គការបញ្ជាដឹងតែគោរពបំពេញតួនាទីដែលអង្គការប្រគល់ឲ្យ ។ ម្ហូបអាហារ សម្លៀកបំពាក់ កន្លែងស្នាក់នៅ ជីវិតគូស្រករនិងរឿងរ៉ាវផ្ទាល់ខ្លួនសុទ្ធតែជាកម្មសិទ្ធិរបស់អង្គការ ។ មិនត្រឹមតែប៉ុណ្ណោះ សូម្បីតែខ្យល់ដង្ហើមក៏ជាកម្មសិទ្ធិរបស់អង្គការដែរ ។ ឲ្យស្លាប់ ឬឲ្យរស់ស្រេចតែអង្គការជាអ្នកកំណត់ គ្មាននរណាម្នាក់មានសិទ្ធិតវ៉ាឡើយ ។

**វ៉អែម សុខឃឹម**

# គំរូអន្តរជាតិសម្រាប់ដាក់ឱ្យបុគ្គលរំលោភសិទ្ធិមនុស្ស ទទួលខុសត្រូវចំពោះមុខច្បាប់

**(តចប់)**



### ច) ប្រទេស អេលសាល់វ៉ាឌ័រ

អង្គការសហប្រជាជាតិបានបង្កើត ផ្តល់ជាបុគ្គលិក និង ចំណាយថវិកាដល់គណៈកម្មការស្វែងរកការពិត ដែលជាផ្នែកមួយនៃកិច្ចព្រមព្រៀងសន្តិភាពរវាងរដ្ឋាភិបាលនិងរណសិរ្សរំដោះជាតិ ហ្វារ៉ាប៊ុនដូ ម៉ាទី នៅឆ្នាំ១៩៩១ ក្រោយពីមានសង្គ្រាមស៊ីវិលដ៏ជូរចត់រួចមក ។ គណៈកម្មការនេះមានពេលវេលា៨ខែ ក្នុងការស៊ើបអង្កេតនិងរៀបចំរបាយការណ៍បញ្ជាក់ឲ្យបានច្បាស់ អំពីទំហំនៃការរំលោភសិទ្ធិមនុស្សដែលបានកើតឡើងនៅក្នុងអំឡុងសង្គ្រាមស៊ីវិលអស់រយៈកាល២០ឆ្នាំ ។ គ្មានជនជាតិ អេលសាល់វ៉ាឌ័រ ណាម្នាក់ត្រូវបានតែងតាំងឲ្យធ្វើការនៅក្នុងគណៈកម្មការនេះទេ ។ គណៈកម្មការបានដៅឈ្មោះអ្នកប្រព្រឹត្តបទល្មើសចំនួន៤០នាក់ ដែលសុទ្ធតែត្រូវបានលើកលែងទោសរួចហើយ ទោះបីជាកិច្ចព្រមព្រៀងសន្តិភាពនៅអេលសាល់វ៉ាឌ័រ អំពាវនាវយ៉ាងទទូចឲ្យ “បញ្ចប់ការរួចទោស” យ៉ាងណាក៏ដោយ ។

គណៈកម្មការគ្មានអំណាចចោទប្រកាន់ឡើយ ។ គណៈកម្មការបានត្រឹមតែស៊ើបអង្កេតនិងឲ្យជាយោបល់តែប៉ុណ្ណោះ ប៉ុន្តែអាចបញ្ជូនសំណុំរឿងទៅអគ្គរដ្ឋអាជ្ញាបាន ។ អាណត្តិរបស់គណៈកម្មការគឺត្រឹមតែស៊ើបអង្កេតទៅលើ“អំពើឃោរឃៅធ្ងន់ធ្ងរ” ហើយនៅទីបញ្ចប់ គណៈកម្មការបានត្រឹមតែពិនិត្យទៅលើ ៣៣ករណី ប៉ុណ្ណោះ ក្នុងចំណោមករណីចំនួនជាង ២២០០០ ដែលខ្លួនបានយកចិត្តទុកដាក់ធ្វើ ។ លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ ប៊ូត្រូស ប៊ូត្រូស ហ្គាលី បានតែងតាំងស្នងការមួយចំនួនដើម្បីធានានូវភាពគួរឲ្យទុកចិត្តបានរបស់គណៈកម្មការស្វែងរកការពិត ។ ដោយសារមានការព្រមព្រៀងគ្នារវាងភាគីនានានៅក្នុងកិច្ចព្រមព្រៀងសន្តិភាព រដ្ឋាភិបាលតម្រូវឲ្យមានកាតព្វកិច្ចទៅលើអនុសាសន៍របស់គណៈកម្មាធិការនេះ ។ គណៈកម្មការបានផ្សព្វផ្សាយឈ្មោះបុគ្គលទាំងឡាយដែលរកឃើញថាបានប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរ ហើយបានផ្តល់អនុសាសន៍សុំឲ្យបណ្តេញមន្ត្រីយោធា ឬមន្ត្រីសាធារណៈផ្សេងៗទៀតចេញពីតំណែង ព្រមទាំងទប់ស្កាត់មិនឲ្យជនដែលមានការពាក់ព័ន្ធវិលកាន់មុខតំណែងវិញឡើយ ។ ចាប់តាំងពីគណៈកម្មការចាប់បដិសន្ធិមក អំពើឃោរឃៅបានថយចុះយ៉ាងច្រើន ហើយមើលទៅមិនឃើញថាគណៈកម្មការនេះធ្វើឲ្យល្អក់កករដល់សន្តិភាពដែលងាយនឹងប្រេះស្រាំទេ ។



### ឆ) ប្រទេស អេត្យូពី

នៅឆ្នាំ១៩៩១ មានរដ្ឋាភិបាលបណ្តោះអាសន្នថ្មីមួយក្រោមការដឹកនាំរបស់លោកប្រធានាធិបតី មេឡេស ហ្សេណាវី នៅប្រទេសអេត្យូពី ក្រោយពីការដួលរលំនៃរបបផ្តាច់ការ ឌែហ្គដែលដឹកនាំដោយលោក ម៉េងហ្គីតស៊ូ ហៃឡេ ម៉ារៀម ដែលកាន់អំណាចជាង២៧ឆ្នាំ ។ នៅក្នុងរបបគ្រប់គ្រងដោយ ម៉េងហ្គីតស៊ូ មានការរំលោភសិទ្ធមនុស្សយ៉ាងធ្ងន់ធ្ងរ រួមទាំងការឃុំខ្លួន និងការធ្វើទារុណកម្មស្រេចតែទំនើងចិត្ត ការបាត់ខ្លួន និងការសម្លាប់ដោយគ្មានការជំនុំជម្រះក្តីត្រឹមត្រូវ ។ ក្រៅពីនោះ យោធាបានរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់មនុស្សធម៌អន្តរជាតិ ទាក់ទងនឹងជម្លោះនៅក្នុងស្រុក ។ ចំណែកឯនយោបាយជម្លៀសប្រជាជនអនុវត្តដោយរបបផ្តាច់ការយោធា បណ្តាលឲ្យប្រជាជនស្លាប់យ៉ាងច្រើនដោយសារគ្រោះទុរ្ភិក្ស ។

ក្រោយពីឡើងមកកាន់អំណាចភ្លាម រដ្ឋាភិបាលបណ្តោះអាសន្នបានប្រកាសនូវគោលបំណងរបស់ខ្លួនក្នុងការនាំយកមន្ត្រីនៃរបបចាស់មកកាត់ទោសពីបទរំលោភសិទ្ធិមនុស្សក្នុងអំឡុងឆ្នាំ១៩៧៤-១៩៩១ ។ រដ្ឋាភិបាលសព្វថ្ងៃចាប់បានអតីតមន្ត្រី

និងយោធានៃរបបមុនប្រមាណ១៧៥០នាក់ ហើយចង់កាត់ទោសបុគ្គលទាំងអស់នេះពីបទចោទប្រកាន់មួយចំនួន ក្នុងនោះរួមមានអំពើប្រល័យពូជសាសន៍និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។ ចំនួនចុងចោទដែលត្រូវបានឃុំខ្លួនសម្រាប់ការកាត់ទោសអាចឡើងកាន់តែច្រើនទៅៗ ទោះបីជាអង្គការឃ្លាំមើលសិទ្ធិមនុស្សឲ្យយោបល់ថា ចុងចោទសំខាន់ៗមានចំនួនច្រើន ហើយធនធានសម្រាប់ដំណើរការប្រព័ន្ធច្បាប់មានកម្រិត អាចបង្ខំឲ្យរដ្ឋាភិបាលពិចារណាទៅលើការចរចាប្តូរចម្លើយជាមួយការសម្រាលឬលើកលែងទោសចំពោះចុងចោទមួយចំនួនក៏ដោយ ។

រដ្ឋាភិបាលមានចេតនាចង់កាត់ទោសជនជាប់ឃុំជាបីដំណាក់កាលៈ ១) អ្នកចេញជាគោលនយោបាយនិងសេចក្តីសម្រេចនានា មន្ត្រីជាន់ខ្ពស់រដ្ឋាភិបាល និងមេបញ្ជាការជាន់ខ្ពស់យោធា ២) មេបញ្ជាការយោធាឬស៊ីវិលដែលចុះផ្ទាល់នៅតាមមូលដ្ឋាន និង៣) ជនដៃដល់ (ចារី) ដែលបានប្រព្រឹត្តអំពើឃោរឃៅ ។

នៅក្នុងចំណោមចុងចោទប្រភេទទី១ ក៏រួមបញ្ចូលអតីតប្រធានាធិបតី ម៉េងហ្គិតស៊ូ ម្នាក់ដែរ ដែលកំពុងតែត្រូវបានកាត់ទោសកំបាំងមុខជាមួយនឹងចុងចោទជាច្រើននាក់ទៀត ។ រដ្ឋាភិបាលបានឃុំខ្លួនចុងចោទតាំងពីឆ្នាំ១៩៩១មកម្ល៉េះ ប៉ុន្តែដោយសារកង្វះខាតផ្នែកប្រព័ន្ធតុលាការនិងធនធាន ធ្វើឲ្យការជំនុំជម្រះក្រុមចុងចោទទី១ត្រូវពន្យារពេលរហូតដល់ខែធ្នូ ឆ្នាំ១៩៩៤ ហើយអង្គជំនុំជម្រះនេះទំនងជាបន្តរហូតជាច្រើនឆ្នាំក្រោយមកទៀត ។ ការចោទប្រកាន់ប្រឆាំងនឹងក្រុមទី១រួមមានឧក្រិដ្ឋកម្មអន្តរជាតិក្រោមលិខិតូបករណ៍អន្តរជាតិនិងដែលបញ្ចូលនៅក្នុងច្បាប់អេត្យូពី និងឧក្រិដ្ឋកម្មធម្មតាក្រោមច្បាប់អេត្យូពី ។ ជនដែលត្រូវបានចោទប្រកាន់នឹងត្រូវដាក់គុក និងទទួលទោសប្រហារជីវិតក្នុងករណីភាគច្រើន ។ រដ្ឋាភិបាលបានបង្ហាញពីចេតនាប្រើងប្រែងដាក់ទោសប្រហារជីវិត ជាពិសេសចំពោះជនដែលត្រូវបានកាត់ឲ្យជាប់ទោសពីបទល្មើសធ្ងន់ធ្ងរបំផុត ។

រដ្ឋាភិបាលបានបង្កើតអយ្យការពិសេសដើម្បីអនុវត្តការចោទប្រកាន់ទៅលើអតីតសមាជិកនៃរបបមុន ។ ក្រៅពីនេះ អយ្យការក៏នឹងដើរតួជាអង្គការមួយដែលមានលក្ខណៈប្រហាក់ប្រហែលនឹងគណៈកម្មការស្វែងរកការពិត ដែលមានអាណត្តិត្រឹមតែផលិតជាឯកសារប្រវត្តិសាស្ត្រទាក់ទងទៅនឹងការរំលោភសិទ្ធិមនុស្សនៃរបបមុន ។ អយ្យការបែកជាបួនក្រុមទៅតាមប្រភេទនៃបទឧក្រិដ្ឋសំខាន់ៗដែលកំពុងតែចោទប្រកាន់ ហើយនៅត្រឹមខែឧសភា ឆ្នាំ១៩៩៤ អយ្យការមានបុគ្គលិកបម្រើការងារចំនួន៤០០នាក់ រួមទាំងរដ្ឋអាជ្ញាជនជាតិអេត្យូពីចំនួន៤៥នាក់ និងទីប្រឹក្សាបរទេស៨នាក់ ។ ប៉ុន្តែដោយសារកង្វះខាតបទពិសោធន៍និងធនធានបានធ្វើឲ្យរាំងស្ទះនិងពន្យារពេលការងាររបស់អយ្យការ ។ ស្ថាប័នអយ្យការបានធ្វើឲ្យមានការរីកចម្រើនក្នុងការហ្វឹកហ្វឺនបុគ្គលិក ហើយបានទទួលផលប្រយោជន៍ពីឯកសារនិងសាក្សីសំខាន់ៗ ព្រមទាំងភ័ស្តុតាងផ្សេងៗទៀតទាក់ទងនឹងសកម្មភាពរបស់របបមុន ។

នៅឆ្នាំ១៩៩៣ រដ្ឋាភិបាលបានបង្កើតនូវប្រព័ន្ធតុលាការឯករាជ្យមួយដែលបែងចែកជាប្រព័ន្ធជាតិនិងតំបន់ ។ ដូចជាអយ្យការដែរ កង្វះខាតធនធានបានធ្វើឲ្យប្រព័ន្ធតុលាការថ្មីជួបឧបសគ្គ ហើយដំណើរការមានលក្ខណៈឆាប់ពេក មិនអាចវាយតម្លៃទៅលើប្រសិទ្ធភាពរបស់ប្រព័ន្ធតុលាការ ភាពត្រឹមត្រូវនិងឯករាជ្យបានទេ ។ ចៅក្រមដើងចាស់ជាច្រើនរូបបានរត់ចោលស្រុកនៅអំឡុងរបប ម៉េងហ្គិតស៊ូ ចំណែកឯចៅក្រមដែលមិនរត់ទៅណា បែរជាគ្មានសមត្ថភាពគ្រប់គ្រាន់ដោយសារតែអ្នកទាំងនោះជាខ្សែរបស់អតីតរបបនេះ ថ្វីបើចៅក្រមទាំងនេះធ្វើជាមេធាវីការពារចុងចោទក៏ដោយចុះ ។

ការកាត់ទោសមន្ត្រីដឹកនាំរបស់អតីតប្រធានាធិបតី ម៉េងហ្គិតស៊ូ ធ្វើឲ្យមានចំណាប់អារម្មណ៍យ៉ាងខ្លាំង និងការចូលរួមយ៉ាងសកម្មពីសំណាក់សហគមន៍អន្តរជាតិ ។ ស្ថាប័នអយ្យការបានទទួលនូវជំនួយបច្ចេកទេសនិងបុគ្គលិកពីរដ្ឋាភិបាលនិងអង្គការមិនមែនរដ្ឋាភិបាលជាច្រើន ព្រមទាំងជំនួយពីបរទេសទៅលើការផ្តល់មេធាវីការពារក្តីសម្រាប់ចុងចោទ ។ ទីប្រឹក្សាបរទេសបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងការជួយប្រមែប្រមូលនិងដាក់ចូលទៅក្នុងប្រព័ន្ធកុំព្យូទ័រនូវលិបិក្រម (លំដាប់ឬរបៀបអក្សរ) នៃភ័ស្តុតាង និងឲ្យយោបល់ទៅលើបញ្ហាច្បាប់អន្តរជាតិនិងយុទ្ធសាស្ត្រក្នុងការជំនុំជម្រះក្តី ។ ការជំនុំជម្រះក្តីនេះបើកចំហ

ឲ្យអ្នកសង្កេតការណ៍អន្តរជាតិចូលរួម ចំណែកឯអង្គការមិនមែនរដ្ឋាភិបាលមួយចំនួនជាអ្នកត្រួតពិនិត្យមើលដំណើរការជំនុំជម្រះក្តី ។

នៅពេលដែលចុងចោទទទួលបាននូវសិទ្ធិមានមេធាវី និងសិទ្ធិប្តឹងឧទ្ធរណ៍ ក្រុមសិទ្ធិមនុស្សបានរិះគន់ទៅលើដំណោះស្រាយរបស់រដ្ឋាភិបាល ទៅលើករណីជាច្រើនទាក់ទងនឹងការជំនុំជម្រះក្តី ។ អង្គការមិនមែនរដ្ឋាភិបាលបានរិះគន់អាជ្ញាធរដែនដី ដែលបានឃុំខ្លួនមនុស្សដោយគ្មានបទចោទប្រកាន់តាមផ្លូវច្បាប់ ហើយដោយចោទអាជ្ញាធរទាំងនោះថា អ្នកទាំងនោះបានរំលោភទៅលើសិទ្ធិរបស់ចុងចោទ ក្នុងការទាក់ទងជាមួយនឹងមេធាវីតាមលក្ខណ៍ការ ។ អង្គការឃ្លាំមើលសិទ្ធិមនុស្សបានសម្តែងការព្រួយបារម្ភថា នីតិវិធីព្រហ្មទណ្ឌរបស់ប្រទេសអេត្យូពីមិនត្រឹមត្រូវទៅតាមបទដ្ឋានច្បាប់អន្តរជាតិពេញលេញទេ ហើយថា ចុងចោទមិនមានលទ្ធភាពទទួលប្រឹក្សាពីមេធាវីឲ្យបានគ្រប់ៗគ្នាឡើយ គឺមួយផ្នែកអាស្រ័យដោយកង្វះខាតធនធានរបស់ការិយាល័យមេធាវីសាធារណៈ ។ អង្គការនេះក៏បានលើកឡើងនូវបញ្ហាទាក់ទងនឹងកម្រិតដែលគេផ្តល់ឲ្យចុងចោទក្នុងការប្រើប្រាស់ភ័ស្តុតាងដាក់បន្ទុក ។ ដោយសារមានពេលវេលាខ្លីពេកក្នុងការស្ទង់ប្រមាណអំពីភាពត្រឹមត្រូវនៃដំណើរការជំនុំជម្រះក្តី កិច្ចខិតខំប្រឹងប្រែងរបស់ប្រទេសអេត្យូពីក្នុងការកាត់ទោសអតីតមន្ត្រីនៃរបបមុន មើលទៅទំនងជាមិនមានភាពត្រឹមត្រូវនិងប្រសិទ្ធភាពទេ ។ ដើម្បីធ្វើដូច្នេះបាន លុះត្រាតែសហគមន៍អន្តរជាតិមានសុឆន្ទៈចង់ផ្តល់នូវធនធានកាន់តែច្រើនជាងនេះទៅទៀត ក្នុងកិច្ចប្រឹងប្រែងដែលធ្វើកន្លងមក ។



## ៨) ប្រទេស ហុងគ្រី

បក្សកុម្មុយនិស្តហុងគ្រីបានឡើងកាន់អំណាចក្រោយពីសង្គ្រាមលោកលើកទីពីរផុតរលត់ទៅ ។ ក្រោយពីមានការរង្កៀសចិត្តអស់មួយទសវត្សរ៍ រវាងទីក្រុងម៉ូស្គូនិងអ្នកដែលនឹងចូលមកកែទម្រង់នយោបាយ ប្រជាជនរួមគ្នាមួយក្រុមធំនៅទីក្រុង ប៊ុយដាប៉េស ញុះញង់បំផុសបដិវត្តន៍ ដែលជាលទ្ធផលបានបណ្តេញនាយករដ្ឋមន្ត្រីកំពុងកាន់អំណាចចេញពីតំណែង ហើយផ្លាស់ប្តូរមេដឹកនាំដែលមានចរិតសេរីនិយមជាងមុន ។ ទីក្រុងម៉ូស្គូមានប្រតិកម្មតបយ៉ាងរហ័សបំផុត ។ ពេលនោះកងទ័ពសូវៀតបានចូលលុកលុយប្រទេសហុងគ្រី ហើយបានលើកបន្តុបអ្នកកាន់អំណាចថ្មីមួយទៀតដែលប្រឆាំងនឹងនយោបាយចាស់ ដោយកម្ចាត់នូវអ្នកកែទម្រង់មុនយ៉ាងឆាប់រហ័ស ហើយបានផ្លាស់ប្តូរនូវវិធានការដែលកាន់តែផ្តាច់ការថែមទៀត ។ ការបង្ក្រាបមិនរើសមុខចេះតែបន្តតិចឬច្រើននៅទសវត្សរ៍បន្តបន្ទាប់ រហូតដល់ចុងទសវត្សរ៍ឆ្នាំ១៩៨០ ដែលនៅពេលនោះមានការទាមទារឲ្យកែទម្រង់វិស័យនយោបាយនិងសេដ្ឋកិច្ច ។ គណបក្សអ្នកកែទម្រង់ចំនួន៣ក៏បង្កើតជារដ្ឋាភិបាលចម្រុះមួយជ្រកក្រោមរដ្ឋធម្មនុញ្ញថ្មីមួយ ។

នៅឆ្នាំ១៩៩១ សភាបានអនុម័តច្បាប់មួយហៅថា “ច្បាប់ហ្សេត ធិនយី តាក់កាក់” ដែលជាការចាប់ផ្តើមអនុវត្តឡើងវិញនូវច្បាប់អាជ្ញាយុកាលដែលអស់សុពលភាពកន្លងរួចមកហើយចំពោះបទល្មើសដែលប្រព្រឹត្តឡើងនៅឆ្នាំ១៩៤៤-៩០ ។ ច្បាប់នេះទាក់ទងសំខាន់ទៅនឹងបទល្មើសឃោរឃៅដែលកើតឡើងនៅពេលការធ្វើបដិវត្តន៍មិនបានជោគជ័យនៅឆ្នាំ១៩៥៦ ដែលបទល្មើសទាំងអស់នេះមិនទាន់ត្រូវបានកាត់សេចក្តីដោយសារហេតុផលនយោបាយ ។ ច្បាប់នេះធ្វើឲ្យមានការជជែកពិភាក្សាគ្នាយ៉ាងតឹងសរសៃកនិងឈ្លោះទាស់ទែងគ្នា ។ អ្នកគាំទ្រមានចំណាប់អារម្មណ៍ថា នៅក្នុងសភាពការណ៍ដែលភាពរួចទោសចេះតែកើនឡើងឥតឈប់ ជនរងគ្រោះបានបង្ខំចិត្តរស់នៅជាមួយនឹងអតីតអ្នកដែលធ្លាប់ធ្វើទារុណកម្មមកលើខ្លួន ។ ចំណែកឯអ្នកប្រឆាំងព្រួយបារម្ភថា ច្បាប់នេះនឹងបង្កឲ្យមានយុទ្ធនាការប្រឆាំងនិងសង្ស័យថ្នាក់មូលដ្ឋាន ហើយនឹងធ្វើឲ្យប្រព័ន្ធច្បាប់ទាំងមូលមានភាពមិននឹងនរ ។

ផ្ទុយមកវិញ អ្នកដែលគាំទ្របានទាញហេតុផលថា សេចក្តីព្រាងច្បាប់នេះចែងសំដៅកាត់ទោសតែអ្នកប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរបំផុតតែប៉ុណ្ណោះ ហើយចំពោះសាលក្រមសម្រេចទោសដែលនឹងត្រូវអនុម័ត មានកម្រិតស្រាលជាងមុន ។ មានអ្នកខ្លះទៀតអះអាងថា ច្បាប់នេះគឺជាការរំលោភទៅលើកិច្ចសន្យាឲ្យរួចទោសដែលធ្វើឡើងដោយពួកប្រឆាំងនឹងជនកុម្មុយនិស្តនិយម

កំណែទម្រង់ នៅពេលពិភាក្សាគ្នាមុនពេលឈានទៅដល់ដំណាក់កាលសន្តិភាព ។

បើតាមទស្សនៈផ្នែកច្បាប់ អ្នកច្បាប់ខ្លះមានទឡ្ហីករណ៍ថាច្បាប់នេះមានលក្ខណៈប្រតិសកម្ម ដូច្នេះ វារំលោភទៅលើគោលការណ៍ "nullem criman sine lege" ដែលមានន័យថាបុគ្គលទាំងឡាយមិនអាចត្រូវកាត់ឲ្យជាប់ទោសពីបទល្មើសណាមួយដែលមិនមែនជាបទល្មើសនៅពេលប្រព្រឹត្តឡើយ ។ មានអ្នកខ្លះទៀតអះអាងថា ច្បាប់ដែលចែងពីបទល្មើសទាំងនេះមានសុពលភាពប្រើប្រាស់បាន ពីព្រោះដំណើរការជំនុំជម្រះក្តីមិនអាចធ្វើទៅកើតនៅអំឡុងប៉ុន្មានឆ្នាំមុន ហើយការយកច្បាប់អាជ្ញាយុកាលមកអនុវត្តឡើងវិញ មិនមែនជាច្បាប់ប្រតិសកម្មពិតៗឡើយ ។ ដោយសារថា អំពើមនុស្សឃាតមានលក្ខណៈមិនស្របច្បាប់ចាប់តាំងពីឆ្នាំ១៩៥៦មកម្ល៉េះ ដូច្នេះច្បាប់នេះមិនបង្កើតការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះបទល្មើសថ្មីទេ ។

នៅឆ្នាំ១៩៩២ នៅដំណើរការជំនុំជម្រះក្តី៩ក្នុងចំណោមដំណើរការជំនុំជម្រះក្តីទាំង១០ ត្រូវបានតុលាការធម្មនុញ្ញសម្រេចថាគ្មានអានុភាពគតិយុត្តិ ដោយសារច្បាប់ប្រតិសកម្មមានលក្ខណៈផ្ទុយគ្នាទៅនឹង "គោលការណ៍សន្តិសុខនៃច្បាប់" ដែលទាមទារឲ្យមានការការពារសិទ្ធិដែលប្រគល់ឲ្យពីមុនមក និងការពារភាពមិនជ្រៀតជ្រែកជាមួយនឹងការបង្កើតឬបញ្ចប់នូវទំនាក់ទំនងនីត្យានុកូល ។ រដ្ឋធម្មនុញ្ញរបស់ប្រទេសហុងគ្រី ហាមប្រាមការដាក់ទណ្ឌកម្មចំពោះ "ទង្វើដែលនៅពេលប្រព្រឹត្ត... អំពើនេះមិនមែនជាបទល្មើសនៅក្នុងច្បាប់ហុងគ្រី" ។ ដោយផ្អែកលើមូលដ្ឋានច្បាប់នេះ តុលាការយល់ឃើញថា "ច្បាប់នេះបញ្ជាក់ថា អាជ្ញាយុកាលច្បាប់ក៏ចាំបាច់ត្រូវតែសម្រេចទៅតាមច្បាប់ដែលចូលជាធរមាននៅពេលមានការប្រព្រឹត្តបទល្មើសដែរ" ។ អាចនិយាយម្យ៉ាងទៀតថា នៅពេលដែលអាជ្ញាយុកាលច្បាប់នៃបទល្មើសផុតកំណត់ ការទទួលខុសត្រូវខាងព្រហ្មទណ្ឌរបស់ជនល្មើសក៏ត្រូវបញ្ចប់ដែរ ។

ដោយយោលទៅតាមសាវតារជាតិនៃបញ្ហានីតិរដ្ឋធម្មនុញ្ញ តុលាការបានពិចារណាទៅលើស្ថានការណ៍លំបាកដែលរបបអន្តរកាលបានជួបប្រទះក្នុងការផ្សំផ្គុំរវាងប្រព័ន្ធច្បាប់ពីមុននិងប្រព័ន្ធច្បាប់បច្ចុប្បន្ន ។ នៅក្នុងកិច្ចខិតខំប្រឹងប្រែងនេះ តុលាការបានពន្យល់ថា "ការប្រមើលវិធានការដែលតម្រូវដោយ "ការផ្លាស់ប្តូរប្រព័ន្ធ" មិនអាចត្រូវគេយល់ផ្សេងពីតម្រូវការរបស់រដ្ឋដែលស្ថិតនៅក្រោមវិធាននៃច្បាប់នោះទេ ដូចដែលបានបញ្ជាក់ច្បាស់ក្រឡែតនៅក្នុងប្រវត្តិនៃរដ្ឋាភិបាលគ្រប់គ្រងដោយលទ្ធិប្រជាធិបតេយ្យ ក៏ដូចជាការសន្មតតាមការសេរីរដ្ឋធម្មនុញ្ញហុងគ្រីនៅឆ្នាំ១៩៨៩" ។ ដូចនេះការផ្លាស់ប្តូរត្រូវតែផ្អែកលើនិរន្តរភាពច្បាប់ ហើយរដ្ឋមួយដែលជានីតិរដ្ឋគឺមិនអាចរំលោភទៅលើធម្មាធិបតេយ្យបានទេ ទោះជាត្រូវឆ្លើយតបទៅនឹង "តម្រូវការត្រឹមត្រូវ" ក៏ដោយ ។

ក៏ប៉ុន្តែ នៅខែតុលា ឆ្នាំ១៩៩៣ តុលាការដដែលនេះក៏បានធ្វើតាមការរុះរើសាឡើងវិញ នូវច្បាប់ដែលបដិសេធចោលអំពើដែលប្រព្រឹត្តនៅឆ្នាំ១៩៥៦ មិនមែនជាឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទេ ដោយសារថាគ្មានអាជ្ញា-យុកាលច្បាប់ក្រោមនីតិអន្តរជាតិ ។ ច្បាប់ថ្មីនេះផ្អែកលើអនុសញ្ញាបីគឺៈ អនុសញ្ញាទីក្រុងហ្សឺណែវទាក់ទងនឹងការប្រព្រឹត្តិមកលើជនស៊ីវិលនៅពេលសង្គ្រាម អនុសញ្ញាទាក់ទងនឹងការប្រព្រឹត្តិមកលើឈ្លើយសឹក និងអនុសញ្ញាស្តីពីការមិនអនុវត្តនូវច្បាប់អាជ្ញាយុកាលទៅលើឧក្រិដ្ឋកម្មសង្គ្រាមនិងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។ ច្បាប់ថ្មីនេះមិនត្រូវបានពិនិត្យពិច័យទៅលើធម្មនុញ្ញភាពទេ ដោយសាររដ្ឋធម្មនុញ្ញនោះបានធ្វើសមាហរណកម្មច្បាប់អន្តរជាតិឲ្យចូលជាច្បាប់ក្នុងស្រុកទៅហើយ ។

## ឈ) ប្រទេស មិកស៊ិក



នៅឆ្នាំ១៩៩០ លោកប្រធានាធិបតី ឃែរ៉ូល សាលីណាដឺ ហ្គោតីអូរី បានបង្កើតនូវគណៈកម្មការជាតិទទួលបន្ទុកសិទ្ធិមនុស្សមួយ ដែលក្រោយមកគណៈកម្មការនេះចេះតែវិវត្តន៍ទៅមុខ រួចក៏ក្លាយទៅជាអង្គការស្វយ័តមួយ ។ ច្បាប់ដដែលបានផ្តល់អំណាចឲ្យរដ្ឋនីមួយៗរបស់ប្រទេសមិចស៊ិកអាចបង្កើតនូវគណៈកម្មការសិទ្ធិមនុស្សដោយខ្លួនឯង គណៈកម្មការថ្នាក់ជាតិនិងគណៈកម្មការមុនៗ ត្រូវបានរិះគន់ថា មិនបានសាច់ការដោយសារខ្វះអំណាចក្នុងការចោទប្រកាន់ទៅលើអ្នកប្រព្រឹត្តិ

បទល្មើស និងគ្មានអំណាចបង្ខំឲ្យភ្នាក់ងាររដ្ឋាភិបាលអនុវត្តទៅតាមអនុសាសន៍របស់ខ្លួន ។ ហេតុដូច្នេះ ការចោទប្រកាន់ពីបទព្រហ្មទណ្ឌត្រូវបានធ្វើឡើងតែទៅលើបុគ្គលិករដ្ឋាភិបាលមួយចំនួនតូចដែលស្ថិតក្រោមការស៊ើបអង្កេតរបស់គណៈកម្មការនេះតែប៉ុណ្ណោះ ។

តាមបទពិសោធន៍ជាក់ស្តែង ការអនុវត្តប្រព័ន្ធវិមជ្ឈការទៅលើបរិធានសិទ្ធិមនុស្ស ធ្វើឲ្យមានការលំបាកក្នុងការត្រួតពិនិត្យមើលដំណើរការស៊ើបអង្កេតដែលចេះតែបន្តទៅ ។ មនុស្សជាច្រើនយល់ថា គណៈកម្មការទាំងនេះគ្រាន់តែជាយានសម្រាប់ទំនាក់ទំនងដែលធ្វើឡើងសម្រាប់ធ្វើឲ្យមានមុខមាត់ប្រទេសម៉ិចស៊ិកនៅលើឆាកអន្តរជាតិតែប៉ុណ្ណោះ ។ អ្នកដែលចេះតែសង្ស័យនិងមានចម្ងល់មិនចេះចប់ទាំងនេះ ចាត់ទុកថាវាមិនមែនជាការចៃដន្យទេដែលគណៈកម្មការទាំងនេះបង្កើតឡើងស្របពេលដែលការចរចាជុំវិញបញ្ហាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីនៃអាមេរិកខាងជើងកំពុងតែដំណើរការ ។ កត្តាដទៃទៀតធ្វើឲ្យការតាំងចិត្តរបស់គណៈកម្មការក្នុងការដោះស្រាយបញ្ហាសិទ្ធិមនុស្ស មានលក្ខណៈគួរឲ្យសង្ស័យ ពោលគឺ គ្មានអង្គការសិទ្ធិមនុស្សណាមួយនៅម៉ិកស៊ិកត្រូវបានពិគ្រោះយោបល់នៅពេលគណៈកម្មការនេះបង្កើតឡើង ហើយនៅពេលចាប់បដិសន្ធិដំបូងគណៈកម្មការនេះស្ថិតនៅជាប់ជាមួយក្រសួងមហាផ្ទៃដែលទទួលបន្ទុកសន្តិសុខផ្ទៃក្នុងប្រទេស ។ ការរំលោភសិទ្ធិមនុស្ស ដូចជាការបាត់ខ្លួន ទារុណកម្ម ការឃុំខ្លួនខុសច្បាប់ ការសម្លាប់ក្រៅអំណាចតុលាការជាដើម ចេះតែបន្តទៅទូទាំងប្រទេសចាប់តាំងពីការបង្កើតគណៈកម្មការនេះ ។ លទ្ធផលចុងក្រោយ គឺអ្វីដែលអ្នកខ្លះបានហៅថា “វប្បធម៌រួចទោស” ពីព្រោះថា អ្នករំលោភសិទ្ធិមនុស្សចេះតែបន្តរួចខ្លួនរហូត ចំណែកឯប្រទេសផ្សេងៗនៅលើពិភពលោកជឿជាក់ថា ប្រទេសម៉ិកស៊ិកកំពុងតែចងក្រងឯកសារទាក់ទងនឹងអំពើឃោរឃៅពីអតីតកាល ។

### ៣) ប្រទេស រ៉្វាន់ដា

មុនពេលអំពើប្រល័យពូជសាសន៍រីករាលដាលនៅឆ្នាំ ១៩៩៤ ប្រទេសរ៉្វាន់ដាកំពុងតែស៊ើបអង្កេតលើករណីរំលោភសិទ្ធិមនុស្សដែលប្រព្រឹត្តឡើងនៅអំឡុងសង្គ្រាមស៊ីវិល ។ អំពើហិង្សារវាងជនជាតិ ហ៊ូទូ, ទុតស៊ី និង ត្វា បានចេញជារូបភាពទៅហើយចាប់តាំងពីទទួលបានឯករាជ្យ ហើយនាំដល់បទឈប់បាញ់គ្នានៅខែកក្កដា ឆ្នាំ១៩៩២ ។ រដ្ឋាភិបាលបានយល់ព្រមបង្កើតនូវគណៈកម្មការស្វែងរកការពិត ដែលជាផ្នែកមួយនៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងអារូហ្សាដែលចរចានៅចុងឆ្នាំ១៩៩២ ។ អង្គការសិទ្ធិមនុស្សនានាបានជំរុញឲ្យបង្កើតអង្គការនេះកាលពីអតីតកាល ហើយជាបន្តបន្ទាប់ក៏សុំឲ្យអង្គការក្រៅរដ្ឋាភិបាលមកពីសហរដ្ឋអាមេរិក កាណាដា បារាំង និងប៊ឺគីណា-ហ្វាសូ ឲ្យបង្កើតនូវគណៈកម្មការនេះឡើង ។ គឺជាលើកទីមួយហើយសម្រាប់ប្រទេសនេះ ដែលមានគណៈកម្មការមួយគាំទ្រដោយរដ្ឋាភិបាលនិងដឹកនាំដោយអង្គការក្រៅរដ្ឋាភិបាល ។ របាយការណ៍របស់គណៈកម្មការត្រូវបានផ្សព្វផ្សាយយ៉ាងទូលាយ ហើយវាមានលក្ខណៈគួរឲ្យជឿទុកចិត្តបាន ដែលអាចឲ្យប្រទេសប៊ែលហ្ស៊ិកនិងបារាំងប្រមើលទៅលើនយោបាយរបស់ខ្លួនចំពោះរដ្ឋាភិបាលរ៉្វាន់ដា ។ គណៈកម្មការនេះកំពុងតែគិតពិចារណាមើលថាតើត្រូវធ្វើការស៊ើបអង្កេតទៅលើអំពើឃោរឃៅរបស់កម្លាំងខុទ្ទាម ដែលអំពើនេះត្រូវបានកាត់ផ្តាច់នៅពេលមរណភាពរបស់លោកប្រធានាធិបតី ជូវេណាល់ ហាប៊ីយ៉ារីម៉ាណា និងដោយការកើតឡើងនូវអំពើហិង្សានៅខែមេសា ឆ្នាំ១៩៩៤ ឬយ៉ាងណា ។

ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិបានឆ្លើយតបទៅនឹងភាពច្របូកច្របល់ តាមរយៈការបង្កើតនូវគណៈកម្មការអ្នកជំនាញការថ្មីមួយទៀតដែលមានទម្រង់ប្រហាក់ប្រហែលគ្នានឹងគណៈកម្មការដែលធ្វើការងារស៊ើបអង្កេតការរំលោភសិទ្ធិមនុស្សនៅអតីតយូហ្គោស្លាវី ។ គណៈកម្មការនេះបានផ្តល់អនុសាសន៍ឲ្យបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិពិសេសមួយ ។ ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិបានធ្វើតាមអនុសាសន៍នេះ ហើយបង្កើតឡើងនូវតុលាការរ៉្វាន់ដាក្រោមជំពូកVII ។ ក្រៅពីសក្ខីកម្មរបស់សាក្សីតុលាការនេះក៏បានពិចារណាទៅលើភស្តុតាងជាក់ស្តែង ដើម្បីជួយបង្កើតឲ្យបានជាធាតុផ្សំ “ចេតនាប្រល័យពូជសាសន៍” ។ ភស្តុតាងជាក់ស្តែងនេះមានដូចជា បញ្ជី

ឈ្មោះមនុស្សដែលត្រូវសម្លាប់ ដែនទីបង្ហាញពីទីតាំងលំនៅឋាន របស់មនុស្សដែលជាមុខសញ្ញាកម្ទេច ការផ្សាយវិទ្យុញុះញង់ ឲ្យជនជាតិហ៊ូទូសម្លាប់ជនជាតិទុតស៊ី ព្រមទាំងឯកសារនានា ទាក់ទងនឹងវិធីបែងចែកអាវុធ ។



### ៨) ប្រទេស អាហ្វ្រិកខាងត្បូង

ដំណាក់កាលផ្លាស់ប្តូរនយោបាយ នៅអាហ្វ្រិកខាងត្បូង ឈានទៅរកអំណាចដឹកនាំមួយដែលមានលក្ខណៈប្រជាធិបតេយ្យ ប្រព្រឹត្តទៅដោយមានការប៉ុនប៉ងចងក្រងឯកសារនិងទម្លាក់កំហុសចំពោះការរំលោភសិទ្ធិមនុស្សដែលប្រព្រឹត្តដោយកងកម្លាំងរដ្ឋាភិបាលមុន និងអតីតសមាជិកគណបក្សប្រឆាំង ជាពិសេស គឺសមាជិកសភាជាតិអាហ្វ្រិកតែម្តង ។ ដោយសារតុល្យភាពរវាងយុត្តិធម៌និងលិទ្ធិប្រជាធិបតេយ្យនៅអាហ្វ្រិកខាងត្បូងមានលក្ខណៈស្រួចស្រាល់ពេក ធ្វើឲ្យកិច្ចការរបស់គណៈកម្មការមានភាពស្មុគស្មាញជាទីបំផុត ។ ការចងក្រងឯកសារអំពីការធ្វើទុក្ខទោស ជាទូទៅប្រព្រឹត្តទៅមុនការដាក់ទណ្ឌកម្មជនដែលទទួលខុសត្រូវចំពោះអំពើឃោរឃៅ ។ ចាប់តាំងពីឆ្នាំ១៩៩០មក មានការបង្កើតគណៈកម្មការចំនួនបួនផ្សេងៗគ្នារួចទៅហើយ ដើម្បីស៊ើបអង្កេតការរំលោភសិទ្ធិមនុស្សនៅក្នុងដែនដីអាហ្វ្រិកខាងត្បូង និងនៅជុំវិញឃុំឃាំងនៅប្រទេសជិតខាង ។

គណៈកម្មការទី១ដែលបង្កើតឡើងដោយប្រធានាធិបតី ឌឺ ក្លឹក បានស៊ើបអង្កេតទាំងទៅលើការរំលោភរបស់រដ្ឋាភិបាល និងរបស់គណបក្សប្រឆាំង ។ គណៈកម្មការកណ្តាលពីរដែលបង្កើតឡើងដោយសភាជាតិអាហ្វ្រិកនៅឆ្នាំ១៩៩២ និង ១៩៩៣ គឺជាគំរូគណៈកម្មការស្វែងរកការពិតដែលបង្កើតឡើងដោយអង្គការមិនមែនរដ្ឋាភិបាល ។ ច្បាប់បង្កើតគណៈកម្មការទី៤ ដែលជាគណៈកម្មការស្វែងរកការពិតនិងការផ្សះផ្សា ត្រូវបានបង្ហាញជូនដោយលោកប្រធានាធិបតី មែនដឺឡា ហើយអនុម័តដោយអង្គនីតិបញ្ញត្តិនៅពាក់កណ្តាលឆ្នាំ១៩៩៥ ។

**អេលីហ្សាប៊ែត ខាន់ស្តាក់**

## សេចក្តីជូនដំណឹង

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់រស់នៅ ឆ្លងកាត់របបខ្មែរក្រហម បាននឹងកំពុងសរសេរអត្ថបទ ឬសៀវភៅអំពីរឿងរ៉ាវផ្ទាល់ខ្លួន ហើយនិងផ្ញើមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជា តាមរយៈអាសយដ្ឋានខាងក្រោមៈ

ប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥
ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨
Email: dccam@bigpond.com.kh
Home page: http://welcome.to/dccam

***ការសរសេរនេះមានសារសំខាន់៥យ៉ាងគឺៈ***

◆ ចូលរួមជាចំណែកមួយនៃប្រវត្តិសាស្ត្រ ទុកសម្រាប់ឲ្យក្មេងជំនាន់ក្រោយបានដឹងនិងសិក្សារៀនសូត្រ ។

◆ ជួយក្នុងការស្វែងរកយុត្តិធម៌ជូនដល់ប្រជាជនកម្ពុជារាប់លាននាក់ ដែលបានស្លាប់បាត់បង់ជីវិតនៅក្នុងសម័យនោះ ។

◆ ជាវិធីមួយដើម្បីរំងាប់អារម្មណ៍ ដោយយកសេចក្តីទុក្ខការខឹងគុំកួន មកតម្កល់ជាឯកសារប្រវត្តិសាស្ត្រ ដើម្បីបម្រើដល់ការស្រាវជ្រាវតទៅថ្ងៃអនាគត ។

◆ ការចងចាំគឺជាវិធីមួយដោយសន្តិវិធីក្នុងការទប់ស្កាត់មិនឲ្យអំពើប្រល័យពូជសាសន៍កើតឡើងបានជាថ្មីម្តងទៀតក្នុងសង្គមមនុស្ស ។

◆ ជួយលើកកម្ពស់ដល់ការគោរពសិទ្ធិមនុស្ស (សិទ្ធិរស់រានមានជីវិត) នៅក្នុងពេលបច្ចុប្បន្ន និងតទៅក្នុងថ្ងៃអនាគត ។

មជ្ឈមណ្ឌលឯកសារកម្ពុជានឹងចុះផ្សាយអត្ថបទទាំងនោះ នៅលើទំព័រទស្សនាវដ្តី ឬបោះពុម្ពជាសៀវភៅ ក្នុងករណីបានទទួលការអនុញ្ញាតពីសាមីខ្លួន ។

សូមអរគុណ ។

## ពាក្យស្លោកខ្មែរក្រហម

◆ **ស្លាប់ក្នុងសង្គ្រាមប្រសើរថ្លៃថ្លា។**
◆ **ស្លាប់ជាការធម្មតារបស់អ្នកតស៊ូ។**
◆ **ជនកុម្មុយនិស្តល្អបងរក្រែ តគស់ចែហ៊ានបូជាជីវិតដើម្បីជាតិ។**

(ដកស្រង់ចេញពីសៀវភៅ អ៊ីវ)

# រដ្ឋធម្មនុញ្ញទាំងឡាយនៅកម្ពុជា

## មហិច្ឆតា ការបន្ត និង ការលុបចោល

រដ្ឋធម្មនុញ្ញរបស់កម្ពុជាដែលប្រើក្នុងពេលសព្វថ្ងៃនេះ មានចំណាស់៥០ឆ្នាំមកហើយ ។ ប្រាកដហើយដែលសេចក្តីព្រាងលើកដំបូងនៃរដ្ឋធម្មនុញ្ញទំនើបត្រូវបានតាក់តែងដោយគណៈកម្មការបារាំងនិងខ្មែរមួយក្រុម បន្ទាប់មកត្រូវបានសម្រួលនិងអនុម័តដោយព្រះមហាក្សត្រ នរោត្តម សីហនុ ។ តាមព្រះរាជប្រកាសមួយចុះថ្ងៃទី១៣ ខែមេសា ឆ្នាំ១៩៤៦ ព្រះមហាក្សត្របានសម្តែងឲ្យដឹងជាបន្តទៀត នូវព្រះរាជបំណងពិគ្រោះយោបល់ពីបញ្ហានេះជាមួយនឹងសភាមួយដែលប្រជារាស្ត្របោះឆ្នោតជ្រើសតាំង មុននឹងសម្រេចយកជាស្ថាពរ ។ សភានេះកើតចេញពីការបោះឆ្នោតតាមលទ្ធិប្រជាធិបតេយ្យពិតប្រាកដជាលើកដំបូងនៅថ្ងៃទី១ ខែកញ្ញា ឆ្នាំ១៩៤៦ ដែលមិនធ្លាប់រៀបចំចាត់ចែងឲ្យមានដំណើរឡើងទាល់តែសោះនៅក្នុងប្រទេសនេះ ។ (អ្នកនិពន្ធសរសេរយ៉ាងច្រើនថា ការបោះឆ្នោតដែលរៀបចំដោយអង្គការសហប្រជាជាតិនៅឆ្នាំ១៩៩៣ គឺជាការបោះឆ្នោតតាមលទ្ធិប្រជាធិបតេយ្យជាលើកដំបូងដែលមិនដែលចាត់ចែងរៀបចំទាល់តែសោះនៅប្រទេសកម្ពុជា ។ រឿងនេះមិនសូវពិតទេ ព្រោះការបោះឆ្នោតនៅឆ្នាំ១៩៤៦, ១៩៤៧ និង១៩៥១ យ៉ាងហោចណាស់ក៏មានលក្ខណៈសេរីនិងយុត្តិធម៌ដូចការបោះឆ្នោតដែលរៀបចំដោយអង្គការសហប្រជាជាតិដែរ ហើយមិនសូវមានលក្ខណៈគួរឲ្យកត់សម្គាល់ដោយការសម្លុតបំភ័យនិងហិង្សានយោបាយដូចការបោះឆ្នោតឆ្នាំ១៩៩៣ឡើយ ដែលការបោះឆ្នោតនេះមានរបៀបដូចគ្នានឹងការបោះឆ្នោតនៅឆ្នាំ១៩៥៥យ៉ាងច្រើន) ។ ការបោះឆ្នោតនេះបានផ្តល់ជ័យជម្នះដល់គណបក្សប្រជាធិបតេយ្យដែលមានភាពច្រើនលើសលប់ ដោយបានបដិសេធគ្មានទីសម្រាប់ឲ្យយោបល់ដែលព្រះមហាក្សត្រមានព្រះរាជបំណងកំណត់ព្រំដែនដល់សភាថ្មី ។ ដូចសភានៃរដ្ឋទូទៅនៅឆ្នាំ១៧៨៩ដែរ សភាថ្មីនេះបានប្រកាសខ្លួនឯងជាសភាធម្មនុញ្ញ ដោយបដិសេធមិនជជែកពិភាក្សាអំពីរដ្ឋធម្មនុញ្ញដែលដាក់ថ្វាយសុំព្រះរាជយោបល់អនុញ្ញាតពីព្រះអង្គឡើយ ។ ដូចដែលលោក ឡាហ្សេ កត់សម្គាល់ពីរឿងនេះថា តាមការពិត ពួកអ្នកដែលប្រជាជនជ្រើសតាំងមានបំណងធ្វើអ្វីមួយក្នុងឋានៈជាអ្នកតំណាងរាស្ត្រនៃសភាបញ្ញត្តិច្បាប់ពិតៗ ។ ដោយបំណងល្អនិងការសម្រុះសម្រួលដែលសភាធម្មនុញ្ញនឹងយល់ព្រមក្នុងបំណងបញ្ចៀសជម្លោះជាមួយព្រះមហាក្សត្រ ទើបរដ្ឋធម្មនុញ្ញចាប់កំណើតនៅថ្ងៃទី១៦ ខែឧសភា ឆ្នាំ១៩៤៧ ។ នេះជាការចាក់គ្រឹះពិតប្រាកដនៃរដ្ឋធម្មនុញ្ញដែលមានក្នុងពេលសព្វថ្ងៃនៅប្រទេសកម្ពុជា ។

៥០ឆ្នាំកន្លងមកហើយ គឺជារយៈពេលខ្លីណាស់ប្រសិនបើពិនិត្យមើលប្រវត្តិសាស្ត្រមួយរបស់កម្ពុជាដែលសិលាចារឹករបស់ខ្មែរត្រូវគេស្គាល់ថាមានឫសគល់តាំងពីឆ្នាំ៦០៤ គឺត្រូវជាមួយពាន់បីរយសែសិបបីឆ្នាំមុនការផ្តល់រដ្ឋធម្មនុញ្ញសម្រាប់រដ្ឋមួយដែលព្រះមហាក្សត្រ នរោត្តម សីហនុ ទ្រង់ហៅនៅពេលសព្វថ្ងៃថាជាព្រះរាជាណាចក្រកម្ពុជាទី១ ។ ក្នុងរយៈពេលជាងដប់ប្រាំសតវត្សរ៍ ព្រះរាជាណាចក្រខ្មែរធ្លាប់ត្រូវបានគ្រប់គ្រងដោយច្បាប់គ្រឹះផ្សេងៗដែលពុំដែលត្រូវប្រកាសឲ្យប្រើ ហើយជាញឹកញាប់ពុំដែលចារជាលាយលក្ខណ៍អក្សរឡើយ ។ ប៉ុន្តែដូចដែលលោក ហ្សង់អាំប៊ែរ សង្កត់បញ្ជាក់អ៊ីចឹង គឺច្បាប់គ្រឹះទាំងនេះមិនសូវមានអត្ថិភាពដោយភាពពិតជាក់លាក់ទេ

(ភ្នំពេញ, សៀវភៅដែលចុះព្រឹត្តិការណ៍ផ្សេងៗគ្រប់ឆ្នាំរបស់មហាវិទ្យាល័យច្បាប់ ឆ្នាំ១៩៦១) ។ ក៏ប៉ុន្តែ៥ទសវត្សរ៍វាល្មមគ្រប់គ្រាន់ហើយ ដើម្បីផ្តោតការពិនិត្យមើលជាទូទៅមួយទៅលើអត្ថបទរដ្ឋធម្មនុញ្ញទាំងអស់ និងថ្លឹងថ្លែងព្រមគ្នានូវមហិច្ឆតាការបន្តធ្វើ និងការលុបចោល ដែលអត្ថបទទាំងនោះបង្ហាញឲ្យឃើញ ។ មុននឹងចំណាយពេលវេលាទៅក្នុងការធ្វើនេះ គេត្រូវតែផ្សៀងពិនិត្យអត្ថបទរដ្ឋធម្មនុញ្ញអំពីសារសំខាន់និងសិក្សាចាប់ពីពេលនេះទៅ នូវយោបល់ដែលប្រជាជនកម្ពុជាមានចំពោះអត្ថបទនៃរដ្ឋធម្មនុញ្ញមួយ ។ ដោយទទួលស្គាល់ថា ការសិក្សារដ្ឋធម្មនុញ្ញមួយមិនប្រើប្រាស់អស់នូវធាតុផ្សំនៃច្បាប់ទាក់ទងនឹងរដ្ឋធម្មនុញ្ញ គេនឹងសុំឲ្យមន្ត្រីទទួលកិច្ចការនេះ ទទួលស្របថាព្រំដែននៃមធ្យោបាយទាក់ទងគ្នាបច្ចុប្បន្ន ហាមមិនឲ្យទៅហួសពីការពិនិត្យមើលច្បាប់រដ្ឋធម្មនុញ្ញទាំងឡាយដោយខ្លួនឯងឡើយ ។

ដូចដែលលោក ក្លូត ហ៊្គីលហ្គូរ សរសេរអំពីរឿងនេះក្នុងសៀវភៅគួរឲ្យកត់សម្គាល់របស់គាត់សម្រាប់ស្ថាប័ននានាដែលត្រឹមត្រូវតាមរដ្ឋធម្មនុញ្ញនិងនយោបាយ នៅក្នុងប្រទេសកម្ពុជាថាៈ “ច្បាប់រដ្ឋធម្មនុញ្ញមួយពុំដែលបង្ហាញឲ្យឃើញអ្វីក្រៅតែពីចម្លើយផ្សេងៗដែលសម្តែងឲ្យដឹងតាមរយៈច្បាប់ដែលមានពិតនៃប្រទេសមួយ ចំពោះបញ្ហាទូទៅ មិនត្រឹមតែខាងបច្ចេកទេសប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងខាងសង្គមសាស្ត្រឬខាងនយោបាយទៀត” ។ ប៉ុន្តែ អ្វីដែលអះអាងនេះបានបង្កឲ្យមានបញ្ហាស្តីពីការពិតនៃច្បាប់វិជ្ជមានមួយរបស់កម្ពុជា ដែលជំរុញឲ្យយើងពិនិត្យមើលដោយយកចិត្តទុកដាក់ដោយផ្ទាល់អំពីលក្ខណៈនៃទំនាក់ទំនងរបស់ប្រជាជនកម្ពុជាជាមួយអ្នកកាន់អំណាច ។ នៅចំពោះមុខប្រជាជនមួយ និងជាពិសេសទៅទៀតវណ្ណៈអ្នកនយោបាយមួយដែលក្នុងកាលៈទេសៈនេះច្រើនជាអ្នកតំណាងរាស្ត្រ បានបញ្ចេញឲ្យឃើញនៅពេលសព្វថ្ងៃជាងពេលណាៗទាំងអស់ នូវអសមត្ថភាពមួយដែលស្ទើរតែមានមកពីកំណើតឬការបដិសេធមួយដែលស្ទើរតែដាច់អហង្ការ ក្នុងការប្រតិបត្តិតាមច្បាប់ផ្សេងៗដែលគេទទួលស្គាល់ជាទូទៅ គឺគេបានត្រឹមតែសង្ស័យពីភាពជាក់លាក់នៃច្បាប់វិជ្ជមានមួយប៉ុណ្ណោះ ។ មិនដែលមានពេលណាដូចពេលសព្វថ្ងៃនេះទេ ប្រហែលលើកលែងតែក្នុងសម័យសាធារណរដ្ឋខ្មែរដ៏ខ្លីរបស់ លន់ ណុល ប៉ុណ្ណោះ ដែលប្រទេសកម្ពុជាបញ្ចេញឲ្យឃើញនូវរូបភាពនៃការមិនព្រមធ្វើអ្វីមួយដែលត្រូវធ្វើក្នុងអំឡុងនៃប្រវត្តិសាស្ត្រសព្វថ្ងៃរបស់ខ្លួន ។ មែនហើយ គេត្រូវតែបន្ថែមថា មិនដែលមានពេលណាដូចសព្វថ្ងៃនេះទេ ដែលប្រទេសជាតិត្រូវប្រឈមមុខនឹងកិច្ចការស្តារឡើងវិញដ៏ធំសម្បើមមួយក្នុងបរិបទនៃសេរីនិយមផ្នែកសេដ្ឋកិច្ចដែលបង្ខិនបង្ខោចជាងគេ ជាមួយកង្វះខាតយ៉ាងខ្លាំងនូវក្របខ័ណ្ឌមន្ត្រីរាជការដែលមានគុណសម្បត្តិខាងវិជ្ជាជីវៈក្នុងបរិបទមួយ ដែលដើរយ៉ាងជ្រៅដោយសារសោកនាដកម្មមួយក្នុងចំណោមសោកនាដកម្មធំៗដែលប្រជាជនមួយមិនដែលទទួលរង និងដោយសារការបាត់បង់របៀបវិនិច្ឆ័យយ៉ាងហួសប្រមាណដែលជាផលនៃសោកនាដកម្មនេះ ។ វាបានត្រឹមតែរាំងរាការប្រព្រឹត្តិផ្សេងៗដែលអាចសង្កេតបាន និង បង្ហាញឲ្យឃើញទំនៀមទម្លាប់ដែលនៅសល់នៃការលម្អៀងយ៉ាងធ្ងន់ដែលគេមិនអាចដឹងនៅក្នុងពេលគេមានបំណងស្វែងយល់ពីអំណាចដែលឆ្លងកាត់សង្គមរបស់កម្ពុជា និងបែបផែននៃអំណាចត្រូវបានបកស្រាយក្នុងអត្ថបទរដ្ឋធម្មនុញ្ញផ្សេងៗ ។ មាត្រា១៣១ នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ បានធ្វើឲ្យនឹកឃើញពីសារសំខាន់ផ្នែកគតិយុត្តិនៃអត្ថបទរដ្ឋធម្មនុញ្ញ និងបញ្ជាក់ពីលំដាប់លំដោយនៃបទដ្ឋាន (គោលការណ៍ដែលទុកជាវិធាន) ផ្សេងៗ ដែលជាគ្រឹះមួយក្នុងចំណោមគ្រឹះនីតិរដ្ឋ ។ រដ្ឋធម្មនុញ្ញបង្ហាញថា “រដ្ឋធម្មនុញ្ញជាច្បាប់កំពូលរបស់ប្រទេសកម្ពុជា ។ ច្បាប់និងសេចក្តីសម្រេចទាំងឡាយនៃស្ថាប័ននានារបស់រដ្ឋ ត្រូវស្របនឹងរដ្ឋធម្មនុញ្ញជាដាច់ខាត” ។ សញ្ញាណនៃច្បាប់គ្រឹះនេះហាក់ដូចជាគ្មានទាក់ទងជាមួយនឹងទម្លាប់ជាប្រពៃណីដែលនៅក្រោមរដ្ឋធម្មនុញ្ញរបស់កម្ពុជាសោះ ។ នៅប្រទេសកម្ពុជា រដ្ឋធម្មនុញ្ញពុំមែនជាអត្ថបទមួយដែលដាក់បង្ខំឲ្យមនុស្សទាំងអស់ព្រមទទួលដោយដាច់ខាតឡើយ ហើយគេអាចកែប្រែដោយប្រើនីតិវិធីដែលពន្យល់ឲ្យចោលគំនិតនោះប៉ុណ្ណោះ ។ ប៉ុន្តែគំនិតនៃ“ច្បាប់គ្រឹះ” មានចារឹកក្នុងរដ្ឋធម្មនុញ្ញជាបន្តបន្ទាប់គ្នាចំនួន៧ ដែលមានជាធរមានតាំងពីឆ្នាំ១៩៥៣ និងដែលគ្មានចែងច្បាស់លាស់ក្នុងរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ ។ ការពិនិត្យកត់ត្រានេះបានផ្តល់នូវការ

បង្ហាញឲ្យឃើញដំបូងមួយ ស្តីពីគម្លាតគ្នារវាងបទដ្ឋានគតិយុត្តិនិងការអនុវត្តជាក់ស្តែង ។

ក្នុងស្រុកនេះ ការបញ្ញត្តិនៃច្បាប់រដ្ឋធម្មនុញ្ញពុំមែនចាត់ទុកជាការបន្ទំមួយទេ ។ ផ្ទុយទៅវិញ វាត្រូវបានយល់ព្រមទុកដូចជាអទត្តពលភាពមួយ (ភាពអាចកើតមានទៅខាងមុខ) ឧត្តមគតិមួយ ដែលតាមរយៈនោះ គេប្រឹងប្រែងចងជាសម្ព័ន្ធញាតិនឹងគ្នា ហើយដែលគេនឹងយកចិត្តទុកដាក់ធ្វើឲ្យសម្រេច ប្រសិនបើភាពចាំបាច់ធ្វើឲ្យខ្លួនដឹងពីរឿងនេះ ។ វាមានរបៀបជជែកពិភាក្សាមួយដោយផ្អែកលើការអនុវត្តនូវបទបញ្ញត្តិផ្សេងៗរបស់រដ្ឋធម្មនុញ្ញ ដែលខុសគ្នាទាំងស្រុងពីការអនុញ្ញាតឲ្យពិភាក្សាឯកសារដូចគ្នាក្នុងប្រទេសកាន់លទ្ធិប្រជាធិបតេយ្យលោកខាងលិចជាច្រើន ។ តាំងពីឆ្នាំ១៩៦៥ម៉្លេះ សាស្ត្រាចារ្យហ្គួរ៍ បានសំអាងលើការពិនិត្យកត់ត្រាដូចគ្នាអំពីរដ្ឋធម្មនុញ្ញឆ្នាំ១៩៤៧ និងការពិនិត្យមើលឡើងវិញជាបន្តបន្ទាប់របស់គាត់ ។ ការពិនិត្យមើលរបស់គាត់ពុំមែនបដិសេធប្រវត្តិសាស្ត្ររដ្ឋធម្មនុញ្ញជាបន្តបន្ទាប់របស់ប្រទេសទេ ។ ការពិនិត្យទាំងនោះសព្វថ្ងៃនេះនៅតែមានលក្ខណៈសមហេតុផលពេញទី ។ (គាត់បានបញ្ចេញយោបល់ថា “រដ្ឋធម្មនុញ្ញរបស់កម្ពុជាពុំមែនជាក្របខ័ណ្ឌដែលដាក់កំហិតជាស្រេច ដែលមិនប្រែប្រួល ហើយដែលឲ្យគេគោរពរាល់អាជ្ញាបញ្ញាខាងគតិយុត្តិរបស់ខ្លួន ស្របទៅនឹងជីវភាពនយោបាយមួយដែលកំពុងវិវឌ្ឍន៍មិនឈប់ឈរនោះទេ ។...) នេះជាដំណើរប្រចូកប្របល់ទូទៅមួយដែលមានភាពជាប់នឹងបំផុត ដែលប្រែប្រួល និងដែលតម្រូវទៅតាមភាគល្អិតល្អន់នៃសេចក្តីត្រូវការផ្សេងៗតាមដំណើរមានពិតប្រាកដ ។ នីតិវិធីក្នុងការពិនិត្យឡើងវិញដែលមានលក្ខណៈសាមញ្ញនិងរហ័សបំផុត មិនដែលអនុញ្ញាតឲ្យរដ្ឋធម្មនុញ្ញរួមបង្កជាហ្វ្រាំងទប់មួយ ដែលនាំទៅដល់ភាពទ័លច្រកផ្នែកគតិយុត្តិទេ ផ្ទុយទៅវិញ អាចតាមសង្កេតមើលយ៉ាងជិតដល់បំផុតនូវការប្រែប្រួលផ្សេងៗនៃជីវភាពនយោបាយ ហើយជួនកាល ជួយសម្រួលថែមទៀត ដោយដើរមុនការប្រែប្រួលនោះ និងទាញមេរៀនពីបរាជ័យខ្លះៗ ហើយបង្កើនបទពិសោធន៍ឡើង ។ របៀបទុកតម្លៃនៃការប្រតិបត្តិជាធំក្នុងការអានរដ្ឋធម្មនុញ្ញពុំមានទាក់ទងនឹងអត្ថន័យដ៏តិចតួចនៃទស្សនៈគិតពីផលប្រយោជន៍ទូទៅទេ ។ សញ្ញាណនៃទ្រព្យសម្បត្តិសាធារណៈមួយដែលទទួលកម្មសិទ្ធិទាំងមូលដោយប្រជាពលរដ្ឋម្នាក់ៗ គឺគ្មានឃើញទាំងស្រុង ។ ដោយហេតុនេះ គេនឹងមិនងឿងឆ្ងល់ឡើយអំពីការស្ទើរតែគ្មានការវែកញែកឲ្យដាច់រវាងកម្មសិទ្ធិសាធារណៈនិងកម្មសិទ្ធិឯកជន ។ ដូច្នេះហើយបានជាក្នុងចំណោមមេកោយពួកអ្នកទាំងឡាយដែលធានាការប្រព្រឹត្តិទៅនៃស្ថាប័នផ្សេងៗគេសង្កេតឃើញភាពមិនច្បាស់លាស់យ៉ាងធំមួយរវាងទ្រព្យសម្បត្តិរួមនិងផលប្រយោជន៍ឯកជន ។ ភាពមិនច្បាស់លាស់នេះបានធ្វើឲ្យចុះខ្សោយសញ្ញាណរដ្ឋដែលគ្មានកាន់ជើងខាងណា ព្រោះតែមិនចង់និយាយថាវាបំផ្លាញរដ្ឋ ។

ពាក្យអំណាចសាធារណៈបានប្រឡូកប្រឡំគ្នាជាមួយអំណាចរបស់បុគ្គលផ្សេងៗដែលរ៉ាប់រង ដោយដាក់លាក់នូវការប្រព្រឹត្តិទៅនៃអំណាចនោះ ។ ពិតហើយ នៅកម្ពុជាក៏ដូចនៅប្រទេសដទៃទៀតរដ្ឋធម្មនុញ្ញឲ្យសច្ចាប័ននិងបញ្ជារដ្ឋ កំណត់នូវចំណែកនិងរចនាសម្ព័ន្ធផ្សេងៗរបស់ខ្លួន បញ្ជាក់ដោយច្បាស់លាស់ពីរបៀបផ្សេងៗនៃការកាន់កាប់អំណាច និងកំណត់ពីច្បាប់នានាដែលនិងអនុញ្ញាតឲ្យជ្រើសរើសបុគ្គលទាំងឡាយដែលនឹងត្រូវប្រគល់ឲ្យទទួលខុសត្រូវក្នុងការកាន់កាប់អំណាច ។ ប៉ុន្តែនៅប្រទេសកម្ពុជានិងនៅប្រទេសផ្សេងៗទៀត រវាងអត្ថបទរដ្ឋធម្មនុញ្ញ ការបកស្រាយ និងការប្រតិបត្តិជាយថាហេតុរបស់វា គេសង្កេតឃើញគម្លាតពីគ្នាជាបន្តបន្ទាប់មួយដែលបណ្តាលឲ្យមានការអនុវត្តផ្សេងៗស្រេចតែចិត្ត ដែលពិតជាស្របយ៉ាងខ្លាំងទៅនឹងទម្លាប់ជាប្រពៃណី ប៉ុន្តែឃ្លាតឆ្ងាយបន្តិចពីបណ្តាគោលការណ៍ធំៗដែលបង្កើតនីតិរដ្ឋមួយ ។ របៀបធ្វើការទាំងនេះ ដែលបង្ហាញឲ្យឃើញនិន្នាការពិបាកបំពេញ ត្រូវតែធ្វើឲ្យដូចគ្នាដោយច្បាស់លាស់ ប្រសិនបើគេចង់សាកល្បងស្វែងយល់រឿងរ៉ាវខ្លះៗនៃជីវភាពនយោបាយរបស់ប្រទេសនេះ និងជៀសវាងការធ្វើឡើងវិញនូវកំហុសផ្សេងៗដែលប្រព្រឹត្តឡើងដោយពួកអ្នកបង្កើតកិច្ចព្រមព្រៀងសន្តិភាពឆ្នាំ១៩៩១ និងក្រុមអ្នកច្បាប់ទាំងហ្វូងរបស់អាជ្ញាធរបណ្តោះអាសន្ននៃអង្គការសហប្រជាជាតិនៅកម្ពុជា “អ៊ុនតាក់” (ឈ្មោះដែលដាក់ឲ្យ

បេសកកម្មអន្តរការសហប្រជាជាតិទទួលបន្ទុកធ្វើឲ្យមានកិច្ចព្រមព្រៀងសន្តិភាពដែលចុះហត្ថលេខានាទីក្រុងប៉ារីស នៅថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ ។ បេសកកម្មនេះបានចាប់ផ្តើមនៅថ្ងៃទី១៥ ខែមីនា ឆ្នាំ១៩៩២ និងបញ្ចប់នៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣) ដែលមកទីនេះ (កម្ពុជា) ជាមួយការរៀបចំតម្លើងច្បាប់រដ្ឋធម្មនុញ្ញមួយដែលនាំចូលពីបស្ចិមប្រទេស ក្នុងគោលបំណងជួយផ្តល់ដល់ពួកអ្នកម្ចាស់ស្រុក ដោយសូមឲ្យពេញចិត្តនឹងច្បាប់នេះដែលមានរបៀបបកស្រាយគតិយុត្តិមួយតាមបែបធម៌និព្វាន ។ អំពីច្បាប់រដ្ឋធម្មនុញ្ញក៏ដូចរឿងផ្សេងទៀត ទស្សនៈដែលជឿអ្វីមួយស៊ប់ គឺជាគ្រោះថ្នាក់មួយដូចគ្នានឹងការយោគយល់ហួសហេតុចំពោះគោលការណ៍ផ្សេងៗដែរ ។ ក្នុងការអនុវត្តន៍ច្បាប់រដ្ឋធម្មនុញ្ញរបស់កម្ពុជា អ្វីដែលមានភាពលើសលប់លើអត្ថបទច្បាប់ និងរបបទាំងឡាយដែលច្បាប់នេះប្រកាសថាដូចគ្នាគឺលក្ខណៈ "ប្រើងប្រែងពង្រីកបក្សពួក" ក្នុងទំនាក់ទំនងផ្សេងៗក្នុងសង្គម ។ ដោយបាត់ក្របខ័ណ្ឌការពារស្មើភាពមួយ ប្រជាជនបានស្វែងរកការគាំពារនិងការតែងតាំងក្នុងមុខងារអស់រយៈពេលជាច្រើនសតវត្សរ៍មកហើយ ឆ្លងកាត់តាមរយៈខ្សែបណ្តាញទំនាក់ទំនងរវាងបុគ្គលផ្សេងៗដែលគ្មានទាក់ទងនឹងប្រព័ន្ធអាស្រ័យរដ្ឋធម្មនុញ្ញមួយឡើយ ។ ការស្វែងរកនេះបានក្លាយតាមលំដាប់លំដោយ ទៅជាលទ្ធិគ្រប់គ្រងពិតប្រាកដមួយដែលមានច្បាប់វិន័យផ្សេងៗផ្ទាល់របស់ខ្លួនដោយគ្មានសរសេរជាលាយលក្ខណ៍អក្សរឡើយ ប៉ុន្តែបានចារឹកយ៉ាងជ្រាលជ្រៅក្នុងការប្រព្រឹត្តផ្សេងៗ ។ លទ្ធិអញ្ញនិយម បក្សពួកនិយម និងការស៊ីសំណូក គឺចេញដោយត្រង់មកពីលទ្ធិគ្រប់គ្រងនេះ ។ សព្វថ្ងៃនេះ បើការគាំពារគណបក្សមួយ បនមួយ គ្រួសារមួយ បុគ្គលម្នាក់ មានភាពសំខាន់ជាងការគោរពច្បាប់ គឺវាជាលទ្ធផលច្រើនសតវត្សរ៍មកហើយ ដែលក្នុងរយៈពេលនោះ ប្រព័ន្ធនេះបានចាក់ឫសយ៉ាងជ្រៅក្នុងចិត្តគំនិតរបស់ប្រជាជនកម្ពុជា ដោយឥតមានបណ្តារដ្ឋាភិបាលជាតិទាំងរដ្ឋាភិបាលអាណានិគម រដ្ឋកម្ពុជាដែលក្លាយទៅជារដ្ឋឯករាជ្យ សាកល្បងដាក់ជំនួសប្រព័ន្ធនេះដោយភាពស្មើគ្នារបស់ប្រជាជពលរដ្ឋនៅចំពោះមុខច្បាប់ដែលឲ្យឈ្មោះម៉្យាងទៀតថា "នីតិរដ្ឋ"ផងទេ ។ ទំនាក់ទំនងរវាងចៅកែនិងអតិថិជន បានស្ថិតនៅក្នុងភាពដដែលតាំងពីឆ្នាំ១៩៥៣ ដោយឆ្លងកាត់របបជាច្រើន រួមទាំងរបបខ្មែរក្រហមផង ។ សព្វថ្ងៃនេះ ទំនាក់ទំនងនៅតែមានទម្ងន់យ៉ាងធ្ងន់នៅឡើយ ដែលវាមានភាពជាឧបសគ្គដល់កិច្ចខិតខំផ្សេងៗក្នុងការធ្វើសមាហរណកម្មផ្នែកនយោបាយនិងសង្គមកិច្ច ដែលបង្អាក់ការបង្កើតរដ្ឋទំនើបមួយ និងប្រជាជាតិប្រមូលផ្តុំមួយ ។ នៅប្រទេសកម្ពុជាភាពអចិន្ត្រៃយ៍មួយទៀតដែលគេអាចសង្កេតបានក្នុងការប្រព្រឹត្តិផ្សេងៗផ្នែកសង្គម គឺសេចក្តីរាយការណ៍ទៅរដ្ឋាភិបាលឆ្លើយតបចំពោះអ្វីដែលជាកម្មវត្ថុនយោបាយ ។ នៅពេលនេះ គេជួបប្រទះនៅចំពោះមុខនូវបាតុភូតផ្នែកវប្បធម៌ដ៏សំខាន់មួយ ដែលត្រូវយកចិត្តទុកដាក់ជាចាំបាច់ ដើម្បីស្វែងយល់ពីតថភាពរបស់កម្ពុជាប្រកបដោយការភ័ន្តច្រឡំតិចតួច ។ ប្រទេសកម្ពុជាមានប្រពៃណីដូចបណ្តាប្រទេសកាន់ព្រះពុទ្ធសាសនាថេរវាទឯទៀតនៅក្នុងភូមិភាគអាស៊ី-អាគ្នេយ៍ដែរ ។ សង្គមវប្បធម៌នេះខុសប្លែកពីតម្លៃផ្នែកគតិយុត្តិបស្ចិមប្រទេសដែលមានកំណើតពីច្បាប់របស់រ៉ូម៉ាំងក៏ដូចការគ្រប់គ្រងរដ្ឋាលរបស់ចិនតាមទម្លាប់ជាប្រពៃណីរបស់មន្ត្រីចិនជំនាន់ដើម ។ "ស្រុកខ្មែរ" ត្រូវបានឃើញរាលដាលនូវការចាប់បដិសន្ធិជាមូលដ្ឋាននេះដែលបែកចេញពីព្រះពុទ្ធសាសនា ថេរវាទ ដែលមេដឹកនាំកំពូលគឺព្រះមហាក្សត្រជាបុគ្គលប្រកបដោយយុត្តិធម៌មួយអង្គ ជាអ្នកធ្វើអំពើល្អចំពោះប្រជារាស្ត្ររបស់ព្រះអង្គ និងជាប្រភពនៃច្បាប់សីលធម៌ ។ ព្រះអង្គជាតំណាងភាពសុខដុមរវាងធម្មជាតិនិងមនុស្សជាតិ ។ តាំងពីពេលនោះមកជីវភាពនយោបាយនិងសង្គមបានក្រឡឹងជុំវិញព្រះរាជា ព្រះរាជបរិពារជាន់ខ្ពស់របស់ព្រះអង្គ បណ្តាក្សត្រដែលទាមទាររាជបល្ល័ង្ក និងសង្ឃា (គ្រាសម្រាប់ក្សត្រ ព្រះលញ្ចករ) ដែលផ្តល់ឲ្យព្រះអង្គនូវភាពពេញលក្ខណៈច្បាប់ ។ គឺចាប់ពីចំណុចសំខាន់នេះហើយដែលលេចចេញទម្រង់ខ្សែបណ្តាញបក្ខពួកនិយម ដែលប្រើប្រាស់ចំណងសាច់ញាតិក្នុងកម្រិតផ្សេងៗ ហើយទ្រទ្រង់ដល់ការប្រឆាំងតាមក្រុមតាមពួក និងការប្រយមមុខរវាងពួកអ្នកដែលគិតតែរឿងខ្លួនឯង ។ ផលប្រយោជន៍ដែលមានលក្ខណៈគិតតែខ្លួនឯងខ្លាំងជាងគេ គឺជាក្បួនខ្នាតនៃការសម្តែងចេញជាក់ស្តែងនូវបំណងរបស់បុគ្គល

ម្នាក់ៗឬក្រុមមួយ ។

ទីបញ្ចប់ លក្ខណៈពិសេសទីបីដែលមានជាអចិន្ត្រៃយ៍ សង្គមកម្ពុជាៈ នៅចំពោះមុខគេនឹងមិនជួបសង្គមមួយដែលព្រមព្រៀងគ្នាជាលាយលក្ខណ៍អក្សរទេ ។ កិច្ចព្រមព្រៀងដោយមាត់ទទេកន្លងមកក្នុងទម្រង់ផ្សេងៗដែលធ្លាប់ធ្វើមកហើយ គឺមានលក្ខណៈបន្ទំច្រើនជាងសន្ធតដែលលាតត្រដាងយ៉ាងជាក់លាក់ដោយលាយលក្ខណ៍អក្សរ នូវកិច្ចសន្យាផ្សេងៗរបស់គណបក្សនានា ។ ទម្លាប់ជាប្រពៃណីដែលធ្វើឡើងដោយវាចា និងដែលធ្លាប់ធ្វើរាល់ដងនេះ បានផ្តល់ដល់សញ្ញាណនៃកិច្ចសន្យា នូវតម្លៃមួយខុសពីតម្លៃដែលឆ្លើយតបទៅនឹងគំនិតនៃបទបញ្ញត្តិផ្សេងៗដែលកំពុងអនុវត្តនូវផ្នែកខ្លះៗដែលអាចទាក់ទងចរចាបាន និងអាចកែឲ្យល្អបានដោយការព្រមព្រៀងរួមគ្នាក្នុងសង្គមទាំងឡាយដែលមានកិច្ចសន្យាជាលាយលក្ខណ៍អក្សរ ។ ទម្លាប់ជាប្រពៃណីនេះនឹងមិននាំចេញទៅរកការប្រមូលចងក្រងជាលាយលក្ខណ៍អក្សរ នូវច្បាប់ផ្សេងៗដែលចារឹកក្នុងសម័យកាលប្រកបដោយអំណាចអចិន្ត្រៃយ៍ទេ ។ ទម្លាប់ជាប្រពៃណីនេះក៏មិនជួយឲ្យមានការផុសឡើងនូវសញ្ញាណនៃច្បាប់កិច្ចសន្យាជាលាយលក្ខណ៍អក្សររវាងរដ្ឋនិងពលរដ្ឋដែរ ។

គេនឹងព្រមព្រៀងគ្នាពីអត្ថបទច្បាប់ដែលមានទម្ងន់មួយអាចប្រែប្រួលទាំងស្រុង បើប្រៀបធៀបនឹងការលម្អៀងយ៉ាងធ្ងន់ទាំងនេះ ទោះបីជាត្រឹមត្រូវតាមច្បាប់រដ្ឋធម្មនុញ្ញក៏ដោយ ។

ដូច្នេះ ដោយប្រាប់ឲ្យដឹងពីខ្លឹមសារដោយឡែកតាមប្រភេទពិតប្រាកដនៃការដាក់បញ្ញត្តិត្រឹមត្រូវតាមរដ្ឋធម្មនុញ្ញរបស់កម្ពុជាឥឡូវនេះគេត្រូវតែធ្វើឲ្យដូចគ្នានូវមហិច្ឆតានិងលក្ខណៈពិសេសផ្សេងៗ ការបន្តធ្វើនិងការលុបចោល ដែលបញ្ជាក់ឲ្យឃើញច្បាស់លាស់ក្នុងរដ្ឋធម្មនុញ្ញនីមួយៗក្នុងចំណោមរដ្ឋធម្មនុញ្ញចំនួន៧របស់បណ្តារបបដែលឡើងកាន់អំណាចបន្តបន្ទាប់គ្នា តាំងពីប្រទេសជាតិទទួលបានឯករាជ្យពេញលេញនៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ ។

យើងសូមរំឭកថា រដ្ឋធម្មនុញ្ញដំបូងត្រូវបានផ្តល់ឲ្យនៅឆ្នាំ១៩៤៧ គឺនៅមុនពេលប្រទេសកម្ពុជាទទួលបានឯករាជ្យភាពក្នុងបរិបទដែលកាលណោះកម្ពុជាជារដ្ឋមួយក្នុងជាសហភាពបារាំង ។ រដ្ឋធម្មនុញ្ញនេះបានដៅឲ្យឃើញដំណើរផ្លាស់ប្តូរពីរបបរាជាធិបតេយ្យផ្តាច់ការមួយដែលធ្វើឲ្យដូចគ្នាយ៉ាងច្បាស់ដោយក្រមលេខ៩ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ១៩៤៥ ទៅជារបបរាជាធិបតេយ្យអាស្រ័យរដ្ឋធម្មនុញ្ញមួយ ។ កំណែទម្រង់ផ្សេងៗដែលបំពេញនៅឆ្នាំ១៩៥៦ បានធ្វើឲ្យមានការផ្លាស់ប្តូរថ្មីមួយ ដោយហេតុថា កំណែទម្រង់នេះបានរៀបចំឲ្យមានជាលើកដំបូង នូវប្រព័ន្ធមួយដែលមានក្រុមអ្នកតំណាងជាតិនៅក្នុងក្របខ័ណ្ឌនៃគណបក្សមួយដែលមានតែម្នាក់ឯង ហើយដែលផ្តល់អំណាចសំខាន់ៗឲ្យព្រះប្រមុខរដ្ឋ លុះត្រាតែលែងអាចទទួលស្គាល់ក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៥៦ នូវលក្ខណៈពិសេសទាំងឡាយសម្រាប់របបរាជាធិបតេយ្យអាស្រ័យរដ្ឋធម្មនុញ្ញ ។ របៀបគ្រប់គ្រងប្លែកមួយដែលចោទជាបញ្ហាបានចូលមកជំនួសរបបនេះ ។ រដ្ឋធម្មនុញ្ញឆ្នាំ១៩៧២ បានធ្វើឲ្យការផ្លាស់ប្តូរទាំងឡាយដែលកើតមាននៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ស្ថិតស្ថេរ និងបានបង្ហាញគំរូអាចទទួលយកបាន ហើយបានដាក់ឲ្យពិនិត្យនូវគំរូសាធារណរដ្ឋមួយដែលលទ្ធិផ្តាច់ការយោធារបស់លោកសេនាប្រមុខមិនដែលប្រើវាឲ្យមានរបៀបរៀបរយឡើយ ។ តមកទៀតដោយសារការដួលរលំនៃរបបនេះនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ទើបបណ្តាលឲ្យកើតមានជាលើកដំបូងនូវរបបជាតិនិយមម៉ៅ របស់ពួកខ្មែរក្រហម និងរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៧៦ របស់ខ្លួនដែលបន្តដោយរបៀបគ្រប់គ្រងតាមបែបប្រជាធិបតេយ្យមួយដូចធ្លាប់មានមកហើយ ហៅប្រជាមានិតដែលតំណាងដោយសាធារណរដ្ឋប្រជាមានិតកម្ពុជា (រដ្ឋធម្មនុញ្ញ ឆ្នាំ១៩៨១) បន្ទាប់មកដោយរដ្ឋកម្ពុជា (រដ្ឋធម្មនុញ្ញឆ្នាំ១៩៨៩) ។ នៅទីបំផុតអាស្រ័យដោយកិច្ចព្រមព្រៀងសន្តិភាពដែលចុះហត្ថលេខានៅទីក្រុងប៉ារីសនាថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ និងសេចក្តីសម្រេច (ក្រោយពីពិភាក្សា) របស់សភាធម្មនុញ្ញមួយដែលជ្រើសតាំងនៅខែមិថុនា ឆ្នាំ១៩៩៣ រដ្ឋធម្មនុញ្ញមួយត្រូវបានប្រកាសឲ្យប្រើនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ និងផ្តល់កំណើតនូវអ្វីដែលសម្តេចព្រះ នរោត្តម សីហនុ ឲ្យឈ្មោះថា “ព្រះរាជាណាចក្រកម្ពុជាទី២” ពោលគឺរបបរាជាធិបតេយ្យអាស្រ័យរដ្ឋធម្មនុញ្ញថ្មីមួយ ។

### ក) មហិច្ឆតា និង លក្ខណៈពិសេសទាំងឡាយ

ជាដំបូង ចូរយើងពិនិត្យមើលដោយល្អិតល្អន់នូវលក្ខណៈអ្វីដែលឲ្យសម្គាល់ធំៗ មហិច្ឆតាសំខាន់ៗរបស់រដ្ឋធម្មនុញ្ញនីមួយៗ ក្នុងចំណោមរដ្ឋធម្មនុញ្ញទាំងនោះ ។

#### រដ្ឋធម្មនុញ្ញឆ្នាំ១៩៤៧

រដ្ឋធម្មនុញ្ញឆ្នាំ១៩៤៧ គឺចេញមកពីចេតនាមួយរបស់បារាំង ដើម្បីផ្តល់លក្ខណៈប្រជាធិបតេយ្យដល់ស្ថាប័នផ្សេងៗ ក្នុងក្របខ័ណ្ឌនៃរបៀបគ្រប់គ្រងអាណានិគមមួយដែលធ្វើឲ្យធូរស្រាល និងដែលបង្ហាញពីចំណុចទី១៦ ដល់១៨ នៃបុព្វកថារបស់រដ្ឋធម្មនុញ្ញសាធារណរដ្ឋទីIVរបស់បារាំង ។

*ចំណុចទី១៦ៈ* ប្រទេសបារាំងបានបង្កើតជាមួយនឹងប្រជាជននានានៃប្រទេសឯនាយសមុទ្រ នូវសហភាពមួយផ្អែកលើភាពស្មើមុខគ្នាខាងសិទ្ធិនិងករណីយកិច្ចផ្សេងៗ ដោយគ្មានរើសអើងពូជសាសន៍និងសាសនា ។

*ចំណុចទី១៧ៈ* សហភាពបារាំងរួមមានប្រជាជាតិនិងប្រជាជនទាំងឡាយដែលដាក់រួមគ្នា ឬសម្របសម្រួលនូវប្រភពធនធាននិងការប្រើប្រែងទាំងអស់របស់ខ្លួនដើម្បីពង្រីកអារ្យធម៌របស់ប្រទេសរៀងៗខ្លួន បង្កើនសុខុមាលភាពនិងរក្សាសន្តិសុខរបស់គេ ។

*ចំណុចទី១៨ៈ* ដោយមិនឃ្លាតចាកពីបេសកកម្មជាប្រពៃណីរបស់ខ្លួន ប្រទេសបារាំងមានបំណងដឹកនាំប្រជាជនទាំងឡាយដែលខ្លួនទទួលបន្ទុកទៅរកសេរីភាពក្នុងការគ្រប់គ្រងប្រទេសដោយខ្លួនឯង និងចាត់ចែងកិច្ចការផ្ទាល់ខ្លួនរបស់ពួកគេតាមលទ្ធិប្រជាធិបតេយ្យ ។ ដោយបំបាត់ប្រព័ន្ធគ្រប់គ្រងបែបអាណានិគមទាំងអស់ដែលសំអាងលើអំណាចផ្តាច់ការ ប្រទេសបារាំងធានាដល់ប្រជាជនគ្រប់រូបនូវភាពស្មើគ្នាក្នុងការចូលបំពេញមុខងារសាធារណៈ និងការយកមកប្រើជាបុគ្គលនិងជារួមនូវសិទ្ធិនិងសេរីភាពផ្សេងៗដែលប្រកាសឬដែលបញ្ជាក់ដូចខាងលើ ។

រដ្ឋធម្មនុញ្ញរបស់បារាំងឆ្នាំ១៩៤៦ នឹងបង្កបង្កើតជាប្រភពនៃការយកគំនិតតាមដ៏សំខាន់សម្រាប់ពួកអ្នកបង្កើតគម្រោងច្បាប់រដ្ឋធម្មនុញ្ញខ្មែរ ដែលនឹងត្រូវដាក់ជូនរដ្ឋសភាជាតិពិនិត្យបន្ទាប់ពីការកែប្រែដែលផ្តល់ឲ្យដោយព្រះមហាក្សត្រ ។

តាមពិត រដ្ឋធម្មនុញ្ញនេះដែលត្រូវការដោយព្រះមហាក្សត្រ គឺជាស្នាដៃរបស់រដ្ឋសភាដែលប្រជាជនបោះឆ្នោតជ្រើសតាំងនៅឆ្នាំ១៩៤៦ ។ រដ្ឋធម្មនុញ្ញនេះបានបង្ហាញពីគោលបំណងបង្កើតរបបរាជាធិបតេយ្យអាស្រ័យរដ្ឋធម្មនុញ្ញមួយក្នុងក្របខ័ណ្ឌលទ្ធិប្រជាធិបតេយ្យអាស្រ័យរដ្ឋសភា ។ ម្យ៉ាងទៀត រដ្ឋធម្មនុញ្ញនេះបានបង្ហាញនូវអ្វីដែលខ្ញុំឲ្យឈ្មោះថា "ការផ្តល់លក្ខណៈប្រជាធិបតេយ្យជាលើកដំបូងនៅប្រទេសកម្ពុជា" (សន្និសីទដែលរៀបចំនៅសាកលវិទ្យាល័យ លុវ៉ាំងឡានឺវ ប្រទេសបែលហ្សិក នាខែមិថុនា ឆ្នាំ១៩៩៥ ស្តីពីមូលបទនៃលទ្ធិប្រជាធិបតេយ្យនៅអាស៊ី ។ សកម្មភាពទាំងឡាយនៃសន្និសីទនេះកំពុងរៀបចំការបោះពុម្ពផ្សាយ) ។

គោលសំខាន់ដូចធ្លាប់មានមកហើយនៃរបៀបគ្រប់គ្រងអាស្រ័យសភាមួយគឺ ទ្វិសភានិយម (របៀបនយោបាយនិយមសភាពីរ) "ដែលមិនពេញលេញៈ រដ្ឋសភាជាតិត្រូវបានជ្រើសតាំងដោយការបោះឆ្នោតសកល ដោយមានឧត្តមភាពជាងក្រុមប្រឹក្សាព្រះរាជាណាចក្រ" មានសិទ្ធិចុះហត្ថលេខាអមហត្ថលេខារដ្ឋមន្ត្រី សម្រាប់សារលិខិតទាំងអស់ទាក់ទងនឹងព្រះមហាក្សត្រ ហើយរដ្ឋាភិបាលទទួលខុសត្រូវនៅមុខសភា ។

ក្រោមលេសនៃហត្ថលេខាអមរដ្ឋមន្ត្រី ព្រះមហាក្សត្រដែលមានអំណាចធ្វើមុនគេទៅលើផ្នែកនីតិបញ្ញត្តិ បានតែងតាំងប្រធានក្រុមប្រឹក្សារដ្ឋមន្ត្រី ហើយអាចធ្វើជាអធិបតីនៃក្រុមប្រឹក្សានេះ ។ ព្រះអង្គតែងតាំងចៅក្រម ផ្តល់ឋានន្តរសក្តិដល់អ្នករាជការស៊ីវិលនិងយោធា ចាត់តាំងអគ្គរាជទូត តែងតាំងសមាជិកពីររូបសម្រាប់ក្រុមប្រឹក្សាព្រះរាជាណាចក្រ និងសមាជិក២រូបសម្រាប់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។ គេនឹងប្រទះក្នុងគម្រោងបំព្រួញដូចធ្លាប់មានមកហើយ នៃរបបប្រជាធិបតេយ្យអាស្រ័យរដ្ឋធម្មនុញ្ញមួយ តាមការសម្របសម្រួលដែលធ្វើឡើងជាមួយព្រះមហាក្សត្រ ប្រសិនបើមាត្រា២១មិនប្រកាសថា "អំណាចគ្រប់យ៉ាងមកពីព្រះមហាក្សត្រ ។ អំណាចទាំងនោះត្រូវប្រើទៅតាមបញ្ញត្តិនៃរដ្ឋធម្មនុញ្ញបច្ចុប្បន្ន" ទេនោះ ។ ដោយសំអាងលើអ្វីដែលរដ្ឋធម្មនុញ្ញត្រូវ "ផ្តល់" ដោយព្រះមហាក្សត្រ ។ បទបញ្ញត្តិទាំងនេះបានធ្វើឲ្យសញ្ញាណនៃហត្ថលេខាអម

រដ្ឋមន្ត្រី និងបេក្ខជនមាត្រាទាំងបង្កើតព្រះមហាក្សត្រអាស្រ័យរដ្ឋធម្មនុញ្ញ បាត់បង់នូវលក្ខណៈដាច់ខាតរបស់ខ្លួន "រដ្ឋធម្មនុញ្ញដែលកំណត់ជាគោលការណ៍នូវអំណាចទាំងឡាយរបស់ព្រះមហាក្សត្រ គឺគ្រាន់ជាការផ្តល់ឲ្យគ្មានគេបង្ខំមួយចំពោះព្រះអង្គប៉ុណ្ណោះ" តាមដែលលោក ហួរ សម្គាល់ឃើញពីរឿងនេះ ។ ដោយហេតុថាព្រះអង្គមានបន្ទូលថា អធិបតេយ្យជាតិចេញមកពីប្រជារាស្ត្រ ។ ដូចដែលលោក ហ្វីលីព ប្រេសស្លេ បានសង្កេតឃើញដែរ "ដូច្នេះភាពខុសគ្នាជាសារវន្ត បានចោទឡើងរវាងភាពសំខាន់នៃអំណាចទាំងអស់ដែលទទួលស្គាល់ចំពោះព្រះមហាក្សត្រ និងការប្រើអំណាចទាំងនេះ ដែលតាមពិតអាចប្រគល់ទៅឲ្យបណ្តាស្ថាប័នឬបណ្តាអង្គការអាស្រ័យរដ្ឋធម្មនុញ្ញឯទៀតៗ" ។ ភាពមានន័យមិនច្បាស់លាស់ ដែលបង្កើតដោយជំពូកដំបូងនៃមាត្រា២១ ហើយដែលអះអាងបន្ថែមដោយគោលការណ៍នៃការផ្តល់រដ្ឋធម្មនុញ្ញ នឹងនាំទៅរកវិបត្តិមួយដោយជៀសមិនរួចរវាងសភានិងព្រះមហាក្សត្រ ។

ខ្ញុំមិនសន្និដ្ឋានឲ្យហួសហេតុដោយអះអាងថា រដ្ឋធម្មនុញ្ញឆ្នាំ១៩៤៧ គឺជាពុម្ពនៃលក្ខណៈរដ្ឋធម្មនុញ្ញនិយមរបស់កម្ពុជាឡើយ ។ បើការភាន់ច្រឡំនៃស្ថាប័នផ្សេងៗលេចឡើងឲ្យឃើញក្រោយមកដូចដែលគេនឹងឃើញបន្តិចទៀតនេះ ស្ថាប័នផ្សេងៗមុខជាមានឧត្តមភាពលើការប្រព្រឹត្តិទៅនៃអង្គការនានាមិនខាន ។ ឧទាហរណ៍ដូចក្រុមប្រឹក្សារដ្ឋមន្ត្រីជាដើម ។ រូបមន្តនេះដែលជាលក្ខណៈពិសេសនៃរបៀបគ្រប់គ្រងផ្សេងៗ ដែលក្នុងនោះគេចង់បានថាប្រធានក្រុមប្រឹក្សាគ្រាន់តែជា "អធិបតី" ដូចដែលពួកអង់គ្លេសាក់សុងអះអាង គឺប្រសើរជាងសញ្ញាណ "រដ្ឋាភិបាល" ដែលដឹកនាំដោយ"រដ្ឋមន្ត្រីទីមួយ"ម្នាក់ ដែលការមានអំណាចខ្លាំងពេករបស់បុគ្គលនេះ អាចនឹងបង្កើតជាឧបសគ្គព្រមគ្នាចំពោះប្រមុខរដ្ឋផងនិងរដ្ឋសភាផង ។ ស្ថាប័នមួយទៀតដែលធ្លាប់មានមួយរយៈក្នុងទ្រឹស្តីរដ្ឋធម្មនុញ្ញរបស់កម្ពុជា គឺទ្វិសភានិយម ដូច្នេះវាមានភាពស្រដៀងគ្នាយ៉ាងច្រើនរវាងក្រុមប្រឹក្សាព្រះរាជាណាចក្រឆ្នាំ១៩៤៧ ឆ្នាំ១៩៥៦ និងព្រឹទ្ធសភាឆ្នាំ១៩៧២ ។ ប៉ុន្តែ របៀបនយោបាយនិយមសភាពីរនេះ នឹងពុំបន្តមានអត្ថិភាពឡើយនៅឆ្នាំ១៩៧៥ ទោះបីជាមានបញ្ហាយ៉ាងច្រើនក្នុងការបញ្ចូលជាថ្មីនៅឆ្នាំ១៩៩៣ក៏ដោយ ។

## រដ្ឋធម្មនុញ្ញឆ្នាំ១៩៥៦

ក្រោយពេលដែលគណបក្សប្រជាធិបតេយ្យទទួលជ័យជំនះដោយសំឡេងភាគច្រើនក្នុងការបោះឆ្នោតចំនួនបីលើក វិបត្តិបានផ្ទុះឡើងរវាងសភានិងព្រះមហាក្សត្រ ។ នៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ១៩៤៩ ព្រះអង្គបានរំលាយសភា និងរៀបចំការបោះឆ្នោតមុនពេលកំណត់នៅខែវិច្ឆិកា ។ ព្រះអង្គបានតែងតាំងរដ្ឋាភិបាលមួយដែលទទួលខុសត្រូវចំពោះព្រះភក្ត្រព្រះអង្គតែមួយគត់ ។ បន្ទាប់ពីរយៈពេល២៣ខែនៃការកកស្ទះស្ថាប័នសភា ការបោះឆ្នោតនៅថ្ងៃទី៩ ខែកញ្ញា ឆ្នាំ១៩៥១ បានផ្តល់សំឡេងភាគច្រើនឲ្យគណបក្សប្រជាធិបតេយ្យជាលើកទី៤ ។ នៅថ្ងៃទី១៥ ខែមិថុនា ព្រះមហាក្សត្របានបញ្ឈប់រដ្ឋាភិបាលប្រជាធិបតេយ្យ ហើយដណ្តើមយកអំណាចទៅកាន់ទាំងអស់សម្រាប់រយៈពេល៣ឆ្នាំ ។ នៅថ្ងៃទី១៣ ខែមករា ឆ្នាំ១៩៥៣ ក្រោយពេលដែលរដ្ឋសភាបដិសេធមិនផ្តល់អំណាចពិសេសដែលព្រះអង្គស្នើសុំព្រះមហាក្សត្របានប្រកាសដាក់ប្រទេសជាតិ ក្នុងភាពអាសន្ន ហើយប្រកាសរំលាយសភា ។ រដ្ឋធម្មនុញ្ញត្រូវបានផ្អាកទៅវិញតាមព្រឹត្តិន័យ (តាមដំណើរការដែលមានរួចមកហើយ) ។ បន្ទាប់មក ព្រះមហាក្សត្របានចាប់ផ្តើម "ព្រះរាជបូជនីយកិច្ច" របស់ព្រះអង្គ ដើម្បីទាមទារឯករាជ្យ ជាឯករាជ្យដែលព្រះអង្គបានទទួលនៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ ដោយជៀសវាងសង្គ្រាមនិងការបែងចែកទឹកដី ។ នៅថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ១៩៥៥ ព្រះអង្គបានដាក់ជូនរាស្ត្រពិនិត្យអំពីសកម្មភាពដឹកនាំរបស់ព្រះអង្គតាំងពីឆ្នាំ១៩៥២មក ក្នុងការបោះប្រជាមតិមួយដែលព្រះអង្គបានទទួលសំឡេងគាំទ្រ៩៩,៨ ភាគរយ ។ នៅថ្ងៃទី១៩ ខែកុម្ភៈ ព្រះអង្គបានបង្ហាញនូវផែនការកែទម្រង់រដ្ឋធម្មនុញ្ញដ៏ធំទូលាយមួយដែលត្រូវបានច្រានចោលដោយគណបក្សប្រជាធិបតេយ្យ ។ នៅថ្ងៃទី៣ ខែមីនា ព្រះមហាក្សត្របានដាក់រាជ្យ ហើយ២៣ថ្ងៃក្រោយមក បានបង្កើតគណបក្ស "សង្គមរាស្ត្រនិយម" ជាសហគមន៍សង្គមរាស្ត្រនិយមដែលបង្ហាញខ្លួនឡើងជា "ការប្រមូលផ្តុំប្រជារាស្ត្រដ៏ទូលំទូលាយមួយ ផ្អែកលើស្មារតីភក្តីចំពោះមេដឹកនាំជាតិជាបុត្រព្រះមហាក្សត្រ និងជាអតីតព្រះ

មហាក្សត្រផ្ទាល់» ។ គណបក្សសង្គម បានទទួលអាសនៈនៅក្នុងរដ្ឋសភាទាំងអស់ក្នុងឱកាសបោះឆ្នោត នៅថ្ងៃទី១១ ខែកញ្ញា ។ នៅថ្ងៃទី១៤ ខែមករា ឆ្នាំ១៩៥៦ រដ្ឋសភាបានប្រកាសឲ្យប្រើនូវកំណែទម្រង់រដ្ឋធម្មនុញ្ញដ៏មានសារៈសំខាន់បំផុតមួយ ដែលគេអាចនិយាយថាជារដ្ឋធម្មនុញ្ញថ្មីមួយ ។

រដ្ឋធម្មនុញ្ញនេះរួមមាន១២២មាត្រា បែកជា១២ជំពូក ។ សេចក្តីស្រង់នូវកំណែទម្រង់ផ្សេងៗ បានបង្ហាញឲ្យឃើញអំពីទំហំនៃការផ្លាស់ប្តូរដែលមានលទ្ធផលដូចខាងក្រោម÷

១) ការធ្វើឲ្យចុះសម្រុងនូវភាពទាំងមូលនៃច្បាប់រដ្ឋធម្មនុញ្ញចំពោះតថភាពថ្មី ដែលចាប់ផ្តើមមានបន្ទាប់ពីប្រទេសទទួលបានឯករាជ្យ ។

២) ការកំណត់ឲ្យស្ត្រីមានសិទ្ធិបោះឆ្នោត ។

៣) ការបង្កើតសភានានា ដែលជ្រើសតាំងតាមការបោះឆ្នោតសកលក្នុងខេត្តនីមួយៗរួមទាំងរាជធានីផង ។

៤) ការបង្កើតតួនាទីនីតិបញ្ញត្តិដល់ក្រុមប្រឹក្សាព្រះរាជាណាចក្រ ។

ក្រោយមក ការកែទម្រង់ផ្សេងៗទៀត បានកើតមានដែលនឹងបញ្ចប់ការផ្លាស់ទ្រង់ទ្រាយនៃគ្រឹះរដ្ឋធម្មនុញ្ញឆ្នាំ១៩៤៧ ។

១) ការធ្វើឲ្យ "សមាជជាតិ" មានលក្ខណៈជាច្បាប់រដ្ឋធម្មនុញ្ញដែលបង្ហាញឲ្យឃើញគោលសំខាន់មួយនៃលទ្ធិប្រជាធិបតេយ្យដោយផ្ទាល់(១៩៥៨) ។

២) ការបង្កើតស្ថាប័នប្រមុខរដ្ឋ(១៩៦០) ។

៣) ការបង្កើតតុលាការប្រជារាស្ត្រមួយ (១៩៦៤) ។

ប្រសិនបើកំណែទម្រង់ផ្សេងៗដែលបំពេញច្បាប់រដ្ឋធម្មនុញ្ញឆ្នាំ១៩៤៧ ជួយធ្វើឲ្យបានសម្រេចពិតប្រាកដនូវស្នាដៃមួយក្នុងចំណោមស្នាដៃសំខាន់ៗរបស់គណបក្សសង្គម ដូចជាការចូលរួមផ្ទាល់របស់ប្រជាជនក្នុងជីវភាពនយោបាយនោះ ក៏គ្មានសេចក្តីសម្រេចណាមួយកំណត់ពីបញ្ហាអធិបតេយ្យដែរ ។

តើលក្ខណៈរបស់របបថ្មីយ៉ាងដូចម្តេច? វាពិបាកបញ្ចូលលក្ខណៈរបស់របបនេះទៅក្នុងប្រភេទមួយ ក្នុងចំណោមប្រភេទដូចធ្លាប់មានមកហើយនៃបណ្តារបបអាស្រ័យរដ្ឋសភាណាស់ ។ ដូច្នេះគេនឹងប្រុងប្រយ័ត្នជាងមុនដោយសម្គាល់ឃើញថា នេះជារបបប្លែកមួយដែលដៅឲ្យឃើញយ៉ាងខ្លាំងដោយបុគ្គលភាពរបស់សម្តេចព្រះ នរោត្តម សីហនុ និងដោយការសន្ទនាផ្ទាល់ដែលព្រះអង្គមានព្រះរាជបំណងសំណេះសំណាលជាមួយប្រជាពលរដ្ឋដែលប្រមូលផ្តុំ ទោះស្ម័គ្រក្តីមិនស្ម័គ្រក្តី ក្នុងចលនាមួយដែលដើរតាមគណបក្សមានតែមួយ ទោះបីជាព្រះអង្គមានព្រះបន្ទូលការពារខ្លួនក៏ដោយ ។ គឺពុំមែនជាចៃដន្យមួយទេ ប្រសិនបើលក្ខន្តិកៈទាំងឡាយរបស់គណបក្សសង្គម ចុះកាលបរិច្ឆេទថ្ងៃទី២២ ខែមីនា ឆ្នាំ១៩៥៥ មានតម្លៃមួយស្មើរតែត្រឹមត្រូវតាមរដ្ឋធម្មនុញ្ញនោះ ។

ដោយសម្របតាមការកែប្រែទាំងឡាយដែលមានជាបន្តបន្ទាប់តាំងពីឆ្នាំ១៩៥៦ លទ្ធិប្រជាធិតេយ្យអាស្រ័យសភាបានស្ថិតនៅគង់វង្ស ។ លទ្ធិប្រជាធិបតេយ្យនេះត្រូវបានជំនួសដោយការផ្សុំគ្នានូវអំណាចដ៏ខ្លាំងមួយនៃជនម្នាក់ៗ ជាមួយរូបមន្តដើម (ដែលមានមុនគេបង្អស់) នៃលទ្ធិប្រជាធិបតេយ្យពាក់កណ្តាលផ្ទាល់មួយ ។ គឺប្រព័ន្ធនេះហើយដែលនឹងដាក់ឲ្យដដែកឡើងវិញនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ។

ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ១៩៦០ ក្រមមួយបានបន្ថែមទៅក្នុងមាត្រា១២២ នៃច្បាប់រដ្ឋធម្មនុញ្ញ ។ មាត្រានេះបានប្រកាសឲ្យប្រើបន្ទាប់ពីការសោយទិវង្គតរបស់ព្រះមហាក្សត្រ សុរាម្រិត ដែលឡើងគ្រងរាជបល្ល័ង្ក តាមរយៈការដាក់រាជ្យរបស់ព្រះអង្គសម្តេចព្រះ នរោត្តម សីហនុ នៅឆ្នាំ១៩៥៥ ។ មាត្រានេះអនុញ្ញាតឲ្យសភាទាំងពីររួមប្រជុំគ្នា "ដើម្បីប្រគល់អំណាចនិងបុព្វសិទ្ធិទាំងឡាយរបស់ប្រមុខរដ្ឋដល់ឥស្សរជនមួយរូបដែលគ្មាននរណាជំទាស់" ។ ប្រាកដណាស់ គឺដោយសំអាងលើមាត្រានេះហើយ ដែលពួកអ្នកនាំអាទិ៍ក្នុងការទម្លាក់សម្តេចព្រះនរោត្តម សីហនុ ពីតំណែងនិងដែលជាអ្នកទទួលផលប្រយោជន៍តែមួយគត់ពីច្បាប់នេះខំប្រឹងអះអាងពីមូលដ្ឋានត្រឹមត្រូវតាមច្បាប់មួយចំពោះសកម្មភាពរបស់គេ ។

## រដ្ឋធម្មនុញ្ញឆ្នាំ១៩៧២

សម្តេចព្រះ នរោត្តម សីហនុ ត្រូវបានទម្លាក់ពីតំណែងនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ក្នុងឋានៈជាព្រះប្រមុខរដ្ឋ ។ សាធារណរដ្ឋត្រូវបានប្រកាសបង្កើតនៅថ្ងៃទី៩ ខែតុលា ។

បន្ទោះថ្ងៃទី១១ ខែមេសា និងទី៩ ខែតុលា ឈ្មោះផ្លូវការរបស់ប្រទេសគឺ“រដ្ឋកម្ពុជា” ។ (ពីឆ្នាំ១៩៨៩ ដល់១៩៩៣ ប្រទេសកម្ពុជាបានដាក់ឈ្មោះនេះជាថ្មី) ។

រដ្ឋធម្មនុញ្ញឆ្នាំ១៩៧២ បានកំណត់នូវរបត់ដ៏សំខាន់មួយក្នុងប្រវត្តិសាស្ត្រនៃរដ្ឋធម្មនុញ្ញរបស់កម្ពុជា ។ រដ្ឋធម្មនុញ្ញនេះបានបញ្ចប់ជាបណ្តោះអាសន្ន ប៉ុន្តែនៅជំនាន់នោះគេមិនទាន់ដឹងនៅឡើយពីរបបរាជាធិបតេយ្យមួយដែលមានឡើងតាំងពីឆ្នាំ១១៦៨ ហើយបានបើកឡើងនូវសម័យកាលសាធារណរដ្ឋមួយសម្រាប់រយៈពេល២១ឆ្នាំ ។ រដ្ឋធម្មនុញ្ញនេះនិងរដ្ឋធម្មនុញ្ញទាំងបីដែលនឹងបន្តពីវា បានប្តូរផ្លាស់ទាំងស្រុងនូវរដ្ឋធម្មនុញ្ញឆ្នាំ១៩៥៦ ហើយតាមការមើលឃើញជាក់ប្រាកដមួយ វាមានតួនាទីត្រឹមត្រូវមួយ បើប្រៀបធៀបនឹងរដ្ឋធម្មនុញ្ញនោះក៏ដូចអត្ថបទរដ្ឋធម្មនុញ្ញដែលមានថ្មីៗមុននេះ ។

ជាមួយការគោរពចំពោះពួកអ្នកច្បាប់របស់កម្ពុជា ដែលបានតាក់តែងច្បាប់រដ្ឋធម្មនុញ្ញនេះ គេត្រូវទទួលស្គាល់ថារដ្ឋធម្មនុញ្ញបានបង្កើតឲ្យមាន“កូនឥតខាន់ស្លា”មួយ ។ គឺក៏ពុំមែនរៀបចំឡើងវិញតាមគំរូរដ្ឋធម្មនុញ្ញរបស់បារាំងឬអាមេរិកាំងទេ ។ វាជាការសាកល្បងទាញយកអ្វីដែលប្រសើរជាងគេ តាមគំរូសភានិយមរបស់បារាំងផងនិងគំរូប្រធានាធិបតីនិយមរបស់អាមេរិកាំងផង ។ នេះជាការសាកល្បងដោយខ្លួនឯងច្រើនគួរសម ប៉ុន្តែជាការសាកល្បងដែលបំបែកបំបាក់រវាងចេតនាទប់ការរំលោភអំណាចនៃរបបដែលមានពីមុន និងកង្វល់ផ្ទះបញ្ចាំងឲ្យឃើញដោយសមរម្យនូវសមតាថ្មីៗ ដែលលេចឡើងក្នុងសង្គមរបស់កម្ពុជានាចុងទសវត្សរ៍ឆ្នាំ១៩៦០ ។ តាមការពិត នេះជាការសាកល្បងដែលបង្ហាញឲ្យឃើញយ៉ាងទូលំទូលាយតាមរយៈការប្រឆាំងរវាងពួកអ្នកមានគំនិតសាធារណរដ្ឋនិយមនិងពួកអ្នកនយោបាយដែលពុំមានបំណងផ្លាស់ប្តូរទម្លាប់កាន់កាប់អំណាចរបស់ពួកគេ បន្ទាប់ពី លន់ ណល់ ឡើងកាន់អំណាចជំនួសសម្តេច សីហនុ ។

បន្ទាប់ពីការទម្លាក់សម្តេចព្រះ នរោត្តម សីហនុ ពីអំណាចនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ សេចក្តីសម្រេចចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ១៩៩៣ របស់សភាធម្មនុញ្ញបានប្រកាសថា នោះជារដ្ឋប្រហារមួយ-សាធារណរដ្ឋត្រូវបានប្រកាសបង្កើតនៅថ្ងៃទី៩ ខែតុលា ។ ប្រទេសជាតិត្រូវបានលិចលង់ទៅក្នុងសង្គ្រាមទាំងស្រុង ហើយមួយផ្នែកយ៉ាងធំនៃទឹកដីរបស់ប្រទេសបានរបូតផុតពីការត្រួតត្រារបស់រដ្ឋាភិបាលយ៉ាងឆាប់រហ័ស ។ គណៈកម្មការមួយដែលទទួលបន្ទុកតាក់តែងរដ្ឋធម្មនុញ្ញថ្មីមួយត្រូវបានរៀបចំបង្កើតនៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ១៩៧១ ។ គណៈកម្មការនេះត្រូវបានរំសាយដោយ លន់ ណុល នៅខែតុលា ហើយនៅពេលនោះគឺរដ្ឋសភាជាតិជាអ្នកតាក់តែងសេចក្តីព្រាងរដ្ឋធម្មនុញ្ញមួយដែល លន់ ណុល មិនត្រូវចិត្តទៀត ។ គណៈកម្មាធិការថ្មីមួយបានពិនិត្យសេចក្តីព្រាងខុសៗគ្នាជាច្រើន ហើយបានសម្រេចការសម្របសម្រួលមួយជាមួយ លន់ ណុល នៅថ្ងៃទី៥ ខែមេសា ឆ្នាំ១៩៧២ ។ រដ្ឋធម្មនុញ្ញត្រូវបានដាក់ឲ្យប្រជាពលរដ្ឋធ្វើប្រជាមតិ ទុកណាជារដ្ឋាភិបាលគ្រប់គ្រងទឹកដីតែមួយភាគបួនក៏ដោយ ។ រដ្ឋធម្មនុញ្ញត្រូវបានយល់ព្រមដោយសំឡេង៩៧,៥ភាគរយនៃចំនួនអ្នកបោះឆ្នោត ១,៥៦លាននាក់ ដែលតំណាងប្រហាក់ប្រហែល៤៥ភាគរយនៃចំនួនប្រជាជនមានអាយុបោះឆ្នោតសរុប ។

ច្បាប់រដ្ឋធម្មនុញ្ញនេះមានបុព្វកថាមួយ មាត្រាអវសានមួយនិង១២១មាត្រាដោយចែកជា១១ជំពូក ។ តាមការពិត ឯកសារនេះពុំបានប្រើឲ្យមានរបៀបរៀបរយឡើយ ។ ដូច្នេះរដ្ឋធម្មនុញ្ញដែលប្រកាសឲ្យប្រើនៅថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៧២ គឺត្រូវផ្អាកយ៉ាងហោចជិតមួយឆ្នាំក្រោយមកទៀត ទើបចូលជាធរមាននៅថ្ងៃទី២៣ ខែមេសា ឆ្នាំ១៩៧៣ ។ ដូច្នេះយើងនឹងធ្វើការពិនិត្យមើលត្រួសៗនូវច្បាប់រដ្ឋធម្មនុញ្ញនេះ ។

រដ្ឋធម្មនុញ្ញបានដាក់ជំនួសអំណាចព្រះមហាក្សត្រដែលតពីឪពុកមកកូន ដោយអំណាចមកពីប្រជាជនវិញ ដែលធានាដោយការជ្រើសរើសប្រធានាធិបតីនិងសមាជិកសភាតាមរយៈការបោះឆ្នោតសកល ។

រដ្ឋធម្មនុញ្ញបានអនុញ្ញាតឲ្យមានរបបប្រធានាធិបតីនិយមមួយៈ ប្រធានាធិបតីគឺត្រូវជ្រើសតាំងដោយការបោះឆ្នោតសកល ហើយរដ្ឋាភិបាលដែលតែងតាំងដោយប្រធានាធិបតីគឺទទួលខុសត្រូវតែចំពោះមុខប្រធានាធិបតីប៉ុណ្ណោះ ។ ដោយ

ហេតុនេះ អំណាចផ្សេងៗរបស់នាយករដ្ឋមន្ត្រីជាអំណាចដែលមានកំណត់ ។

ប្រធានាធិបតីជាអ្នកតែងតាំងឯកអគ្គរដ្ឋទូតទាំងឡាយ សមាជិកក្រុមប្រឹក្សារដ្ឋ អភិបាលខេត្ត ឧត្តមសេនានី សាកលវិទ្យាធិការ នាយករដ្ឋការកណ្តាល និងសមាជិកនៃក្រុមប្រឹក្សាសេន្យានុភាព ។ ប្រធានាធិបតីជាមេបញ្ជាការជាន់ខ្ពស់បំផុតនៃកម្លាំងទ័ពរបស់សាធារណរដ្ឋ ។

សភាមានពីរគឺ ព្រឹទ្ធសភា និង សភាជាតិ ។ សហសភានេះមានអំណាចសម្តែងនូវការមិនទុកចិត្តរបស់ខ្លួនចំពោះសមាជិកម្នាក់ឬច្រើននាក់របស់រដ្ឋាភិបាល ។ ទ្វិសភានិយមនេះបានកំណត់ឲ្យរដ្ឋសភាជាតិមានអំណាចខ្ពស់ជាង ។

លក្ខណៈថ្មីដ៏ធំនៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៧២ គឺការបង្កើតអំណាចតុលាការមួយដែលឯករាជ្យយ៉ាងគួរឲ្យកត់សម្គាល់ ។ ជាការបង្កើតដោយគ្មានគិតពីថ្ងៃបន្ទាប់ វាបង្ហាញឲ្យឃើញនូវបំណងធ្វើឲ្យមានលក្ខណៈប្លែកមួយពីរបៀបគ្រប់គ្រងដែលមានពីមុនមក ។ លក្ខន្តិកៈរបស់ពួកអ្នកកាន់អំណាចតុលាការ(ចៅក្រម) សមាសភាពនៃតុលាការកំពូល និងឧត្តមក្រុមប្រឹក្សា តុលាការ លក្ខខណ្ឌផ្សេងៗនៃការចាត់តាំងសមាជិកទាំងឡាយរបស់អង្គការទាំងពីរនេះ បានផ្តល់ឲ្យអំណាចតុលាការនូវឋានៈឯករាជ្យដែលគេបានឃើញជាថ្មីនៅក្នុងច្បាប់រដ្ឋធម្មនុញ្ញដែលយល់ព្រមនៅឆ្នាំ១៩៩៣ ។ គួរកត់សម្គាល់ផងដែរពីឥទ្ធិពលរបស់ពួកអ្នកកាន់អំណាចជំនាន់នោះ អនុក្រឹត្យទាំងអស់សម្រាប់អនុវត្តនូវរាល់បទបញ្ញត្តិត្រឹមត្រូវតាមច្បាប់រដ្ឋធម្មនុញ្ញ ទាក់ទងទៅនឹងអំណាចតុលាការ ត្រូវបានយកជាការក្នុងរយៈពេល៥ខែ ដែលមានបន្តពីការប្រកាសឲ្យប្រើច្បាប់រដ្ឋធម្មនុញ្ញ ។

ស្ថាប័នថ្មីៗដែលធ្វើការអ្វីតែមួយមុខត្រូវបានបង្កើតឡើងដើម្បីនឹងពង្រីកការបែងចែកអំណាច និង ធ្វើឲ្យអាចអនុវត្តបាននូវបណ្តាច្បាប់គ្រឹះដែលទទួលស្គាល់ដោយប្រជាពលរដ្ឋ គឺតុលាការធម្មនុញ្ញ តុលាការជាន់ខ្ពស់ ក្រុមប្រឹក្សារដ្ឋ ក្រុមប្រឹក្សាសេន្យានុភាព ក្រុមប្រឹក្សាជាតិខាងការអប់រំនិងខាងវប្បធម៌ និងក្រុមប្រឹក្សាសេដ្ឋកិច្ចនិងសង្គមកិច្ច ។

បទបញ្ញត្តិខ្វះៗនៃរដ្ឋធម្មនុញ្ញនេះនឹងត្រូវប្រើប្រាស់សម្រាប់ការបោះឆ្នោតជ្រើសរើសប្រធានាធិបតី រដ្ឋសភាជាតិ និងព្រឹទ្ធសភា ។

ដំណើរមានគគ្រាហូរហៃនៃព្រឹត្តិការណ៍សំខាន់ៗ ផ្នែកយោធាពុំអនុញ្ញាតឲ្យរដ្ឋធម្មនុញ្ញនេះទទួលការសាកល្បងអ្វីពីហេតុការណ៍ផ្សេងៗទេ ។ ការសម្តែងឆន្ទៈរបស់ក្រុមវរជនមួយដែលទាក់ទងនឹងបញ្ហានិងសង្គម ដែលមានភាគតិចបំផុតនៅឡើយក្នុងប្រទេស យល់ថា រដ្ឋធម្មនុញ្ញឆ្នាំ១៩៧២ ហាក់ដូចជាធ្វើមុនពេលវេលារបស់ខ្លួន ។ ដោយហេតុនេះ វាសម្តែងឲ្យឃើញនូវមហិច្ឆតាមួយដែលអាចចុះសម្រុងតិចតួចជាមួយនឹងសមត្ថភាពនិងឆន្ទៈរបស់ប្រជាជនភាគច្រើនបំផុតដែលទទួលស្គាល់នូវកាតព្វកិច្ចផ្សេងៗនៃនីតិរដ្ឋមួយ ។ តាមរបៀបដ៏ជាក់លាក់មួយ រដ្ឋធម្មនុញ្ញនេះបានអះអាងបន្ថែមនូវការបន្ថយសកម្មភាពរបស់ខ្លួនបន្ទាប់ពីការប្រកាសឲ្យប្រើចំនួន១១ខែ ។

**រដ្ឋធម្មនុញ្ញឆ្នាំ១៩៧៦**

ពីរបីសប្តាហ៍បន្ទាប់ពីការដណ្តើមកាន់កាប់ទីក្រុងភ្នំពេញ ប្រភេទមហាសន្និបាតជាតិមួយ បានធ្វើឡើងនៅក្នុងអតីតមណ្ឌលកីឡាមួយ ពីថ្ងៃទី២៥ ដល់ថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៧៥ ដែលមានកម្មាភិបាលនៃរបបថ្មីជាច្រើនរយនាក់ចូលរួម ។ នៅក្នុងឱកាសនោះ គណៈកម្មាធិការរដ្ឋធម្មនុញ្ញមួយត្រូវបានបង្កើតឡើង ដើម្បីតាក់តែងសេចក្តីព្រាងរដ្ឋធម្មនុញ្ញ ។ បន្ទាប់មកសេចក្តីព្រាងនេះត្រូវបានយល់ព្រមដោយក្រុមប្រឹក្សារដ្ឋមន្ត្រី ហើយបន្ទាប់មកទៀត ដោយការប្រជុំមួយដែលមានកម្មាភិបាល ៧០០នាក់ចូលរួមក្នុងរយៈពេល៦សប្តាហ៍នៅស្តាតអូឡាំពិក នាខែវិច្ឆិកា-ធ្នូ ឆ្នាំ១៩៧៥ ។ រដ្ឋធម្មនុញ្ញត្រូវបានប្រកាសឲ្យប្រើនៅថ្ងៃទី៥ ខែមករា ឆ្នាំ១៩៧៦ និងណែនាំឲ្យដឹងតាមវិទ្យុដោយ ហ៊ូ នឹម ជារដ្ឋមន្ត្រីព័ត៌មាននិងឃោសនាការ ។ នៅថ្ងៃបន្ទាប់ បទអត្ថាធិប្បាយមួយរបស់ ខៀវ សំផន ត្រូវបានផ្សព្វផ្សាយតាមវិទ្យុដែរ ។ ទោះជាយ៉ាងណាក៏ដោយ នេះជាបុព្វហេតុដ៏វិការរបស់រដ្ឋធម្មនុញ្ញនេះ ដែលបង្ហាញដោយ ខៀវ សំផន ថា “ជាផ្លូវដែលត្រួសត្រាយដោយឈាមស្រស់របស់បណ្តាកម្មករ កសិករ កងទ័ពបដិវត្តន៍ និងប្រជាជនកម្ពុជា” ។

យើងសូមចាប់ផ្តើមដោយពិនិត្យមើលអ្វីដែលពុំឃើញមាន

នៅក្នុងច្បាប់រដ្ឋធម្មនុញ្ញ ។ វាគួរឲ្យឆ្ងល់ដែរដែលប្រការនេះអាចមាន ព្រោះគេមិនប្រទះឃើញទាល់តែសោះនៅក្នុងរដ្ឋធម្មនុញ្ញនេះ នូវពាក្យ“ខ្មែរ” “សង្គមនិយម” “កុម្មុយនិស្តនិយម” “ម៉ាក្សនិយម” “បក្ស” ។ សម្រាប់អ្វីដែលទាក់ទងនឹងការគ្មានពាក្យ “ខ្មែរ” ដែលរឹតតែឲ្យឆ្ងល់ជាងមូលបទនៃ “ពូជសាសន៍ខ្មែរ” នឹងលេចឡើងកាន់តែច្រើនឡើងៗ នៅក្នុងសុន្ទរកថានិងសៀវភៅទាំងឡាយរបស់ពួកខ្មែរក្រហម ។ អតីតកម្មាភិបាលនៃបក្សនេះបាននិយាយប្រាប់ខ្ញុំថា នៅពេលដំបូងនៃសម័យកម្ពុជាប្រជាធិបតេយ្យ ការប្រើប្រាស់ពាក្យក្នុងបំណងជាតិនិយមជ្រុលហួសហេតុដោយរបប លន់ ណុល នៅតែមានក្នុងចិត្តគំនិតប្រជាជនទាំងអស់ ។ គេមិនត្រូវការរង់ចាំយូរដើម្បីនឹងឲ្យការស្អប់ខ្ពើមនេះរលាយបាត់ទេ ។ ចំពោះការគ្មានឃើញពាក្យផ្សេងៗទៀត លោក ដេវីដ ឆេនដល័រ បានបកស្រាយថា គឺដោយបំណងបង្កើតប្រភេទមនោគមវិជ្ជាមួយដែលប្លែកខុសគ្នារវាងកម្ពុជាប្រជាធិបតេយ្យនិងពួកអ្នកបដិវត្តន៍ជិតខាងដែលនិយមតាមក្បួនទ្រឹស្តីជាង ។ ការបកស្រាយនេះពុំផ្ទុយគ្នានឹងការបកស្រាយរបស់ខ្ញុំទេៈ កន្លល់បិទបាំងអត្តសញ្ញាណពិតប្រាកដនៃកម្លាំងនយោបាយដែលលាក់ខ្លួនពីក្រោយអ្វីដែលគេធ្លាប់ស្គាល់ក្រោយឈ្មោះអង្គការ ។ គេដឹងថា គេត្រូវតែរង់ចាំរហូតដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៧៧ មុននឹង ប៉ុល ពត និយាយឲ្យដឹងថា អង្គការគ្មានអ្វីផ្សេងក្រៅពីបក្សកុម្មុយនិស្តឡើយ ។

រដ្ឋធម្មនុញ្ញនេះមានបុព្វកថាមួយ និង២១មាត្រា ដោយចែកជា១៦ជំពូក ។

បុព្វកថាបានរំឭកពីតួនាទីដ៏សំខាន់ដែលសម្តែងក្នុងជ័យជម្នះដោយកម្មករ កសិករក្រ កសិករកណ្តាល ថ្នាក់ក្រោម និងស្រទាប់ពលករផ្សេងទៀតនៅជនបទនិងទីក្រុង ដែលមានចំនួនជាង៩៥ភាគរយនៃប្រជាជាតិកម្ពុជាទាំងមូល “រួមទាំងកងទ័ពបដិវត្តកម្ពុជាទាំងបីប្រភេទផង” ។ ពួកអ្នកបង្កើតជ័យជម្នះទាំងនេះចង់បានសង្គមមួយដែល “គ្មានអ្នកមាន គ្មានអ្នកក្រ គ្មានវណ្ណៈជិះជាន់គេ គ្មានវណ្ណៈត្រូវគេជិះជាន់” ។ ការបញ្ជាក់អត្តសញ្ញាណរបស់ពួកអ្នកបង្កើតជ័យជម្នះបានបង្ហាញឲ្យឃើញការប្រាប់ឲ្យដឹងមួយ អំពីការបដិសេធមិនចាត់ទុកអង្គការសង្គមទាំងអស់ជាប្រជាជាតិទាំងមូល ។ ក្នុងពេលដំបូង ប្រជាជនមួយផ្នែកគ្មានដឹងពីការប្រកាសប្រើរដ្ឋធម្មនុញ្ញនេះទេ ។ គ្មានសេចក្តីបញ្ជាក់ណាមួយត្រូវបានធ្វើឡើងចំពោះបណ្តាក្រុមសង្គមជាប្រពៃណីទេៈ គ្រួសារ សហគមន៍ សាសនានានា បណ្តាជនជាតិភាគតិច ។ ទស្សនៈសមភាពនៃរដ្ឋាភិបាលថ្មីក៏ត្រូវបានប្រកាសតាំងតែពីដំបូងដែរ ។

ជំពូក១ មាត្រា១ បានបង្ហាញឈ្មោះរដ្ឋថ្មី និងបញ្ជាក់ជាពិសេសថា គឺកម្មករ-កសិករ និងពលករកម្ពុជាផ្សេងទៀតទាំងអស់សុទ្ធតែម្ចាស់កម្មសិទ្ធិរដ្ឋនេះ ។

ជំពូក២ មាត្រា២ បានចែងក្នុងកថាខណ្ឌដំបូងថា មធ្យោបាយផលិតកម្មទាំងអស់ជាកម្មសិទ្ធិរបស់ប្រជាជនសមូហភាព ។ កថាខណ្ឌទីពីរបញ្ជាក់ថា របស់ប្រើប្រាស់ប្រចាំថ្ងៃស្ថិតនៅជាកម្មសិទ្ធិផ្ទាល់របស់ឯកជន ។

លោក ដេវីដ ឆេនដល័រ បានសង្កេតឃើញនូវភាពខុសគ្នាយ៉ាងខ្លាំងផ្នែកស័ព្ទន័យរវាងពាក្យទាំងឡាយដែលគូសបញ្ជាក់ក្នុងជំពូកនិងមាត្រាទាំងពីរដំបូង ដើម្បីប្រាប់ឲ្យដឹងពីពាក្យ “មាន” ។ ពាក្យពេចន៍ខ្មែរដែលប្រើប្រាស់ គឺមានលក្ខណៈខ្លាំងជាងសម្រាប់ចង្អុលបង្ហាញនៅមាត្រា២ កថាខណ្ឌទី១ ។ រដ្ឋជាម្ចាស់កម្មសិទ្ធិគឺដើម្បីសម្គាល់ថា កម្មករ-កសិករ និងពលករផ្សេងទៀតទាំងអស់ជាម្ចាស់របស់រដ្ឋ (មាត្រា១) និងសម្រាប់សម្គាល់កម្មសិទ្ធិរបស់ប្រជាជនម្នាក់ៗ (មាត្រា២ កថាខណ្ឌទី២) ។

គ្មានអត្ថន័យណាមួយបញ្ជាក់ពីអ្វីដែលគេចង់និយាយថា “របស់របរប្រើប្រាស់ប្រចាំថ្ងៃ”ឡើយ ។ គេអាចត្រឹមតែវាយតម្លៃថាវាពុំមែនជាមធ្យោបាយផលិតកម្មប៉ុណ្ណោះ ។ ចុះចំណែករបស់ទ្រព្យដូចជា ទីលំនៅ ច្បារបន្លែ ចម្ការ ដើមឈើហូបផ្លែ វត្ថុអនុស្សាវរីយ៍ផ្សេងៗ (របស់គ្រួសារ) ដែលពុំមែនជារបស់របរប្រើប្រាស់ប្រចាំថ្ងៃ និងពុំមែនជាមធ្យោបាយផលិតកម្ម តើត្រូវគិតយ៉ាងណាវិញ? ។ រដ្ឋធម្មនុញ្ញពុំទទួលស្គាល់អត្ថិភាពរបស់វាទេ ។

ជំពូក៣ មាត្រា៣ និយាយអំពីរបបវប្បធម៌ ដែលត្រូវតែមានលក្ខណៈ “ជាតិ ប្រជាជន និងចម្រើនស្អាតស្អំ” ដោយប្រឆាំងដាច់ខាតនឹង “វប្បធម៌ពុករលួយប្រតិកិរិយារបស់វណ្ណៈជិះជាន់

ផ្សេងៗ និងរបស់អាណានិគមនិយមចក្រពត្តិនិយមនៅកម្ពុជា” ។

ការប្រឆាំងនេះរួមបញ្ចូលទាំងការបដិសេធមិនឲ្យមានភាសាបរទេសទាំងអស់ គឺបារាំងនិងអង់គ្លេស ប៉ុន្តែ ក៏បដិសេធទស្សនៈផ្សេងៗដែលជួយនឹងបដិវត្តន៍ដែរ ដូចជា កម្មសិទ្ធិសួនតួសិទ្ធិឯកត្តជន សេចក្តីថ្លៃថ្នូរផ្ទាល់ខ្លួន...។

ជំពូក៤ មាត្រា៤ បញ្ជាក់ពីរបបសមូហភាពដឹកនាំនិងធ្វើការងារ ។

ជំពូក៥ ដែលមាន៣មាត្រា អធិប្បាយអំពីអំណាចធ្វើច្បាប់ ។ “សភាតំណាងប្រជាជនកម្ពុជា” មួយដែលត្រូវបោះឆ្នោតជ្រើសរើសតាំងឡើងក្នុងរយៈកាល៥ឆ្នាំម្តង រួមមានសមាសភាពតំណាងកសិករ១៥០នាក់ តំណាងកម្មករនិងពលករផ្សេងៗទៀត៥០នាក់ និងតំណាងកងទ័ពបដិវត្តន៍៥០នាក់ ។ សភាតំណាងប្រជាជនមានភារៈសម្រេចច្បាប់និងកំណត់មាគ៌ានយោបាយផ្សេងៗក្នុងប្រទេសនិងក្រៅប្រទេស ។ នៅខែមីនា ឆ្នាំ១៩៧៦ ការបោះឆ្នោតជ្រើសតាំងសភានេះបានដាក់កំណត់ដល់ពួកអ្នកបោះឆ្នោតតាមការជ្រើសរើសជាមុនមួយ ដែលធ្វើឡើងដោយអង្គការ ។ វាហាក់ដូចជាថា សភាតំណាងប្រជាជននេះដែលប្រគល់អំណាចដ៏ទូលំទូលាយដោយរដ្ឋធម្មនុញ្ញ បានរួមប្រជុំគ្នាតែមួយដងគត់ពីថ្ងៃទី១១ ដល់ទី១៣ ខែមេសា ឆ្នាំ១៩៧៦ ។ ការប្រជុំនេះដឹកនាំដោយ នួន ជា ជាជនទី២នៃឋានានុក្រមនយោបាយ ។ ដោយអាស្រ័យអំណាចនៃរដ្ឋធម្មនុញ្ញ ដែលឲ្យសភាតំណាងប្រជាជនជ្រើសតាំងរដ្ឋាភិបាល តុលាការប្រជាជន គណៈប្រធានរដ្ឋ សភាតំណាងប្រជាជននេះមិនដែលប្រើអំណាចដែលរដ្ឋធម្មនុញ្ញប្រគល់ឲ្យទាល់តែសោះ ។

ជំពូក៦ មាន២កថាខណ្ឌ និយាយអំពីអង្គការនីតិប្រតិបត្តិ ដែល “មានភារកិច្ចអនុវត្តច្បាប់និងមាគ៌ានយោបាយទាំងអស់របស់សភាតំណាងប្រជាជនកម្ពុជា” ។ រដ្ឋាភិបាលត្រូវជ្រើសតាំងឡើងដោយសភាតំណាងប្រជាជនកម្ពុជា ហើយត្រូវទទួលខុសត្រូវទាំងស្រុងចំពោះមុខសភាតំណាងប្រជាជនកម្ពុជា ។

ជំពូក៧ មាន២មាត្រានិយាយអំពីតុលាការ ជាតុលាការរបស់រដ្ឋ សំដៅការពាររដ្ឋ ពោលគឺរដ្ឋអំណាច ។ តុលាការជា “តុលាការរបស់ប្រជាជន តំណាងយុត្តិធម៌របស់ប្រជាជនការពារសិទ្ធិសេរីភាពប្រជាធិបតេយ្យរបស់ប្រជាជន ហើយផ្តន្ទាទោសដល់គ្រប់សកម្មភាពដែលប្រឆាំងនឹងរដ្ឋរបស់ប្រជាជន ឬល្មើសនឹងច្បាប់រដ្ឋរបស់ប្រជាជន ។ ប្រភេទសកម្មភាពប្រឆាំងនេះនឹងត្រូវផ្តន្ទាទោសកម្រិតខ្ពស់បំផុត ហើយចំពោះប្រភេទល្មើសក្រៅពីប្រភេទល្មើសខាងលើ ត្រូវអប់រំកសាងក្នុងអង្គការរដ្ឋ ឬក្នុងក្របខ័ណ្ឌអង្គការប្រជាជន ។ តុលាការគ្រប់ជាន់ថ្នាក់ត្រូវជ្រើសរើសនិងតែងតាំងដោយសភាតំណាងប្រជាជន ។

មាត្រា១១ នៃជំពូកទី៨ និយាយអំពីគណៈប្រធានរដ្ឋ រួមមាន ប្រធានមួយរូប និងអនុប្រធាន២រូប (ទី១និងទី២) ដែលជ្រើសរើសនិងតែងតាំងឡើងដោយសភាតំណាងប្រជាជនកម្ពុជាសម្រាប់រយៈពេល៥ឆ្នាំម្តង ។ មុខងាររបស់គណៈប្រធានរដ្ឋនេះ គ្រាន់តែជាតំណាងប៉ុណ្ណោះ ។

ជំពូក៩ មាន៣មាត្រា និយាយអំពីសិទ្ធិនិងករណីយកិច្ចរបស់ប្រជាជនម្នាក់ៗ សិទ្ធិជីវភាពពេញទីខាងសម្ភារ ខាងស្មារតី និងខាងវប្បធម៌ ដែលត្រូវបានកែប្រែឲ្យរីកចម្រើនខ្ពស់ឡើងជានិច្ច ។ ប្រជាជនគ្រប់រូបសុទ្ធតែត្រូវបានធានាអះអាងខាងជីវភាពទាំងអស់ កម្មករគ្រប់រូបជាម្ចាស់រោងចក្រ កសិករគ្រប់រូបជាម្ចាស់ស្រែចម្ការ ។ មាត្រានេះនិយាយថា ពួកគេសុទ្ធតែជាម្ចាស់ ហើយលោក ដេវីដ ឆេនដល័រ បានសង្កេតឃើញថា ពាក្យពេចន៍ដែលប្រើប្រាស់បង្ហាញថា ពួកគេពុំមែនជាម្ចាស់កម្មសិទ្ធិរបស់ទាំងនោះ ។ ច្បាប់នេះគឺត្រូវបញ្ចូលទៅក្នុងបរិបទជាប្រវត្តិសាស្ត្ររបស់វា បើគេចង់យល់ច្បាស់ថាគោលបំណងដែលសម្តែងឲ្យឃើញនៅក្នុងរដ្ឋធម្មនុញ្ញនេះ គឺបញ្ចប់នូវសិទ្ធិនានា ដែលរហូតមកទល់ពេលនេះ មានយ៉ាងច្រើនលើសលប់របស់ពួកម្ចាស់កម្មសិទ្ធិដី ពួកព្រឹទ្ធិករ (អ្នកយកការប្រាក់ហួសហេតុ) ពួកអ្នកជំនួញ ។ តាមការពិត គេក៏ដឹងដែរថា ចៅហ្វាយថ្មីរបស់ប្រទេសកំពុងបង្ខំឲ្យប្រជាជនទាំងអស់ព្រមទទួលច្បាប់នេះដោយអំណាច ហើយដែលគ្មានបញ្ចូលទាល់តែសោះ ក្នុងរដ្ឋធម្មនុញ្ញ គឺបក្ស ។ សិទ្ធិមានការងារធ្វើនិងភាពគ្មានការងារធ្វើ ក៏ត្រូវប្រកាសក្នុងរដ្ឋធម្មនុញ្ញដែរ ។ ប៉ុន្តែគេត្រូវតែយល់ថែមទៀតថា បទបញ្ញត្តិនេះជាការហាមមួយមិនឲ្យប្រជាជននៅទំនេរ ពីព្រោះប្រជាជនគ្រប់រូបមានសិទ្ធិមានការងារធ្វើមួយ ។ មាត្រា១៣ ជំពូក៩ ចែងថា

ត្រូវមានសមភាពពេញទីរវាងប្រជាជនកម្ពុជាទាំងអស់ក្នុងសង្គមកម្ពុជាមួយស្មើភាព យុត្តិធម៌ ប្រជាធិបតេយ្យ ជាសមភាពដែលមានន័យជាអាទិ៍ថា ការស្តាប់បង្គាប់ដូចគ្នាទាំងអស់ចំពោះបដិវត្តន៍ ។ ការហាមឃាត់ពីរ ត្រូវបានបន្ថែមទៅលើសិទ្ធិទាំងនោះ គឺការមិនអនុញ្ញាតឲ្យមានប្រពន្ធច្រើនឬប្តីច្រើនឡើយ ។

មាត្រា១៥ ជំពូក១០ ប្រាប់ឲ្យដឹងថា ភ្នំពេញនៅតែជារដ្ឋធានី ។ មាត្រា១៦ ជំពូក១១ រៀបរាប់ពីទង់ជាតិដែលមានរូបប្រាសាទកំពូលបីពណ៌លឿងនៅចំកណ្តាលផ្ទៃក្រហម ។ ប្រាសាទអង្គរវត្តពណ៌លឿងជានិមិត្តរូបនៃប្រពៃណីជាតិនិងប្រជាជនកម្ពុជាដែលជាអ្នកការពារប្រទេស ជាអ្នកស្ថាបនាប្រទេសឲ្យបានថ្កុំថ្កើងរុងរឿង ។ គេនឹងសម្គាល់ឃើញថា ទង់ជាតិនេះមិនសូវខុសគ្នានឹងទង់ជាតិរបស់ពួកខ្មែរឥស្សរៈដែលប្រយុទ្ធប្រឆាំងនឹងវត្តមានរបស់បារាំងនៅចុងសតវត្សរ៍ឆ្នាំ១៩៤០ និងដើមទសវត្សរ៍ឆ្នាំ១៩៥០ ប៉ុន្មានទេ លើកលែងតែចំណុចមួយប៉ុណ្ណោះ គឺប្រាសាទកំពូលបីជំនួសប្រាសាទកំពូលប្រាំពីមុន ។

មាត្រា១៧ ជំពូក១២ រៀបរាប់ពីសញ្ញាជាតិគឺមានប្រព័ន្ធភ្លឺស្រែនិងប្រឡាយទឹក ជានិមិត្តរូបនៃភាពជឿនលឿន រោងចក្រមួយមានកម្រងកួរស្រូវព័ទ្ធពីក្រៅជារាងស្នែងក្របី និងមានឈ្មោះប្រទេសពីក្រោម ។ សញ្ញាជាតិនេះមានលក្ខណៈសាមញ្ញជាងសញ្ញាជាតិដែលមានពីមុនៗ ហើយដែលគ្មានសញ្ញាយោងពីព្រះពុទ្ធសាសនាទាល់តែសោះ ។

មាត្រា១៨ ជំពូ១៣ បញ្ជាក់ថា ភ្លេងជាតិនៃកម្ពុជាប្រជាធិបតេយ្យគឺ "១៧ មេសា មហាជោគជ័យ" ដែលជាព្រឹត្តិការណ៍មួយមានន័យធំធេងជាងសម័យអង្គរទៅទៀត ។ តាមពិតនេះជាចម្រៀងកងទ័ពមួយខទ្ទិសដល់ជោគជ័យរបស់កងទ័ពច្រើនជាងជោគជ័យរបស់ប្រទេស ។

មាត្រា១៩ ជំពូក១៤ និយាយពីកងទ័ពបដិវត្តន៍ដែលរួមមានកងទ័ពស្រួចតំបន់ ឈ្លប ដែលយុទ្ធជន-យុទ្ធនារីកម្មាភិបាលសុទ្ធតែជាកូនចៅរបស់ប្រជាជន កម្មករ កសិករ ពលរដ្ឋកម្ពុជាផ្សេងទៀត ។ កងទ័ពនេះរ៉ាប់រងការពាររដ្ឋអំណាចរបស់ប្រជាជន និងរួមចំណែកកសាងប្រទេសជាតិឲ្យថ្កុំថ្កើងរុងរឿង ។ ប្រការនេះបង្ហាញថា កងទ័ពរួមបង្កជាឧបករណ៍ដ៏សំខាន់ក្នុងការកាន់កាប់អំណាច ។

ជំពូក២០ មាត្រា១៥ និយាយអំពីសិទ្ធិខាងជំនឿនិងសាសនា ហើយជាពិសេសសិទ្ធិ "មិនជឿលើជំនឿអ្វី ឬមិនជឿសាសនា" ក៏បាន ។ សិទ្ធិមិនជឿនេះគឺត្រូវបានលើកឡើងដោយខៀវ សំផន ក្នុងការនិយាយរបស់គាត់ផ្សាយតាមវិទ្យុថា ជាការរីកលូតលាស់ដ៏សំខាន់មួយ និងជាការបង្កើត "សេរីភាពថ្មី" មួយ ។ គ្រប់ការនិយាយយោងពីព្រះពុទ្ធសាសនា គឺគ្មានតែម្តងដែលមានភាពផុយគ្នាយ៉ាងខ្លាំងនឹងរដ្ឋធម្មនុញ្ញផ្សេងៗទៀតទាំងអស់ ។

មាត្រាចុងក្រោយគឺមាត្រា២១ មានលក្ខណៈវែងជាងគេ ។ មាត្រានេះនិយាយអំពីនយោបាយក្រៅប្រទេសទាំងស្រុង និងបានរំឭកអំពីបំណងគោរពអធិបតេយ្យភាព បូរណភាពដែនដីគ្នាទៅវិញទៅមក ប្រកាន់ខ្ជាប់នូវនយោបាយឯករាជ្យ សន្តិភាព អព្យាក្រឹត និងមិនចូលបក្សសម្ព័ន្ធ ដែលបង្ហាញឲ្យដឹងរួចមកហើយក្នុងមាត្រា១ ដើម្បីបញ្ជាក់លក្ខណៈប្រទេស និងក្នុងមាត្រា១៩ ដើម្បីបង្ហាញពីរដ្ឋអំណាចដែលកងទ័ពទាំងបីប្រភេទត្រូវតែការពារ ។ មាត្រានេះប្រឆាំងដាច់ខាតនឹងការជ្រៀតជ្រែកគ្រប់បែបយ៉ាងពីខាងក្រៅមក រួមទាំងតាមរូបភាព "មនុស្សធម៌" ផង ។ មាត្រានេះបានប្រកាសពីការស្ថិតនៅក្នុងមហាគ្រួសារនៃបណ្តាប្រទេសមិនចូលបក្សសម្ព័ន្ធ ហើយខិតខំបង្កើនសាមគ្គីភាពរបស់ខ្លួនជាមួយប្រទេសនានា ដែលកំពុងប្រយុទ្ធប្រឆាំងនឹងចក្រពត្តិនិយម ។ សារៈសំខាន់នៃមាត្រានេះ ដែលផ្តល់ឲ្យមកអំពីនយោបាយការបរទេស ភាពវែងនៃមាត្រានេះបង្ហាញឲ្យឃើញពីភាពសំខាន់ពីរដងច្រើនជាងមាត្រាឯទៀតៗ គឺមាត្រានិយាយពីកងទ័ព បានបង្ហាញការប្រើមាត្រានេះសំដៅបញ្ជូនជាអាទិ៍នូវន័យនយោបាយដ៏ធំមួយចំពោះពិភពខាងក្រៅ ។

### ការកត់សំគាល់សំខាន់ខ្លះៗ

១) គំរូនៃសង្គមដែលដាក់គ្រឿងបង្កើតផលិតកម្មទាំងប៉ុន្មានឲ្យទៅជាសម្បត្តិរួម ជាសញ្ញាឲ្យដឹងយ៉ាងច្បាស់ថា សមភាពនិយមក្នុងភាពជាអ្នកបម្រើរដ្ឋ ត្រូវបានសង្កត់បញ្ជាក់ក្នុងមាត្រាជាច្រើន (មាត្រា២, ៤, ១៣, ១៤, ១៩) ។

២) រដ្ឋធម្មនុញ្ញនេះប្រកាសនូវការកាត់ផ្តាច់ដាច់ស្រឡះមួយ

ជាមួយអតីតកាល ។

អ្វីៗទាំងអស់ដែលបន្តបង្កើតជាប្រពៃណីរបស់កម្ពុជាដូចជា គ្រួសារ សាសនា ព្រះរាជវាំង រដ្ឋបាលជាន់ខ្ពស់ ឋានានុក្រមនៃសង្គម គឺគ្មាននិយាយទាល់តែសោះ បើមិនដូច្នេះទេ ត្រូវរំលាយចោលតែម្តង ។ សភាតំណាងរដ្ឋាភិបាល តុលាការប្រជាជនគ្រប់ជាន់ថ្នាក់ និងកងទ័ព គឺជាស្ថាប័នតែមួយគត់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនេះ ។

ដើម្បីបញ្ចប់រដ្ឋធម្មនុញ្ញរបស់ប្រទេសកម្ពុជាប្រជាធិបតេយ្យនេះ យើងសូមវាយតម្លៃពីសារៈសំខាន់ដ៏តិចតួចរបស់វា ។ ភាគច្រើននៃមាត្រាដែលមានចំនួនតិចបំផុតស្រាប់ទៅហើយ គឺមិនដែលត្រូវបានអនុវត្តទេ ។ ចំពោះពួកមេដឹកនាំបានណែនាំឲ្យជឿថា អំណាចពុំមែនចេញពីប្រជាជន ពីក្បួនទ្រឹស្តីមួយទេ ប៉ុន្តែគឺពិតជាចេញពីកងទ័ព ។ រដ្ឋធម្មនុញ្ញនេះ គ្រាន់តែជាការតុបតែងមួយសំដៅធ្វើឲ្យគេជឿពីអត្ថិភាពនៃរដ្ឋមួយទៅតាមន័យរបស់ពាក្យដូចធ្លាប់មានមកហើយប៉ុណ្ណោះ ។

## រដ្ឋធម្មនុញ្ញឆ្នាំ១៩៨១

ក្នុងឱកាសនៃការបង្កើតដំបូងរបស់ខ្លួននៅថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៧៨ ក្នុងស្រុកស្នួលខេត្តក្រចេះ រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា បានបង្ហាញឲ្យដឹងនូវកម្មវិធីមួយ មាន១១ចំណុច ដែលមានខ្លឹមសារជាពិសេសគឺ ការសន្យារៀបចំតាក់តែង “រដ្ឋធម្មនុញ្ញថ្មីមួយ ដោយអះអាងនូវសិទ្ធិផ្សេងៗ អំពីសមភាព សេរីភាពពិតប្រាកដ និងលទ្ធិប្រជាធិបតេយ្យ” ។

លោក រស់ សម័យ សមាជិកម្នាក់ក្នុងចំណោមសមាជិកនៃក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជាដែលជារចនាសម្ព័ន្ធរដ្ឋាភិបាលមួយធ្លាប់គ្រប់គ្រងដឹកនាំសាធារណរដ្ឋប្រជាមានិតកម្ពុជានៅពេលដំបូងៗ ត្រូវបានផ្ទុកផ្តាក់ឲ្យរៀបចំតាក់តែងរដ្ឋធម្មនុញ្ញដំបូងមួយ ។ បើគេសំអាងលើកិច្ចការផ្សេងៗរបស់លោក វូហ៊័រ ឃីសូ និង ម៉ៃឃើល វីកឃើរី គឺអត្ថបទផ្សេងៗទៀតនៃរដ្ឋធម្មនុញ្ញ ត្រូវបានរៀបចំដោយក្រុមការងារជាច្រើននៅវាងឆ្នាំ១៩៧៩ និង ១៩៨១ ។ ការរៀបចំរដ្ឋធម្មនុញ្ញបានផ្តល់ឱកាសឲ្យមានការជជែកពិភាក្សាគ្នាយ៉ាងខ្លាំងក្លាក្នុងផ្ទៃបក្សនិងរដ្ឋាភិបាល ។ មហាសន្និបាតមួយដែលមានកម្មាភិបាលបក្សជាច្រើននាក់ចូលរួម បានពិភាក្សាគ្នាក្នុងរយៈពេល៣ថ្ងៃនៅខែកុម្ភៈ ឆ្នាំ១៩៨១ ហើយរបៀបអធិប្បាយថ្មីមួយអំពីច្បាប់រដ្ឋធម្មនុញ្ញ ត្រូវបានបង្ហាញជូនមនុស្ស ១០ ០០០ នាក់ ដែលប្រមូលផ្តុំនៅស្តាតអូឡាំពិកនាថ្ងៃទី១០ ខែមីនា ឆ្នាំ១៩៨១ ។

ការបោះឆ្នោតបានប្រព្រឹត្តទៅនៅថ្ងៃទី១ ខែឧសភា ។ ចំនួនបេក្ខជនឈរឈ្មោះមាន ១៤៨រូប ច្រើនជាងអាសនៈដែលមានចំនួន១១៧ ។ ក្នុងចំណោមបេក្ខជនទាំងនោះ មានឥស្សរជនជាច្រើនរូបដែលគ្មានអតីតកាលជាកុម្មុយនិស្ត ជួនកាលពុំមែនជាអ្នកនយោបាយពីមុនមកផង ។ នៅពេលបើកការប្រជុំរបស់ខ្លួននាថ្ងៃទី២៤ ខែមិថុនា រដ្ឋសភាបានចាប់ផ្តើមពិភាក្សាសេចក្តីព្រាងនៃច្បាប់រដ្ឋធម្មនុញ្ញ ។ ការធ្វើវិសោធនកម្មជាច្រើនត្រូវបានបញ្ចូល ហើយរដ្ឋធម្មនុញ្ញត្រូវបានអនុម័តនៅថ្ងៃទី២៧ ខែមិថុនា ។

រដ្ឋធម្មនុញ្ញរួមមានបុព្វកថាមួយ និង៩៣មាត្រា ចែកជា ១០ជំពូក ។

ជំពូកទី១ និយាយពីប្រព័ន្ធនយោបាយមួយដែល “បោះជំហានទៅមុខជាលំដាប់ៗ ឆ្ពោះទៅសង្គមនិយម” (មាត្រា១) ។ អំណាចទាំងអស់ជារបស់ប្រជាជនដែលប្រើរដ្ឋអំណាច តាមរយៈរដ្ឋសភានិងអង្គការរដ្ឋនានាដែលប្រជាជនជ្រើសតាំងឡើង (មាត្រា២) ។ ភារកិច្ចដឹកនាំរបស់បក្សប្រជាជនបដិវត្តន៍កម្ពុជាគឺមានបញ្ជាក់ក្នុងមាត្រា៤ ។ រដ្ឋអនុវត្តនយោបាយសាមគ្គីភាពនិងស្មើភាពរវាងជនជាតិទាំងអស់ដែលរស់នៅក្នុងសហគមន៍ជាតិកម្ពុជា ។ ភាសានិងអក្សរព្រមទាំងទម្លាប់ល្អៗរបស់ជនជាតិភាគតិច ត្រូវគោរពនិងអភិវឌ្ឍ ។ អំពើប្រមាថមាក់ងាយ អំពើជិះជាន់ និងការបែងចែកជនជាតិនានា ត្រូវបានហាមឃាត់ (មាត្រា៥) ។ សេរីភាពខាងជំនឿត្រូវបានគោរព ប៉ុន្តែសាសនាមិនអាចត្រូវបានប្រើប្រាស់ដើម្បីធ្វើឲ្យប៉ះពាល់ដល់សន្តិសុខរបៀបរៀបរយសាធារណៈឡើយ (មាត្រា៦) ។ បុរសនិងស្ត្រីមានសិទ្ធិស្មើគ្នាក្នុងអាពាហ៍ពិពាហ៍និងក្នុងគ្រួសារ អាពាហ៍ពិពាហ៍ត្រូវធ្វើតាមលក្ខការណ៍ស្ម័គ្រចិត្តប្តីមួយប្រពន្ធមួយ ។ ការបង្ខិតបង្ខំក្នុងអាពាហ៍ពិពាហ៍ត្រូវហាមឃាត់ (មាត្រា៧) ។ មាតាបិតាមានករណីយកិច្ចអប់រំថែទាំចិញ្ចឹមកូន កូនមានកាតព្វកិច្ចបីបាច់ថែ

រក្សាមាតាបិតា (មាត្រា៨) ។ ប្រជាជនម្នាក់ៗមានករណីយកិច្ចការពារប្រទេស ហើយកងកម្លាំងប្រដាប់អាវុធទាំងអស់ត្រូវធ្វើយ៉ាងណាឲ្យសមនឹងការស្រលាញ់រាប់អាននិងការទុកចិត្តរបស់ប្រជាជន (មាត្រា៩) ។ សាធារណរដ្ឋប្រជាមានិតកម្ពុជាអនុវត្តនយោបាយក្រៅប្រទេសមួយតាមទិសដៅ "ឯករាជ្យ សន្តិភាព និងមិនចូលបក្សសម្ព័ន្ធ" ហើយ "រឹតចំណងសាមគ្គីភាពមិត្តភាព និងសហប្រតិបត្តិការជាមួយវៀតណាម ឡាវ សហភាពសូវៀត និងប្រទេសសង្គមនិយមជាបងប្អូនឯទៀតៗ" (មាត្រា១០) ។

ដោយរៀបចំប្រទេសទៅតាមប្រព័ន្ធកុម្មុយនិស្តនិងចំណងទាក់ទងទាំងឡាយរបស់ខ្លួនជាមួយអន្តរជាតិ ជំពូកទីមួយនេះបានធ្វើឲ្យមានឡើងវិញនូវគោលសំខាន់ៗជាប្រពៃណីរបស់សង្គមកម្ពុជាដែរ ការរួមរស់ដោយសុខដុមរមនារវាងជនជាតិភាគតិចទាំងអស់របស់ប្រជាជាតិ គ្រួសារ ហើយជាពិសេសទំនាក់ទំនងរវាងមាតាបិតា កូន ការប្រតិបត្តិសាសនា ទោះជាត្រង់ចំណុចនេះ ព្រះពុទ្ធសាសនាពុំត្រូវបានធ្វើឲ្យមានស្ថានភាពខ្ពស់ជាងគេដូចពីដើមវិញក៏ដោយ ។

ជំពូក២ និយាយពីរឿងសេដ្ឋកិច្ច វប្បធម៌ អប់រំ និងសុខាភិបាល ។ បន្ទាប់ពីបានបញ្ជាក់ការគ្រប់គ្រងរបស់រដ្ឋលើសេដ្ឋកិច្ចជាតិ (មាត្រា១១) រដ្ឋធម្មនុញ្ញបានបែងចែកសេដ្ឋកិច្ចជា៣ផ្នែកៈ សេដ្ឋកិច្ចរដ្ឋ សេដ្ឋកិច្ចសមូហភាព និងសេដ្ឋកិច្ចគ្រួសារ (មាត្រា១២) ។ រដ្ឋយកចិត្តទុកដាក់ពង្រីកផលិតកម្មកសិកម្ម ផលិតកម្មឧស្សាហកម្មដែលបម្រើកសិកម្ម ពង្រីកផលិតកម្មរបស់ប្រើប្រាស់ ពង្រីកពាណិជ្ជកម្ម គមនាគមន៍ និងការដឹកជញ្ជូន (មាត្រា១៣) ។ រដ្ឋជាម្ចាស់កម្មសិទ្ធិលើដីធ្លី ព្រៃឈើ សមុទ្រ ទន្លេ បឹង ធនធានធម្មជាតិ មជ្ឈមណ្ឌលសេដ្ឋកិច្ច វប្បធម៌ មូលដ្ឋានការពារប្រទេស និងសំណង់ផ្សេងៗ (មាត្រា១៤) ។ រដ្ឋប្រគល់ឲ្យគ្រួសារនីមួយៗនូវដីមួយកន្លែងតាមកំណត់នៃច្បាប់ដើម្បីសង់ផ្ទះនៅ និងធ្វើជាសួនច្បារសួនបន្លែ ហើយដីសម្បទានគឺជាមរតកតពីឪពុកម្តាយទៅកូន (មាត្រា១៥) ។ ក្រៅពីដីសម្រាប់សង់ផ្ទះនៅ និងធ្វើជាសួនច្បារសួនបន្លែ ដែលមានកំណត់ក្នុងច្បាប់ និងក្រៅពីចំណែកដីដែលក្រុមសាមគ្គីបង្កបង្កើនផលប្រគល់ឲ្យគ្រួសារនីមួយៗអាចបានរដ្ឋឲ្យខ្ចីដីបន្ថែម ហើយមានសិទ្ធិទទួលផលពីដីនេះ (មាត្រា១៦) ។ ជនណាក៏ដោយ គ្មានសិទ្ធិទិញ លក់ បញ្ចាំ ឬប្រវាស់ដីធ្លីឡើយ ។ ជនណាក៏ដោយ មិនអាចប្រើប្រាស់ដីធ្លីកសិកម្ម ដីព្រៃ ដោយចិត្តឯង ក្នុងគោលបំណងផ្សេងទៀតបានឡើយ បើគ្មានការអនុញ្ញាតពីក្រសួងមានសមត្ថកិច្ច (មាត្រា១៧) ។ កម្មសិទ្ធិឯកជននៃពលរដ្ឋលើកម្រៃការងារត្រូវបានការពារដោយច្បាប់ (មាត្រា១៨) ។ រដ្ឋគ្រប់គ្រងពាណិជ្ជកម្មក្រៅប្រទេសផ្តាច់មុខ និងជួយជំរុញពាណិជ្ជកម្មក្នុងប្រទេស ដែលពលរដ្ឋទាំងអស់អាចលក់ដូរផលិតផលកសិកម្ម និងផលិតផលសិប្បកម្មគ្រួសារ (មាត្រា១៩) ។ នយោបាយគ្រប់គ្រងរូបិយវត្ថុនិងប្រព័ន្ធហិរញ្ញវត្ថុគឺជាបុព្វសិទ្ធិមួយរបស់រដ្ឋ ។ ការយកពន្ធដារអាចធ្វើទៅបានលុះត្រាតែមានច្បាប់អនុញ្ញាត ។ ការតម្រូវឲ្យលក់ជូនរដ្ឋ ត្រូវតែធ្វើឡើងដោយអនុលោមទៅតាមច្បាប់កំណត់ (មាត្រា២០) ។ មាត្រា២១ដល់២៤ និយាយពីរដ្ឋត្រូវយកចិត្តទុកដាក់ក្នុងការពង្រីកវប្បធម៌ នវូបនីយកម្ម (ការធ្វើឲ្យទំនើប) ភាសាខ្មែរ ការពង្រីកវិស័យអប់រំ ការផ្តល់អាហារូបករណ៍សិក្សា ការលុបបំបាត់ភាពមិនចេះអក្សរ ការជំរុញការលូតលាស់វិទ្យាសាស្ត្រនិងបច្ចេកទេស ការធ្វើសហប្រតិបត្តិការផ្នែកវប្បធម៌ជាអន្តរជាតិ ការការពារបេតិកភណ្ឌ ការពង្រីកផ្នែកទេសចរណ៍ ។ មាត្រា២៥ដល់២៩ និយាយពីរដ្ឋយកចិត្តទុកដាក់រៀបចំប្រព័ន្ធសុខាភិបាលមួយ ។ រដ្ឋយកចិត្តទុកដាក់ជាពិសេសចំពោះមាតានិងកុមារ អតីតយុទ្ធជន អ្នករបួសពិការ ស្ត្រីមេម៉ាយ និងក្មេងកំព្រា ។

ក្រោមការគ្រប់គ្រងរបស់រដ្ឋ គេឃើញដំណើរមានជាថ្មីនូវកម្មសិទ្ធិឯកជនមួយ ក្នុងកម្រិតនៃការធ្វើអាជីវកម្មកសិកម្មគ្រួសារក៏ដូចការធ្វើជំនួញ ។ រូបមន្តនៃការធ្វើរួមគ្នា ពោលគឺក្រុមសាមគ្គី ត្រូវតែរ៉ាប់រងព្រមជាមួយគ្នាក្នុងការបង្កើតផលដ៏តិចតួចស្តួចស្តើងមួយ និងពើបប្រទះការខ្វះប្រភពធនធានមនុស្សដ៏សម្បើមមួយដែលទទួលដំណែលពីរបបមុន (មេគ្រួសារជាង ៣០ភាគរយសុទ្ធតែជាស្ត្រីមេម៉ាយ) ។ រដ្ឋបានរៀបចំឲ្យមានឡើងវិញនូវសេវាផ្សេងៗខាងវិស័យវប្បធម៌ អប់រំ និងសុខាភិបាល ។ ***(នៅមានត)***

**រ៉ាន្ទីល ខែន់រ**



កងទ័ពបដិវត្តន៍ខ្មែរក្រហម



# អង្គការសហប្រជាជាតិ

## សេចក្តីដកស្រង់ពីមហាសន្និបាតអង្គការសហប្រជាជាតិ ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០២

## សម័យប្រជុំលើកទី៥៧ របៀបវារៈលេខ១០៩ (C)

### II. *បេសកកម្មលើកទីប្រាំនិងទីប្រាំមួយរបស់តំណាងពិសេសរបស់លោកអគ្គលេខាធិការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា*

*៦) នៅថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០០២ ការិយាល័យទទួលបន្ទុកកិច្ចការច្បាប់របស់លេខាធិការដ្ឋានអង្គការសហប្រជាជាតិ បានប្រកាសថា ខ្លួនកំពុងតែដកខ្លួនថយពីការចរចាជាមួយរដ្ឋាភិបាលកម្ពុជា ទៅលើបញ្ហាស្តីពីការបង្កើតតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ ទស្សនកិច្ចការងារនេះគឺជាលើកទីមួយហើយ សម្រាប់តំណាងពិសេសចាប់តាំងពីការចេញប្រកាសកន្លងមកនោះ ។ ជាលទ្ធផល បញ្ហានេះលេចធ្លោជាងគេនៅក្នុងកិច្ចប្រជុំទាំងឡាយរបស់លោក ។ លោកតំណាងពិសេសបានខិតខំស្ទាបស្ទង់រាល់ការយល់ឃើញអំពីបញ្ហានេះពីសង្គម ឲ្យបានកាន់តែទូលាយតាមតែអាចធ្វើទៅបាន ហើយជាផ្នែកមួយនៃដំណើរការងារនេះដែរ លោកបានទៅទស្សនាគុកទួលស្លែងដែលស្ថិតនៅទីក្រុងភ្នំពេញ ជាអតីតសាលារៀន ដែលនៅទីនោះ អ្នកទោសខ្មែរក្រហមត្រូវបានឃុំឃាំងនិងធ្វើទារុណកម្មមុនពេលយកទៅប្រហារជីវិត ។ លោកបានជួបនាយកផលិតកម្មភាពយន្តឈ្មោះ ឫទ្ធី ប៉ាន់ ហើយរួមជាមួយនឹងជនជាតិខ្មែរមួយចំនួនទៀតដែលធ្លាប់បានរស់ឆ្លងកាត់សម័យខ្មែរក្រហមផង បានមើលខ្សែភាពយន្តមួយដែលផលិតដោយលោកនាយកផ្ទាល់ ដើម្បីរុករកចម្លើយផ្សេងៗ ។*

#### ***ក) តុលាការខ្មែរក្រហម***

*៣៩) ការិយាល័យកិច្ចការច្បាប់នៃលេខាធិការដ្ឋានអង្គការសហប្រជាជាតិបានប្រកាសនាថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០០២ ថានឹងមិនបន្តការចរចាជាមួយរដ្ឋាភិបាលកម្ពុជាតទៅទៀតឡើយ អំពីបញ្ហាបង្កើតតុលាការជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហម ។ សេចក្តីសម្រេចចិត្តនេះបានធ្វើឲ្យមានការមិនពេញចិត្តយ៉ាងខ្លាំងនៅក្នុងប្រទេសកម្ពុជានិងនៅក្នុងចំណោមរដ្ឋាភិបាលប្រទេសអ្នកផ្តល់ជំនួយ ។ មានការបញ្ចេញទស្សនៈផ្សេងៗគ្នាទៅលើបញ្ហាថាតើត្រូវបន្ទោសអ្នកណា ប៉ុន្តែមានការមូលមតិគ្នាប្រមាណមួយភាគបួនថាកម្ពុជានៅតែត្រូវការជាចាំបាច់នូវផ្លូវដើម្បីស្វែងរកចម្លើយទាក់ទងនឹងសម័យប្រកបដោយសោកនាដកម្មនៅក្នុងប្រវត្តិសាស្ត្ររបស់កម្ពុជា ។*

*៤០) សេចក្តីសម្រេចនេះបានទុកជម្រើសធំៗពីរឲ្យកម្ពុជាសម្រាប់ដោះស្រាយឧក្រិដ្ឋកម្មនាសម័យខ្មែរក្រហម ។ ជម្រើសទីមួយគឺបង្កើតតុលាការមិនមានការចូលរួមពីសំណាក់អង្គការសហប្រជាជាតិប៉ុន្តែមានការចូលរួមពីសំណាក់ចៅក្រមបរទេស (ម្នាក់ឬច្រើននាក់) ។ ជម្រើសមួយទៀតគឺជាតុលាការជាតិសុទ្ធសាធ ។ តាមគំនិតរបស់លោកតំណាងពិសេសថា គំនិតទាំងពីរនេះគ្មានគំនិតណាមួយគួរឲ្យប្រាថ្នាឡើយ ។ តុលាការដែលមិនមានអង្គការសហប្រជាជាតិចូលរួមនឹងក្លាយជាជម្រើសល្អបន្ទាប់ ។ គួរឲ្យកត់សម្គាល់ថា រដ្ឋាភិបាលដែលបានសម្តែងនូវសុឆន្ទៈចង់គាំទ្រគំនិតនេះ ក៏មើលឃើញតាមផ្លូវនេះដែរ ។ តុលាការជាតិសុទ្ធសាធនឹងខ្វះនូវជំនឿទុកចិត្ត ដោយសារប្រព័ន្ធតុលាការកម្ពុជាមិនសូវរឹងប៉ឹង ។ ជួយកម្ពុជាក្នុងការដោះស្រាយអតីតកាលរបស់ខ្លួនតាមផ្លូវនេះ មិនសូវមានតម្លៃប៉ុន្មានទេ ហើយអាចបំផ្លាញនូវជំនឿទុកចិត្តទៅលើប្រព័ន្ធតុលាការរបស់ប្រទេសនេះផង ។*

*៤១) តំណាងពិសេសមានចំណាប់អារម្មណ៍ថា ប្រជាជនកម្ពុជាគ្រប់ស្រទាប់វណ្ណៈនិងគ្រប់ជំនាន់ ប្រាថ្នាចង់ដឹងនូវការពិតអំពីអ្វីដែលបានកើតឡើងហើយចង់បានយុត្តិធម៌ ។ វាពិបាកនឹងប្រយុទ្ធប្រឆាំងនឹងភាពរួចទោសណាស់ ប្រសិនបើឧក្រិដ្ឋកម្មប្រព្រឹត្តឡើងដោយខ្មែរក្រហមមិនត្រូវគេផ្តន្ទាទោសទេនោះ ។ បញ្ហានេះមិនត្រឹមតែជាបញ្ហាច្បាប់ទេ ប៉ុន្តែជាបញ្ហាសីលធម៌ទៀតផង ។ សង្គមកម្ពុជាដែលមានរបួសមិនទាន់ជាសះ និងជាសង្គមដែលប្រកបដោយការប៉ះទង្គិចផ្លូវអារម្មណ៍យ៉ាងខ្លាំងនោះ គឺត្រូវការជាចាំបាច់នូវការព្យាបាលនិងយុត្តិធម៌ ។ សង្គមកម្ពុជាក៏ត្រូវការជាចាំបាច់នូវការប្រព្រឹត្តិប្រកបដោយការគោរពនិងដំណោះស្រាយបញ្ហាប្រកបដោយភាពប៉ិនប្រសប់កម្រិតខ្ពស់ ។ ការជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហមគឺជាជំហានមួយដ៏សំខាន់នៅលើមាគ៌ាឆ្ពោះ*

ទៅរកការរំសាយអារម្មណ៍ដ៏មានប្រយោជន៍ដល់ប្រជាជនកម្ពុជាឲ្យផ្សះផ្សារបួសពីអតីតកាលរបស់ផងខ្លួន ។ នេះគឺជាគំនិតរបស់តំណាងពិសេសដែលថា អង្គការសហប្រជាជាតិគួរតែធ្វើអ្វីដែលខ្លួនអាចធ្វើទៅបានដើម្បីជួយជ្រោមជ្រែងដល់ដំណើរការនេះ ។

**៤) តុលាការខ្មែរក្រហម**

៩៣) តំណាងពិសេសផ្តល់ជាអនុសាសន៍ថា ការបន្តនូវកិច្ចខិតខំប្រឹងប្រែងស្វែងរកការពិតនិងយុត្តិធម៌ ទាក់ទងនឹងឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅសម័យខ្មែរក្រហម ។ តុលាការមួយដែលមានការឧបត្ថម្ភគាំទ្រពីសំណាក់អង្គការសហប្រជាជាតិ គឺជាជម្រើសដ៏ល្អបំផុត ដោយហេតុថា តុលាការប្រភេទនេះនឹងធានាបានក្នុងកម្រិតខ្ពស់បំផុតនូវយុត្តិធម៌ដែលមានបទដ្ឋានអន្តរជាតិ ។ ក៏ប៉ុន្តែបើគ្មានតុលាការក្នុងលក្ខណៈបែបនេះទេ លទ្ធភាពផ្សេងៗទៀតក្នុងការជំរុញនូវការផ្សះផ្សា(ជាតិ) ក៏គួរតែលើកមកពិចារណាដែរ ។

# ការខិតខំចុងក្រោយស្តីអំពីបញ្ហាតុលាការខ្មែរក្រហម៖ អាណត្តិចុងក្រោយសម្រាប់យុត្តិធម៌នៅកម្ពុជា

នៅថ្ងៃពុធ ទី២០ ខែវិច្ឆិកា មហាសន្និបាតអង្គការសហប្រជាជាតិបានអនុម័តលើសេចក្តីសម្រេចលេខរៀង១០៩ (ខ) ដោយមានប្រទេសចំនួន៣៩មិនចូលរួមបោះឆ្នោត ។ ប្រទេសហុល្លង់បានស្នើឲ្យមានការបោះឆ្នោតនេះ ហើយអ្នកផ្សេងទៀតដែលមិនបោះឆ្នោតគឺសុទ្ធតែជាអ្នកដែលជឿជាក់លើបទដ្ឋានអន្តរជាតិ ។

សេចក្តីសម្រេចនេះត្រូវបានសហការរ៉ាប់រងដោយរដ្ឋាភិបាលបារាំងនិងជប៉ុន ដែលធ្វើការរួមគ្នាជាមួយគណៈកម្មការមួយដែលមាន“ប្រទេសដែលចាប់អារម្មណ៍”ចំនួន២៦ប្រទេស ក្នុងគោលបំណងចាប់ផ្តើមសាជាថ្មីនូវកិច្ចចរចាដែលបានផ្អាកមួយរយៈមកហើយ ។ សេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិបញ្ជាឲ្យលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ កូហ្វី អាណាន់ ចាប់ផ្តើមការចរចាសាជាថ្មីដោយគ្មានការពន្យារពេលជាមួយកម្ពុជា ដើម្បីឈានទៅដល់កិច្ចព្រមព្រៀងមួយជាមួយរាជរដ្ឋាភិបាលកម្ពុជា ដោយផ្អែកលើលទ្ធផលនៃការចរចាមុនៗក្នុងការបង្កើតតុលាការកាត់សេចក្តីមេដឹកនាំខ្មែរក្រហម ។

សេចក្តីសម្រេចនេះមាន១០ចំណុច ដែលសង្កត់ធ្ងន់លើចំណុចមួយចំនួនមានលក្ខណៈប្រហាក់ប្រហែលនឹងអ្វីដែលលោក ហេន កូរែល បានលើកឡើងម្តងរួចមកហើយនៅថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០០២ ពោលគឺបទដ្ឋានយុត្តិធម៌អន្តរជាតិ មានភាពមិនលម្អៀង គួរឲ្យជឿជាក់បាន និងត្រឹមត្រូវតាមនីតិវិធីដូចដែលបានចែងនៅក្នុងមាត្រាទី១៤និង១៥នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ។ លើសពីនេះទៀត សេចក្តីសម្រេចនេះក៏បានស្នើឲ្យលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ បញ្ចូលនៅក្នុងរបាយការណ៍អនុសាសន៍របស់ខ្លួនសម្រាប់ឲ្យមានប្រតិបត្តិការរបស់អង្គជំនុំជម្រះវិសាមញ្ញប្រកបដោយប្រសិទ្ធភាពសមតាមចំនួនតម្លៃដែលត្រូវចំណាយ ដោយរួមមានទាំងវិភាគទានដោយស្ម័គ្រចិត្តជាថវិកា សម្ភារ និងសេវាកម្មតាមរយៈការផ្តល់នូវបុគ្គលជំនាញការដែលអាចត្រូវការមកពីរដ្ឋនានា អង្គការអន្តររដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល ។

កន្លងមក មានអ្នកការទូតនិងអ្នកសង្កេតការណ៍មួយចំនួនមានតម្រិះថា ការដែលកម្ពុជាក្រាញនាលមិនបង្ហាញសុឆន្ទៈពិតប្រាកដលើបញ្ហាបង្កើតតុលាការនេះ គឺប្រហែលដោយសារកម្ពុជាមានការទូទាត់លាត់សើយនិងសម្របសម្រួលរួចជាស្រេចទៅហើយជាមួយប្រទេសចិន ។ ទាក់ទងនឹងបញ្ហាដ៏ក្តៅគគុកនេះ លោក ខៀវ កាញារិទ្ធិ អ្នកនាំពាក្យនៃរាជរដ្ឋាភិបាលកម្ពុជាបានទាត់ចោលគំនិតយល់ឃើញបែបនេះទាំងស្រុង ហើយបញ្ជាក់ថា លោកអាចធានាបានថានេះមិនមែនជាការពិតសោះឡើយ ។

ប៉ុន្តែទោះជាយ៉ាងណា ពេលវេលាជិតដល់ទីបញ្ចប់ហើយ ដូចដែលលោក ឆាំង យុ មានប្រសាសន៍ថា “ខ្ញុំសង្ឃឹមថារដ្ឋាភិបាល (កម្ពុជា) ចាត់ទុកថានេះគឺជាឱកាសចុងក្រោយសម្រាប់ខ្លួន ក្នុងការធ្វើកិច្ចការជាមួយនឹងអង្គការសហប្រជាជាតិប្រយោជន៍ដើម្បីបង្កើតឡើងនូវតុលាការមួយ” ។ **សួ ប៊ុនស៊ូ**

# ដំណើរឈានទៅរកការកាត់ទោសមេដឹកនាំខ្មែរក្រហម

## សេចក្តីដកស្រង់ចេញពីសន្និសីទសារពត៌មានរបស់អង្គការសហប្រជាជាតិ

## មហាសន្និបាតលើកទី៥៧ គណៈកម្មាធិការទី៣ សម័យប្រជុំលើកទី៥៥ និង ទី៥៦ ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០២

មហាសន្និបាតអនុម័តនូវសេចក្តីសម្រេចព្រាងចំនួន១២ទៀត ស្តីអំពីសិទ្ធិមនុស្ស បញ្ហាជនភៀសខ្លួន រួមទាំងអត្ថបទស្តីអំពីប្រទេសកម្ពុជា ស៊ូដង់ សិទ្ធិទទួលនូវស្បៀងអាហារ សិទ្ធិកុមារ ។

មហាសន្និបាតនឹងសម្រេចបន្តអត្ថិភាពនៃការិយាល័យឧត្តមស្នងការទទួលបន្ទុកជនភៀសខ្លួន រហូតដល់ប្រាំឆ្នាំទៀត គិតចាប់តាំងពីថ្ងៃទី១ ខែមករា ឆ្នាំ២០០៤ ក្រោមលក្ខខណ្ឌដែលបានចែងនៅក្នុងសេចក្តីសម្រេចមួយដែលអនុម័តជាឯកច្ឆ័នថ្ងៃនេះ ដោយគណៈកម្មាធិការទីបី (គណៈកម្មាធិការទទួលបន្ទុកសង្គមកិច្ច មនុស្សធម៌ វប្បធម៌) ។

ដោយប្រាថ្នាចង់ឲ្យសហគមន៍អន្តរជាតិបន្តឆ្លើយតបយ៉ាងវិជ្ជមានក្នុងការជ្រោមជ្រែងកិច្ចខិតខំប្រឹងប្រែងស៊ើបអង្កេតប្រវត្តិសាស្ត្រប្រកបដោយសោកនាដ្យកម្មនៅកម្ពុជា មហាសន្និបាតអង្គការសហប្រជាជាតិសូមស្នើដល់អគ្គលេខាធិការអង្គការសហប្រជាជាតិ ឲ្យចាប់ផ្តើមការចរចាសាជាថ្មីដោយគ្មានការពន្យារពេលដើម្បីឈានដល់កិច្ចព្រមព្រៀងគ្នាមួយជាមួយរដ្ឋាភិបាលកម្ពុជា ប្រយោជន៍ដើម្បីបង្កើតឡើងនូវអង្គជំនុំជម្រះវិសាមញ្ញដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងដោយខ្មែរក្រហមក្រោមលក្ខខណ្ឌនៃអត្ថបទច្បាប់ដែលអនុម័តរួចហើយដោយសំឡេងឆ្នោតគាំទ្រ១២៣ និងអនុប្បវាទចំនួន ៣៧ (ឧបសម្ព័ន្ធទី VII) ។

គណៈប្រតិភូទាំងឡាយមានការព្រួយបារម្ភថា ភាសានៃសេចក្តីសម្រេចនោះមិនបានកំណត់ឲ្យបានគ្រប់គ្រាន់នូវអណត្តិរបស់លោកអគ្គលេខាធិការ ដែលត្រូវបានសុំឲ្យផ្អាកចំនួន២៤ម៉ោង ដើម្បីត្រងត្រាប់នូវទស្សនះរបស់ក្រុមប្រឹក្សាអ្នកច្បាប់ ប៉ុន្តែញត្តិនោះត្រូវបានធ្វើឲ្យបរាជ័យដោយសំឡេងឆ្នោត១៥គាំទ្រ ទល់នឹង៩០ប្រឆាំង និងអនុប្បវាទ៥៩ (ឧបសម្ព័ន្ធទី VI) ។ គណៈប្រតិភូជាច្រើនមកពីតំបន់អាស៊ីខាងកើត បានគាំទ្រដល់ជំហានឆ្ពោះទៅមុខ ដោយសង្កត់ធ្ងន់ថា គោលបំណងនៃអត្ថបទសេចក្តីសម្រេចចិត្តនេះមានលក្ខណៈច្បាស់លាស់ ហើយថានៅពេលដែលអនុម័តភ្លាម កិច្ចការចម្បងនឹងត្រូវប្រតិបត្តិសម្រាប់ឲ្យលោកអគ្គលេខាធិការចាប់ផ្តើមការចរចាសំខាន់ៗជាមួយនឹងរដ្ឋាភិបាលកម្ពុជា ។

### ព្រឹត្តិការណ៍ជុំវិញ

គណៈកម្មាធិការទីបីបានជួបប្រជុំគ្នាដើម្បីចាត់វិធានការទៅលើសេចក្តីសម្រេចព្រាងលើរបៀបវារៈដែលពាក់ព័ន្ធដល់បញ្ហាសិទ្ធិមនុស្ស ការជំរឿន និងការពារកុមារនិងជនភៀសខ្លួន ព្រមទាំងជនផ្លាស់ប្តូរលំនៅដ្ឋាននៅក្នុងស្រុក ។

ទាក់ទិននឹងបញ្ហាតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម (ឯកសារលេខ A/C.3/57/L.70) មានសេចក្តីសម្រេចចិត្ត (ព្រាង) មួយ ដែលតាមរយៈសេចក្តីសម្រេចនេះ មហាសន្និបាតនឹងស្នើឲ្យអគ្គលេខាធិកាចាប់ផ្តើមការចរចាជាថ្មីដោយគ្មានពន្យារពេលដើម្បីបញ្ចប់កិច្ចព្រមព្រៀងមួយជាមួយរដ្ឋាភិបាលកម្ពុជា ដោយផ្អែកលើលទ្ធផលនៃការចរចាមុនៗ ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីវិនិច្ឆ័យទោសជនទាំងឡាយដែលត្រូវបានសង្ស័យថាជាអ្នកទទួលខុសត្រូវចំពោះអំពើឃោរឃៅដែលប្រព្រឹត្តឡើងដោយខ្មែរក្រហម ។ មហាសន្និបាតនឹងស្នើបន្ថែមទៀត ដោយឲ្យអគ្គលេខាធិការបញ្ចូលនៅក្នុងរបាយការណ៍អនុសាសន៍របស់ខ្លួនសម្រាប់ឲ្យមានប្រតិបត្តិការនៃអង្គជំនុំជម្រះវិសាមញ្ញប្រកបដោយប្រសិទ្ធិភាពការងារខ្ពស់ សមនឹងចំណាយថវិកានិងធនធានមនុស្ស ក្នុងនោះរួមមានទាំងចំនួនវិភាគទានស្ម័គ្រចិត្ត សម្ភារៈ និងសេវាកម្មនានាផ្តល់ដល់អង្គជំនុំជម្រះតាមរយៈបុគ្គលិកជំនាញការដែលនឹងត្រូវបញ្ជូនមកពីរដ្ឋនានា អង្គការអន្តររដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល ។

សេចក្តីសម្រេចព្រាងស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា (ឯកសារលេខ RA/C.3/57/67) នឹងធ្វើឲ្យមហាសន្និបាតទទួលស្គាល់ថា ប្រវត្តិប្រកបដោយសោកនាដកម្មរបស់ប្រទេសកម្ពុជាតម្រូវឲ្យមានវិធានការពិសេសៗ ដើម្បីធានានូវការការពារសិទ្ធិរបស់ប្រជាពលរដ្ឋទូទៅនៅក្នុងប្រទេស និងកុំឲ្យមានបញ្ចូលនៅក្នុងនយោបាយ និងការអនុវត្តន៍ជាក់ស្តែងនូវអ្វីដែលបានកើតឡើងកាលពីអតីតកាលនេះ ។ សេចក្តីសម្រេចព្រាងនេះនឹងជំរុញឲ្យរដ្ឋាភិបាលកម្ពុជាអនុម័តច្បាប់និងក្រមច្បាប់នានាឲ្យបានឆាប់រហ័ស ដែលកត្តាទាំងពីរនេះជាធាតុផ្សំដ៏សំខាន់នៃក្របខ័ណ្ឌច្បាប់គ្រឹះ ក្នុងនោះរួមមានក្រមព្រហ្មទណ្ឌចាស់ ច្បាប់ព្រហ្មទណ្ឌ និងច្បាប់ស៊ីវិល ហើយបានជំរុញឲ្យពង្រឹងការហ្វឹកហ្វឺនចៅក្រម និងមេធាវីឲ្យកាន់តែមានកម្រិតចេះដឹងខ្ពស់ថែមទៀតផង ។

## ការប្រតិបត្តិតាមសេចក្តីសម្រេចចិត្ត (ព្រាង)




គណៈកម្មាធិការនេះបានចាប់ផ្តើមកិច្ចការរបស់ខ្លួនដោយជ្រើសរើសយកនូវសេចក្តីសម្រេចព្រាងស្តីអំពីជនភៀសខ្លួន ។ រួចហើយគណៈកម្មាធិការនេះក៏អនុម័តទៅលើសេចក្តីសម្រេចព្រាងដូចដែលត្រូវបានពិនិត្យឡើងវិញដោយផ្ទាល់មាត់ស្តីពីស្ថានការណ៍សិទ្ធិមនុស្សនៅកម្ពុជា (A/C.3/57/L.67) ។

មុនពេលអនុម័ត តំណាងមកពីប្រទេសយេម៉ែននិយាយថា៖ គ្មានតម្លាភាពនៅក្នុងការពិនិត្យដោះស្រាយបញ្ហាសិទ្ធិមនុស្សមួយចំនួន ។ ប្រទេសមួយចំនួនត្រូវបានគេកត់សម្គាល់ថាមានផលប្រយោជន៍នៅក្នុងប្រទេសខ្លះ ។ តំណាងរូបនោះនឹងមិនចូលរួមបោះឆ្នោតគាំទ្រឬប្រឆាំងទៅលើស្ថានភាពសិទ្ធិមនុស្សនានា គឺដោយសារហេតុផលនេះ ។

ក្រោយពីអនុម័តហើយ តំណាងរបស់កម្ពុជានិយាយថា៖ អ្នកស្រីបានសម្តែងនូវជំហររបស់អ្នកស្រីរួចហើយ ស្តីអំពីស្ថានការណ៍សិទ្ធិមនុស្សនៅក្នុងប្រទេសរបស់អ្នកស្រី ។ កម្ពុជាជាចំណែកមួយនៃការមូលមតិគ្នានៅឆ្នាំនេះ ក្នុងស្មារតីសហប្រតិបត្តិការ ។ ក្នុងខណៈដែលកំពុងតែដំណើរការ ការការពារ និងជំរឿនសិទ្ធិមនុស្ស គឺជាអាទិភាពមួយក្នុងចំណោមអាទិភាពចម្បងៗនៃរដ្ឋា-ភិបាលរបស់អ្នកស្រី ។ អ្នកស្រីបានសម្តែងនូវការចាប់អារម្មណ៍ខ្ពស់ចំពោះគណៈប្រតិភូមកពីប្រទេសជប៉ុនដែលជាអ្នករៀបរៀងនូវសេចក្តីសម្រេចនេះ ។

នៅពេលដែលគណៈកម្មាធិការលើកយកអត្ថបទស្តីពីតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម (ឯកសារលេខ A/C.3/57/L.70) ប្រធានគណៈកម្មាធិការបានជម្រាបដល់គណៈប្រតិភូដែលចូលរួម ថាបានទទួលរួចហើយនូវសំណើសុំពន្យារពេលចាត់ការទៅលើសេចក្តីព្រាងរហូតដល់ថ្ងៃស្អែក ។

តំណាងមកពីប្រទេសជប៉ុនមានការព្រួយបារម្ភទៅលើសំណើ (នៅក្នុងអត្ថបទ) សុំឲ្យផ្អាក ហើយបានសួរទៅការិយាល័យនោះ ថាតើគណៈប្រតិភូណាខ្លះដែលធ្វើសំណើយល់ព្រម ហើយដោយមានមូលហេតុអ្វី ។

តំណាងមកពីប្រទេសកាណាដានិយាយថា គណៈប្រតិភូរបស់អ្នកស្រីគឺជាតួអង្គមួយក្នុងចំណោមគណៈប្រតិភូផ្សេងៗទៀត ដែលបានស្នើសុំឲ្យមានការផ្អាកនេះដោយសារបញ្ហាធ្ងន់ធ្ងរជាច្រើន ដូចជាចំណុចនិយាយពីអាណត្តិ ដែលចែងថា អគ្គលេខាធិការចរចាជាមួយនឹងរដ្ឋាភិបាលកម្ពុជា ស្តីពីការបង្កើតតុលាការកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងដោយខ្មែរក្រហម ។ ប្រទេសកាណាដាចង់បានយោបល់ពីលោកអគ្គលេខាធិការនិងក្រុមប្រឹក្សាអ្នកច្បាប់ ទៅលើបញ្ហានេះ ។

តំណាងមកពីប្រទេសហ្វីលីពីនបានគាំទ្រប្រទេសជប៉ុន ហើយរំឭកថា ការចរចាទៅលើអត្ថបទនេះបានប្រព្រឹត្តទៅអស់រយៈពេលជាងពីរខែទៅហើយ ។ គណៈប្រតិភូរបស់លោកមានអារម្មណ៍ថា ភាសានេះគឺជាជម្រើសដ៏ល្អបំផុតដែលអាចនឹងផ្តល់សេចក្តីសង្ឃឹម ទោះជាស្ថិតក្នុងកាលៈទេសៈបែបនេះ ដូច្នេះ

លោកជឿជាក់ថា ការពន្យារពេលមិនសម្រេចពេលនេះនឹងធ្វើឲ្យបញ្ហានេះកាន់តែស្មុគ្រស្មាញថែមទៀត ។ លោកបានស្នើឲ្យគណៈកម្មាធិការសម្រេចនាថ្ងៃនេះ ។

តំណាងរបស់ប្រទេសហុល្លង់យល់ស្របជាមួយនឹងតំណាងប្រទេសកាណាដាដែលថា ការផ្អាកមួយរយៈពេលខ្លីដើម្បីជម្រាបឲ្យគណៈកម្មាធិការនិងមហាសន្និបាតជ្រាបកាន់តែទូលំទូលាយ គឺដើម្បីប្រយោជន៍យើងទាំងអស់គ្នា ។

តំណាងមកពីប្រទេសស៊ុីសបានគាំទ្រសំណើរឲ្យមានការផ្អាកមិនព្រមសម្រេចមួយរយៈសិន ហើយផ្តល់យោបល់ដល់គណៈប្រតិភូដែលដឹកនាំកិច្ចចរចា ពោលគឺប្រទេសជប៉ុននិងបារាំង ។ ប៉ុន្តែលោកមានប្រសាសន៍ថា សេចក្តីព្រាងនេះមិនទាន់រួចរាល់សព្វគ្រប់នៅឡើយទេ ។ សេចក្តីព្រាងនេះផ្ទុកទៅដោយន័យមិនប្រាកដ ។ គណៈកម្មាធិការគួរតែស្វែងរកទស្សនៈពីអគ្គលេខាធិការ ហេតុដូច្នេះអត្ថបទនេះមិនទទួលបាននូវការមូលមតិគ្នាទេ ។ ការដោះស្រាយបញ្ហានេះគឺមានសារសំខាន់ណាស់ដើម្បីធានាឲ្យមានការចូលរួមពីសហគមន៍អន្តរជាតិនៅក្នុងបញ្ហាដ៏មហាសំខាន់នេះ ។

តំណាងមកពីប្រទេសស៊ុីសបានគាំទ្រការផ្អាកនេះដើម្បីឲ្យអគ្គលេខាធិការបញ្ចេញយោបល់ទៅលើសេចក្តីព្រាងនេះ ។

តំណាងមកពីប្រទេសថៃបានគាំទ្រដល់ការលើកឡើងរបស់តំណាងប្រទេសជប៉ុន ។

តំណាងរបស់ប្រទេសជប៉ុននិយាយថា គណៈប្រតិភូរបស់លោកមិនជឿតាមទឡ្ហីករណ៍របស់គណៈប្រតិភូនានាដែលសុំឲ្យទុកសេចក្តីព្រាងមួយអន្លើសិន ។ ជប៉ុនទទូចសូមឲ្យមានការបោះឆ្នោតថ្ងៃនេះដូចដែលបានគ្រោងទុក ។ លោកបានសង្កត់ធ្ងន់ថា សេចក្តីព្រាងត្រូវបានរៀបចំជាការឆ្លើយតបទៅនឹងសេចក្តីអំពាវនាវរបស់អគ្គលេខាធិការ ដើម្បីទទួលនូវអាណត្តិគ្រប់គ្រាន់ និងច្បាស់លាស់ ទោះបីជាមកពីក្រុមប្រឹក្សាសន្តិសុខក្តី ឬមកពីមហាសន្និបាតអង្គការសហប្រជាជាតិក្តី ។ អាណត្តិនោះនឹងផ្តល់សិទ្ធិឲ្យអគ្គលេខាធិការបន្តការចរចាសាជាថ្មីជាមួយរដ្ឋាភិបាលកម្ពុជាដើម្បីបង្កើតតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ សរុបមកវិញ លោកនិយាយថា គោលការណ៍សំខាន់បំផុតគឺការប្រតិបត្តិឆន្ទៈរបស់រដ្ឋជាសមាជិកអង្គការសហប្រជាជាតិ មិនមែនបំពេញចិត្តអ្នកទាំងឡាយដែលគាំទ្រផលប្រយោជន៍ជាតិរបស់ខ្លួនឯងនោះទេ ។

តំណាងមកពីប្រទេសអាល្លឺម៉ង់និយាយថា គណៈប្រតិភូរបស់លោកក៏បានស្នើឲ្យមានការផ្អាកសិនដែរ ។ សេចក្តីព្រាងនេះគឺជាជំហានប្រកបដោយន័យវិជ្ជមានក្នុងគោលដៅត្រឹមត្រូវខ្លាំងណាស់ ប៉ុន្តែនៅមានបញ្ហាមិនប្រាកដប្រជាមួយចំនួនមិនទាន់ដោះស្រាយ ។ តំណាងមកពីប្រទេសចិននិយាយថា គណៈប្រតិភូរបស់លោកមិនយល់អំពីសំណើចង់ផ្អាកការសម្រេចចិត្តទៅលើអត្ថបទដែលត្រូវបានពិនិត្យពិចារណាយ៉ាងយូរនោះឡើយ ។ តើការពន្យារពេលត្រឹមតែ២៤ម៉ោងនោះអាចជួយបានអ្វីខ្លះទៅ? អត្ថបទច្បាប់នេះមានលក្ខណៈច្បាស់លាស់ ហើយនៅពេលដែលអនុម័តរួចហើយ វានឹងផ្តល់ជាកិច្ចការចម្បងឲ្យអគ្គលេខាធិការចាប់ផ្តើមកិច្ចចរចាដ៏មានសារសំខាន់ជាមួយរដ្ឋាភិបាលកម្ពុជា ។

តំណាងមកពីប្រទេសអៀរឡង់ក៏និយាយដូចជាគណៈប្រតិភូដទៃៗទៀតដែរថា លោកនៅតែមានការបារម្ភមួយចំនួនទៅលើភាពមានន័យមិនច្បាស់លាស់នៅផ្នែកខ្លះនៃសេចក្តីព្រាងនេះ ។ លោកក៏មានអារម្មណ៍ថា យកល្អគួរតែរង់ចាំការចូលរួមយោបល់ពីសំណាក់លោកអគ្គលេខាធិការសិន ។

តំណាងមកពីប្រទេសគុយបានិយាយថា ប្រទេសគុយបាមិនគាំទ្រដល់ការផ្អាកមិនធ្វើការសម្រេចទៅលើសេចក្តីសម្រេចព្រាងនេះទេ ។

តំណាងមកពីប្រទេសបារាំងនិយាយថា លោកចូលរួមខាងគណៈប្រតិភូដែលមិនពេញចិត្តទៅនឹងការផ្អាកមិនសម្រេចទៅលើសេចក្តីសម្រេចព្រាងនេះ ។ លោកមានសេចក្តីងឿងឆ្ងល់ថាតើការផ្អាកនេះមានការទាក់ទិនឬចាំបាច់ដែរឬទេ ។ មហាសន្និបាតអង្គការសហប្រជាជាតិចាំតែផ្តល់ដល់លោកអគ្គលេខាធិការនូវអាណត្តិរបស់លោក ។ សេចក្តីសម្រេចព្រាងនេះគឺជាអត្ថបទដែលត្រូវបានចរចាអស់រយៈពេលជាច្រើនខែរួចមកហើយ ។ អ្នកដែលគាំទ្រការពន្យារពេលមិនទាន់សម្រេចបានចូលរួមពិភាក្សាយ៉ាងល្អិតល្អន់តាំងពីការចាប់ផ្តើមមកម្ល៉េះ ។

តំណាងមកពីប្រទេសកម្ពុជានិយាយថា ការផ្អាកមួយ

រយៈនេះនឹងធ្វើឲ្យគ្រោះថ្នាក់ដល់ការចាប់ផ្តើមចរចាសាជាថ្មីជាមួយនឹងអគ្គលេខាធិការ និងគ្រោះថ្នាក់ដល់ការផ្តល់យុត្តិធម៌សម្រាប់ប្រជាជនកម្ពុជាដែលរងគ្រោះដោយសារស្នាដៃខ្មែរក្រហម ។ លោកបានសុំឲ្យគណៈប្រតិភូសម្រេចទៅលើសេចក្តីព្រាងនេះឲ្យបានរួសរាន់ ។

តំណាងមកពីប្រទេសស៊ូដង់ក៏បានគាំទ្រដល់ការអនុម័តសេចក្តីសម្រេចព្រាងឲ្យបានឆាប់រហ័សដែរ ។

តំណាងមកពីប្រទេសឥណ្ឌាគាំទ្រដល់ជំហររបស់គណៈប្រតិភូជប៉ុន ។ លោកបន្ថែមថា គណៈប្រតិភូដែលគាំទ្រដល់ការពន្យារពេល គឺសុទ្ធតែជាអ្នកដែលបានជ្រាបពីសភាពការណ៍តាំងពីដើមទីមកម្ល៉េះ ។ គ្មានព្រឹត្តិការណ៍អ្វីថ្មីត្រូវលើកមកនិយាយឲ្យសមទៅនឹងសំណើសុំផ្អាកមិនសម្រេចដូច្នេះឡើយ ។ បើចេះតែរង់ចាំយោបល់ពីលោកអគ្គលេខាធិការ វានឹងធ្វើឲ្យឃ្លីងឃ្លោងដល់សេចក្តីសម្រេចព្រាងដែលខិតខំធ្វើទម្រាំតែមានតុល្យភាពបែបនេះ ។ លោកនិយាយថា ត្រូវចងចាំក្នុងចិត្តអំពីបញ្ហានេះ ។ លោកបានផ្តល់ជាយោបល់ថា គួរតែផ្តល់នូវការសម្រេចចិត្តក្នុងថ្ងៃនេះ ។

តំណាងមកពីប្រទេសឥណ្ឌូនេស៊ីនិយាយថា ការចរចាដែលត្រូវបានបញ្ចប់កន្លងមក គឺដោយសារការរិះគន់មួយក្នុងចំណោមការរិះគន់ដទៃទៀតទៅលើរដ្ឋាភិបាលកម្ពុជា ដែលថា កម្ពុជាចេះតែព្យាយាមបន្ទាយពេលវាលាមិនចាត់ការរឿងនេះ ។ គណៈប្រតិភូរបស់លោកសង្កត់ធ្ងន់ថា វាដល់ពេលដែលគណៈកម្មាធិការទីបីឈប់ពន្យារពេលតទៅទៀតហើយ ។

តំណាងមកពីចក្រភពអង់គ្លេសបន្ថែមសំឡេងរបស់លោកទៅខាងអ្នកដែលសុំឲ្យមានការផ្អាកមិនផ្តល់ការសម្រេចចិត្តមួយរយៈខ្លី ។ គណៈប្រតិភូជាច្រើនបានសម្តែងនូវសេចក្តីប្រាថ្នាចង់បានគំនិតពីអគ្គលេខាធិការដ្ឋាន ។ យកគំនិតនេះទៅគិតគូរ គឺជាការឈ្លាសវៃ ។

តំណាងមកពីសហរដ្ឋអាមេរិកនិយាយថា លោក វីនស្តុន ឆឺឈីល ធ្លាប់បាននិយាយថា “ធ្វើអ្វីត្រូវធ្វើឲ្យហើយនៅក្នុងថ្ងៃនេះ» ។ ដូច្នេះ សហរដ្ឋអាមេរិកចង់សម្រេចនៅថ្ងៃនេះតែម្តង ។ លោកបានរំឭកដល់គណៈកម្មាធិការនេះថា រដ្ឋាភិបាលកម្ពុជាបានគាំទ្រសេចក្តីសម្រេចនេះ ។ ប្រការនេះនឹងផ្តល់ឱកាសដ៏ធូរធង់ដល់លោកអគ្គលេខាធិការ ក្នុងការធ្វើដំណើរទៅមុខឆ្ពោះទៅរកសន្តិភាពនិងការផ្សះផ្សាជាតិ ព្រមទាំងបញ្ចប់នូវវប្បធម៌នៃភាពរួចទោស ។

តំណាងមកពីប្រទេសស៊ូរីណាមនិយាយថា សេចក្តីសម្រេចនេះជាទូទៅមិនមែនលើកមកដើម្បីពន្យារពេលទេ ។ ប្រសិនបើអ្នករ៉ាប់រងធំៗគាំទ្រទៅហើយ តើនៅរង់ចាំដល់ណាទៀត? ដូច្នេះមានន័យថា ស៊ូរីណាមគាំទ្រទៅលើការសម្រេចចិត្តដោយគ្មានបង្អែបង្អង់ ។

ប្រធានអង្គប្រជុំស្នើឲ្យបោះឆ្នោតទៅលើសំណើសុំឲ្យផ្អាកមិនសម្រេចចិត្តមួយរយៈសិន ទៅលើសេចក្តីសម្រេចព្រាងនេះ ។ សំណើនេះបានទទួលបរាជ័យ ដោយសំឡេងឆ្នោត១៤គាំទ្រ ៩០ប្រឆាំង និង៥៩អនុប្បវាទ (ឧបសម្ព័ន្ធទី VI) ។

នៅពេលដែលគណៈកម្មាធិការលើកយកសេចក្តីព្រាងមកពិភាក្សា តំណាងមកពីប្រទេសជប៉ុននិយាយថា ប្រសិនបើអត្ថបទនេះត្រូវបានអនុម័ត វានឹងត្រួសត្រាយផ្លូវសម្រាប់ឲ្យមានតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមដែលគួរឲ្យជឿជាក់បាន ។ ប៉ុន្តែ ប្រសិនបើមិនអនុម័តទេ ឱកាសបែបនេះដែលមានការចូលរួមយ៉ាងសកម្មពីសំណាក់អង្គការសហប្រជាជាតិនឹងត្រូវបាត់បង់ជារៀងរហូត ។

**ដូច្នេះ ការបោះឆ្នោតចងក្រងជាឯកសារត្រូវបានស្នើឡើង**

តំណាងមកពីប្រទេសហុល្លង់ដែលនិយាយក្នុងនាមប្រទេសអាល្លឺម៉ង់និងអៀរឡង់ និយាយថា គណៈប្រតិភូទាំងបីនឹងមិនចូលរួមបោះឆ្នោត ។ អ្នកទាំងនេះសម្តែងការសោកស្តាយយ៉ាងខ្លាំងចំពោះទង្វើបែបនេះ ប៉ុន្តែធ្វើយ៉ាងនេះគឺក្នុងគោលបំណងតាំងចិត្តនឹងដោះស្រាយឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងដោយខ្មែរក្រហម ។ ដោយគិតយ៉ាងដូច្នេះ សារជាតិនៃអំពើដ៏ធ្ងន់ធ្ងរដែលសេចក្តីព្រាងចង់ដោះស្រាយ តម្រូវការពិនិត្យពិចារណាថ្លឹងថ្លែងឲ្យបានត្រឹមត្រូវប្រាកដប្រជាពីសំណាក់សហគមន៍អន្តរជាតិ ។ គណៈប្រតិភូរបស់លោកមានការសោកស្តាយយ៉ាងខ្លាំងថា សមាជិកភាពទាំងអស់មិនបានស្តាប់នូវទស្សនៈរបស់ក្រុមប្រឹក្សាអ្នកច្បាប់ទៅលើបញ្ហានេះ ។

តំណាងមកពីប្រទេសកាណាដានិយាយក្នុងនាមប្រទេសនូវែលហ្សេឡង់ថា ខ្លួនមានការសោកស្តាយយ៉ាងខ្លាំងដែលគណៈប្រតិភូរបស់អ្នកស្រីនឹងមិនចូលរួមបោះឆ្នោតទៅលើសេចក្តីព្រាងនេះ ។ យ៉ាងណាក៏ដោយ ប្រទេសកាណាដាព្រួយបារម្ភថា តុលាការមួយទោះបីជាត្រូវផ្តល់អាណត្តិឬការយល់ព្រមពីមហាសន្និបាតអង្គការសហប្រជាជាតិក៏ដោយ គឺជាអង្គការដែលគួរឲ្យជឿទុកចិត្តបាន ដែលមានលទ្ធភាពបំពេញបាននូវអាណត្តិដែលផ្តល់ឲ្យនោះ ព្រមទាំងមានលទ្ធភាពធ្វើឲ្យបានសម្រេចនូវដំណើរការរឿងក្តីពិតប្រាកដដែលនឹងផ្តល់ជាលទ្ធផលចុងក្រោយ ។ អង្គការសហប្រជាជាតិត្រូវតែបានទទួលនូវអាណត្តិដ៏ខ្លាំងមួយ ដើម្បីធានាឲ្យបាននូវដំណើរការរឿងក្តីដែលមានភាពឯករាជ្យនិងទូលំទូលាយ ។ ប្រទេសកាណាដាក៏បានរិះគមធ្យោបាយពន្យារពេល ដើម្បីស្តាប់នូវទស្សនៈរបស់លោកអគ្គលេខាធិការ ឬក្រុមប្រឹក្សាអ្នកច្បាប់ ទៅលើបញ្ហានេះ ។

តំណាងមកពីប្រទេសអាល្លឺម៉ង់និយាយថា គណៈប្រតិភូរបស់លោកនឹងធ្វើអនុប្បវាទទៅលើការប្រើពាក្យនិងអត្ថបទនោះក៏ដូចជាភាពមិនប្រាកដប្រជាផ្សេងៗទៀត ។ ជាអកុសលអត្ថបទនេះគ្មានលក្ខណៈច្បាស់លាស់ទៅលើបទដ្ឋានយុត្តិធម៌ដែលតុលាការស្នើឡើងនឹងប្រតិបត្តិតាមផ្លូវនេះ ។ ប្រទេសអាល្លឺម៉ង់ក៏មានការព្រួយបារម្ភដែរថា កម្ពុជាមិនមែនជាអ្នករ៉ាប់រងសេចក្តីព្រាងនោះទេ ។ លោកសួរថា តើមានមូលហេតុអ្វីខ្លះទៅ?

តំណាងមកពីប្រទេសអៀរឡង់និយាយថា អត្ថបទនេះ "ទុកចន្លោះឲ្យមានភាពមិនប្រាកដប្រជានានាដែលគ្មានប្រយោជន៍" ។ ប្រទេសអៀរឡង់មានការព្រួយបារម្ភជាពិសេសថា សេចក្តីព្រាងនេះនឹងសមស្របទៅនឹងសេចក្តីត្រូវការរបស់អ្នកដែលនឹងត្រូវប្រគល់ភារកិច្ចប្រតិបត្តិ ។ គណៈប្រតិភូរបស់លោកមានក្តីសង្ឃឹមថា នឹងមានឱកាសស្តាប់គំនិតយោបល់របស់តំណាងក្រុមប្រឹក្សាអ្នកច្បាប់ទៅលើបញ្ហានេះ ។

### សេចក្តីសម្រេចត្រូវបានអនុម័តដោយសំឡេងឆ្នោត ១២៣គាំទ្រ ៣៧អនុប្បវាទ (ឧបសម្ព័ន្ធទី VII) ។

តំណាងមកពីប្រទេសស៊ុីសនិយាយថា លោកមានការសោកស្តាយដែលការពន្យារពេលនេះមិនអាចធ្វើទៅបាន ។ លោកបានប្រាថ្នាចង់ទទួលនូវអ្វីដែលលោកអគ្គលេខាធិការចង់ផ្តល់ទៅលើសេចក្តីសម្រេច ហើយមានការសោកស្តាយយ៉ាងខ្លាំង ចំពោះលទ្ធផលចេញពីការពិភាក្សានេះ ។ ឥឡូវនេះអត្ថបទត្រូវបានអនុម័តទាំងមានលក្ខណៈមិនប្រាកដប្រជា និងដែលធ្វើឲ្យគណៈកម្មាធិការមានការបែកបាក់ ។ ក៏ប៉ុន្តែទោះជាយ៉ាងណា លោកសង្ឃឹមថាការចរចានឹងទទួលបានជោគជ័យ ។

តំណាងមកពីប្រទេសស៊ុយអែដនិយាយថា អ្នកស្រីមិនបានបោះឆ្នោតគាំទ្រការពន្យារពេលសេចក្តីសម្រេចនេះឡើយ ទោះបីជាប្រទេសស៊ុយអែដគឺជាអ្នកគាំទ្រដ៏ខ្លាំងខ្លាដល់ការបង្កើតនូវតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមក៏ដោយ ។ ក៏ប៉ុន្តែដើម្បីតម្រូវឲ្យលោកអគ្គលេខាធិការចាប់ផ្តើមការចរចាជាថ្មីដែលត្រូវផ្អែកទៅលើអត្ថបទដែលមិនដោះស្រាយកំហុសនានាចេញពីការចរចារចុងក្រោយនោះ គឺជាការប្រថុយគ្រោះថ្នាក់ធ្វើឲ្យជនដែលប្រព្រឹត្តអំពើឧក្រិដ្ឋនៅក្នុងរយៈកាលនៃរបបខ្មែរក្រហមរួចទោស និងមិនធានាបាននូវបទដ្ឋានច្បាប់អន្តរជាតិ ។

តំណាងមកពីសហរដ្ឋអាមេរិកបានអរគុណដល់អ្នកទាំងឡាយដែលបានខិតខំធ្វើការយ៉ាងខ្លាំងអំពីសេចក្តីសម្រេចនេះ ។ សហរដ្ឋអាមេរិកនៅតែគាំទ្រយ៉ាងខ្លាំងទៅលើតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមមួយដែលមានភាពគួរឲ្យជឿទុកចិត្តបាន ។ ប៉ុន្តែលោកមានការសោកស្តាយដែលគណៈប្រតិភូមកពីប្រទេសកម្ពុជាមិនបានសហការរ៉ាប់រងដល់សេចក្តីសម្រេចនេះ ។

តំណាងមកពីប្រទេសប៊ែលហ្ស៊ិកនិយាយថា ការប្រយុទ្ធប្រឆាំងនឹងការរួចទោស គឺជាអាទិភាពចម្បងដែលជាហេតុធ្វើឲ្យលោកមានការសោកស្តាយចំពោះការចាំបាច់របស់អ្នកទាំងនោះដែលធ្វើអនុប្បវាទដោយសារតែភាពមិនប្រាកដប្រជាមួយចំនួន ។

តំណាងមកពីចក្រភពអង់គ្លេសនិយាយថា លោកបានធ្វើអនុប្បវាទ ទោះបីជាចក្រភពអង់គ្លេសក៏ជាអ្នកចង់ឲ្យលោកអគ្គលេខាធិការត្រឡប់មកចរចាជាមួយនឹងកម្ពុជាវិញក៏ដោយ ។ ការខកខានរបស់កម្ពុជាមិនបានសហការរ៉ាប់រងសេចក្តីសម្រេចនេះ គឺជាសញ្ញាណបញ្ជាក់អំពីកង្វះការតាំងចិត្តដោយស្មោះស្ម័គ្រ ។

តំណាងមកពីប្រទេសអូទ្រីសនិយាយថា លោកបានបោះ

ឆ្នោតគាំទ្រដល់សេចក្តីសម្រេចនេះ ដើម្បីឲ្យតុលាការកាត់ទោសខ្មែរក្រហមបានបញ្ចប់នូវវប្បធម៌នៃភាពរួចទោស ។ ក៏ប៉ុន្តែប្រទេសអូទ្រីសនៅតែមានការព្រួយបារម្ភអំពីតុលាការ ថាមិនអាចបំពេញបាននូវបទដ្ឋានច្បាប់អន្តរជាតិ ។

តំណាងមកពីប្រទេសឡិចថេនស្តេននិយាយថា ប្រទេសរបស់លោកគឺជាអ្នកគាំទ្រចំពោះយុត្តិធម៌អន្តរជាតិនិងតុលាការជាយូរយាណាស់មកហើយ ។ ការគាំទ្របែបនេះមានសារសំខាន់ណាស់ក្នុងការពង្រឹងនីតិរដ្ឋជាអន្តរជាតិ និងនាំមកនូវយុត្តិធម៌សម្រាប់ប្រជាជនកម្ពុជា ។ រដ្ឋាភិបាលកម្ពុជាចំបាច់ត្រូវតែមានការតាំងចិត្តឲ្យមាំមួន ។ ប្រការនេះនឹងស្តែងឲ្យឃើញច្បាស់ប្រសិនបើកម្ពុជាសហការរ៉ាប់រងសេចក្តីសម្រេចនេះ ។ វាជាការគួរឲ្យសោកស្តាយដែរ ដែលគណៈកម្មាធិការនេះមិនបានស្តាប់គំនិតយោបល់របស់អគ្គលេខាធិការទៅលើសេចក្តីព្រាង ។

តំណាងមកពីប្រទេសអូស្ត្រាលីមានការតាំងចិត្តកាត់ទោសមេដឹកនាំខ្មែរក្រហម និងមានការខកចិត្តដែលថា ការចរចាត្រូវបានកាត់ផ្តាច់រវាងរដ្ឋាភិបាលកម្ពុជា និងអគ្គលេខាធិការនៅដើមឆ្នាំនេះ ។ ក្នុងខណៈដែលលោកសង្ឃឹមថាអត្ថបទនេះនឹងផ្តល់អាណត្តិមាំទាំដល់អគ្គលេខាធិការដែលបានអនុម័តរួចរាល់ហើយយ៉ាងណាក៏ដោយ លោកបានជំរុញឲ្យរដ្ឋាភិបាលកម្ពុជាធ្វើកិច្ចសហប្រតិបត្តិការបង្កើតនូវតុលាការមួយដែលគួរឲ្យទុកចិត្តបាន ។

### ឧបសម្ព័ន្ធទី VI

ការបោះឆ្នោតពន្យារពេលផ្តល់សេចក្តីសម្រេចទៅលើបញ្ហាតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម

ញត្តិគាំទ្រការពន្យារពេលផ្តល់សេចក្តីសម្រេចទៅលើសេចក្តីសម្រេចព្រាងស្តីពីការបង្កើតតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម (ឯកសារលេខ A/C.3/57/L.70) ត្រូវបានប្រឆាំងជាទាស់ដោយសំឡេងឆ្នោត១៤ទល់នឹង៩០ និងអនុប្បវាទ៥៩ ។

#### *ប្រទេសដែលគាំទ្រ(ដល់ការពន្យារពេល)៖*

បែលហ្ស៊ិក, កាណាដា, ហ្វាំងឡង់, អាល្លឺម៉ង់, អៀរឡង់, ហូឡង់, ឡិចថេនស្តេន, លុចសំបួរ, ហុល្លង់, ស៊ុយអែដ, នូវែលសេឡង់, ន័រវេ, ស្វ៊ីស, ចក្រភពអង់គ្លេស ។

#### *ប្រទេសដែលប្រឆាំង(នឹងការពន្យារពេល)៖*

អាហ្វហ្គានីស្ថាន, អង់ដូរ៉ាស់, អង់ហ្គោឡា, បង់ក្លាដេស, អាហ្សែបៃហ្សង់, អង់ទីហ្គ័រ និង បាប៊ូដា, ប៊ូតង់, ប្រ៊ុយណេ, បូស្នៀ-ហឺស៊ីហ្គោវីណា, ដារូសាឡឹម, បឺគីណាហ្វាសូ, ប៊ូរុនឌី, កម្ពុជា, ឆាដ, ចិន, កូម៉ូរ៉ូស, សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកុងហ្គោ, គុយបា, ស៊ីព្រូស, កុងហ្គោ, ជីប៊ូទី, អេក្វាទ័រ, អេរីត្រេ, អេត្យូពី, ហ្វ៊ីជី, បារាំង, ហ្គាបុង, ហ្គាមប៊ី, ហ្សកចា, ក្រិច, ហ្គ្រេណាដា, ហ្គាតាម៉ាឡា, ឥណ្ឌា, ឥណ្ឌូនេស៊ី, ជប៉ុន, អ៊ីស្រាអែល, អ៊ីតាលី, កាហ្សាក់ស្តង់, កេនយ៉ា, សាធារណរដ្ឋប្រជាធិបតេយ្យឡាវ, លីបេរីយ៉ា, ម៉ាឡាវី, ម៉ាឡេស៊ី, ម៉ាលឌីវេ, ម៉ាហ្សាលអាយឡែន, ម៉ូរីតានី, ម៉ូរីតទីស, ម៉ិចស៊ីកូ, ម៉ូណាកូ, ម៉ុងហ្គោលី, ម៉ូហ្សំប៊ិក, មីយ៉ាន់ម៉ា, ណាមីប៊ី, ណេប៉ាល់, នីការ៉ាហ្គ័រ, នីហ្សេរីយ៉ា, ប៉ារ៉ាហ្គាយ, ប៉េរូ, ហ្វីលីពីន, ប៉ូឡូញ, ព័រទុយហ្គាល់, រ៉ូម៉ានី, សហព័ន្ធរុស្ស៊ី, សង់គីត និង ណេវីស, សង់លូហ្ស៊ា, សាម៉ូ, អារ៉ាប់ប៊ី-សាអូឌីត, សេណេហ្គាល់, សេរ៉ាឡេអូន, សិង្ហបុរី, សូម៉ាលី, អាហ្វ្រិកខាងត្បូង, អេស្ប៉ាញ, ស្រីលង្ការ, ស៊ូដង់, សូរីណាម, ស្វាហ្ស៊ីឡង់, ស៊ីរី, ថៃ, តូហ្គោ, ទុយនេស៊ី, ទួរគី, ទូវ៉ាលូ, អ៊ូហ្គង់ដា, សហភាពសាធារណរដ្ឋតង់ហ្សានី, អ៊ូរ៉ាហ្គាយ, សហរដ្ឋអាមេរិក, វៀតណាម, ហ្សាមប៊ី, ហ្ស៊ីមបាវេ ។

#### *ប្រទេសដែលអនុប្បវាទ៖*

អាល់បានី, អាល់ហ្សេរី, អាហ្សង់ទីន, អាមេនី, អូស្ត្រាលី, អូទ្រីស, បាហាម៉ាស, បាបាឌូស, បេឡារូស, បេលីហ្សេ, បេនីន, ប៊ុលលីវី, បូតស្វាណា, ប្រេស៊ីល, ប៊ុលហ្គារី, កាមីរូន, ខេបវែឌី, ឈីលី, កូឡុំប៊ី, កូស្តារីកា, កូដឺវ័រ, ក្រូអាស៊ី, សាធារណរដ្ឋឆែក, សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ, ដាណឺម៉ាក, សាធារណរដ្ឋដូមីនីកា, សាធារណរដ្ឋដូមីនីកា, អេហ្ស៊ីប, អេស្តូនី, ហ្គាណា, ហ្គីនៀ-ប៊ីសសូ, ហ្គូយ៉ាណា, ហុងគ្រី, អាយឡែន, អ៊ីរ៉ង់, ចាម៉ៃកា, គូវេត, ឡាតវី, ឡេបេណុន, ឡេសូថូ, លីថូនី, ម៉ាដាហ្គាស្កា, ម៉ាលី, ម៉ាល់តា, ម៉ូរ៉ូកូ, ប៉ាគីស្ថាន, ប៉ាណាម៉ា, កាតា, សាធារណរដ្ឋកូរ៉េ, សាធារណរដ្ឋម៉ូលដូវ៉ា, រ៉្វាន់ដា, ស្លូវ៉ាគី, សានម៉ារីណូ, ស្លូវ៉ានី, ទ្រីនីដាត និង តូបាហ្គោ, អ៊ុយក្រែន,

វេណេហ្ស៊ុយអេឡា, យូហ្គោស្លាវី, សាធារណរដ្ឋម៉ាសេដូនីនៃអតីតយូហ្គោស្លាវី ។

**ប្រទេសអវត្តមានៈ**

បារ៉េន, សាធារណរដ្ឋអាហ្វ្រិកកណ្ដាល, ហ្គីណេអាក្វាទ័រ, ហ្គីណេ, ហៃទី, ហុងឌូរ៉ាស់, អ៊ីរ៉ាក់, គីរីបាទី, គីហ្គីស្តង់, លីបេរីយ៉ា, រដ្ឋសហព័ន្ធមីក្រូនេស៊ី, ណូរូ, នីហ្សេ, អូម៉ាន, ប៉ាឡូ, ប៉ាពូញ៉ូហ្គីណេ, សង់វ៉ាំងសង់ និង គ្រីណាឌីន, សៅតូម៉េ និង ប្រាំងស៊ីប៉េ, សីឆេឡេស, សូឡូម៉ុងអាយឡែន, តាហ្ស៊ីគីស្តង់, ទីម័រឡេស្តេ, តុងហ្គា, ទូមេនីស្តង់, សហភាពអារ៉ាប់អ៊ីមីរ៉ាត, អ៊ូបេគីស្តង់, វ៉ានូទូ, យេមែន ។ (ចប់ឧបសម្ព័ន្ធទី VI)

**ឧបសម្ព័ន្ធទី VII**

ការបោះឆ្នោតលើការបង្កើតតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម

សេចក្តីសម្រេចព្រាងស្តីពីតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម (ឯកសារលេខ A/C.3/57/L.70) ត្រូវបានអនុម័តដោយសំឡេងឆ្នោត១២៣ទល់នឹងសូន្យ និងមានអនុប្បវាទ៣៧ ។

**អ្នកដែលបោះឆ្នោតគាំទ្រ(សេចក្តីសម្រេចចិត្ត)ៈ**

អាល់ហ្សេរី, អង់ដូរ៉ាស់, អង់ទីហ្គ័រ និង បាប៊ូដា, អូទ្រីស, អាហ្សង់ទីន, អាមេនី, អូស្ត្រាលី, អាស៊ែបៃហ្សង់, បាហាម៉ាស, បង់ក្លាដេស, បាបាដូស, បេលីហ្សេ, ប៊ូតង់, បូលីវី, ប៊ូតស្វាណា, បូស្នៀ និង ហឺស៊ីហ្គោវីណា, ប្រ៊ុយណេដារូសាឡឹម, ប៊ូហ្គារី, ប៊ីគីណាហ្វាសូ, ប៊ូរុនឌី, កម្ពុជា, ឆាដ, ឈីលី, ចិន, កូឡុំប៊ី, កូម៉ូរូស, កូឌីវ័រ, គុយបា, ស៊ីព្រុស, សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកុងហ្គោ, ជីប៊ូទី, ដូមីនីកា, អេក្វាឌ័រ, អេហ្ស៊ីប, សាធារណរដ្ឋដូមីនីកា, អេលសាល់វ៉ាឌ័រ, អេរីតេទ្រា, អេត្យូពី, ហ្វីជី, បារាំង, ហ្គាបុង, ហ្សកហ្ស៊ី, ហ្គាណា, ក្រិច, ហ្គាតេម៉ាឡា, ហ្គីណេ-ប៊ីសសូ, ហ្គូយ៉ាណា, ហៃទី, ហុងឌូរ៉ាស, ឥណ្ឌា, ឥណ្ឌូនេស៊ី, អ៊ីរ៉ង់, អ៊ីស្រាអែល, អ៊ីតាលី, ចាម៉ៃកា, ជប៉ុន, ហ្សកដង់, កាហ្សាក់ស្តង់, គូវ៉េត, លីបេណុន, ឡេសូថូ, សាសាធារណរដ្ឋ ប្រជាមានិតប្រជាធិបតេយ្យឡាវ, លីបេយ៉ា, ម៉ាដាហ្គាសកា, ម៉ាឡាវី, ម៉ាឡេស៊ី, ម៉ាលឌីវ៉េ, ម៉ាលី, ម៉ាលតា, ម៉ូរីតានី, ម៉ូរីទីស, ម៉ិកស៊ិកូ, ម៉ូណាកូ, ម៉ុងហ្គោលី, ម៉ូរ៉ុក្កូ, ម៉ូហ្សំប៊ិក, មីយ៉ាន់ម៉ា, ណាមីប៊ី, ណេប៉ាល់, នីការ៉ាហ្គ័រ, ប៉ាគីស្ថាន, ប៉ាណាម៉ា, ប៉ារ៉ាហ្គាយ, ប៉េរូ, ហ្វីលីពីន, ប៉ូឡូញ, ព័រទុយហ្កាល់, កាតា, សាធារណរដ្ឋម៉ុលដូវ៉ា, រ៉ូម៉ានី, សហព័ន្ធរុស្ស៊ី, វ៉ាន់ដា, សង់លូហ្ស៊ា, សង់ម៉ារីណូ, អារ៉ាប់ប៊ី-សាអូឌីត, សេណេហ្កាល់, សេរ៉ាឡេអូន, សិង្ហបុរី, ស្លូវ៉ាគី, សូម៉ាលី, អាហ្វ្រិកខាងត្បូង, អេស្ប៉ាញ, ស្រីលង្កា, ស៊ូដង់, ស៊ូរីណាម, ស្វាហ្ស៊ីឡង់, ស៊ីរី, ថៃ, តូហ្គោ, ទ្រីនីដាដ និង តូបាហ្គោ, ទុយនេស៊ី, ទួរគី, ទូវ៉ាលូ, អ៊ូហ្កង់ដា, អ៊ុយក្រែន, សហភាពសហរដ្ឋអាមេរិក, អ៊ូរ៉ាហ្គាយ, វ៉េណេហ្ស៊ុយអេឡា, វៀតណាម, សាធារណរដ្ឋតង់ហ្សានី, ហ្សាមប៊ី, ហ្ស៊ីមបាវ៉េ ។

**ប្រទេសដែលបោះឆ្នោតប្រឆាំងៈ** គ្មាន ។

**ប្រទេសអនុប្បវាទៈ**

អាល់បានី, អង់ហ្គោឡា, បេឡារូស, ប៉ែលហ្ស៊ិក, បេនីន, ប្រេស៊ីល, កាមឺរូន, កាណាដា, ខេបវែឌី, កូស្តារីកា, ក្រូអាស៊ី, សាធារណរដ្ឋឆេក, ដាណឺម៉ាក, អេស្តូនី, ហ្វាំងឡង់, ហ្គាមប៊ី, អាល្លឺម៉ង់, ហុងគ្រី, អាយឡែន, អៀរឡង់, ហុល្លង់, ឡាវី, ឡិចថេនស្តេន, លីថូនី, លុចសំបួរ, ម៉ាហ្សាល់អាយឡែន, ណូវែលហ្សេឡង់, ន័រវ៉េ, សាធារណរដ្ឋកូរ៉េ, សាម៉ូ, ស្លូវេនី, ស៊ុយអែដ, ស្វ៊ីស, សហភាពអារ៉ាប់អ៊ីមីរ៉ាត, ចក្រភពអង់គ្លេស, សាធារណរដ្ឋម៉ាសេដូនីនៃអតីតយូហ្គោស្លាវី, និង យូហ្គោស្លាវី ។

**ប្រទេសអវត្តមានៈ**

អាហ្វហ្គានីស្ថាន, បារ៉េន, សាធារណរដ្ឋអាហ្វ្រិកកណ្ដាល, កុងហ្គោ, រដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ, ហ្គីណេអាក្វាទ័រ, ហ្គ្រេណាដា, ហ្គីណេ, អ៊ីរ៉ាក់, កេនយ៉ា, គីរីបាទី, គីហ្គីស្តង់, លីបេរីយ៉ា, រដ្ឋសហព័ន្ធមីក្រូនេស៊ី, នូរូ, នីហ្សេ, អូម៉ាន, ប៉ាឡូ, ប៉ាពូញូវហ្គីណេ, សង់គីត និង ណេវីស, សូឡូម៉ុងអាយឡែន, ហ្សង់វ៉ាំងសង់ និង គ្រេណាឌីន, សៅតូម៉េ និង ប្រាំងស៊ីប៉េ, សីឆេឡេស, តាត់ហ្ស៊ីគីស្តង់, ទីម័រឡេស្តេ, តុងហ្គា, អ៊ូបេគីស្តង់, ទួរមែននីស្តង់, វ៉ានូទូ, យេមែន ។

(ចប់ឧបសម្ព័ន្ធ VII)

**ចប់សេចក្តីដកស្រង់**

**ប្រែសម្រួលក្រៅផ្លូវការដោយៈ សូ ប៊ុនស៊ី**

# បទសម្ភាសន៍ជាមួយ សម្តេចព្រះឧត្តមបញ្ញា ជួន ផន់ នន្ទិយោ ព្រះចៅអធិការវត្ត មហានន្ទិយ នេរញ្ញ រារាមនិវេទន ហៅ វត្តព្រែកប្រាំង


សម្តេចព្រះឧត្តមបញ្ញា ជួន ផន់ នន្ទិយោ

***សំណួរៈ*** ខ្ញុំព្រះករុណាសូមសួរទាក់ទងទៅនឹងរឿងតុលាការខ្មែរក្រហមដែលដំណើរការជាច្រើនឆ្នាំកន្លងមកនេះ តើសម្តេចទ្រង់ព្រះតម្រិះយ៉ាងណាដែរ?

***ចម្លើយៈ*** ក្នុងលោកយើងនេះមានច្បាប់ពីរ លោកនីតិប្រតិបត្តិផង និងធម្មានីតិប្រតិបត្តិផង ។ ដូច្នេះ ទោះបីលោកជាខ្មែរក្រហម ឬលោកជាប្រជារាស្ត្រទូទាំងសកលលោកក៏ដោយចុះ កាលបើមានភាវៈពូតផ្តុំរស់រានជាជីវិតមនុស្សហើយ គ្រប់មនុស្សភាវៈមិនអាចនៅក្រៅបន្ទាត់ច្បាប់លោកនិងច្បាប់ធម៌បានទេ ។ សូមជម្រាបជូនថា ទោះជននោះប្រភេទណា គណៈណា ក្រុមពួកណាក៏ដោយចុះ ក៏ស្ថិតនៅលើច្បាប់លោកនិងច្បាប់ធម៌ដូចគ្នា ។ ភាវៈកើតមកជាមនុស្សសិទ្ធិរស់នៅជាមនុស្ស ស្រឡាញ់សិទ្ធិយ៉ាងណា ស្រឡាញ់ជីវិតយ៉ាងណា ប្រជាជននៅក្នុងព្រះរាជាណាចក្រកម្ពុជាក្តី ប្រជាជននៅលើសកលលោកក្តី ក៏ស្រឡាញ់សិទ្ធិនិងជីវិតមរតកថ្លៃថ្នូរដូចៗគ្នា ។ ដូច្នេះច្បាប់លោកនិងច្បាប់ធម៌បានន័យថា ជាលោកបាលដែលរក្សាជីវិតិន្ទ្រីយ៍របស់មនុស្សឲ្យរស់រានមានជីវិត ដោយមានច្បាប់ទាំងពីរនេះជាគោលអាង ។ ចំពោះអ្នកដែលធ្វើអំពើមិនល្អមកលើជីវិតមនុស្ស ឈ្មោះថាខុសនឹងច្បាប់លោក ខុសនឹងច្បាប់ធម៌ ។

***សំណួរៈ*** សូមសម្តេចទ្រង់ព្រះមេត្តាពន្យល់បន្ថែមថា តើច្បាប់លោកនិងច្បាប់ធម៌មានន័យថាដូចម្តេច?

***ចម្លើយៈ*** ពាក្យថាច្បាប់លោកគឺសំដៅរកព្រះសភាជាតិ មាននីតិរដ្ឋធម្មនុញ្ញនៃប្រទេសនីមួយៗ ជាពិសេសគឺសភាជាតិនៃព្រះរាជាណាចក្រកម្ពុជា មានច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា នេះជាច្បាប់លោក ។ ហើយច្បាប់ធម៌នៅលើផ្ទៃនៃព្រះរាជាណាចក្រកម្ពុជា គឺស្ថិតនៅលើធម្មនីតិប្រតិបត្តិព្រះត្រៃបិដក ដែលព្រះសម្មាសម្ពុទ្ធចារឹកទុកជាវដ្តប្រតិបត្តិមកលើប្រជារាស្ត្រកម្ពុជាប្រតិបត្តិកន្លងមកហើយ ។ ដូច្នេះបើមនុស្សណាម្នាក់ប្រព្រឹត្តនូវអំពើមិនល្អ ខុសឆ្គងនឹងច្បាប់លោកនិងច្បាប់ធម៌ហើយ ឈ្មោះថាបុគ្គលនោះមិនគោរពតាមច្បាប់លោក មិនគោរពតាមច្បាប់ធម៌ ។ អ្វីចឹងច្បាប់លោកនិងច្បាប់ធម៌ជាតុលាការនៃផ្ទៃសកលទាំងមូល ក៏ដូចជាផ្ទៃនៃព្រះរាជាណាចក្រកម្ពុជាទាំងមូល ។ អ្វីដែលខុសទៅហើយ គឺបុគ្គលដែលខុសគប្បីដឹងខ្លួនថាធ្វើទៅខុសទាំងច្បាប់លោកទាំងច្បាប់ធម៌ ។ អ៊ីចឹងសេចក្តីខុសនោះវាមានពីរ មួយបុគ្គលដែលធ្វើខ្លួនផ្ទាល់ខុស មួយទៀតបុគ្គលដែលទទួលការសាបព្រោះពីជនដទៃមកក៏ស៊ីឈ្នួលបម្រើគេ ឬក៏ឱនទៅឲ្យគេទឹមធ្វើជាប្រការណាមួយដោយទៅធ្វើអំពើមិនល្អនោះជំនួសគេ ។ វាមានពីរបញ្ហាហ្នឹង ។ ដូច្នេះ ទាំងអ្នកបញ្ជាឲ្យធ្វើ និងអ្នកកំពុងតែធ្វើឬធ្វើរួចហើយគឺសន្មតឲ្យឈ្មោះថា ខុសនីតិលោកផង ខុសនីតិធម៌ផង ។ ច្បាប់លោកនិងច្បាប់ធម៌ជាសភាវិនិច្ឆ័យការរស់នៅរបស់មនុស្សលោកជាស្វ័យប្រវត្តិ ដោយមិនចាំបាច់អ្នកណារាយការណ៍ ដោយមិនបាច់អ្នកណាចាប់អូស ដោយមិនចាំបាច់អ្នកណាបង្ខំព្រោះកិរិយាខ្លួនដែលបានធ្វើដោយផ្ទាល់រៀងៗខ្លួន ។

***សំណួរៈ*** តើច្បាប់លោកគឺច្បាប់របស់ប្រទេស ហើយច្បាប់ធម៌គឺច្បាប់“កម្ម-ផល”ដែលពុទ្ធឱវាទបានចែងមក ពិតមែនទេសម្តេច?

***ចម្លើយៈ*** ចម្រើនពរ! សត្វអាស្រ័យកម្ម កាលណាបើកើតមកក៏ធម៌បង្កើត តែច្បាប់លោកក៏អមដំណើរ ។ អ៊ីចឹង កាលណាដែលខ្លួនធ្វើខុស យើងជាអ្នកអាស្រ័យកម្មគឺគួរទទួលខុសទាំងច្បាប់ធម៌ គួរទទួលខុសទាំងច្បាប់លោក ។ ដោយស្វ័យប្រវត្តិមិនចាំបាច់គេបង្ខំ ។ ព្រះពុទ្ធអង្គសម្តែងថា អត្តាហិ អត្តនោនាថោ គឺ“ខ្លួនជាទីពឹងរបស់ខ្លួន” ព្រោះខ្លួនកើតមកជាមនុស្សភាវៈ

ជាអ្នកអាស្រ័យកម្មផល ។ ច្បាប់លោកក្តី ច្បាប់ធម៌ក្តី ជាត្រីវិស័យមួយសម្រាប់ចង្អុលជីវិតិន្ទ្រីយ៍មរគករស់នៅរបស់សត្វ ។ អីចឹងសត្វគួរគប្បីដឹងថាខ្លួនធ្វើទៅគួរ ដឹងថាខ្លួនធ្វើទៅមិនគួរ ។ រីឯ ធ្វើទៅគួរនោះគឺផ្តល់ផលប្រយោជន៍យ៉ាងណាចំពោះខ្លួន តែងពិចារណាដឹងស្រាប់ ដែលប្រព្រឹត្តទៅមិនគួរនោះវាផ្តល់ផលវិបាកយ៉ាងណា ក៏លោកទាំងអស់ជ្រាប ។ ដូច្នេះចំពោះវិនិច្ឆ័យទៅលើបុគ្គលខុស ឲ្យទទួលស្គាល់ថាតើច្បាប់លោក ច្បាប់ធម៌ហ្នឹងសម្រាប់អ្វី ។ អីចឹងច្បាប់លោកច្បាប់ធម៌ជាតុលាការមរតកតាំងពីយើងនៅក្នុងឧទរមាតាម្ល៉េះ ។ កាលដែលយើងនៅក្នុងឧទរមាតា ប្រសិនបើមាតាហ្នឹងខុសនឹងច្បាប់លោក ខុសនឹងច្បាប់ធម៌ ប្រហែលជាគាត់ទម្លាក់យើងឲ្យស្លាប់តាំងពីនៅក្នុងផ្ទៃម្ល៉េះ ។ ដូច្នេះ បុគ្គលដែលរស់ជាមនុស្សភាវៈ មានជីវិតិន្ទ្រីយ៍រស់ដូចគ្នាហើយ មិនគួរគប្បីធ្វើអ្វីឲ្យប៉ះពាល់ដល់ជីវិតដែលនៅក្នុងផ្ទៃ ឬជីវិតដែលកើតមករស់នៅបច្ចុប្បន្ននេះ ។ គួរតែយកនីតិទាំងពីរនេះមកវិនិច្ឆ័យដោយខ្លួនផ្ទាល់ៗ ទើបស័ក្តិសមទៅជាអ្នកស្គាល់មនុស្សលោកពិតប្រាកដ ស្គាល់មរគកជីវិតមនុស្សលោកពិតប្រាកដ ស្គាល់សិទ្ធិសេរីភាពនៃការរស់នៅរបស់មនុស្សពិតប្រាកដ ។

**សំណួរៈ** ចំពោះមេខ្មែរក្រហម តើអាចលើកលែងខាងច្បាប់លោក ហើយគេទទួលត្រឹមតែខាងច្បាប់ធម៌ ឬក៏អាចលើកលែងខាងច្បាប់ធម៌ ហើយឲ្យគេទទួលកំហុសតាមច្បាប់លោក បានទេសម្តេច?

**ចម្លើយៈ** ទាំងពីរហ្នឹងមិនអាចលើកលែងបាន ទាំងច្បាប់លោក ទាំងច្បាប់ធម៌ ព្រោះអំពើរបស់ខ្លួនធ្វើផ្ទាល់ ។ បើខ្លួនខុសធម៌រួចហើយ អាក្រក់រួចហើយ ។ ច្បាប់លោកអីចឹងដែរ ខ្លួនខុសច្បាប់ក្នុងលោកជាមួយនឹងច្បាប់ធម៌ដែរ ។ ដូច្នេះមិនអាចថាធម៌នោះឲ្យយើងស្រាលវិញ ឬឲ្យរួចខ្លួននោះទេ ព្រោះខ្លួនធ្វើខុសហើយ ។ ច្បាប់លោកក៏អីចឹង ខ្លួនឯងបានធ្វើខុសហើយមិនអាចលោកនោះអនុគ្រោះថាឲ្យលោករួចខ្លួនពីអំពើអាក្រក់នោះទេ វាបន្សល់ទុកឯកសារ ។ ដូច្នេះសាមីជនដែលធ្វើខុស ទោះបីមនុស្សប្រភេទណាក៏ដោយចុះ ឲ្យតែធ្វើខុស គួរគប្បីសរសេរលិខិតណាមួយចេញដោយផ្ទាល់ខ្លួន ឬចម្លើយណាមួយចេញដោយផ្ទាល់ខ្លួន ។ ហ្នឹងសន្មតថាខ្លួនទទួលកំហុស សុំឲ្យប្រជារាស្ត្រទាំងអស់ សុំឲ្យរាជការទាំងអស់ មេត្តាអនុគ្រោះដល់លោក ឬក៏មិនអនុគ្រោះដល់លោក ទៅតាមច្បាប់ធម៌និងច្បាប់លោក ។ មិនអាចប៉ាវថា បុគ្គលហ្នឹងខុសតិច ហើយបុគ្គលគ្នាល្អនោះច្រើន បុគ្គលរងគ្រោះហ្នឹងតិច បុគ្គលដែលមិនរងគ្រោះនោះច្រើន ។ សាមីជនដែលខុសនោះត្រូវមានឆន្ទៈយ៉ាងណាដើម្បីបំភ្លឺដល់រាជការ ច្បាប់លោក បំភ្លឺដល់ច្បាប់ធម៌ សម្រាប់ប្រតិបត្តិកុំឲ្យសល់ឯកសារបន្តទៅគំរូជនអាក្រក់ ។

**សំណួរៈ** តើបុគ្គលដែលធ្វើខុសអាចត្រឹមតែសរសេរសេចក្តីថ្លែងនូវកំហុសរបស់ខ្លួន ដោយមិនចាំបាច់ឡើងតុលាការដើម្បីទទួលការវិនិច្ឆ័យក្តីមែនទេ?

**ចម្លើយៈ** ជាការពិត បើហ៊ានសរសេរគឺបានន័យថា ទឹកខ្មៅនិងសរសេរវាជាតុលាការ ។ ហើយការលើកលែងនិងមិនលើកលែង លុះត្រាតែសរសេរប្រាប់ឲ្យគេដឹងនូវឆន្ទៈរបស់ខ្លួនធ្វើអាក្រក់ម៉េចៗ ខ្លួនសុំទោសចំពោះការអាក្រក់នោះ តើប្រជារាស្ត្រទាំងអស់យោគយល់ទេ អនុគ្រោះឲ្យទេ ។ បើរាស្ត្រនោះមិនអនុគ្រោះទេ ហ្នឹងបានន័យថា យើងឃើញទឹកតាងនៃការសរសេរនេះ ។ ហ្នឹងវិនិច្ឆ័យទៅលើខ្លួនសរសេរផ្ទាល់ មិនមានតុលាការណាទៅវិនិច្ឆ័យឲ្យទេ គឺខ្លួនអ្នកសរសេរទទួលកំហុស ហើយសុំទោសខ្លួនយើង ។ ដល់សរសេរកំហុសខ្លួនឯង សុំទោសខ្លួនឯង តើអ្នកដែលរងគ្រោះទាំងអស់នោះគេឯកភាពទេ ។ ដោយមិនបាច់ចាំបង្ខំចិត្ត ជាស្វ័យប្រវត្តិ ។

**សំណួរៈ** តើបុគ្គលម្នាក់ដែលបានធ្វើខុសហើយ នឹងទទួលផលនៃអំពើរបស់ខ្លួនដូចម្តេចខ្លះ?

**ចម្លើយៈ** ប្រាកដជាអំពើបាបហើយ បាបក្នុងលោកត្រូវអាប់យស បាបទៅបរលោកគឺមាន នរក អវិចី តិរច្ឆាន ប្រេតជាដើម ។ យើងធ្វើកំហុសយើងត្រូវអាប់យស បច្ចុប្បន្នត្រូវអាប់យស ឬក៏តាមសកលលោកគេមិនអនុគ្រោះ ត្រូវគេធ្វើបែបយ៉ាងណាទៅតាមច្បាប់នីតិរដ្ឋគេ ដែលសឹងមានបច្ចុប្បន្ន ។ រីឯច្បាប់ធម៌គឺបាប ។ ដូច្នេះសាសនាព្រះពុទ្ធមិនមែនជាសាសនាអរូបធម៌ទេ ជាសាសនារូបធម៌ពិតប្រាកដ ។ រឿងអនុគ្រោះឬមិនអនុគ្រោះនោះស្ថិតនៅលើសាមីជននិងសាមីជន ជនរងគ្រោះនិងជនប្រព្រឹត្ត ។ បើលោកអ្នកសាមីខ្លួនដែលរងគ្រោះ យល់ឃើញថាមិនគួរធ្វើដល់ខ្លួន ខ្លួននឹងរៀបចំច្បាប់យ៉ាងណាឲ្យ

ស័ក្តិសមនឹងទោសកំហុសរបស់អ្នកនោះ ។ អាហ្នឹងរឿងខ្លួនទាំងពីរ ។ អ៊ីចឹងអ្នកទាំងពីរត្រូវមានការផ្តាច់ផង ក៏ត្រូវមានការអង្វរករផង ត្រូវមានការសម្របសម្រួលផង ត្រូវមានការចរចារផង ត្រូវមានសន្តិភាពផង ត្រូវមានការលះផ្តាច់ផង ស្ថិតតែនៅលើសាមីខ្លួនទាំងពីរ ។ ប៉ុន្តែសម្របសម្រួលមានពីរ មួយសម្របសម្រួលក្រឹត្យច្បាប់យកទោសវិញ មួយសម្របសម្រួលសន្តិវិធីឲ្យរស់មួយជីវិត គ្រាន់តែរស់ ។

**សំណួរៈ** ខ្ញុំព្រះករុណាសូមឲ្យសម្តេចព្រះប្រទានឱវាទថាតើយើងគួរតែធ្វើយ៉ាងម៉េចដើម្បីឲ្យជនរងគ្រោះបានស្ងប់ចិត្ត ហើយអាចផ្សះផ្សារួមរស់នៅក្នុងសង្គមមួយជាមួយនឹងអ្នកដែលធ្លាប់បានធ្វើបាបខ្លួនពីពេលមុនមក?

**ចម្លើយៈ** តាមសាសនាព្រះពុទ្ធជាអង្គម្ចាស់ ត្រូវធ្វើលិខិតប្រវត្តិមួយ ដើម្បីឲ្យជនទាំងពួងមានការរាងចាល ។ ទីមួយតាមផ្លូវធម៌តាមរយៈវិន័យដែលតឹងរ៉ឹង ។ បើជាអ្នកបួស ប្រសិនបើប៉ះពាល់ដល់ជីវិតហើយ គេឲ្យឈ្មោះថាបុគ្គលនោះចាញ់ ។ ពាក្យថា "ចាញ់" មួយម៉ាត់ អធិប្បាយតាមច្បាប់ធម៌ច្រើនប្រភេទ ចាញ់ដោយមិនអាចរស់នៅបាន ចាញ់ដោយរស់នៅបាន ចាញ់ដោយមានការឃុំគ្រងណាមួយ ។ ពាក្យថា "ចាញ់" មួយម៉ាត់ហ្នឹងគឺបានន័យច្រើនណាស់ ច្រើនប្រភេទ អធិប្បាយទៅច្រើនប្រភេទ ។ បើវិនិច្ឆ័យបង្រួបបង្រួមទៅថា គួរតែនឹងរក្សាបែបណាដើម្បីឲ្យសុខចិត្តសុខកាយទាំងសងខាង វិនិច្ឆ័យទៅតាមផ្លូវធម៌ ប៉ុន្តែធម៌មួយលោកសម្តែងថាខុសគឺខុស ត្រូវគឺត្រូវ ។

**សំណួរៈ** តើធ្វើយ៉ាងណាដើម្បីឲ្យចិត្តរបស់ជនរងគ្រោះបានស្ងប់ ដើម្បីកុំឲ្យមានកំហឹងទៅលើអ្នកដែលប្រព្រឹត្តខុសមកលើខ្លួនទៀត?

**ចម្លើយៈ** បើតាមច្បាប់ធម៌ ក្រណាស់ ។ គ្រប់បុគ្គលនឹងរំងាប់បានដោយធម៌ ច្រើនតែរំងាប់បានដោយលោកានីតិវិធា និងរំងាប់បានដោយការដណ្តើមយកវិញ ទោះបីបុគ្គលនោះរស់ក្តីស្លាប់ក្តីក៏ដណ្តើមយកវិញ ។ វាមានន័យរបស់វាអ៊ីចឹង ដូច្នេះដើម្បីសម្របសម្រួលច្បាប់លោកយកមកប្រតិបត្តិដើម្បីស្វែងរកការសម្របសម្រួលនោះ គួរតែសាមីជនដែលធ្វើអំពើអាក្រក់នោះព្រមព្រៀងសុខចិត្តចំពោះមុខប្រជារាស្ត្រនិងចំពោះមុខអន្តរជាតិ ទើបអាចសម្របសម្រួលបាន ។ បើប្រជារាស្ត្រយើងរងគ្រោះម៉្លឹងហើយ គេនៅមានសន្ទុះសង្ស័យ ។ បើអ្នកនោះសារភាពឲ្យសកលលោកឮ ហើយសកលលោកគេនឹងអនុគ្រោះ ទើបរាស្ត្រហ្នឹងយោលទៅតាមសេចក្តីនោះបាន ។ អ៊ីចឹងបើមិនមានឯកសារពីសកលលោកទេ នៅតែមិនស្ងប់ ។ ព្រោះអារម្មណ៍ផ្តេកទៅតាមការរស់នៅរបស់លោកទាំងមូល វាប៉ះពាល់ដល់ការរស់នៅរបស់លោកទាំងមូល ។ អ៊ីចឹង ការសម្របសម្រួលបាន ទាល់តែសកលលោកហ្នឹងគេយោគយល់ថាឲ្យរស់នៅផង ឬក៏មិនឲ្យរស់នៅផង ទើបប្រព្រឹត្តទៅបាន ។ ច្បាប់ធម៌គឺយោលទៅតាមសេចក្តីរបស់សាមីជនដើមធ្វើអាក្រក់ និងសាមីជនដែលអនុគ្រោះឬក៏មិនអនុគ្រោះ ស្ថិតនៅសាមីជនទាំងពីរ ។

**សំណួរៈ** តើអាចមានវិធីផ្សេងពីនេះឬទេសម្តេច?

**ចម្លើយៈ** មិនអាចមានវិធីផ្សេងពីនេះទេ ព្រោះធម៌លោកសម្តែងអ៊ីចឹង ។ ទទួលទោសជាផ្លូវការតាមច្បាប់ជាតិអន្តរជាតិសិន ។

**សំណួរៈ** តើពុទ្ធឱវាទថា "រំងាប់ពៀរដោយការមិនចងពៀរ" អាចប្រតិបត្តិចំពោះរឿងខ្មែរក្រហមបានទេ?

**ចម្លើយៈ** ក្នុងលោកបាន តែទៅបរលោកសោយផលដដែល ។ តាមផ្លូវពុទ្ធសាសនា ទៅអនាគតមិនបាន ។ កាលណាក្នុងលោកយើង គេអត់សម្លាប់អ្នកហ្នឹងវិញទេ តែអ្នកហ្នឹងអនិច្ចធម្មទៅ អ្នកហ្នឹងទៅសោយអំពើរបស់ខ្លួនដែលធ្វើនោះដដែល ច្បាប់ធម៌អ៊ីចឹង ។ ប៉ុន្តែប្រជាជនប្រាកដជាមិនអស់ចិត្ត ព្រោះមិនទាន់មាននីតិសកលលោកណាមួយចែងបើមាននីតិសកលលោកណាមួយចែង ទើបប្រជារាស្ត្រទាំងអស់ហ្នឹងយោលតាម ។ ដូចជាបច្ចុប្បន្នយើងកំពុងតែសម្របសម្រួលនៃគោលការណ៍ ប៉ុន្តែការសម្របសម្រួលនៃគោលការណ៍ហ្នឹង យើងអត់បានអញ្ជើញអង្គការសហប្រជាជាតិមកប្រជុំវិនិច្ឆ័យថាតើគួរនឹងធ្វើយ៉ាងម៉េច នឹងអនុគ្រោះយ៉ាងម៉េចទេ ។

**សំណួរៈ** តើការដែលប្រជាជនខ្មែរធ្លាក់ទៅក្នុងរបបវាលពិឃាតជាកម្ម-ផលដែលបណ្តាលឲ្យទៅជាអ៊ីចឹងឬ?

**ចម្លើយៈ** ហេតុមានពីរ ទីមួយវេរាកម្មផលយើងកើតមកជួបនឹងប្រទេសក្តៅ ហើយក៏ទទួលក្តៅជាមួយប្រទេសទៅ ទីពីរកើតមកប្រទេសក្តៅដែរ ប៉ុន្តែគេចេះសម្របសម្រួបខ្លួនឲ្យរស់បានដោយមិនត្រូវកម្តៅ តាមរយៈការកែច្នៃដោយបញ្ញាណាមួយ ឬក៏ធ្វើការប្រតិបត្តិណាមួយ ដើម្បីឲ្យរួចចាកប្រទេសក្តៅនោះក្លាយជាប្រទេសត្រជាក់វិញ ។ មានបុគ្គលដែលក្តៅទៅបួក

ជាមួយនឹងក្តៅដែរ បុគ្គលដែលគេសម្រេចខ្លួនបានត្រជាក់ទៅបូកជាមួយនឹងត្រជាក់ទៅ ខ្លះក៏បានរស់ ខ្លះក៏មិនរស់ ។ ព្រោះហេតុដូច្នេះបានជាអាត្មាចម្រើនពរជូនថា ខ្លះកើតមកជាមនុស្សភាវៈទៅកើតចំប្រទេសក្តៅ ខ្លះក៏ត្រូវក្តៅរងគ្រោះដោយប្រទេសទៅខ្លះទៀតក៏មិនបានរងគ្រោះទេ គេសម្រេចខ្លួនរបៀបណាកុំឲ្យកម្តៅដល់ខ្លួន ក៏បានរស់ទៅ ។

***សំណួរៈ*** តើរឿងអស់នេះពាក់ព័ន្ធទៅនឹងកម្មពៀររបស់ប្រជាជនដែលជាអ្នករងគ្រោះឬទេសម្តេច?

***ចម្លើយៈ*** ជាការពិត តាមផ្លូវធម៌អាចពោលដូច្នេះបាន ពិតជាវេរាកម្មរបស់យើង ក្រែងលោវាសេស ប្រទេសគគោកម៉េចមិនកើត មកកើតអីតែមកប្រទេសខ្មែរមានអីចឹង ។ នេះគួរឲ្យជឿថាវេរាដែរ គួរឲ្យជឿថាវេរាទៅតាមនីតិធម៌ ។ ដូច្នេះ អាត្មាភាពជឿថា ប្រហែលជាយើងហ្នឹងមានសេសវេរាពីជំនាន់ណាមកបានជាយើងកើតមក ។ អាកន្លែងគេអត់សង្គ្រាមមិនកើត មកកើតអីចំកន្លែងដីម្តុំសង្គ្រាម អីចឹងគួរឲ្យជឿនូវកម្មផលដែរ ។

***សំណួរៈ*** ចុះមេដឹកនាំខ្មែរក្រហម តើជាកម្មរបស់គេដែរឬក៏មិនមែន?

***ចម្លើយៈ*** អាហ្នឹងគឺគំនូសតំណក់ឈាមរបស់គេ ។ គេចង់បានបែបហ្នឹងរហូត បានជាគេប្រព្រឹត្តអំពើបែបហ្នឹង ។ បានន័យថា គេកើតមកគេចង់បានបែបហ្នឹង ។

***សំណួរៈ*** តើមានហេតុអ្វីដែលបណ្តាលឲ្យចិត្តគេទៅជាបែបហ្នឹង?

***ចម្លើយៈ*** គឺច្បាប់ក្រហម គេចង់ធ្វើក្រហម គេដាក់ឈ្មោះគេថាខ្មែរក្រហមអីចឹង ។ ជាវេរាកម្មឬក៏ផលរបស់ក្រហមហ្នឹង មិនដឹងថាក្រហមហ្នឹងកើតចេញពីប្រភពណា ។ អីចឹងប្រហែលជាខ្មែរណាមួយគេមានឈាមគេដុះមក គេថាឈាមគេក្រហម បានជាគេធ្វើច្បាប់ក្រហមក៏មិនដឹង សូមលោកវិនិច្ឆ័យ ។

***សំណួរៈ*** តើពាក្យ «កម្ម» «កម្ម-ពៀរ» «កម្ម-ផល» និងពាក្យ «វេរា» មានន័យដូចម្តេច?

***ចម្លើយៈ*** «កម្ម» គឺធ្វើផ្ទាល់ដៃ «វេរា» គឺផ្លូវចិត្ត កើតមកចង់តែអីចឹង គេហៅវេរា ។ ឧទាហរណ៍ថា មនុស្សដែលមានវេរាខាងសម្លាប់ កើតមកដឹងក្តីកាលណាចង់តែសម្លាប់ កាប់សាច់ជ្រូកមួយជីវិតទាល់តែស្លាប់ទៅវិញ អារ-កមាន់មួយជីវិត ដាក់មងរហូតមួយជីវិតស្លាប់ទៅវិញ ដឹកស្រារហូតទាល់តែស្លាប់ទៅវិញ ។ ឈាមហ្នឹងវាស្រេកអីចឹង អាហ្នឹងគេហៅថា«វេរា» ។ រីឯ«កម្ម»នោះឯងគឺធ្វើដោយផ្ទាល់ដៃ មុនដំបូងគំនិតគិតហ្នឹងគេហៅវេរា វេរាតែងតាមគំនិត វេរាវាបញ្ជាកាយ កាយជាអ្នកអាស្រ័យ«កម្ម» «វេរា»រួចដល់«ពៀរ» ។ «ពៀរ»នោះអីចេះទៅវិញទេ វាយគេ គេវាយវិញ ទៅវាយគ្រាប់បែក គ្រាប់បែកផ្ទុះងាប់ខ្លួនឯងវិញ នេះ«ពៀរ» ។ ដូចជាអ្នកធ្វើអំពើអាក្រក់ធម្មានីតិនិងលោកានីតិត្រូវវិនិច្ឆ័យ អាហ្នឹង«ពៀរ» ហើយ ។ អ្នកធ្វើអាក្រក់ត្រូវតែលោកានីតិនិងធម្មានីតិហ៊ានវិនិច្ឆ័យលោក ទោះបីលោកមិនប្រគល់ខ្លួនឲ្យក៏ដោយ ក៏អ្នកផងទាំងពួងគេថាលោកធ្វើខុសទាំងច្បាប់ធម៌ លោកធ្វើខុសទាំងច្បាប់លោក នេះ«ពៀរ»ហើយ ។

***សំណួរៈ*** ចុះ«កម្ម-ផល»?

***ចម្លើយៈ*** «កម្ម» គឺធ្វើផ្ទាល់ដៃ «វេរា» គឺគំនិតគិត «ពៀរ» គឺអាប់យសអីចឹងទាំងពីរហ្នឹងគឺសោយផលខុសគ្នា អ្នកអាប់យសសោយផលអាក្រក់ អ្នកដែលធ្វើល្អកម្មល្អហ្នឹងសោយផលល្អមានន័យអីចឹង ។ អីចឹងកម្មពៀរវេរាមិនមែនអត់រូបទេ គឺមានរូប ។

***សំណួរៈ*** តើ «ពៀរ» មានន័យស្មើនឹង «ផល» ដែលត្រូវទទួលមកពី «កម្ម» ដែរឬទេ?

***ចម្លើយៈ*** «ពៀរ»អាក្រក់ «ផល»ល្អ ។ «ពៀរ»វាអ្នកធ្វើអាក្រក់វាអាប់យស ស្លាប់ទៅហើយ គេថាមនុស្សហ្នឹងអាក្រក់ ហ្នឹង«ពៀរ»ហើយ ។ រួចផលហ្នឹង ស្លាប់ទៅហើយ គេថាគាត់ហ្នឹងធ្វើល្អណាស់ ជួយជាតិ ហ្នឹងគេហៅ«ផល» ។ ពាក្យពីរនេះចែកគ្នាដាច់ស្រឡះ «កុសលា» និង «អកុសលា» ។ ពាក្យថាល្អហើយនិងផលវាជាមួយគ្នានឹងចម្រើន ។ អ្នកធ្វើល្អ ទទួលផលល្អតែចម្រើនកើនឡើងគេហៅថា«ផល» ។ ផលហ្នឹងការកើតឡើងនៃសេចក្តីចម្រើនលូតលាស់ រីឯអ្នកធ្វើការកម្មពៀរអាក្រក់នោះគឺទទួលវេរាអាក្រក់ដោយអាប់យស គេចងចាំដាក់ជាប្រវត្តិសាស្ត្ររហូតទៅតៗគ្នា គេរៀនជាឯកសារប្រវត្តិសាស្ត្រ ហ្នឹងគេមិនហៅផលទេ គេហៅវេរាអាក្រក់ ឬវិបាកធម៌អាក្រក់ ។

***សំណួរៈ*** បើដូច្នេះតើប្រជាជនខ្មែរដែលរងគ្រោះកាលរបបខ្មែរក្រហម ជាពៀររបស់គេពីមុនមកឬយ៉ាងណា?

***ចម្លើយៈ*** អាហ្នឹងតាមច្បាប់ធម៌ មានរូបបែបពៀរវេរាកម្មផលផង មានរូបធ្វើដោយទ្រង់ទ្រាយតាមផ្លូវចិត្តផង ដោយទ្រង់ទ្រាយ

ផ្លូវវាចាផង ទ្រង់ទ្រាយផ្លូវកាយផង ។ អ៊ីចឹងទាំងវេរា ទាំងពៀរ ទាំងកម្ម ទាំងផល វាដល់ព្រមទាំងច្បាប់លោកជាមួយហ្នឹង ។ មិនមែនចាត់ទុកថាពៀរវេរាហ្នឹងដោយឡែកពីច្បាប់ទេ ពៀរវេរាគឺជាច្បាប់ធម៌ផង វាជាច្បាប់លោកផង បានជាគេសរសេរថា "យុត្តិធម៌" ភាសាធម៌នៅហ្នឹងស្រេចហើយ យុត្តិ-ធម៌ ។

**សំណួរៈ** តើពាក្យ "យុត្តិធម៌" មានន័យដូចម្តេច?

**ចម្លើយៈ** "យុត្តិ"គឺវិនិច្ឆ័យត្រឹមត្រូវ វិនិច្ឆ័យមិនត្រឹមត្រូវហៅថា "អយុត្តិ" ។

**សំណួរៈ** តើពាក្យថា "ពៀររំងាប់ដោយការមិនចងពៀរ" មានន័យដូចម្តេច?

**ចម្លើយៈ** ពាក្យ "ពៀរដែលរំងាប់ដោយមិនចងពៀរ" ចង់និយាយថាមិនមានកាត់ទោសក្នុងលោក ។ បើបុគ្គលខុស ខុសតែមនុស្សលោក ដល់អស់មួយអាយុហ្នឹងទៅ លោកទៅសោយផល ។ ពីរឿងស្លាប់ទៅហើយបានសោយហ្នឹងហៅថាមិនតបតដោយទ្រង់ទ្រាយកាយ មិនរំងាប់ដោយពៀរ ។ ហ្នឹងច្បាប់លោកសម្តែងអ៊ីចឹង ប៉ុន្តែធម្មវិនិច្ឆ័យលោកថា ពេលខ្លួនកំពុងធ្វើពិតមែនតែគេមិនរំងាប់ដោយពៀរ ដោយសង្គ្រាមធម៌ណាមួយមែន ប៉ុន្តែខ្លួនធ្វើខ្លួនឯង ទទួលខ្លួនឯងហើយ ។ អ៊ីចឹងធម្មវិនិច្ឆ័យថា ពិតប្រាកដជាទទួលក្នុងលោកផង ពិតប្រាកដទទួលទៅលោកខាងនាយផង ។ ធម្មវិនិច្ឆ័យគឺលោកសម្តែងអ៊ីចឹង ។ ដូច្នេះ ពៀរមិនរំងាប់ដោយធ្វើពៀរនោះលោកចង់និយាយថាមិនធ្វើក្នុងលោកមែន ប៉ុន្តែបានតែក្នុងលោកទេ ។

**សំណួរៈ** តើពេលដែលស្លាប់ទៅអាចយកធម៌នោះមកដោះស្រាយបានឬទេសម្តេច?

**ចម្លើយៈ** មិនអាចទេ មិនអាចយកធម៌មកដោះស្រាយបានទេ ព្រោះធម្មវិនិច្ឆ័យ ។

**សំណួរៈ** តើអាចយកពុទ្ធឱវាទ "ពៀររំងាប់ដោយការមិនចងពៀរ" មកប្រើនៅសម្រាប់សង្គមខ្មែរបច្ចុប្បន្នបានទេ?

**ចម្លើយៈ** បើប្រមុខនៃសកលលោកលើកនីតិហ្នឹងអាចស្របជាមួយប្រជារាស្ត្រប្រទេសមួយ ។ តែបើសកលលោកមិនលើកឡាត់ទេ ប្រទេសមួយនោះក៏មិនអាច ពីព្រោះអានេះវាគំរូដល់សកល ហើយជាច្បាប់នៃសកលតាមច្បាប់លោក ហើយវាជាច្បាប់ធម៌ក្នុងសកលលោក វាជាច្បាប់ធម៌ក្នុងប្រទេសមួយ ។ ផ្លូវចិត្តរបស់ប្រជារាស្ត្រយកធម៌មកដាក់ហើយ ប៉ុន្តែបុគ្គលដែលធ្វើអាក្រក់ហើយ ទោះជារាស្ត្រទាំងអស់ថាមិនធ្វើតបតអ្នកឯងដោយពៀរណាមួយមែន ប៉ុន្តែពេលអ្នកឯងអស់អាយុទៅ អ្នកឯងគង់តែទទួលពៀរ ។ អ៊ីចឹងរាស្ត្រទាំងអស់កំណត់ហើយថាអ្នកហ្នឹងពិតជាបាប ។ បើប្រជារាស្ត្រជឿជាក់អ៊ីចឹងទាំងច្បាប់ធម៌ហើយនោះ មិនតបតដោយបុគ្គលហ្នឹងមែនតែវាខុសនឹងច្បាប់រដ្ឋ ច្បាប់អង្គការសហប្រជាជាតិ ។ ប្រហែលជាមានខ្មែរយើងណាមួយចំនួននៅក្នុងប្រទេសយើងហ្នឹងគេគង់តែតែងតាមផ្ចាញ់ផ្ចាលទាល់តែបាន ។

**សំណួរៈ** តើសម្តេចទ្រង់ព្រះតម្រិះថា ការតពៀរឬមិនតពៀរចំពោះខ្មែរក្រហម នឹងបន្សល់ជាឧទាហរណ៍ឲ្យមនុស្សជំនាន់ក្រោយទៀតទេ?

**ចម្លើយៈ** ជាការពិត នៅមានជាធរមាន ខ្លះក៏នៅមានគំនិតហ្នឹង ។

**សំណួរៈ** តើមេដឹកនាំខ្មែរក្រហមគួរតែទទួលការកាត់ទោសក្នុងលោកនេះឲ្យរួចហើយ ឬក៏រង់ចាំឲ្យគេទទួលបាបទៅលោកខាងមុខ?

**ចម្លើយៈ** ខាងផ្នែកព្រះសង្ឃគឺពោលពាក្យបានតែត្រឹមថា បុគ្គលទទួលធ្វើអំពើមិនល្អ គួរគប្បីទទួលផលមិនល្អ ឬវេរាមិនល្អនោះទៅ ។ ហ្នឹងគឺធម្មនីតិ លោកសម្តែងថាអ៊ីចឹង ទោះបីតបតទៅវិញក្តី មិនតបតទៅវិញក្តី ត្រូវតែមានធម៌មួយដាក់នៅក្នុងខ្លួនថា ណ្ហើយកុំតបត យើងគិតតែជម្រះខ្លួនយើងទៅរីឯអ្នកណាធ្វើអ្នកហ្នឹងយក អាក្រក់ក្តីល្អក្តី ។

**សំណួរៈ** តើពេលនេះតុលាការខ្មែរក្រហមមានសារសំខាន់ប៉ុនណាសម្រាប់សង្គមខ្មែរ?

**ចម្លើយៈ** ព្រះពុទ្ធដីកាសម្តែងមួយឃ្លាលោកសម្តែងថា "តបោ តីតិក្ខា និព្វានំ" ។ តបធម៌ជាធម៌ដុតបង់អាក្រក់ ទើបរកព្រះនិព្វានឃើញ ។ ពន្យល់ពាក្យថា "តបោ តីតិក្ខា" ដុតបង់អាក្រក់នេះមានន័យទូលំទូលាយច្រើនជាអនេកបរិយាយ ។ ដុតបង់ដោយប្រការណាមួយ ទ្រង់ទ្រាយតូច ទ្រង់ទ្រាយធំ ទ្រង់ទ្រាយកណ្តាល ដុតបង់ដោយកាយ ដោយវាចា ដោយចិត្ត ។ ដុតបង់ផ្លូវលោក ដុតបង់ផ្លូវធម៌ ពាក្យថាដុតបង់មួយម៉ាត់ហ្នឹងវាទូលាយពេក ។

បើបុគ្គលធ្វើអាក្រក់ដោយមិនដុតបង់ប្រការណាមួយ តូចក្តី ធំក្តីនោះ ទ្រព្យសម្បត្តិយ៉ាងណាក្តីនោះ ឈ្មោះថាបុគ្គលនោះមិនបានដល់ព្រះនិព្វាន គឺសេចក្តីសុខនោះទេ លុះត្រាតែដុតបង់អំពើអាក្រក់នោះចេញ ទើបបានសម្រេចព្រះនិព្វាន ។ ចំពោះបុគ្គលម្នាក់ៗក៏ដូចជាទូទៅ ទាល់តែខ្លួនហ្នឹងដុតបង់អំពើអាក្រក់ ។ អ៊ីចឹងពាក្យថាដុតបង់ហ្នឹង តាមច្បាប់ព្រះធម៌លោកសម្តែងថា គួរតែកម្ចាត់ចោលរៀងៗខ្លួន អ្នកធ្វើអាក្រក់ទទួលអាក្រក់ខ្លួនឯង បើលោកនេះទៅលោកនាយ ដោយមានពុទ្ធដីកាអាងថា "តបោ តីតិក្ខា និព្វានំ" កិរិយាដុតបង់នូវតបធម៌ ទើបទៅព្រះនិព្វានបាន ។

**សំណួរៈ** តើប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហមនឹងចប់ត្រឹមតែពេលដែលតុលាការខ្មែរក្រហមកើតឡើង ឬក៏បន្តជាមួយនឹងមនុស្សជំនាន់ក្រោយទៀត?

**ចម្លើយៈ** បើតុលាការហ្នឹងបានវិនិច្ឆ័យស្របតាមអង្គការសហប្រជាជាតិ វានឹងបាត់មិនមានតទៀត តែបើអង្គការមិនមានទេ អាចពូជហ្នឹងលាស់តិចឬច្រើនជាពុំខាន ។

**សំណួរៈ** ដូច្នេះតើគួរប្រាប់ដល់ក្មេងជំនាន់ក្រោយទៀតឲ្យដឹងអំពីប្រវត្តិសាស្ត្ររបបខ្មែរក្រហម ឬក៏គួរបំភ្លេចចោល?

**ចម្លើយៈ** អាហ្នឹងបើយើងដុតបង់ហើយ យើងបញ្ចប់ មិននិយាយប្រាប់ រឿងហ្នឹងចប់ ។ តែបើយើងមិនដុតបង់នូវតបធម៌ទេ រឿងហ្នឹងវាមិនចប់ នៅតែនិយាយប្រាប់គ្នា ។ ច្បាប់ហ្នឹងវាមានតាំងពីសម័យព្រះមក លោកបានប្រដៅទុកហើយ លោកថា អ្នកដែលធ្វើអាក្រក់មិនខានពីមាន ។ មនុស្សម្នាក់តែងមានអាក្រក់តិចឬច្រើន ។ ដូច្នេះយើងគួរតែសម្ភាទាន កាន់យក "តបោ តីតិក្ខា ៗ" យកមកដុតបង់រាល់ថ្ងៃទើបអស់ ។ អ៊ីចឹងទោះបីតុលាការនោះកាត់ហើយស្រេចក៏ដោយ ចប់ដោយទ្រព្យ-សម្បត្តិធំ ច្រើន ប៉ុន្តែមនុស្សភាវៈក្នុងលោក អាត្មាភាពជឿថា មិនអាចធ្វើល្អពីថ្ងៃប្រសូត្ររហូតទល់ថ្ងៃស្លាប់ទេ ហើយមនុស្សក្នុងលោកក៏មិនអាចធ្វើអាក្រក់ពីថ្ងៃប្រសូត្រទល់ថ្ងៃស្លាប់ដែរ ។ ពិតជាមានការប្រែប្រួលពីល្អមកអាក្រក់ ពីអាក្រក់មកល្អ ជាធម្មតារបស់មនុស្ស ។ ព្រោះហេតុដូច្នោះហើយបានជាមានច្បាប់លោកនិងច្បាប់ធម៌ ។ ខ្មែរក្រហមហ្នឹងក៏វាចូលរឿងធម៌ ។ "តបោ" មួយម៉ាត់ ចង់និយាយថា "ដុត" ហើយដុតមិនមែនដុតតែថ្ងៃពេលកាត់ហ្នឹងស្រេចទេ ទុកឯកសារហ្នឹងតទៅទៀត ហើយដុតរហូតទៅទៀត ។ កាត់ហើយក្តី មិនកាត់ហើយក្តី ត្រូវតែប្រុងប្រយ័ត្នទុកច្បាប់ហ្នឹងជាឯកសារ ដូចជាមានធម៌បានសម្តែង ។

**សំណួរៈ** តើអំពើបាបរបស់បុគ្គលម្នាក់អាចទូទាត់សងវិញដោយការធ្វើអំពើល្អច្រើនទេ?

**ចម្លើយៈ** មិនអាចទេ លុះត្រាណាដែលធ្វើមុនអាក្រក់ គឺទទួលអាក្រក់មុន លុះត្រាណាដែលឈប់ធ្វើអាក្រក់ហើយដល់មកធ្វើល្អ សោយអាក្រក់ហ្នឹងអស់បានមកឡើងកន្លែងល្អ ។

**សំណួរៈ** ចុះប្រសិនបើបុគ្គលម្នាក់បានធ្វើខុសហើយ គេទទួលទោសតាមច្បាប់លោកហើយ តើគេនឹងទទួលទោសតាមច្បាប់ធម៌នៅពេលក្រោយទៀតឬអត់ទេ?

**ចម្លើយៈ** ទទួលដដែល ។ ក្នុងលោកទទួលហើយ ធម៌ក៏ទទួលទៀតបានត្រឹមត្រូវទាំងសងខាង ។ មិនមែនទទួលនៅក្នុងលោកហើយថាធម៌រួចខ្លួនមិនទេ មិនរួចទេ ធ្វើល្អប៉ុន្មានក៏មិនរួចដែរ ។ ដល់ពេលសោយអាក្រក់ហ្នឹងអស់ ហើយខ្លួនបានធ្វើល្អក្រោយបានទៅសោយល្អក្រោយ យូរណាស់ ។

**សំណួរៈ** តើយើងអាចលើកលែងមេដឹកនាំខ្មែរក្រហមឲ្យរួចពីទោសតាមផ្លូវលោកបានទេ?

**ចម្លើយៈ** ចំពោះរូបអាត្មាជាព្រះសង្ឃ អាត្មាជាអ្នកប្រព្រឹត្តនូវកុសល ហើយខ្មែរក្រហមលោកដាច់ដោយឡែក ។ មិនដឹងថាលោកធ្វើហ្នឹងលោកសន្សំកុសលឬក៏សន្សំអកុសលទេ ។ អ៊ីចឹងអាត្មាសុំវិនិច្ឆ័យថា គួរតែឲ្យលោកទទួលស្គាល់ថាខ្លួនលោកធ្វើអាក្រក់ទៅ ទើបស័ក្តិសមជាមនុស្សកើតមកក្នុងលោកតាមលោកនីតិវិធីនិងធម្មានីតិវិធី ។

**សំណួរៈ** តើការធ្វើបែបនេះនឹងផ្តល់ផលដូចម្តេចខ្លះដល់សង្គមជាតិខ្មែរ?

**ចម្លើយៈ** កាលណាយើងយកច្បាប់ហ្នឹងយកមកវិនិច្ឆ័យទៅសង្គមខ្មែរយើងនឹងមានឯកសារមួយ មិនធ្វើតាមអ្នកអាក្រក់ ។ បើប្រទេសមួយមិនធ្វើអាក្រក់ហើយ ប្រទេសនោះនឹងអាចអភិវឌ្ឍជឿនលឿន ហើយនិងយុត្តិធម៌ជាទីបំផុត បរិសុទ្ធជាទីបំផុត ។

**សម្ភាសន៍ដោយ សាន់ កល្យាណ និង សើ សាយ្យាណា**

# ការពិត

ក្រោយពីខ្ញុំបានទទួលទស្សនាវដ្ដីស្វែងរកការពិតដែលផ្ដល់ជូនតាមរយៈសាលាស្រុកក្នុងមួយខែចំនួន២ច្បាប់ឃើញថា រូបភាព និងខ្លឹមសារអត្ថន័យមានសារសំខាន់ណាស់សម្រាប់រូបខ្ញុំផ្ទាល់ក៏ដូចជាប្រជាពលរដ្ឋនៅក្នុងឃុំទ្រានិងទូទាំងប្រទេសដែរ ។ ហើយវាចាំបាច់ជាមូលដ្ឋានក្នុងការកសាងសំណុំរឿងក្នុងការកាត់ទោសមេដឹកនាំខ្មែរក្រហមនៅពេលខាងមុខ និងជាប្រវត្តិសាស្ត្រយូរអង្វែងសម្រាប់យើងទាំងអស់គ្នា ។

ប៉ុន្តែជាគំនិតរបស់ខ្ញុំនិងប្រជាពលរដ្ឋទាំងអស់ក៏មិនខុសគ្នាដែរទេ កន្លងមកគឺយល់ឃើញថា ការពិតនៅលើមាត់គេថានិងអ្នកសរសេរតែប៉ុណ្ណោះ គឺដូចស្លោកគេនិយាយថាៈ ឮគេថាមួយរយដងមិនស្មើនឹងបានឃើញខ្លួនឯងម្ដងទេ ពីព្រោះយើងមិនដែលបានឃើញនូវអ្វីដែលយើងស្គាល់នៅក្នុងទស្សនាវដ្ដីស្វែងរកការពិត ។

ទើបតែមកដល់ខែតុលា ឆ្នាំ២០០១ លេខ២២ ទស្សនាវដ្ដីស្វែងរកការពិតបានចេញមក មានឈ្មោះសមមិត្ត គឹម ទន ហៅ គឹម ទុយ ដែលរស់នៅក្នុងភូមិកំពង់ទ្រាជាមួយខ្ញុំ នៅឃុំទ្រា ស្រុកសំរោង ខេត្តតាកែវ ។ ហើយប្រវត្តិរូបដូចគ្នាទាំងអស់ ខុសបងប្រុសទីពីរឈ្មោះ ភុន (ឈ្មោះពិត ប៉ុម) និងបាត់បងប្រុសទីបីឈ្មោះ គឹម ស៊ិន នៅកំពង់ទ្រា (ស្លាប់) ។ ហើយខ្ញុំបាទនិងប្រជាពលរដ្ឋទាំងអស់ក្នុងភូមិទ្រាគ្រាន់តែដឹងថា គឹម ទន ហៅ គឹម ទុយ នេះធ្វើជាកងទ័ពខ្មែរក្រហមតែប៉ុណ្ណោះ ។ ស្រាប់តែឯកសារស្រាវជ្រាវស្វែងរកការពិតឃើញរូបថតឈ្មោះ គឹម ទុយ ជាអ្នកសួរចម្លើយនៅគុកទួលស្លែង ធ្វើឲ្យយើងខ្ញុំនិងប្រជាពលរដ្ឋទាំងអស់ក្នុងឃុំមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង ហើយបានដឹងច្បាស់ថា ទស្សនាវដ្ដីស្វែងរកការពិតគឺពិតមែន មិនដូចគេថា ការពិតនៅលើមាត់គេថា ដៃគេអ្នកសរសេរនោះទេ ។

ហើយខ្ញុំបានសុំអនុញ្ញាតរាយការណ៍និងជម្រាបជូនផងដែរថា ពេលបានទស្សនាវដ្ដីមកហើយ ខ្ញុំបាទបានប្រជុំភូមិប្រជាពលរដ្ឋតាមភូមិឲ្យគេដឹងនិងឃើញគ្រប់ៗគ្នាថា ទស្សនាវដ្ដីស្វែងរកការពិតគឺបោះពុម្ពផ្សាយសុទ្ធតែការពិតទាំងអស់ មិនភូតភរទេ ព្រមទាំងជូនទៅតាមភូមិឲ្យប្រជាពលរដ្ឋអានមើលដែរ ។

រហូតមកដល់ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០២ ភ្នាក់ងារស្រាវជ្រាវចំនួន៤រូបបានចុះមកដល់ឃុំខ្ញុំបាទ និងចុះសាកសួរអំពីប្រវត្តិរបស់ឈ្មោះដូចតទៅ÷

១) ឈ្មោះ គឹម ទុយ នៅភូមិកំពង់ទ្រា ប្រពន្ធឈ្មោះ ជ អឹម មានកូន១នាក់ស្រី ។ ឈឺស្លាប់ដំងឺពិសនៅភូមិកំពង់ទ្រា ឆ្នាំ១៩៨០ ។

២) ឈ្មោះ អ៊ុក វន ហៅ អ៊ុក វ៉ិន ប្រធានវរៈ៧០៣ នៅភូមិសំរោង ឃុំទ្រា បាត់ខ្លួនជិតនាន់ជាមួយ តាណាត ។

៣) ឈ្មោះ គឹម សុខ កងទ័ពខ្មែរក្រហម ភេទប្រុស នៅភូមិឫស្សីជុំ ឃុំទ្រា បាត់ដំណឹង ។

៤) ម៉ម រឹម កងទ័ពខ្មែរក្រហម ភេទស្រី នៅភូមិសំរោង ឃុំទ្រា ប៉ុន្តែបច្ចុប្បន្នផ្លាស់ទៅនៅឃុំថ្នល់ដាច់ ស្រុកមោងឫស្សី ខេត្តបាត់ដំបង ។

៥) ប៉ិច ម៉េត ពេទ្យ៦មករាភ្នំពេញ ខ្មែរក្រហម នៅភូមិឫស្សីជុំ ឃុំទ្រា បច្ចុប្បន្ននៅភូមិត្នោតទេរ ឃុំទ្រា ប្រពន្ធឈ្មោះ តាន់ ម៉េតា ។

ខ្ញុំសុំកោតសរសើរយ៉ាងខ្លាំងដល់មជ្ឈមណ្ឌលស្រាវជ្រាវដែលបាននិងកំពុងខិតខំស្រាវជ្រាវរុករកការពិតស្ថិតនៅក្នុងភាពអាថ៌កំបាំងគ្រប់ទីកន្លែង ដើម្បីផ្សព្វផ្សាយជូនដល់ប្រជាពលរដ្ឋទូទាំងប្រទេសឲ្យបានដឹងនូវការពិតអំពីរបបខ្មែរក្រហម ពិសេសគឺក្មេងៗជំនាន់ក្រោយដែលកើតមិនទាន់របបនោះ និងនៅក្នុងអន្តរជាតិផងដែរ ។

ក្នុងនាមខ្ញុំតំណាងប្រជាពលរដ្ឋក៏ដូចតំណាងគ្រួសារដែលកូនចៅបាត់ខ្លួន ក៏ដូចគ្រួសារស្រាវជ្រាវរកឃើញនេះ សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះភ្នាក់ងារទស្សនាវដ្ដីស្វែងរកការពិតដែលបានអញ្ជើញមកដល់ឃុំភូមិយើងខ្ញុំ ថ្វីដ្បិតតែមិនបានឃើញកូនចៅក្មួយពិតមែន ពេលទទួលបានដំណឹងពិតនេះក៏ដូចបានឃើញនិងដឹងច្បាស់អំពីប្រវត្តិរបស់ក្មួយកូនពិតប្រាកដ ។

សូមគោរពជូនពរដល់លោកប្រធានការិយាល័យទស្សនាវដ្ដីស្វែងរកការពិតនិងភ្នាក់ងារទាំងអស់ សូមមានសុខភាពល្អ បន្តការងារស្រាវជ្រាវទៅទៀត និងទទួលបាននូវពុទ្ធពរទាំងប្រាំប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ និង បដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ ។

សូមអរគុណ

ធ្វើនៅឃុំទ្រា ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០០២

**មេឃុំទ្រា សួន រិទ្ធិ**



យុទ្ធនារីកងទ័ពបដិវត្តន៍ខ្មែរក្រហម

*ដើម្បីឧបត្ថម្ភការបោះពុម្ពនិងចែកចាយដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំនៅទូទាំងព្រះរាជាណាចក្រកម្ពុជា*
*ទស្សនាវដ្តីចំនួន១០០០ច្បាប់ ជារៀងរាល់លេខនឹងដាក់លក់តែនៅក្នុងរាជធានីភ្នំពេញប៉ុណ្ណោះ មួយច្បាប់ក្នុងតម្លៃ ៧០០០រៀល*

*មជ្ឈមណ្ឌលឯកសារកម្ពុជាអំពាវនាវដល់រដ្ឋាភិបាល មូលនិធិនានា និងសាធារណជនគ្រប់រូប សូមជួយឧបត្ថម្ភការបោះពុម្ពផ្សាយទស្សនាវដ្តីនេះ ទៅតាមលទ្ធភាពដែលអាចធ្វើបាន ។ ព័ត៌មានបន្ថែមចំពោះការបោះពុម្ពផ្សាយទស្សនាវដ្តីស្វែងរកការពិត សូមមេត្តាទាក់ទងមកកាន់នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា តាមទូរស័ព្ទលេខ (៨៥៥) ២៣ ២១១ ៨៧៥ ។ សូមអរគុណ!*

The Documentation Center of Cambodia would like to appeal to governments, foundations and individuals for support of the publication of Searching for the Truth! For contribution, please contact (855) 23 211 875 or By Email: dccam@bigpond.com.kh. Thank you.

A magazine of the Documentation Center of Cambodia: *Searching for the truth*. Number 35, November 2002.
Funded by the Royal Ministry of Foreign Affairs, Oslo, Norway, Section for the Human Rights and Humanitarian Assistance; the Royal Danish Government; Swedish International Development Co-operation Agency (Sida); Embassy of Switzerland; and the Royal Netherlands Government, *The Hague*.